អារម្ភកថា

សៀវភៅសំណួរ និងចម្លើយ ប្រវត្តិវិទ្យា ពីសម័យហ្វូណានដល់សម័យរដ្ឋកម្ពុជានេះជា ឯកសារជំនួយស្មារតីមួយដ៏សំខាន់សម្រាប់សិស្សានុសិស្សកម្រិតមធ្យមសិក្សា ជាពិសេសថ្នាក់ទី១២ ដើម្បីយកជាពុទ្ធិក្នុងការត្រៀមប្រឡងសញ្ញាបត្រមធ្យមសិក្សាទុតិយភូមិ។ សៀវភៅនេះផងដែរ គឺមានសំណួរនិងចម្លើយទៅតាមសម័យកាលនីមួយៗ ដើម្បីងាយស្រួលដល់អ្នកសិក្សា សិស្សានុសិស្ស សម្រាប់ឈ្វេងយល់ពីខ្លឹមសារនៃព្រឹត្តិការណ៍ប្រវត្តិសាស្ត្រខ្មែរ។ ខ្ញុំសង្ឃឹមថា សៀវភៅមួយនេះនឹងក្លាយជាមិត្តដ៏ល្អនិងអាចជួយដល់សិស្សានុសិស្សឱ្យទទួលបានលទ្ធផលល្អក្នុងការសិក្សារៀនសូត្រ ក៏ដូចជាការប្រឡងប្រជែងនានាផងដែរ។

យ៉ាងណាមិញខ្ញុំបាទក៏សូមអភ័យទោសនូវាល់កំហុសឬចំណុចខ្វះខាតដោយអចេតនាដែលកើតមានឡើងនៅក្នុងសៀវភៅនេះទាំងផ្នែកខ្លឹមសារ និងអក្ខរាវិរុទ្ធ ហើយខ្ញុំសូមទទួលការរិះគន់ដើម្បីស្តាបនាពីមិត្តអ្នកសិក្សាទាំងអស់គ្នាដើម្បីឱ្យស្នាដៃកាន់តែល្អថែមទៀត។ ជាចុងក្រោយខ្ញុំបាទសូមជូនពរដល់សិស្សានុសិស្ស អ្នកសិក្សាឱ្យទទួលបានជោគជ័យក្នុងការសិក្សាទាំងអស់គ្នា។

ថ្ងៃអង្គារ ៩កើត ខែបុស្ស ឆ្នាំរោង ឆស័ក ព.ស.២៥៦៨
បន្ទាយមានជ័យ ថ្ងៃទី៧ ខែមករា ឆ្នាំ២០២៥

នី ធារ៉ា

មាតិកា

ខ្លឹមសារ ទំព័រ
១. អំពីសម័យហ្វូណាន.....១
២. អំពីសម័យចេនឡា.....១១
៣. អំពីសម័យអង្គរ.....១៩
៤. អំពីសម័យចតុមុខ.....៤០
៥. អំពីសម័យលង្វែក.....៤៩
៦. អំពីសម័យឧដុង្គ.....៥៩
៧. អំពីសម័យអាណានិគមបារាំង.....៧២
៨. អំពីសម័យសង្គមរាស្ត្រនិយម.....១០៣
៩. អំពីសម័យសាធារណរដ្ឋខ្មែរ.....១២២
១០. អំពីសម័យកម្ពុជាប្រជាធិបតេយ្យ.....១៣៧
១១. អំពីសម័យសាធារណរដ្ឋប្រជាមានិតកម្ពុជានិងរដ្ឋកម្ពុជា..១៥៤
១២. សំណួរនិងចម្លើយពីនេះពីនោះ ស្តីពីប្រវត្តិវិទ្យា.....១៨១
១៣. ឯកសារយោង.....២១២

សំណួរ-ចម្លើយ ស្តីពីសម័យហ្វូណាន

ប្រធាន

១. តើពាក្យថា ហ្វូណាន មានន័យដូចម្តេច?

ចម្លើយ៖ ហ្វូណាន មកពីពាក្យខ្មែរថា រ្នំ ឬ ភ្នំ មានន័យថា ស្តេចភ្នំ ឬ នគរភ្នំ។

២. តើនគរភ្នំ មានទីតាំងភូមិសាស្ត្រដូចម្តេច?

ចម្លើយ៖ នគរភ្នំ ឬ ហ្វូណាន មានទីតាំងភូមិសាស្ត្រ គឺស្ថិតនៅខាងលិចប្រទេសលិនយី ឬ ចម្ប៉ា ប្រមាណ៣០០០លី(១លី=៥៧៦ ម៉ែត្រ) ហើយមានចម្ងាយ៧០០០លី ពីតុងកឹង ហើយនគរភ្នំស្ថិតនៅក្នុងឈូងសមុទ្រ ដ៏ធំមួយឬឈូងសមុទ្រថៃ និងមានទន្លេមេគង្គ ហូរចេញពីទិសពាយ័ព្យទៅចាក់ចូលសមុទ្រ។

៣. តើនគរភ្នំ មានទំនាក់ទំនងជាមួយប្រទេសណាខ្លះ?

ចម្លើយ៖ នគរភ្នំ មានទំនាក់ទំនងជាមួយប្រទេសដូចជា៖ចម្ប៉ា ជ្វា ចិន ឥណ្ឌា។

៤. តើព្រះរាជាដែលសោយរាជ្យនៅនគរភ្នំ ឬ ហ្វូណាន មានព្រះនាមអ្វី?

ចម្លើយ៖ ព្រះនាងសោមា ឬ នាងនាគ។

៥. តើនាងនាគ ឬ ព្រះនាងសោមា បានរៀបអភិសេកជាមួយអ្នក ណា?

ចម្លើយ៖ ហ៊ុន ទៀន ឬ កោណ្ឌញ្ញទី១ ជាព្រាហ្មណ៍មកពីប្រទេសឥណ្ឌា។

៦. តើរាជធានីហ្វូណាន មានឈ្មោះអ្វី?

ចម្លើយ៖ វ្យាធបុរៈ។

៧. ចូររៀបរាប់ពីព្រះរាជាដែលសោយរាជ្យក្រោយព្រះបាទកោណ្ឌញ្ញទី១។

ចម្លើយ៖ ព្រះរាជាដែលសោយរាជ្យក្រោយព្រះបាទកោណ្ឌញ្ញទី១គឺ

-ព្រះបាទ ហ៊ុន ផាន់ហ្វាន់ ជាព្រះរាជបុត្រ ហ៊ុន ទៀន

-ព្រះបាទ ផាន់ ផាន់ ជាព្រះរាជបុត្រ ហ៊ុន ផាន់ ហ្វាន់

-ព្រះបាទ ហ្វាន់ ស៊ីម៉ាន់ ឬ ស្រីមារៈ ជាឧត្តមសេនីយ៍

-ព្រះបាទ ហ្វាន់ ចាន់ ជាក្មួយប្រុសរបស់ ហ្វាន់ ស៊ីម៉ាន់ ឬស្រីមារៈ

-ព្រះបាទ ស៊ី យុន

៨. តើពាក្យឥណ្ឌានីយកម្ម មានន័យដូចម្តេច?

ចម្លើយ៖ឥណ្ឌានីយកម្ម គឺការនាំយកនូវវប្បធម៌ឥណ្ឌា ឬការប្រព្រឹត្តតាមហិណ្ឌូនិយម។

៩. តើនៅសម័យហ្វូណាន គេគោរពលើសាសនាអ្វីខ្លះ?

ចម្លើយ៖ ចំពោះព្រះរាជា ព្រះរាជវង្សានុវង្ស និងនាម៉ឺនមន្ត្រី ច្រើនកាន់ព្រាហ្មណ៍សាសនា គោរពលើព្រះវិស្ណុ និងព្រះសិវ។ រីឯប្រជានុរាស្ត្រសាមញ្ញ ប្រកាន់យកនូវព្រះពុទ្ធសាសនាមហាយាន។

១០. តើនៅសម័យនោះ គេចែកសង្គមមនុស្សជាប៉ុន្មានវណ្ណៈ?

ចម្លើយ៖ គេចែកសង្គមមនុស្សជា៤វណ្ណៈ គឺ

-វណ្ណៈព្រាហ្មណ៍

-វណ្ណៈក្សត្រ

-វណ្ណៈវៃស្យៈ

-វណ្ណៈសូទ្រៈ។

១១. តើវណ្ណៈនីមួយៗ មានន័យដូចម្តេចខ្លះ?

ចម្លើយ៖

-វណ្ណៈព្រាហ្មណ៍ ជាវណ្ណៈ ឬជាគ្រូបង្រៀនដល់ស្តេច និងប្រជាជន។

-វណ្ណៈក្សត្រ ជាត្រកូលអ្នកចម្បាំង និងអ្នកសាងនគរ។

-វណ្ណៈវៃស្យៈ ជាត្រកូលអ្នកជំនួញ ជួញដូរ ឬ ធ្វើស្រែចម្ការ។

-វណ្ណៈសូទ្រៈ ជាត្រកូលអ្នកស៊ីឈ្នួលគេ។

១២. តើសម័យហ្វូណាន ចាប់ពីឆ្នាំណាដល់ឆ្នាំណា?

ចម្លើយ៖ ឆ្នាំ៥០ ដល់ ៥៥០ ឬ សតវត្សទី១ ដល់សតវត្សទី៦។

១៣. មូលហេតុអ្វីបានជាជនជាតិឥណ្ឌាមកនគរភ្នំ?

ចម្លើយ៖ មូលហេតុនៃការមកដល់នៃពួកឥណ្ឌាគឺ៖

-ការផ្សព្វផ្សាយសាសនា ៖ ព្រះចៅអធិរាជឥណ្ឌាព្រះនាម អសោក បានបញ្ជូនប្រតិភូខាងព្រាហ្មណ៍សាសនានិងខាងពុទ្ធសាសនាមកផ្សព្វផ្សាយនៅអាស៊ីអាគ្នេយ៍។

-ការភៀសខ្លួនពីសង្គ្រាម ៖នៅសតវត្សទី១ ពួកអ៊ីរ៉ង់បានវាយត្រួតត្រាប្រទេសឥណ្ឌាភាគកណ្តាលនិងខាងលិច ភាពវឹកវរក្នុងប្រទេសបាន

កើតឡើងដោយជម្លោះរាជវង្ស ធ្វើឱ្យប្រជាជនឥណ្ឌាកៀស ខ្លួនមក រស់នៅអាស៊ីអាគ្នេយ៍។

-ការធ្វើជំនួញ ៖ ពួកឈ្មួញឥណ្ឌាជាច្រើនបានមករកស៊ីនៅនគរភ្នំ ដោយទិញគ្រឿងមាស ប្រាក់ និងគ្រឿងអលង្ការផ្សេងៗ ហើយលក់ ក្រណាត់ គ្រឿងក្រអូប និងគ្រឿងទេសផ្សេងៗឱ្យអ្នកស្រុកនគរភ្នំ។

១៤. ចូររៀបរាប់ពីការដួលរលំនៃនគរភ្នំឬ ហ្វូណាន។

ចម្លើយ៖ មូលហេតុនៃការដួលរលំនៃនគរភ្នំ មានដូចជា៖

+កត្តាគ្រោះធម្មជាតិ

-នៅឆ្នាំនោះអាណាចក្រភ្នំត្រូវបានទឹកជំនន់លេបត្របាក់ ជាហេតុនាំ ឱ្យអ្នកស្រុកនគរភ្នំកៀសខ្លួនទៅរស់នៅតំបន់ដីគោកគឺរដ្ឋចេនឡា។

+កត្តាទំនាស់សាសនា

-អ្នកស្រុកចេនឡា កាន់សាសនាព្រាហ្មណ៍ រីឯអ្នកស្រុកហ្វូណានកាន់ សាសនាព្រះពុទ្ធហីនយាន ក្រោយពីនគរភ្នំចុះខ្សោយ នគរចេនឡា បានបង្ខំឱ្យអ្នកស្រុកហ្វូណានកាន់ព្រាហ្មណ៍សាសនាដែរ។

+កត្តាវិបត្តិផ្ទៃក្នុង

-អ្នកស្រុកហ្វូណានភាគច្រើនពុំពេញចិត្តនឹងព្រះបាទរុទ្រវរ្ម័ន ដែល បានសម្លាប់ព្រះអង្គម្ចាស់គុណវរ្ម័នត្រូវជាប្អូនប្រុស ដើម្បីដណ្តើមរាជ្យ សម្បត្តិ ហើយពួកប្រជាជននោះក៏នាំគ្នាបះបោរប្រឆាំងនឹងរុទ្រវរ្ម័ន។

+កត្តាសង្គ្រាម

-ព្រះបាទភវវរ្ម័ន ត្រូវជាចៅរបស់ព្រះបាទរុទ្រវរ្ម័ននិងជាស្តេចសោយ រាជ្យនៅចេនឡា បានលើកទ័ពមកវាយក្រុមបះបោរប្រឆាំងនឹង

អយ្យការ ដើម្បីដណ្តើមត្រួតត្រាលើនគរភ្នំ។ ចាប់ពីពេលនោះមក អាណាចក្រភ្នំត្រូវបានកែប្រែឈ្មោះមកជាអាណាចក្រចេនឡាវិញ ដោយគ្រប់គ្រងដោយព្រះបាទភវវរ្ម័នទី១។

១៥. ចូររៀបរាប់ដោយសង្ខេបអំពីអរិយធម៌នៃអ្នកស្រុកនគរភ្នំ។

ចម្លើយ៖ នគរភ្នំគឺជារដ្ឋមួយដែលធ្វើជំនួញតាមសមុទ្រជាមួយប្រទេសចិន ចម៉ា ឥណ្ឌា និងប្រទេសនៅអឺរ៉ុបដូចជាចក្រភពរ៉ូមជាដើម។ នគរភ្នំជាកំពង់ផែដ៏ធំមួយ ដែលមានលក់ដូរលោហធាតុមានតម្លៃ ដូចជាភ្លុក គជ់ ឈើ ជាដើម។ នៅសម័យនោះមានភាពរុងរឿងដល់កម្រិតកំពូល ដោយនគរភ្នំបានត្រួតត្រាលើក្សត្របុរីតូចៗជាច្រើននៅតាមឆ្នេរសមុទ្រ ដែលសុទ្ធតែទទួលឥទ្ធិពលពីឥណ្ឌា។ នគរភ្នំមានស្តេចច្រើនអង្គបានឡើងសោយរាជ្យជាបន្តបន្ទាប់ហើយស្តេចចុងក្រោយបង្អស់មាននាមថា«ព្រះបាទរុទ្រវរ្ម័ន(៥១៤ - ៥៥០)។ អ្នកនគរភ្នំគោរពសាសនាចំនួនពីរ គឺព្រាហ្មណ៍សាសនា និងព្រះពុទ្ធសាសនា។ គេសរសេរអក្សរជាភាសាសំស្ក្រឹត ដែលមានប្រភពមកពីឥណ្ឌា អ្នកស្រុកស្លៀកពាក់សំពត់ចងក្បិន និងលែងខ្លួនទទេ។ គេរស់នៅក្នុងផ្ទះឈើ ខ្ពស់ផុតដី ពួកគេជាសិប្បករយ៉ាងចំណាន។ ពួកគេចេះធ្វើប្រព័ន្ធប្រឡាយទឹក ចេះធ្វើសំពៅធំៗសម្រាប់ធ្វើជំនួញនិងសង្គ្រាមទៀតផង។

១៦. តើសម័យហ្វូណាន វិធីរំលាយសពមានប៉ុន្មានប្រភេទ?

ចម្លើយ៖ វិធីរំលាយសព មានបួនប្រភេទគឺ៖

-ការបោះចោលទៅក្នុងទឹកទន្លេ

-ការបូជាដោយភ្លើង

-ការយកសពទៅកប់

-ការយកសពទៅដាក់ចោលក្នុងព្រៃស្មសានឱ្យសត្វស៊ី។

១៧. តើការផ្សព្វផ្សាយវប្បធម៌ឥណ្ឌាប្រព្រឹត្តទៅតាមផ្លូវប៉ុន្មានយ៉ាង?

ចម្លើយ៖ តាមរយៈផ្លូវពីរយ៉ាងគឺ

-តាមរយៈពួកឈ្មួញ

-តាមរយៈសាសនា និងពួកបញ្ញាវន្តខ្មែរក្នុងវណ្ណៈខ្ពស់។

១៨. ចូររៀបរាប់ពីតួនាទីពាណិជ្ជកម្មនៃឥណ្ឌាការូបនីយកម្ម។

ចម្លើយ៖ តួនាទីនៃឥណ្ឌាការូបនីយកម្មគឺ ពាណិជ្ជកម្មបានដើរតួនាទីយ៉ាងសំខាន់ក្នុងការហូរចូលនៃវប្បធម៌ឥណ្ឌា។ អាណាចក្រភ្នំគឺជាអាណាចក្រមួយ តែជាមជ្ឈមណ្ឌលពាណិជ្ជកម្មដ៏សំខាន់នៅក្នុងតំបន់អាស៊ីអាគ្នេយ៍ ហើយកំពង់ផែអូរកែវ គឺជាកំពង់ផែដ៏សំខាន់របស់អាណាចក្រនេះ។

១៩. តើនៅសម័យនគរភ្នំ ឬហ្វូណាន គេរកយុត្តិធម៌តាមវិធីប៉ុន្មានយ៉ាង? អ្វីខ្លះ?

ចម្លើយ៖ គេរកយុត្តិធម៌ តាមវិធី២យ៉ាងគឺ

-វិធីទី១៖ ដើម្បីរកយុត្តិធម៌ត្រូវយកបាយមួយពំនូតទៅដាក់ចំពោះមុខព្រះកក្រ្តអាទិទេព ដោយធ្វើពិធីអង្វរកលន់តួសុំឱ្យអាទិទេពជួយ

រក លុះព្រឹកឡើងយកបាយពំនូតនេះទៅឱ្យអ្នកជាប់ទោសស៊ី បើមានឈាមហូរចេញពីរាងកាយជននោះត្រូវជាប់ចោទ បើគ្មានឈាមហូរទេ ជននោះពុំជាប់ចោទឡើយ។

-វិធីទី២៖ ជនជាប់ចោទត្រូវបង្អត់បាយ ហើយត្រូវឆ្លងកាត់ការពិសោធន៍ដូចជា ឱ្យជនជាប់ចោទលូកយកវត្ថុអ្វីមួយ នៅក្នុងទឹកកំពុងពុះ បើលោកត្រូវជាប់ចោទបទល្មើស បើមិនរលោកត្រូវរួចខ្លួន។ មួយវិញទៀត ឱ្យជនជាប់ចោទកាន់ដែកដុតឡើងក្រហម បើលោកត្រូវជាប់ចោទ បើមិនរលោកត្រូវបានរួចខ្លួន។

នៅសម័យនគរភ្នំគេមិននិយមធ្វើគុកដាក់ជនទុច្ចរិតទេ គេច្រើនតែផាកពិន័យជាទោសស្រាលៗតែបើមានកំហុសធ្ងន់ត្រូវយកទៅឱ្យក្រពើស៊ី ឬសត្វសាហាវស៊ី។

២០. ចូររៀបរាប់ពីនយោបាយក្នុងប្រទេសនិងក្រៅប្រទេសនៅសម័យនគរភ្នំ។

ចម្លើយ៖ នយោបាយក្នុងប្រទេសនិងក្រៅប្រទេសនៃនគរភ្នំគឺ

+នយោបាយក្នុងប្រទេស

-ការរៀបចំនយោបាយតាមរបៀបឥណ្ឌាអ្នកដឹកនាំរដ្ឋគឺជាស្តេច

-ព្រះមហាក្សត្រគ្រប់គ្រងប្រទេសតែងតែធ្វើសក្ការបូជាចំពោះអាទិទេព (ការតម្កល់លិង្គព្រះឥសូរ ពិធីសិរៈរាត្រី)

-ព្រះមហាក្សត្រ មានឋានៈខ្ពស់តំណាងឱ្យអាទិទេព ត្រូវបានប្រជានុរាស្ត្រគោរពរាប់អាន រីឯការឡើងគ្រងរាជ្យបន្តអំណាចពីព្រះរាជបិតាទៅឱ្យបុត្រា

-ប្រជានុរាស្ត្រសាមញ្ញមិនអាចឡើងគ្រងរាជ្យបានទេ លើកលែងតែមានករណីចាំបាច់ខ្លះដូចជាមានការជ្រែករាជ្យ ឬនគរគ្មានស្តេចសោយរាជ្យ

-ព្រះរាជាសម័យនោះ អនុវត្តគោលនយោបាយវាតទីនិយម ឬពង្រីកទឹកដីដោយលើកទ័ពទៅទន្ទ្រានលុកលុយប្រទេសជិតខាង ពេលណាឈ្នះដាក់ប្រទេសនោះជារណបរបស់ខ្លួន។

+នយោបាយក្រៅប្រទេស

-ក្រៅពីប្រទេសឥណ្ឌា នគរភ្នំមានទំនាក់ទំនងជិតស្និទ្ធជាមួយអាណាចក្រចិន ជ្វា និងប្រទេសចាម។

២១. ក្នុងពេលប្រទានសវនាការឬកាត់ក្តី តើព្រះមហាក្សត្រទម្លាប់គង់ដូចម្តេច?

ចម្លើយ៖ ព្រះរាជាទម្លាប់គង់ដាក់ព្រះបាតឆ្វេងដល់ដី បញ្ឈរព្រះបាទស្តាំ។ នៅខាងមុខព្រះមហាក្សត្រក្រាលដោយព្រំនិងដុតគ្រឿងក្រអូបតម្កល់លើកម្រាលព្រំនោះ។ ចំណែកឯស្រីស្នំ និងនាម៉ឺនមន្ត្រីនានាអង្គុយគាល់ព្រះមហាក្សត្រជាប្រចាំ។

២២. តើសេដ្ឋកិច្ចសម័យនគរភ្នំពឹងផ្អែកលើវិស័យអ្វីខ្លះ?

ចម្លើយ៖ សេដ្ឋកិច្ចនៅសម័យនគរភ្នំពឹងផ្អែកលើវិស័យកសិកម្មនិងវិស័យពាណិជ្ជកម្ម។ កសិកម្មរីកចម្រើនដោយសារនយោបាយទឹក រីឯ

ពាណិជ្ជកម្មពឹងផ្អែកទៅលើកំពង់ផែអូរកែវ តាមរយៈកំពង់ផែនេះ បានធ្វើឱ្យនគរភ្នំមានទំនាក់ទំនងយ៉ាងសកម្មក្នុងការផ្លាស់ប្តូរទំនិញជាមួយប្រទេសជាច្រើនដូចជាចក្រភពរ៉ូមាំង ឥណ្ឌា ចិន ចាម ជ្វា ជាដើម។

២៣. តើនៅសម័យនគរភ្នំទំនិញដែលនាំចូលនិងទំនិញនាំចេញមានអ្វីខ្លះ?

ចម្លើយ៖ ទំនិញដែលនាំចូលមានដូចជា មាស ប្រាក់ សំពត់ គ្រឿងកែវ...។ រីឯទំនិញនាំចេញមានដូចជា មាស ប្រាក់ ទង់ដែង សំណ ប៉ាហាំង គ្រឿងក្រអូប ឈើក្រអូប ភ្លុកដំរី ជាពិសេសគុជនិងពេជ្រ។

២៤. តើសិល្បៈឬស្ថាបត្យកម្មនិងនគរូបនីយកម្មនៅសម័យនគរភ្នំមានលក្ខណៈដូចម្តេច?

ចម្លើយ៖ ស្ថាបត្យកម្មនៅសម័យនគរភ្នំ ជាស្ថាបត្យកម្មមួយដែលទទួលឥទ្ធិពលពីឥណ្ឌា ប្រាសាទភាគច្រើនសង់ឡើងដោយចោះ ឬលុងភ្នំធ្វើប្រាសាទ ឬដាក់តម្កល់អាទិទេពណាមួយដែលគេគោរពបូជាដូចជាប្រាសាទភ្នំដា។ ប្រាសាទមួយចំនួនទៀតសង់ឡើងអំពីឥដ្ឋ តាមរយៈសំណង់បុរាណជាច្រើននៅតំបន់អូរកែវ ហើយត្រូវបានគេអះអាងថា រូបបដិមាទាំងអស់មានរាងកាច់ចង្កេះ ឬមានរាងធាត់ដែលទទួលឥទ្ធិពលពីឥណ្ឌា។ បើនិយាយពីនគរូបនីយកម្ម ទីក្រុងទាំងអស់នៃនគរភ្នំ ត្រូវបានពង្រឹងឡើងដោយរបងអំពីឈើ។

២៥. ចូររៀបរាប់ដោយសង្ខេបពីការកកើតរដ្ឋហ្វូណានឬនគរភ្នំ។

ចម្លើយ៖ ដែនដីសណ្តទន្លេមេគង្គនៅដើមគ.ស ជាទឹកដីស្ថិតនៅក្រោមកិច្ចដឹកនាំនៃព្រះនាងលីវយី។ លុះប្រមាណជាឆ្នាំ៥០នៃគ.ស ព្រះនាងលីវយី ត្រូវបានតទល់នឹងទ័ពសំពៅឥណ្ឌាក្រោមបញ្ជាការរបស់ព្រាហ្មណ៍ ហ៊ុន ទៀន ដែលបានចូលមកកាន់កាប់ទឹកដីព្រះនាង។ ទ័ពសំពៅព្រាហ្មណ៍ហ៊ុន ទៀន បានយកជ័យជម្នះបានលើម្ចាស់ស្រុក។ ព្រាហ្មណ៍ហ៊ុន ទៀន ក៏ប្រកាសតាំងខ្លួនជាស្តេចលើភូមិភាគដីសណ្ត ព្រមទាំងបានរៀបអភិសេកជាមួយព្រះនាងលីវយី។ តមកព្រះបាទហ៊ុន ទៀន បានរៀបចំទឹកដីវាលទំនាបទន្លេមេគង្គភាគខាងត្បូងឱ្យកើតបានជារដ្ឋមួយទៅតាមទស្សនៈរាជាធិបតេយ្យឥណ្ឌា។ រាជធានីហ្វូណានតាំងនៅស្រុកអង្គរបុរី ខេត្តតាកែវ មានឈ្មោះថាវ្យាធបុរៈ និងមានកំពង់ផែអន្តរជាតិអូរកែវ ពីសតវត្សទី១ដល់សតវត្សទី៦ នៃគ.ស។ ព្រះរាជាណាចក្រហ្វូណាន ជាមហាអំណាចល្បីល្បាញមួយនៃភូមិភាគអាស៊ីអាគ្នេយ៍មានឈ្មោះល្បីរន្ទឺសុសសាយរៀងរហូតដល់ពាក់កណ្តាលសតវត្សទី៦។

សំណួរ-ចម្លើយ ស្តីពីសម័យចេនឡា

ប្រធាន

១. តើសម័យចេនឡាចាប់ពីឆ្នាំណាដល់ឆ្នាំណា?

ចម្លើយ៖ ៥៥០ ដល់ ៨០២ឆ្នាំនៃគ.ស។

២. តើចេនឡាចែកភូមិសាស្ត្រនិងទឹកដីជាប៉ុន្មាន?

ចម្លើយ៖ ចេនឡាចែកចេញជា២ផ្នែកគឺ៖

-ខាងជើង ៖ ចាប់ពីជួរភ្នំដងរែកទៅទល់នឹងរដ្ឋណានឆាវ និងរដ្ឋយូណាន សម្បូរទៅដោយកូនភ្នំ និងខ្ពង់រាប។

-ខាងត្បូង ៖ ចាប់ពីជួរភ្នំដងរែករហូតដល់សមុទ្រនិងឧបទ្វីបម៉ាឡាយូ សម្បូរទៅដោយវាលទំនាប ទន្លេ សមុទ្រ។

៣. ចូររៀបរាប់ពីព្រះរាជាដែលសោយរាជ្យនៅនគរចេនឡា។

ចម្លើយ៖ ព្រះរាជាដែលបានសោយរាជ្យគឺ

-ព្រះបាទ ភវវរ្ម័នទី១ ពីឆ្នាំ៥៥០ដល់៦០០នៃគ.ស

-ព្រះបាទ មហិន្ទ្រវរ្ម័ន ពីឆ្នាំ៦០០ដល់៦១៥នៃគ.ស

-ព្រះបាទ ឦសានវរ្ម័នទី១ ពីឆ្នាំ៦១៥ដល់៦៣៥នៃគ.ស

-ព្រះបាទជ័យវរ្ម័នទី១ ពីឆ្នាំ៦៥៥ដល់៦៨១នៃគ.ស

៤. តើនគរចេនឡា មានទីតាំងភូមិសាស្ត្រដូចម្តេចខ្លះ?

ចម្លើយ៖ នគរចេនឡា មានទីតាំងស្ថិតនៅត្រង់វាលទំនាបកណ្តាលនៃទន្លេមេគង្គ ក្នុងតំបន់បាសាក់នៃប្រទេសឡាវសព្វថ្ងៃ និងតំបន់

ខាងត្បូងខ្ពង់រាបកូរ៉ាត់ប្រទេសថៃទល់នឹងទន្លេមេណាម និងវាលទំនាបទន្លេមេគង្គខាងជើងត្រង់តំបន់ប៉ាក់សេ វត្តភូ នៃទឹកដីឡាវ។

៥. តើមូលហេតុអ្វីដែលបណ្តាលឱ្យចេនឡាត្រូវបែកបាក់?

ចម្លើយ៖ មូលហេតុនៃការបែកបាក់នៃនគរចេនឡាគឺ៖

-វិសាលភាពទឹកដី៖ ទឹកដីនៃនគរចេនឡាមានទំហំធំណាស់ ជាហេតុនាំឱ្យពិបាកក្នុងការគ្រប់គ្រង។

-វិបត្តិផ្ទៃក្នុង៖ ក្រោយពីព្រះបាទជ័យវរ្ម័នទី១ ចូលទីវង្គតទៅ ពុំមានរជ្ជទាយាទ ដូចនេះសមន្តរដ្ឋជាច្រើនបានបះបោរចង់ផ្តាច់ខ្លួន ចង់គ្រប់គ្រងអំណាច ហើយចម្បាំងក៏កើតឡើងធ្វើឱ្យបាក់បែកចេនឡា។

-សមត្ថភាពគ្រប់គ្រង៖ ព្រះបាទជ័យវរ្ម័នទី១ សោយទិវង្គតទៅ រាជសម្បត្តិត្រូវធ្លាក់មកលើព្រះនាងជ័យទេវី ដែលជាមហេសីរបស់ព្រះអង្គ ព្រះនាងមានការលំបាកក្នុងការគ្រប់គ្រង ហើយមន្ត្រីក្រោមឱវាទនិងនគរចំណុះមិនស្តាប់បង្គាប់ ឈ្លោះគ្នា រហូតធ្វើឱ្យចេនឡាត្រូវបានបែកបាក់ជាពីរ គឺចេនឡាដីគោកនិងចេនឡាទឹកលិច។

៦. តើចេនឡាដីគោក មានរាជធានីឈ្មោះអ្វី?

ចម្លើយ៖ ចេនឡាដីគោក មានរាជធានីឈ្មោះ **ភវបុរៈ**។

៧. ចូររៀបរាប់ដោយសង្ខេបពីអរិយធម៌ខ្មែរសម័យចេនឡា។

ចម្លើយ៖ នៅសម័យចេនឡាក្នុងរជ្ជកាលព្រះបាទឥសានវរ្ម័នទី១ រាជធានីមានឈ្មោះថា ឥសានបុរៈ(សម្បូរព្រៃគុកខាងជើងក្រុងកំពង់ធំ) ហើយមានមនុស្សរស់នៅជាង២០០០០គ្រួសារ។ ឯទីក្រុងតូចៗមានចំនួន៣៣។ ក្រុងនីមួយៗមានមនុស្សរស់នៅច្រើនពាន់គ្រួសារ និង

មានមន្ត្រីម្នាក់ជាអ្នកគ្រប់គ្រង។ បីថ្ងៃម្តង ព្រះរាជាបើកសវនាការនៅក្នុងបន្ទប់ធំមួយនៅកណ្តាលទីក្រុង អ្នកស្រុកចេនឡាមានមាឌតូចទាំងប្រុសទាំងស្រីបួងសក់ ហើយពាក់រយ៉ា រាល់ព្រឹក គេលុបលាងខ្លួនហើយសូត្រធម៌ ចំពោះអាហារ គេចូលចិត្តហូបបាយ សាច់ ទឹកដោះ និងស្ករ។ គេគោរពសាសនាចំនួនពីរ គឺព្រាហ្មណ៍សាសនា និងព្រះពុទ្ធសាសនា ហើយគេកសាងប្រាសាទអំពីឥដ្ឋ។

៨. ចូររៀបរាប់ពីការកាន់ទុក្ខនៅសម័យចេនឡា។

ចម្លើយ៖ ក្នុងករណីមានទុក្ខពួកកូនចៅនៃសពត្រូវកោរសក់យំស្រែកយ៉ាងខ្លាំង ហើយអត់បាយរយៈពេល៧ថ្ងៃទៀតផង។ ចំពោះសពត្រូវបានគេបូជា ហើយគេប្រមូលធាតុដាក់ក្នុងកោដ្ឋធ្វើពីមាស ឬប្រាក់ ហើយបោះចោលទៅក្នុងទឹកដ៏ជ្រៅ។ ពួកអ្នកក្រីក្រគេប្រើកោដ្ឋធ្វើពីដី ហើយមានលាបពណ៌ផ្សេងៗ មានអ្នកខ្លះទៀតពេលមានមនុស្សស្លាប់ គេគ្រាន់តែយកទៅដាក់ចោលក្នុងព្រៃភ្នំទុកឱ្យសត្វស៊ីជាការស្រេច។

៩. តើចេនឡាមានព្រំប្រទល់ជាប់ប្រទេសណាខ្លះ?

ចម្លើយ៖ ចេនឡាបានពង្រីងអំណាចលើឥណ្ឌូចិនរហូតដល់សតវត្សទី៨ ដែលជាប់នឹងប្រទេសជិតខាងដូចជា៖

-ខាងត្បូងជាប់នគរជ្វា

-ខាងកើតជាប់ចម្ប៉ា

-ខាងជើងជាប់ចិន

-ខាងលិចជាប់មន។

១០. ចូររៀបរាប់សង្ខេបពីការកកើតចេនឡា។

ចម្លើយ៖ ចេនឡា ជាឈ្មោះនគរខ្មែរបុរាណ កាលពីដើមឡើងជារដ្ឋ រណបមួយរបស់នគរភ្នំក្នុងចន្លោះសតវត្សទី១ដល់ទី៦នៃគ.ស ដែលគេហៅថាសមន្តរដ្ឋ។ លុះដល់ពាក់កណ្តាលទី២នៃសតវត្សទី៦ ទន្ទឹមនឹងការធ្លាក់ចុះរបស់នគរភ្នំ រដ្ឋសមន្តរាជចេនឡា បានវាយយកនគរភ្នំដោយដណ្តើមយកអំណាចទាំងមូលនៅក្នុងសតវត្សទី៧។ រដ្ឋនេះបានគ្រប់គ្រងប្រទេសបន្តពីនគរភ្នំរហូតដល់បានរីកចម្រើនយ៉ាងខ្លាំងនៅសតវត្សទី៨ធ្វើឱ្យអតីតនគរភ្នំលែងមានតួនាទីអ្វីទៅទៀតនៅតំបន់អាស៊ីអាគ្នេយ៍។

១១. ដើម្បីរកយុត្តិធម៌ តើអ្នកស្រុកចេនឡានិយមធ្វើដូចម្តេច?

ចម្លើយ៖ អ្នកស្រុកចេនឡានិយមជឿលើការស្បថស្បែរ។

១២. តើក្នុងពិធីជំនុំជម្រះក្តី តើគេធ្វើពិធីអ្វីខ្លះ?

ចម្លើយ៖ គេធ្វើពិធីផ្សេងៗដូចជា៖

-បន្ទាប់ពីស្បថរួច ហើយគេបោះចិញ្ចៀន ឬពងមាន់ចូលទៅក្នុងទឹកក្តៅពុះ ហើយគូក្តីទាំងសងខាងចាប់យកវត្ថុនោះចេញពីទឹកពុះ។ អ្នកណាស្មោះត្រង់មិនរលាកដៃទេ។

-វិធីមួយទៀត គេដុតច្រវាក់ឱ្យក្តៅហើយប្រគល់ឱ្យគូក្តីក្តាន់ដើរឱ្យបាន៧ជំហាន បើអ្នកណាម្នាក់ធ្វើខុសត្រូវរលាកដៃ តែបើអ្នកសុច្ចរិតវិញនឹងមិនរលាកដៃទេ។

-វិធីមួយខ្លះទៀត គេយកគូក្តីទាំងពីរបោះចូលក្នុងទឹក បើអ្នកណាម្នាក់ស្មោះត្រង់នោះមិនលិចទឹកទេ។

១៣. តើវិស័យនយោបាយក្នុងសម័យចេនឡាមានលក្ខណៈដូចម្តេចខ្លះ?

ចម្លើយ៖ វិស័យនយោបាយនៅសម័យចេនឡាគឺ

+ចំពោះនយោបាយក្នុងប្រទេស

-របបគ្រប់គ្រងរដ្ឋតាមលក្ខណៈឥណ្ឌាដែរ គឺព្រះមហាក្សត្រគ្រប់គ្រងប្រទេសធ្វើពិធីសក្ការបូជាចំពោះមហេស្វរៈ(កន្ទ្រេស្វរៈ) នៅលើកំពូលភ្នំលិង្គប៌វត។ កំពូលភ្នំនេះស្ថិតនៅត្រង់វត្តភូ នៅប្រទេសលាវសព្វថ្ងៃ។

-ព្រះមហាក្សត្រ ជាតំណាងដ៏ខ្ពង់ខ្ពស់របស់អាទិទេព ការឡើងគ្រងរាជ្យគឺមានតែព្រះឱរស នៃមហាក្សត្រីយានីអគ្គមហេសីពេញច្បាប់ដែលត្រូវបានឡើងគ្រងរាជ្យជំនួសព្រះបិតា។

-ព្រះមហាក្សត្រសម័យចេនឡា អនុវត្តគោលនយោបាយពង្រីកទឹកដីដូចក្សត្រអង្គមុនដែរ។

+ចំពោះនយោបាយក្រៅប្រទេស

-នៅសម័យចេនឡាព្រះមហាក្សត្រមានទំនាក់ទំនងក្រៅប្រទេស និងការទូតជាមួយអាណាចក្រចិន ចាម ជ្វា និងមនជាដើម។

១៤. តើវិស័យកសិកម្មនៅសម័យចេនឡាមានលក្ខណៈដូចម្តេច?

ចម្លើយ៖ ក្នុងសម័យចេនឡាត្រូវបានគេរកឃើញថាវិស័យកសិកម្មបានពង្រីកឡើងតាមរយៈការប្រើប្រាស់ដី ការរុករានដីថ្មីបូកផ្សំនិងយុទ្ធសាស្ត្រដណ្តើមឱ្យឈ្នះលើតំបន់វាលក់។

១៥. តើគេចែកដីធ្លីសម័យចេនឡាជាប៉ុន្មានប្រភេទ? អ្វីខ្លះ?

ចម្លើយ៖ គេចែកដីធ្លីជាបីប្រភេទគឺ
-ដីប្រភេទទី១ ជាកម្មសិទ្ធិរបស់ព្រះមហាក្សត្រ។
-ដីប្រភេទទី២ ជាកម្មសិទ្ធិរបស់វត្តអារាមឬព្រហ្មស្រម។
-ដីប្រភេទទី៣ ជាកម្មសិទ្ធិរបស់នាហ្មឺន គហបតី គ្រហស្ថនិងអ្នកស្រែ។

១៦. តើអ្នកស្រុកចេនឡាប្រកបមុខរបរអ្វីខ្លះ?

ចម្លើយ៖ អ្នកស្រុកចេនឡា ប្រកបមុខរបរធ្វើស្រែចម្ការ ដាំក្រូច ត្រាវ ដូង ស្លា ល្មុត ល្ហុង ចេក ព្រមទាំងបន្លែសព្វយ៉ាង។ រីឯអ្នកស្រុកខ្លះទៀតប្រកបរបរជាសិល្បករ និងជាងសំណង់ដ៏ប៉ិនប្រសប់។

១៧. តើនៅសម័យចេនឡាការបង់ពន្ធគិតជាអ្វី?

ចម្លើយ៖ អ្នកស្រុកចេនឡាប្រកាន់យកច្បាប់បង់ពន្ធដល់ប្រទេសដោយគិតជា មាស ពេជ្រ គុជ និងផលិតផលដែលបានមកពីស្រែចម្ការ ដើម្បីរួមចំណែកកសាងរាជាណាចក្រមួយឱ្យកាន់តែរីកចម្រើនជាលំដាប់។ រីឯព្រះមហាក្សត្រនិងរាជវង្សានុវង្សមានអភ័យឯកសិទ្ធិគឺមិនបង់ពន្ធទេ តែមានភារកិច្ចដឹកនាំប្រទេសឱ្យបានរុងរឿង។

១៨. តើភាសាផ្លូវការដែលគេប្រើក្នុងសម័យចេនឡាជាភាសាអ្វី?

ចម្លើយ៖ ភាសាសំស្ក្រឹត។ រីឯអ្នកស្រុកប្រាស្រ័យទាក់ទងគ្នាដោយប្រើភាសាស្ថិតនៅក្នុងអម្បូរមន-ខ្មែរ ឬភាសាដើម។

១៩. តើអ្នកស្រុកចេនឡាគោរពលើសាសនាអ្វី?

ចម្លើយ៖ អ្នកស្រុកចេនឡាគោរពលើសាសនាព្រហ្មញ្ញសាសនានិងព្រះពុទ្ធសាសនាបែបមហាយាន។

២០. តើនៅសម័យចេនឡាមានប្រារព្ធពិធីបុណ្យអ្វីខ្លះ?

ចម្លើយ៖ នៅសម័យចេនឡាមានប្រារព្ធពិធីបុណ្យគឺ

-ពិធីបុណ្យតាមបែបព្រាហ្មណ៍សាសនា ដូចជាពិធីអភិសេកព្រះមហាក្សត្រ ពិធីបុណ្យសព ពិធីរំលឹកគុណឧបការីជន ឬវីរជនស្នេហាជាតិ ពិធីគិរិស: ជាដើម។

-ពិធីបុណ្យតាមបែបពុទ្ធសាសនា ពុំទាន់លេចចេញច្បាស់លាស់នៅឡើងទេ។

២១. តើស្ថាបត្យកម្មនៅសម័យចេនឡាមានរចនាបថដូចម្តេច?

ចម្លើយ៖ ស្ថាបត្យកម្មសម័យចេនឡាមានរចនាបថបីដែលប្រវត្តិវិទូបានដាក់ឈ្មោះទៅតាមប្រាសាទសំខាន់ៗសម្រាប់សម្គាល់គឺ៖

-រចនាបថសម្ប្រៃ (ដើមសតវត្សទី៧)

-រចនាបថព្រៃក្មេង (ចុងសតវត្សទី៧)

-រចនាបថកំពង់ព្រះ (នៅក្នុងសតវត្សទី៨)។

២២. ចូររៀបរាប់ពីរចនាបថទាំងបីនេះ។

ចម្លើយ៖ រចនាបថទាំងបីគឺ

-រចនាបថសម្ប្រៃ ៖មានដូចជាប្រាសាទសម្ប្រៃព្រៃគុក ប្រាសាទភ្នំធំ ប្រាសាទដំបងដែក ជាដើម។

-រចនាបថព្រៃក្មេង៖ មានប្រាសាទព្រៃក្មេង ប្រាសាទស្វាយព្រហ្ម៌ ប្រាសាទភ្នំបាសិត ប្រាសាទព្រៃប្រាសាទនិងប្រាសាអណ្តែត។

-រចនាបថកំពង់ព្រះ៖ មានប្រាសាទកំពង់ព្រះ ប្រាសាទត្រពាំងធំ ប្រាសាទភ្នំបាសិត ប្រាសាទភូមិប្រាសាទ និងប្រាសាទអកយំ។

ប្រាសាទក្នុងរចនាបថទាំងបីនេះសុទ្ធតែសង់ពីឥដ្ឋ បូកបាយអ ដៃលផ្សំពីខ្សាច់ម៉ត់ កំបោរនិងស្ករ។

២៣. តើចម្លាក់នៅសម័យចេនឡាមានលក្ខណៈដូចម្តេច?

ចម្លើយ៖ សិល្បៈចម្លាក់បានដើរតួនាទីយ៉ាងសំខាន់ក្នុងការបម្រើឱ្យ វិស័យសាសនា ជាពិសេសព្រហ្មញ្ញសាសនាដៃលមានការនិយមភាគ ច្រើននៅសម័យនោះ។ គេបានឆ្លាក់រូបបដិមាព្រះវិស្ណុ ព្រះព្រហ្ម ព្រះ ហរិហរៈ សម្រាប់តម្កល់ទុកគោរពបូជានៅតាមប្រាសាទនានា។ ខាង ព្រះពុទ្ធសាសនាមហាយានមានរូបតំណាងពុទ្ធបដិមា អវលោកេស្វរ ធ្វើអំពីសំរិទ្ធទៅវត្តកំពង់ហ្លួង ស្រុកព្រៃកប្បាស ខេត្តតាកែវ។

២៤. តើសិល្បៈចម្លាក់ក្នុងសម័យចេនឡាអ្នកបុរាណវិទ្យាបាន កំណត់ស្នាដៃសិល្បៈជាប៉ុន្មានធំៗ?

ចម្លើយ៖ គេចែកជា២ធំៗគឺ

-ទីមួយ៖ រូបបដិមាព្រះហរិហរៈនៅប្រាសាទអណ្តែត។

-ទីពីរ៖ រូបទេវតា។

២៥. តើពិធីមង្គលការនៅសម័យចេនឡាមានលក្ខណៈដូចម្តេច?

ចម្លើយ៖ ពិធីមង្គលការនៅសម័យចេនឡាគឺដំបូងកូនកម្លោះត្រូវយក ជំនូនខ្លះទៅផ្ទះខាងស្រី បន្ទាប់មកទើបគ្រួសារខាងស្រីរើសថ្ងៃមង្គល ណាមួយ ដើម្បីនាំកូនស្រីមកកាន់ផ្ទះកូនកម្លោះវិញ។ កាលណាពិធី មង្គលការបានចប់សព្វគ្រប់ហើយ កូនប្រុស ក្រោយដៃលទទួលបាន មរតកខ្លះពីឪពុកម្តាយក៏ទៅតាំងទីលំនៅមួយផ្សេងទៀត។ នៅពេល ឪពុកម្តាយស្លាប់អស់ទៅ កូនៗដៃលនៅលីវទើបមានសិទ្ធិទទួលមរត

ក។ ប្រសិនបើកូនទាំងនោះបានរៀបការហើយ បានទទួលមរតក ហើយ មរតកដែលនៅសល់ត្រូវចូលក្នុងឃ្លាំងសាធារណៈ។

២៦. តើសិលាចារឹកជាភាសាខ្មែរដំបូងគេគឺជាសិលាចារឹកអ្វី?

ចម្លើយ៖ គឺសិលាចារឹកអង្គរបុរី។ ចុះកាលបរិច្ឆេទឆ្នាំ៦១១នៃគ.ស។

សំណួរ-ចម្លើយ ស្តីពីសម័យអង្គរ

ប្រធាន

១. តើសម័យអង្គរ ចាប់ពីឆ្នាំណាដល់ឆ្នាំណា?

ចម្លើយ៖ ៨០២ ដល់ ១៤៣២ ឆ្នាំនៃគ.ស។

២. តើព្រះរាជខ្មែរអង្គណា ដែលជាក្សត្រដំបូងគេនៃសម័យអង្គរ?

ចម្លើយ៖ ព្រះបាទ ជ័យវរ្ម័នទី២។

៣. តើព្រះបាទ ជ័យវរ្ម័នទី២ សោយរាជ្យពីឆ្នាំណាដល់ឆ្នាំណា?

ចម្លើយ៖ ពីឆ្នាំ៨០២ ដល់ ៨៥០ ។

៤. ចូររៀបរាប់ពីព្រះរាជាខ្មែរដែលល្បីៗនៅសម័យចក្រភពអង្គរ។

ចម្លើយ៖ ព្រះរាជាខ្មែរដែលល្បីនៅសម័យចក្រភពអង្គរ មានដូចជា៖

-ព្រះបាទ ជ័យវរ្ម័នទី២ ពីឆ្នាំ៨០២ ដល់ ៨៥០

-ព្រះបាទ ឥន្ទ្រវរ្ម័នទី១ ពីឆ្នាំ៨៧៧ ដល់ ៨៨៩

-ព្រះបាទយសោវរ្ម័នទី១ ពីឆ្នាំ៨៨៩ ដល់ ៩០០

-ព្រះបាទ ជ័យវរ្ម័នទី៤ ពីឆ្នាំ៩២៨ ដល់ ៩៤២

-ព្រះបាទ រាជេន្ទ្រវរ្ម័នទី២ ពីឆ្នាំ៩៤៤ ដល់ ៩៦៨

-ព្រះបាទ សូរ្យវរ្ម័នទី១ ពីឆ្នាំ១០១០ ដល់១០៥០
-ព្រះបាទ ឧទយាទិត្យវរ្ម័នទី២ ពីឆ្នាំ១០៥០ ដល់ ១០៦៦
-ព្រះបាទ សូរ្យវរ្ម័នទី២ ពីឆ្នាំ១១១៣ ដល់ ១១៥០
-ព្រះបាទ ជ័យវរ្ម័នទី៧ ពីឆ្នាំ១១៨១ ដល់ ១២១៨

៥. ចូររៀបរាប់ពីនយោបាយដឹកនាំប្រទេសនៅសម័យអង្គរ។

ចម្លើយ៖ នយោបាយដឹកនាំប្រទេសនៅសម័យអង្គរគឺ

-នយោបាយក្រៅប្រទេស ៖ការអនុវត្តនយោបាយវាតទីទឹកដី ដោយធ្វើសង្គ្រាមជាមួយរដ្ឋតូចៗ តែអនុវត្តនយោបាយមិត្តភាពជាមួយប្រទេសធំៗដែលមានអរិយធម៌រីកចម្រើនដូចជាប្រទេសចិនជាដើម។

-នយោបាយក្នុងប្រទេស ៖ ការបង្រួបបង្រួមជាតិឱ្យមានឯកភាពជុំវិញព្រះរាជបល្ល័ង្ករួមកម្លាំងកសាងប្រទេស និងពង្រីកទឹកដី។

៦. តើគេចែកអំណាចគ្រប់គ្រងនៅសម័យអង្គរជាប៉ុន្មានប្រភេទ ?

ចម្លើយ៖ គេចែកអំណាចគ្រប់គ្រងជាពីរប្រភេទគឺ អំណាចមជ្ឈិម និងអំណាចភូមិភាគ។

៧. តើព្រះរាជានៅសម័យអង្គរ មានសិទ្ធិអំណាចនិងតួនាទីអ្វីខ្លះ ?

ចម្លើយ៖ ព្រះរាជានៅសម័យអង្គរ មានសិទ្ធិអំណាចដូចជា៖

-ព្រះរាជា មានអំណាចជាស្តេចចក្រវាឡ និងជាម្ចាស់ផែនដី

-ព្រះរាជា គឺមានសិទ្ធិលើដីធ្លីទាំងអស់

-ព្រះរាជា ជាអ្នកកាន់ច្បាប់និងជាអ្នករើសតាំង ឬ ដកហូតមន្ត្រីធំៗតាមព្រះទ័យ

-ព្រះរាជា ជាមេបញ្ជាការកងទ័ពដោយផ្ទាល់

-ព្រះរាជា ជាអ្នកដឹកនាំនយោបាយ ហើយជាចៅក្រម និងជាមេសាសនា

ដូចនេះ ព្រះរាជាខ្មែរសម័យអង្គរ ព្រះអង្គកាន់អំណាចទាំងបី គឺអំណាចនិតីប្បញ្ញត្តិ និតីប្រតិបត្តិ និងតុលាការ។

៨. តើគេចែកកម្រិតទោស ឬការផ្តន្ទាទោសជាប៉ុន្មានកម្រិត?អ្វីខ្លះ?

ចម្លើយ៖ គេចែកជា៣កម្រិតគឺ៖

-ទោសស្រាល ៖ គេពិន័យឱ្យបង់ប្រាក់ ឬរបស់មានតម្លៃផ្សេងៗ។

-ទោសមធ្យម ៖ គេចៀរស្លឹកត្រចៀក កាត់ច្រមុះ ឬ កៀបក្បាលក្នុងដង្កៀបជាដើម។

-ទោសធ្ងន់ ៖ គេយកទៅកប់ចោលទាំងរស់។

៩. តើគេចែកវណ្ណៈសង្គម នាសម័យអង្គរជាប៉ុន្មានប្រភេទ? អ្វីខ្លះ?

ចម្លើយ៖ គេចែកវណ្ណៈសង្គម នាសម័យអង្គរជា៤ប្រភេទ គឺ៖

-វណ្ណៈក្សត្រនិងរាជវង្ស៖មានបុព្វសិទ្ធិរួចពន្ធជារ និងមិនជាប់កំណែនអ្វីទាំងអស់ ក្សត្រជាអំបូរអ្នកដឹកនាំ មានកាតព្វកិច្ចពង្រីកទឹកដីឱ្យមានវិសាលភាពធំធេង និងផ្តល់សេចក្តីសុខដល់រាស្ត្រ។

-វណ្ណៈព្រាហ្មណ៍និងបព្វជិត ៖ មានតួនាទីនៅក្នុងព្រះរាជវាំង ព្រោះពួកគេជាព្រះរាជគ្រូរបស់ក្សត្រ ពួកមន្ត្រី ឬរបស់ប្រជារាស្ត្រផ្សេងៗទៀត។

-វណ្ណៈអ្នកជា ឬកសិករ ៖ តំណាងឱ្យប្រជាជនភាគច្រើន ដែលមានមុខរបរធ្វើស្រែចម្ការ។

-វណ្ណៈទាសករ ៖ ទាសករបិតនៅខាងក្រោមនៃសង្គម មានជីវភាពពិបាកតោកយ៉ាកគ្មានសិទ្ធិសេរីភាពអ្វីទាំងអស់ក្នុងសង្គមទាសករ មួយចំនួនជាខ្ញុំគេអស់មួយជីវិត បន្តពីឪពុកទៅកូន គេច្រើនតែកេណ្ឌពួកនេះឱ្យទៅសង់ប្រាសាទលើកទំនប់ និងធ្វើទ័ពជាដើម។

១០. តើការកសាងប្រាសាទមានប៉ុន្មានបែប? អ្វីខ្លះ?

ចម្លើយ៖ ការកសាងប្រាសាទមាន២បែបគឺ៖

-ប្រាសាទភ្នំ ៖ ជាប្រាសាទដែលកសាងលើភ្នំធម្មជាតិ ឬសង់លើខឿនច្រើនជាន់ សម្រាប់លទ្ធិទេវរាជ ដូចជា ប្រាសាទបាគង ប្រាសាទបក្សីចាំក្រុង ប្រាសាទអង្គរវត្ត ប្រាសាទតាកែវ ប្រាសាទបាពួន ប្រាសាទប្រែរូប ប្រាសាទបាយ័ន...។

-ប្រាសាទទាបនឹងដី ៖ ជាប្រាសាទសង់ផ្ទាល់ដី ដើម្បីលទ្ធិបុគ្គលនិយម ដូចជាប្រាសាទព្រះគោ លលៃ វត្តនគរ តាព្រហ្ម...។

១១. តើព្រះបាទជ័យវរ្ម័នទី៧ កសាងអ្វីខ្លះក្នុងវិស័យសំណង់?

ចម្លើយ៖ ស្នាព្រះហស្តក្នុងវិស័យសំណង់មានដូចជា ការកសាងក្រុងអង្គរទី៣ ដែលមានកំពែងគូទឹកព័ន្ធជុំវិញ និងមានប្រាសាទបាយ័ននៅចំកណ្តាល។ នៅជុំវិញមានកសាងប្រាសាទបន្ទាយក្តី តាព្រហ្ម ព្រះខ័ន នាគព័ន្ធ តាសោម ក្រោលគោនិងនៅតាមខេត្តផ្សេងៗទៀត ដូចជា ប្រាសាទបន្ទាយឆ្មារ (បន្ទាយមានជ័យ) វត្តនគរ (កំពង់ចាម) តាព្រហ្ម(តាកែវ)ព្រមទាំងបានកសាងមន្ទីរពេទ្យចំនួន១០២ និងសាលាសំណាក់ចំនួន១២១ ជាដើម។

១២. ចូររៀបរាប់ពីវណ្ណៈព្រាហ្មណ៍និងបព្វជិត នៅក្នុងសម័យអង្គរ។

ចម្លើយ៖ នៅសម័យអង្គរ វណ្ណៈព្រាហ្មណ៍មានតួនាទីយ៉ាងសំខាន់ណាស់ក្នុងព្រះរាជវាំង ព្រោះពួកគេចាត់ទុកវណ្ណៈនេះជារាជគ្រូឬជាអ្នករៀបចំពិធីផ្សេងៗទាក់ទងនឹងលទ្ធិព្រាហ្មណ៍។ ពួកព្រាហ្មណ៍និងបព្វជិត មានដូចជា ៖

-ពួកប៉ាន់យាប គឺពួកព្រាហ្មណ៍ ៖ គេស្លៀកពាក់ដូចគេឯងដៃរ ខុសត្រង់ថាមានពាក់អំបោះវេញមួយខ្សែនៅក ជាសញ្ញាថាជាអ្នកមានចំណេះដឹងខ្ពង់ខ្ពស់។

-ពួកជូគូ ឬ ចៅគូ ៖ គឺពួកព្រះសង្ឃខាងពុទ្ធសាសនា។ ពួកនេះកោរសក់ និងគ្រងចីវរពណ៌លឿង បញ្ចេញស្មាស្តាំធាន់ក្នុងមួយថ្ងៃតែម្តងហើយគោរពព្រះពុទ្ធរូប។

-ពួកប៉ាស៊ីរី ឬ ពួកតាបស ៖ ស្លៀកពាក់ដូចអ្នកស្រុកធម្មតា តែជួតក្បាលកំណាត់ពណ៌ក្រហម ឬ ស។

១៣. ចូររៀបរាប់ពីជម្លោះផ្ទៃក្នុងក្រោយរាជ្យព្រះបាទជ័យវរ្ម័នទី៧។

ចម្លើយ៖ ក្រោយពីព្រះបាទជ័យវរ្ម័នទី៧សោយទីវង្គត មានការគំរាមកំហែងពីថៃផង ពួកម៉ុងហ្គោលផង និងមានជម្លោះផ្ទៃក្នុងជាញឹកញាប់ផង ដែលធ្វើឱ្យស្ថានភាពក្នុងប្រទេសជាតិកាន់តែដុនដាបទៅៗ ស្តេចស្រីន្ទ្រវរ្ម័ន ជាកូនប្រសាររបស់ព្រះបាទជ័យវរ្ម័នទី៨ បង្ខិតបង្ខំឱ្យព្រះបិតាក្មេកផ្ទេររាជ្យសម្បត្តិឱ្យខ្លួនដោយបង្ខំឱ្យមហេសីទៅលួចព្រះខ័នរបស់បិតា ដើម្បីឡើងសោយរាជ្យ។

១៤. ចូររៀបរាប់ពីវិបត្តិសេដ្ឋកិច្ចនៅចុងសម័យអង្គរ។

ចម្លើយ៖ វិបត្តិសេដ្ឋកិច្ចនៅចុងសម័យអង្គរ គឺ

-សង្គ្រាមនិងគ្រោះធម្មជាតិ ៖ពេលសង្គ្រាមជាមួយសៀម ពួកវាបានបំផ្លាញផ្ទះសម្បែង ទ្រព្យសម្បត្តិ ផលដំណាំកាប់សម្លាប់ និងបានបំផ្លាញសេដ្ឋកិច្ចខ្មែរដល់ឫសគល់តែម្តង ដូចជា កម្ទេចនូវបារាយណ៍ប្រព័ន្ធធារាសាស្ត្រ និងដីស្រែជាដើម។ ក្នុងពេលនោះតំបន់អង្គរមានអាកាសធាតុក្តៅ ជីប្រៃក្រហែង បានជំរុញឱ្យមានប្រតិកម្មយ៉ាងសាហាវ ដែលធ្វើឱ្យប្រព័ន្ធធារាសាស្ត្រខ្មែរខូចខាតមិនអាចជួសជុលបានហើយទឹកស្ទឹងដែលជាប្រភពរស់នៅរបស់ប្រជាជនត្រូវរាំងស្ទះដោយសារល្បប់ច្រើនពេក ប្រការនេះនាំឱ្យយើងលើករាជធានីទៅតាំងឯកន្លែងថ្មីទៀត។

-ការខូចខាតធនធានជាតិនិងកង្វះតុល្យភាពពាណិជ្ជកម្ម ៖ ការបាត់បង់ធនធានជាតិ ដូចជារោគរាតត្បាត ការស្រុតចុះនៃផ្នែកស្មារតីដោយសាររងទុក្ខវេទនា ពេលមានចម្បាំងរាំងជល ទាំងអស់នេះគឺជាកត្តាធ្ងន់បំផុតដែលធ្វើឱ្យសេដ្ឋកិច្ចជាតិធ្លាក់ចុះ។ រីឯពាណិជ្ជកម្មក្រៅប្រទេសវិញ យើងនាំចេញសុទ្ធតែជាវត្ថុធាតុដើមដូចជា ដំរី ក្រមួន ស្លកដំរី កុយរមាស ក្រវាញ ម្រេច ...។ ហើយនាំចូលមានដូចជា មាស ប្រាក់ កំណាត់គ្រប់ធុន សំណ ថាស គ្រឿងបារតេ ឈើក្រអូប ដៃកស្ពាន់ ។

១៥. តើមូលហេតុអ្វី បានជាព្រះបាទពញាយ៉ាតចាកចោលក្រុងអង្គរ?

ចម្លើយ៖ មូលហេតុគឺ៖

-កត្តាប្រជាជន ៖ ពេលធ្វើសង្គ្រាមជាមួយសៀម ពួកសៀមបានសម្លាប់ប្រជាជនខ្មែរនិងកៀរប្រជាជនខ្មែរនៅតំបន់អង្គរស្ទើរអស់រលីង ដូចនេះប្រជាជននៅក្នុងតំបន់អង្គរ ដែលនៅសេសសល់តិចតួចមិនអាចការពារក្រុងអង្គរបានតទៅទៀត ហើយប្រជាជនខ្លះទៀតកៀសខ្លួនចេញពីតំបន់អង្គរ។

-កត្តាសេដ្ឋកិច្ច ៖ ដោយសារសង្គ្រាមផ្ទៃក្នុងនិងសង្គ្រាមជាមួយពួកសៀម បានបំផ្លាញសង្គម សេដ្ឋកិច្ច ហេដ្ឋារចនាសម្ព័ន្ធ បារាយណ៍ប្រឡាយ ផ្លូវថ្នល់ ទំនប់ ធារាសាស្ត្រខ្ទេចខ្ទីអស់ ដែលមិនអាចស្តារការខូចខាតបាន។

-កត្តាភូមិសាស្ត្រ ៖ ក្រុងអង្គរនៅជិតក្រុងអយុធ្យាចម្ងាយតែ៤០០គីឡូម៉ែត្រពីគ្នាប៉ុណ្ណោះ ដូចនេះពួកសៀមនឹងអាចវាយលុកចូលក្រុងអង្គរម្តងទៀត។

-កត្តាឥទ្ធិពលឬកម្លាំង ៖ ខ្មែរចុះខ្សោយទាំងកម្លាំងកាយ កម្លាំងចិត្ត រីឯសៀមពង្រីកទឹកដី ពង្រីកអំណាច។

១៦. ចូររៀបរាប់ពីរាជវង្សមុនព្រះបាទត្រសក់ផ្អែម។

ចម្លើយ៖ រាជវង្សមុនព្រះបាទត្រសក់ផ្អែមមានដូចជា៖

-ព្រះបាទជ័យវរ្ម័នទី៨ (១២៤៣ដល់១២៩៦)

-ព្រះបាទស្រីន្ទ្រវរ្ម័ន ឬ ឥន្ទ្រវរ្ម័នទី៣ (១២៩៥ដល់១៣០៧)

-ព្រះបាទស្រីន្ទ្រជ័យវរ្ម័ន ឬ ឥន្ទ្រវរ្ម័នទី៤ (១៣០៧ដល់១៣២៧)

-ព្រះបាទជ័យវរ្ម័នទី៩ (១៣២៧ដល់១៣៣៦)

១៧. តើប្រាសាទអង្គរវត្ត កសាងដោយព្រះមហាក្សត្រខ្មែរអង្គណា?

ចម្លើយ៖ ព្រះបាទសូរ្យវរ្ម័នទី២។

១៨. ចូររៀបរាប់ពីសណ្ឋានដីកសិកម្មនៅសម័យអង្គរ។

ចម្លើយ៖ កសិកម្មនៅសម័យអង្គរមានការបែងចែកទៅតាមសណ្ឋានដីគឺ៖

-ដីទំនាបនៅជុំវិញបឹងទន្លេសាប ជាដីសម្បូរដីជាតិតែនៅរដូវវស្សាដីមួយភាគធំត្រូវបានទឹកលិច ពោលគឺអាចដាំបានតែក្នុងរដូវប្រាំងតែប៉ុណ្ណោះ។

-តំបន់ខ្លះគេអាចធ្វើស្រូវឡើងទឹក ឬស្រូវពង្រោះដែលឱ្យផលពីរ ឬបីដងក្នុងមួយឆ្នាំ។

-ស្រែទាំងឡាយដែលនៅតំបន់ខ្ពស់ គេធ្វើស្រូវនៅរដូវវស្សាដោយពឹងផ្អែកលើទឹកភ្លៀង ប្រព័ន្ធធារាសាស្ត្រ និងបារាយណ៍។

១៩. មូលហេតុអ្វីដែលនាំឱ្យសម័យអង្គរចុះខ្សោយ?

ចម្លើយ៖ មូលហេតុនោះគឺ

-វិបត្តិនៅចុងសម័យអង្គរពីសតវត្សទី១៤ដល់ទី១៥

-ជម្លោះផ្ទៃក្នុងរាជវង្ស

-ជម្លោះសាសនា រវាងព្រះពុទ្ធសាសនា និងព្រាហ្មញ្ញសាសនា

-គ្រោះធម្មជាតិ

-បរទេសឈ្លានពាន គឺសៀម។

២០. ចូររៀបរាប់ឈ្មោះអ្នកប្រាជ្ញល្បីៗនៅសម័យអង្គរ។

ចម្លើយ៖ អ្នកប្រាជ្ញល្បីៗនៅសម័យអង្គរមានដូចជា៖

-**បណ្ឌិត សិរីសោម** និពន្ធរឿងមហាការតៈ ក្បួនវេយ្យាករណ៍ និងសិលាចារឹកប្រាសាទកណ្តោលដើម។

-**បណ្ឌិតយតិអមរភារៈ** ជាអ្នកប្រាជ្ញសំខាន់ក្នុងរជ្ជកាលព្រះបាទយសោវរ្ម័ន និងជាអ្នកតាក់តែងសិលាចារឹកភ្នំបាយ៉ង់ក្នុងខេត្តតាកែវ។

-**បណ្ឌិតសិវាចារ្យ** ជាអធិការត្រួតត្រាខាងសីលធម៌ ក្នុងរជ្ជកាលព្រះបាទជ័យវរ្ម័នទី៥ ដែលបានតែងសិលាចារឹកជាភាសាសំស្ក្រឹតនៅប្រាសាទតាកែវ។

-**បណ្ឌិតកវិន្ទ្រៈ** ជាអ្នកប្រាជ្ញនិងអ្នកនិពន្ធក្នុងរជ្ជកាលព្រះបាទសូរ្យវរ្ម័នទី១ មានតួនាទីជាព្រះរាជគ្រូ។ លោកបានតែងនិពន្ធសិលាចារឹកប្រាសាទខ្នា ជាភាសាសំស្ក្រឹត។

-**បណ្ឌិតសទាសិវៈ** ជាក្មួយរបស់បណ្ឌិតសិវាចារ្យ លោកជាកវីដែលតែងសិលាចារឹកប្រវត្តិសាស្ត្រស្តុកកក់ធំ ក្នុងរជ្ជកាលព្រះបាទសូរ្យវរ្ម័នទី១។

-**បណ្ឌិតភូបេន្ទ្រៈ** ជាអ្នកប្រាជ្ញល្បីល្បាញក្នុងរជ្ជកាលព្រះបាទជ័យវរ្ម័នទី៧ មានតួនាទីជាចៅក្រមខាងនីតិសាស្ត្រ លោកបាននិពន្ធសិលាចារឹកប្រាសាទទរ ដែលស្ថិតនៅតំបន់វត្តភូ ប្រទេសឡាវបច្ចុប្បន្ន។

២១. តើបុត្ររបស់ព្រះបាទពញាយ៉ាត មានប៉ុន្មានអង្គ?

ចម្លើយ៖ បុត្ររបស់ព្រះបាទពញាយ៉ាត មាន៣អង្គគឺ៖

-ព្រះបាទ នរាយណ៍រាជា

-ព្រះបាទ ស្រីរាជា

-ព្រះបាទ ធម្មរាជា

២២. តើព្រះបាទជ័យវរ្ម័នទី២ ជាព្រះមហាក្សត្រដូចម្តេច?

ចម្លើយ៖ ព្រះបាទជ័យវរ្ម័នទី២ ជាក្សត្រមានព្រះរាជហឫទ័យស្នេហាជាតិក៏ខ្លាំងក្លា និងមានឧត្តមគតិជាតិដ៏ខ្ពង់ខ្ពស់ ទ្រង់បានយល់ថាប្រទេសកម្ពុជាត្រូវតែមានព្រះមហាក្សត្រជាចក្រពត្តិគ្រប់គ្រងជាដរាប ព្រះអង្គបានចាត់ចែងកសាងអ្វីៗគ្រប់យ៉ាងដើម្បីព្រះរាជាណាចក្រជាចក្រភព។

២៣. តើព្រះបាទជ័យវរ្ម័នទី២ បានបង្កើតលក្ខណៈសម្គាល់ធំៗប៉ុន្មានយ៉ាងក្នុងយុគសម័យនៃប្រវត្តិសាស្ត្រខ្មែរ?

ចម្លើយ៖ ព្រះអង្គបានបង្កើតលក្ខណៈសម្គាល់៣គឺ

-នយោបាយកសិកម្ម៖ ការបង្កើតប្រព័ន្ធនយោបាយបញ្ចេញបញ្ចូលទឹកនិងដីកព្រែក ដែលអាចធានាការប្រមូលផលដំណាំបានពីរដងឬបួនដងក្នុងមួយឆ្នាំ។ ការកើនឡើងនៃផលិតផលដំណាំនេះបានផ្តល់លទ្ធភាពយ៉ាងទូលំទូលាយដល់ប្រជារាស្ត្រទូទៅក្នុងជីវភាពរស់នៅ។

-លទ្ធិទេវរាជ ឬពុទ្ធរាជ៖ លទ្ធិនេះមានជំនឿថាព្រះមហាក្សត្រចាប់បដិសន្ធិពីព្រះសិវៈ ព្រះវិស្ណុឬព្រះពោធិសត្វ។ ព្រះមហាក្សត្រជាអ្នកមានអំណាច អាចសុំទឹកភ្លៀងធ្វើឱ្យបានភោគផលស្រែចម្ការជាដើម ព្រះបាទជ័យវរ្ម័នទី២ បានប្រារព្ធពិធីទេវរាជជាផ្លូវការនៅលើកំពូលភ្នំគូលែន ធ្វើឱ្យកម្ពុជាជារដ្ឋឯករាជ្យ ព្រមទាំងធ្វើឱ្យព្រះអង្គមានឋានៈជាស្តេចចក្រវាល។

-ប្រាសាទភ្នំ៖ ការកសាងប្រាសាទធំៗស្តឹមស្តែ ដើម្បីជានិមិត្តរូបនៃភ្នំព្រះសុមេរុ ដែលជាស្ថានរបស់ទេវៈ ហើយជាមជ្ឈមណ្ឌលនៃចក្រ

វិលទៀតផង។ បណ្តាប្រាសាទទាំងនោះសាងឡើងលើកំពូលភ្នំឬ
សាងច្រើនជាន់នៅចំកណ្តាលរាជធានីតែម្តង។

២៤. តើព្រះបាទជ័យវរ្ម័នទី២ បានសាងគ្រឿងសាស្ត្រាវុធអ្វីខ្លះ?

ចម្លើយ៖ ក្នុងរាជ្យព្រះអង្គបានសាងគ្រឿងសាស្ត្រាវុធដូចជា៖

+ការសាងសាស្ត្រាវុធសម្រាប់ព្រះមហាក្សត្រ

-ព្រះខ័នរាជ្យ

-ព្រះខ័នរង

-ព្រះទំរង់អសិខ្លី

-ព្រះទំរង់អសិវែង

-ព្រះទំរង់លំពែងជ័យ

+ការសាងព្រះខ័នសម្រាប់ស្តេចឧបរាជស្រុក ស្តេចត្រាញ់ ព្រមទាំងយុទ្ធោបករណ៍ផ្សេងៗទៀត។

+ការសាងគ្រឿងសាស្ត្រាវុធនិងគ្រឿងយុទ្ធកណ្ឌសម្រាប់សេនាទាហានជាច្រើនសម្រាប់ការពារប្រទេស។

២៥. ដើម្បីឱ្យស្ទាត់ជំនាញក្នុងក្បួនយុទ្ធសាស្ត្រសម្រាប់ការពារប្រទេស ព្រះមហាក្សត្រទ្រង់បានធ្វើពិធីអ្វី? ចូររៀបរាប់។

ចម្លើយ៖ ព្រះមហាក្សត្រទ្រង់បានធ្វើពិធីទ្វារទេសមាសគឺ

-ខែកត្តិក ធ្វើពិធីសមយុទ្ធទាហានជើងទឹក។

-ខែចែត្រ ធ្វើពិធីសមយុទ្ធទាហានជើងគោក។

-ខែជេស្ឋ ធ្វើពិធីប្រសិទ្ធិគ្រឿងសរពើយុទ្ធ។

-ខែស្រាពណ៍ ធ្វើព្រះរាជពិធីអានជម្រះព្រះខ័នជ័យ។

ពិធីទាំងអស់នេះបញ្ជាក់ថា ព្រះមហាក្សត្រខ្មែរពីបុរាណនិយមយកព្រះទ័យទុកដាក់ជាសំខាន់ក្នុងលទ្ធិខត្តិយៈ ហើយប្រជារាស្ត្រក៏និយមកិច្ចការយោធាជាសំខាន់ផងដែរ។

២៦. តើព្រះបាទជ័យវរ្ម័នទី២ សោយទិវង្គតនៅឆ្នាំណា? ហើយមានព្រះមរណនាមដូចម្តេច?

ចម្លើយ៖ ព្រះបាទជ័យវរ្ម័នទី២ សោយទិវង្គតនៅហរិហរាល័យនាឆ្នាំ ៨៥០ ហើយទ្រង់ទទួលមរណនាមថា បរមេស្វរៈ។

២៧. តើព្រះរាជាខ្មែរណាខ្លះដែលសោយរាជ្យនៅហរិហរាល័យបន្តពីព្រះបាទជ័យវរ្ម័នទី២?

ចម្លើយ៖ ព្រះរាជាខ្មែរដែលសោយរាជ្យបន្តគឺ

-ព្រះបាទ ជ័យវរ្ម័នទី៣ (៨៥០ដល់៨៧៧)

-ព្រះបាទ ឥន្ទ្រវរ្ម័នទី១ (៨៧៧ដល់៨៨៩)។

២៨. តើស្នាព្រះហស្តរបស់ព្រះបាទឥន្ទ្រវរ្ម័នទី១មានអ្វីខ្លះ?

ចម្លើយ៖ ស្នាព្រះហស្តរបស់ព្រះបាទឥន្ទ្រវរ្ម័នទី១មានដូចជា៖

-ព្រះអង្គបានបន្តការបង្រួបបង្រួមជាតិរបស់ព្រះបាទជ័យវរ្ម័នទី២ បានធ្វើឱ្យមានឯកភាពទូទាំងចេនឡាទឹកលិច។

-ឆ្នាំ៨៧៧ ព្រះអង្គបានបញ្ជាឱ្យជីកបារាយណ៍មួយនៅខាងជើងរាជធានី (បារាយណ៍ឥន្ទ្រតាដាក) មានបណ្តោយ៣គីឡូម៉ែត្រនិងទទឹង ៨០០ម៉ែត្រ។

-ឆ្នាំ៨៧៩ ព្រះអង្គបានកសាងប្រាសាទព្រះបាគោ ដើម្បីឧទ្ទិសចំពោះបុព្វបុរសព្រះអង្គ។

-ឆ្នាំ៨៨១ ព្រះអង្គបានកសាងប្រាសាទបាគងដែលជាប្រាសាទភ្នំទី១ ធ្វើអំពីថ្មកក់ សម្រាប់តម្កល់លិង្គទេវរាជឈ្មោះឥន្ទ្រេស្វរៈ។

២៩. តើព្រះបាទឥន្ទ្រវរ្ម័នទី១ សោយទិវង្គតនៅឆ្នាំណា? ហើយព្រះរាជាខ្មែរអង្គណាសោយរាជ្យបន្ត?

ចម្លើយ៖ ព្រះបាទឥន្ទ្រវរ្ម័នទី១ សោយទិវង្គតនៅឆ្នាំ៨៨៩។ បន្ទាប់ពីព្រះអង្គសោយទិវង្គតទៅ ព្រះបាទយសោវរ្ម័នទី១ ជាបុត្រាឡើងសោយរាជ្យបន្ត។

៣០. តើព្រះបាទយសោវរ្ម័នទី១ មានលក្ខណៈសម្បត្តិប៉ុន្មានយ៉ាង?

ចម្លើយ៖ ព្រះបាទយសោវរ្ម័នទី១ ពុំគ្រាន់តែមានពុទ្ធិខាងទស្សនវិជ្ជាប៉ុណ្ណោះទេ ថែមទាំងមានពុទ្ធិឬចំណេះដឹងផ្នែកសិល្បៈគ្រប់ប្រភេទទៀតផង។ ហើយព្រះអង្គមានលក្ខណៈសម្បត្តិបួនយ៉ាងគឺថាមពលពុទ្ធិ គុណធម៌ និងសិល្បវិធី។

៣១. តើព្រះបាទយសោវរ្ម័នទី១ បានកសាងអ្វីខ្លះ?

ចម្លើយ៖ ព្រះបាទយសោវរ្ម័នទី១ បានកសាងដូចជា៖

-ពេលព្រះអង្គឡើងសោយរាជ្យភ្លាមព្រះអង្គក៏បានកសាងអាស្រមចំនួន១០០ ដែលរាយនៅតាមខេត្តខណ្ឌ។

-ឆ្នាំ៨៩៣ ព្រះអង្គបានកសាងប្រាសាទលលៃនៅចំកណ្តាលបារាយណ៍ឥន្ទ្រតាដាក សម្រាប់ឧទ្ទិសចំពោះមាតាបិតានិងជីដូនជីតាខាងមាតារបស់ទ្រង់។

៣២. ចូររៀបរាប់ពីស្នាព្រះហស្តរបស់ព្រះបាទសូរ្យវរ្ម័នទី២។

ចម្លើយ៖ ស្នាព្រះហស្តរបស់ព្រះបាទសូរ្យវរ្ម័នទី២មានដូចជា៖

-ព្រះអង្គ ជាស្តេចសឹកសង្គ្រាមនិងបានបង្រួបបង្រួមទឹកដីបន្ទាប់ពីមានការបែកបាក់។

-ព្រះអង្គបានរៀបចំប្រទេសជាតិឱ្យមានសុខសន្តិភាពនិងការអភិវឌ្ឍ។

-ព្រះអង្គបានស្ថាបនានៅតាមបណ្តាខេត្តដូចជា ប្រាសាទភ្នំជីសូរ ប្រាសាទភ្នំសណ្តាក ប្រាសាទវត្តកូ ប្រាសាទព្រះវិហារ ប្រាសាទបឹងមាលា ប្រាសាទព្រះខ័ន (កំពង់ស្វាយ)។

-នៅអង្គរ ព្រះអង្គបានកសាងប្រាសាទធម្មនន្ទ ប្រាសាទចៅសាយទេវតា ប្រាសាទព្រះពិធូរ បន្ទាយសំរែ និងប្រាសាទអង្គរវត្ត។

៣៣. ចូររៀបរាប់ពីមហេសីនិងបណ្តាសក្តិក្នុងព្រះបរមរាជវាំង។

ចម្លើយ៖ ព្រះមហេសីរបស់ព្រះមហាក្សត្រមានចំនួន៥អង្គគឺ

-អង្គទី១ មានតំណែងយសជាព្រះអង្គអគ្គមហេសី ឬរាជិនី នៅក្បែរព្រះមហាក្សត្រជានិច្ច។

-៤អង្គទៀត គឺមានតំណែងយសជារាជទេវី ស្មើគ្នាទាំងអស់នៅក្នុងប្រាសាទជាមួយនឹងព្រះមហាក្សត្រ តែក្រឡាបន្ទំផ្សេងគ្នាពីព្រះមហាក្សត្រ នៅតាមទិសធំទាំងបួន។

ក្នុងក្សត្រីទាំង៥អង្គនេះ អង្គទី១ព្រះអគ្គមហេសី ប្រៀបដូចជាព្រះរាជាម្ចាស់ផែនដី។ រីឯព្រះរាជទេវីទាំង៤ ប្រៀបដូចមន្ត្រីចតុស្តម្ភឬសេនាបតីទាំង៤។ ក្រៅពី៥អង្គនេះទ្រង់ក៏មានព្រះជាយារងផ្សេងៗទៀតជាច្រើនដែលគេកំណត់ហៅថា ស្នំ។

៣៤. តើរបៀបកត់ត្រានៅសម័យអង្គរ គេសរសេរលើអ្វី? ហើយប្រើភាសាអ្វី?

ចម្លើយ៖ នៅសម័យអង្គរគេកត់ត្រាលើថ្ម ឬលើស្បែកសត្វ។ ក្នុងការកត់ត្រាលើផ្ទាំងថ្ម ឬសិលាចារឹក គេនិយមប្រើភាសាសំស្ក្រឹត ភាសាខ្មែរបុរាណនិងភាសាបាលី។

៣៥. តើភាសាសំស្ក្រឹត ជាភាសាដូចម្តេចនៅសម័យអង្គរ?

ចម្លើយ៖ ភាសាសំស្ក្រឹត ជាភាសារបស់អ្នកប្រាជ្ញសម្រាប់ប្រើកត់ត្រាធ្វើបញ្ជីព្រះរាជវង្សានុវង្ស ឬមហាក្សត្រ និងតែងសេចក្តីសរសេរដល់ក្សត្រដែលកសាងប្រាសាទ ឬអស់លោកអ្នកមានសទ្ធាជ្រះថ្លាធ្វើអំណោយទាន។ ភាសាសំស្ក្រឹតនិងភាសាខ្មែរបុរាណ និយាយទាក់ទងនឹងប្រវត្តិក្សត្រ ព្រមទាំងការគ្រប់គ្រងអាណាចក្រខ្មែរដែលមានច្បាប់សម្រាប់ស្រុកទេស សម្រាប់តុលាការ និងកត់ត្រាវិជ្ជាផ្សេងៗទៀត។

៣៦. តើព្រះនាងឥន្ទ្រទេវី មានចំណេះដឹងលើផ្នែកអ្វីខ្លះ?

ចម្លើយ៖ ព្រះនាងឥន្ទ្រទេវី ជាមហេសីរបស់ព្រះបាទជ័យវរ្ម័នទី៧ ព្រះនាងមានចំណេះវិជ្ជាផ្នែកអក្សរសិល្ប៍ ចេះភាសាសំស្ក្រឹតច្បាស់លាស់ ចេះវិទ្យាសាស្ត្រផ្សេងៗហើយមានប្រាជ្ញាឈ្លាសវៃ។

៣៧. ហេតុអ្វីបានជាសៀមចូលមកតាំងទីលំនៅលើទឹកដីខ្មែរ?

ចម្លើយ៖ បានជាសៀមចូលមកតាំងទីលំនៅលើទឹកដីខ្មែរ ព្រោះ
-ពួកម៉ុងហ្គោល បានចូលមកលុកលុយសៀម បណ្តាលឱ្យសៀមភៀសខ្លួនមករស់នៅលើទឹកដីខ្មែរ។

-សៀមបានដណ្តើមបានសុខោទ័យ និងសុវណ្ណលោក ពួកសៀមបានវាយបណ្តេញខ្មែរឱ្យចេញពីតំបន់នោះ។

-សៀមរើបម្រាស់ពីការត្រួតត្រារបស់ខ្មែរ និងបង្កើតជារដ្ឋឯករាជ្យរបស់ខ្លួននៅក្នុងសតវត្សទី១៣។

៣៨. តើព្រឹត្តិការណ៍សំខាន់ៗរបស់ខ្មែរមុនសតវត្សទី១៣មានអ្វីខ្លះ?

ចម្លើយ៖ ព្រឹត្តិការណ៍សំខាន់ៗរបស់ខ្មែរមុនសតវត្សទី១៣មានដូចជា៖

-មានសង្គ្រាមក្នុងស្រុកអស់រយៈពេល៩ឆ្នាំ

-ការបះបោរវាយកម្ទេចសិវលិង្គដែលជានិមិត្តរូបនៃអំណាចព្រះរាជា

-ការបះបោរដណ្តើមរាជ្យពីព្រះបាទយសោវរ្ម័នទី២

-ចាមវាយលុកចូលក្រុងអង្គរក្នុងឆ្នាំ១១៧៧។

៣៩. តើសៀមបានវាយត្រួតត្រាក្រុងអង្គរប៉ុន្មានលើក? ចូររៀបរាប់។

ចម្លើយ៖ សៀមបានវាយត្រួតត្រាក្រុងអង្គរចំនួន៣លើកគឺ៖

-លើកទី១៖ (១៣៥៣-១៣៥៧) ដោយស្តេចសៀមឈ្មោះ រាមាធិបតី ហើយនៅឆ្នាំ១៣៥៧ ព្រះបាទស្រីសុរិយោវង្សទី១ បានរំដោះក្រុងអង្គរពីសៀមមកវិញ។

-លើកទី២៖ (១៣៩៤-១៤០១) ដោយស្តេចឈ្មោះ រាមាសូរ ហើយនៅឆ្នាំ១៤០១ ព្រះបាទស្រីសុរិយោវង្សទី២ បានរំដោះក្រុងអង្គរពីសៀមបានវិញ។

-លើកទី៣៖ (១៤២០-១៤២១) ដោយស្តេចសៀមឈ្មោះពញាព្រែក ហើយនៅឆ្នាំ១៤២១ ព្រះបាទពញាយ៉ាតបានរំដោះក្រុងអង្គរចេញពីសៀមវិញ។

៤០. ចូរបង្ហាញពីព្រឹត្តិការណ៍ដែលនាំឱ្យសៀមត្រួតត្រា ក្រុងអង្គរលើកទី១ និងបានរំដោះក្រុងអង្គរពីសៀមមកវិញ។

ចម្លើយ៖ ព្រឹត្តិការណ៍ដែលនាំឱ្យសៀមត្រួតត្រាក្រុងអង្គរ លើកទី១ បាននិងការរំដោះក្រុងអង្គរពី សៀមមកវិញ មានដូចខាងក្រោម៖

-នៅឆ្នាំ១៣៥១ ស្តេចសៀមនាមរាមាធិបតីនៃក្រុងអាយុធ្យាបានលើកទ័ពមកវាយក្រុងអង្គរ តែត្រូវទ័ពព្រះស្រីសុរិយោទ័យវាយឱ្យដកថយទៅវិញ។ ព្រះបាទលំពង្សរាជាស្មានថាសៀមលែងហ៊ានវាយក៏បញ្ជាឱ្យស្រីសុរិយោទ័យរំលាយទ័ពខ្មែរដើម្បីជួយធ្វើស្រែចំការ សៀមដឹងខ្មែរំលាយទ័ពក៏លើកទ័ពវាយចូលក្រុងអង្គរនៅឆ្នាំ១៣៥២ ពេលនោះស្តេចលំពង្សរាជាគាំងបេះដូងសុគត រីឯព្រះបាទស្រីសុរិយោទ័យត្រូវសៀមធ្វើឃាត។

-ស្តេចសៀមនាមរាមាធិបតីបានតែងតាំង បុត្រា៣អង្គឱ្យគ្រងរាជ្យនៅក្រុងអង្គរ(បាសាទ បារេត កំពង់ពិសី)។

-នៅឆ្នាំ១៣៥៧ស្តេចខ្មែរនាមស្រីសុរិយោវង្សទី១ ជាអនុជលំពង្សរាជាបានកៀសខ្លួនមកពី ឡាវហើយបានប្រមូលទ័ពមករំដោះក្រុងអង្គរ ដោយសម្លាប់កំពង់ពិសីចោល រួចព្រះអង្គ បានរៀបចំក្រុងអង្គរឡើងវិញ។

៤១. តើសៀមបានប្រើល្បិចដូចម្តេច ដើម្បីត្រួតត្រាក្រុងអង្គរលើកទី២បាន?

ចម្លើយ៖ ដើម្បីត្រួតត្រាក្រុងអង្គរលើកទី២បាន សៀមបានប្រើល្បិចដូចជា៖

-នៅឆ្នាំ១៣៩៣ ទាហានសៀម១៥នាក់ចុះចូលជាមួយទ័ពខ្មែរ ទ័ពខ្មែរមិនយល់ល្បិចសៀមដូចនាំសត្រូវចូលផ្ទះ ជាឱកាសធ្វើឱ្យសៀមបើកទ្វារក្រុងអង្គរពីខាងលិចឱ្យទ័ពសៀមសម្រុកចូលយកក្រុងអង្គរបាន។

-សៀមបានត្រួតត្រាអង្គរលើកទី២ ពីឆ្នាំ១៣៩៤ដល់១៤០១ ស្តេចសៀមរាមាសូរ បានចាត់ឱ្យបុត្រឈ្មោះពញាព្រែកត្រួតត្រានៅក្រុងអង្គរ។

-នៅឆ្នាំ១៤០២ ព្រះបាទស្រីសុរិយោវង្សទី២ បានរំដោះក្រុងអង្គរពីសៀមមកវិញ។

៤២. ហេតុអ្វីបានជាព្រះបាទ ពញាយ៉ាតអាចរំដោះក្រុងអង្គរពីសៀមបាន?

ចម្លើយ៖ បានជាព្រះបាទពញាយ៉ាត អាចរំដោះក្រុងអង្គរពីសៀមបានព្រោះ ព្រះអង្គបានប្រើល្បិចឱ្យទ័ពខ្មែរស្មើគ្រចិត្ត១២នាក់ទៅចុះចូលជាមួយទ័ពសៀម ហើយដកអាវុធសម្លាប់ស្តេចពញាព្រែកចោលនៅឆ្នាំ១៤២១ទើបរំដោះបានរាជធានីអង្គរវិញបាន។

៤៣. តើលទ្ធិទេវរាជ ជាអ្វី?

ចម្លើយ៖**លទ្ធិទេវរាជ** គឺជាពិធីគោរពបូជាដល់ស្តេចអាទិទេពនៃស្តេចទេវតាដែលផ្តើមបង្កើតឡើងដោយព្រះបាទជ័យវរ្ម័នទី២នៅឆ្នាំ៨០២ នៃគ.ស។

៤៤. តើលទ្ធិទេវរាជបានផ្តល់ផលប្រយោជន៍អ្វីខ្លះដល់ប្រទេសជាតិ?

ចម្លើយ៖ លទ្ធិទេវរាជបានផ្តល់ផលប្រយោជន៍ដល់ប្រទេសជាតិដូចជា៖

-ផ្តល់ឥទ្ធិពលយ៉ាងខ្លាំងក្លាក្នុងការបង្រួបបង្រួមជាតិ

-ធ្វើឱ្យប្រជារាស្ត្រជឿស៊ប់លើព្រះរាជា

-ធ្វើឱ្យប្រទេសជាតិរីកចម្រើន

-មានវិសាលភាពធំទូលាយ

៤៥. ប្រាសាទបាយ័ន ឬអង្គរធំ គឺជាប្រាសាទបែបពុទ្ធសាសនា។ ចូរពន្យល់ពីមូលហេតុនៃការគោរពពុទ្ធសាសនានៅពេលនោះ។

ចម្លើយ៖ មូលហេតុនៃការគោរពពុទ្ធសាសនានាពេលនោះគឺ៖

-នៅមុខរជ្ជកាលរបស់ព្រះបាទជ័យវរ្ម័នទី៧ កើតមាននូវកុប្បកម្ម ការបះបោរ និងទំនាស់រាជសម្បត្តិ ជាហេតុនាំឱ្យមានចលាចលនិងអស្ថិរភាពសង្គម។

-ការលុកលុយក្រុងអង្គរដោយកងទ័ពពួកចម្ប៉ានៅឆ្នាំ១១៧៧ ជាអន្លូងមួយយ៉ាងធ្ងន់វាយទៅលើលទ្ធិទេវរាជ។

-ប្រជាជនលែងជឿទៅលើប្រសិទ្ធភាពនៃលទ្ធិទេវរាជក្នុងព្រហ្មញ្ញសាសនា។

-ប្រជាជនជាច្រើនបានក្លាយជាពុទ្ធសាសនិករួចស្រេចទៅហើយ ក្នុងខណៈដែលមន្ត្រីរាជវាំងជឿលើព្រហ្មញ្ញសាសនា។
-ដើម្បីស្រោចស្រង់ជាតិឱ្យមានពន្លឺឡើងវិញបន្ទាប់ពីការឈ្លានពានរបស់ចម្ប៉ា នាឆ្នាំ១១៧៧។
-ព្រះបាទជ័យវរ្ម័នទី៧ (១១៨១-១២២១) ទ្រង់បានខិតខំរកមធ្យោបាយការពារក្រុង តាមបែបពុទ្ធសាសនាមហាយាន ដែលទ្រង់យល់ថាមានប្រសិទ្ធភាពជាងសាសនារបស់រាជាមុនៗ។
-ព្រះបាទជ័យវរ្ម័នទី៧ ទ្រង់ពឹងផ្អែកលើព្រះពោធិសត្វ អវលោកេស្វរៈដែលពោរពេញដោយធម៌មេត្តា ករុណា ហើយប្រមើលមើលសុខទុក្ខរបស់សត្វលោក។
-លទ្ធិពុទ្ធសាសនាជាលទ្ធិបែបមនុស្សនិយម មានទំនោរទៅរកជីវភាពរស់នៅប្រចាំថ្ងៃរបស់ប្រជារាស្ត្រទូទៅ។
-ព្រះបាទជ័យវរ្ម័នទី៧ ជាអ្នករំដោះក្រុងអង្គរពីចម្ប៉ា ទ្រង់មានមហេសីព្រះនាងជ័យទេវី និងព្រះនាងឥន្ទ្រទេវី ដែលសុទ្ធតែជាអ្នកជ្រះថ្លាក្នុងព្រះពុទ្ធសាសនា។
-ចំពោះប្រជានុរាស្ត្រវិញ លទ្ធិពុទ្ធសាសនាមហាយាន មានសមត្ថភាពស្រោចស្រង់ ការពារ និងបម្រើរាស្ត្រ។

៤៦. តើស្ពានប្រាប់ទិស នៅកំពង់ក្តី(សៀមរាប) កសាងដោយព្រះរាជាអង្គណា? មានអាយុកាលប៉ុន្មានឆ្នាំ?

ចម្លើយ៖ កសាងដោយព្រះបាទជ័យវរ្ម័នទី៧។ មានបណ្តោយប្រហែល៨៤ម៉ែត្រ មានអាយុកាលជិត១០០០ឆ្នាំហើយ។

៤៧. តើថ្មកក់ដែលគេបានយកមកសាងសង់ប្រាសាទនៅអង្គរគេដឹកពីកន្លែងណាមក?

ចម្លើយ៖ គេដឹកមកពីភ្នំគូលែននឹងដឹកជញ្ជូនតាមស្ទឹងសៀមរាប។

៤៨. តើប្រាសាទអង្គរវត្ត បែរមុខទៅទិសខាងណា?

ចម្លើយ៖ ប្រាសាទអង្គរវត្ត បែរមុខទៅទិសខាងលិច។

៤៩. ចូររៀបរាប់ខ្លីៗស្តីពីប្រាសាទអង្គរវត្ត។

ចម្លើយ៖ រៀបរាប់ខ្លីៗស្តីពីប្រាសាទអង្គរវត្តគឺ៖

-ទីតាំង៖ មានចម្ងាយ៦គីឡូម៉ែត្រ ខាងជើងក្រុងសៀមរាប។

-សាងសង់៖ នៅពាក់កណ្តាលទី១នៃសតវត្សទី១២។

-ក្សត្រស្ថាបនិក៖ ព្រះបាទសូរ្យវរ្ម័នទី២។

-ឧទ្ទិសចំពោះ៖ ព្រះវិស្ណុក្នុងសាសនាព្រាហ្មណ៍។

-ប្រភេទឬកិនភាគ៖ ជាប្រាសាទភ្នំ មាន៣ថ្នាក់ កំពែង៤ជាន់។

-សង់អំពី៖ ថ្មកក់និងថ្មបាយក្រៀម។

-គូទឹកព័ន្ធជុំវិញ៖ មានទទឹងប្រវែង១៩០ម៉ែត្រ។

-រូបចម្លាក់៖ មានជាផ្ទាំងធំៗរវែងៗរចនាជារឿងផ្សេងៗគ្នា។

៥០. តើនៅសម័យអង្គរស្ត្រីមានតួនាទីសំខាន់អ្វីខ្លះ?

ចម្លើយ៖ នៅសម័យអង្គរស្ត្រីមានតួនាទីសំខាន់ដូចជា៖

-ស្ត្រីជាអ្នកជំនួញ

-ស្ត្រីជាហោរា

-ស្ត្រីជាអ្នករាជការ

-ស្ត្រីជាសាស្ត្រាចារ្យ...។

សំណួរ-ចម្លើយ ស្តីពីសម័យចតុមុខ

ប្រធាន

១. តើសម័យចតុមុខ ពីឆ្នាំណាដល់ឆ្នាំណា?

ចម្លើយ៖ ១៤៣១ ដល់ ១៥១៦ ឆ្នាំនៃគ.ស ឬ សតវត្សទី១៥។

២. តើព្រះបាទ ពញាយ៉ាត ផ្លាស់ប្តូររាជធានីពីទួលបាសានទៅចតុមុខនៅឆ្នាំណា?

ចម្លើយ៖ នៅឆ្នាំ១៤៣១ ដោយសារតែទួលបាសានមានទឹកជំនន់ជន់លិច។

៣. ហេតុអ្វីបានជាព្រះបាទពញាយ៉ាត ជ្រើសរើសយកក្រុងចតុមុខធ្វើជារាជធានី?

ចម្លើយ៖ បានជាព្រះបាទពញាយ៉ាត ជ្រើសរើសយកក្រុងចតុមុខធ្វើជារាជធានីព្រោះ៖

-មានទីតាំងភូមិសាស្ត្រល្អ

-គេចពីសត្រូវឈ្លានពាន(សៀម)

-ដីមានជីវជាតិងាយស្រួលក្នុងការធ្វើកសិកម្ម

-ជាទីប្រសព្វនៃផ្លូវជំនួញទាំងផ្លូវទឹកនិងផ្លូវគោក

-សម្បូរផ្លូវទឹកក្នុងការធ្វើកសិកម្មនិងជំនួញ

-ភាគខាងត្បូងមានប្រជាជនរស់នៅច្រើន មានធនធានដើម្បីកសាងសេដ្ឋកិច្ចជាតិ។

៤. តើក្រុងចតុមុខមានឈ្មោះពេញដូចម្តេច?

ចម្លើយ៖ ក្រុងចតុមុខមង្គល សកលកម្ពុជាធិបតី សិរីធរបវរ ឥន្ទបត្ត បុរីរដ្ឋរាជសីមា មហានគរ។

៥. ចូររៀបរាប់រាជវង្សខ្មែរនៅសម័យចតុមុខ។

ចម្លើយ៖ រាជវង្សខ្មែរនៅសម័យចតុមុខគឺ៖

-ព្រះបាទពញាយ៉ាត (១៤៣៤ដល់១៤៦៣)

-ព្រះបាទនារាយណ៍រាជា (១៤៦៣ដល់១៤៦៩)

-ព្រះបាទស្រីរាជា (១៤៦៩ដល់១៤៨៥)

-ព្រះបាទធម្មរាជា (១៤៨៥ដល់១៥០៤)

-ព្រះបាទស្រីសុគន្ធបទ (១៥០៤ដល់១៥១២)

-ព្រះបាទស្រីជេដ្ឋា ឬស្តេចកន (១៥១២ដល់១៥១៦)។

៦. តើព្រះបាទស្រីរាជា ជាព្រះមហាក្សត្រដូចម្តេច?

ចម្លើយ៖ ព្រះអង្គជាក្សត្រដែលមានមនសិការជាតិខ្ពស់ ដោយព្រះអង្គចិញ្ចឹមចិត្តដើម្បីស្តាបនាជាតិឱ្យបានប្តុំប្តើងឡើងវិញ និងស្តាយស្រណោះនូវទឹកដីខ្មែរប៉ែកខាងលិចដែលត្រូវសៀមលេបត្របាក់កន្លងមក។

៧. ចូររៀបរាប់ឈ្មោះវត្ត ព្រែក និងបឹងនៅក្នុងរជ្ជកាលព្រះបាទពញាយ៉ាត។

ចម្លើយ៖ ក្នុងរាជ្យព្រះបាទពញាយ៉ាត មានវត្ត ព្រែក និងបឹងដូចជា

បឹងតេជោ ព្រែកចិនដំដែក ព្រែកឧកញ៉ាផ្លុង ព្រែកតាកែវ ព្រែកអូរគ វត្តធម្មលង្កា វត្តកោះ វត្តចិនដំដែក វត្តពិភទ្ធវង្សី វត្តពាមផ្លុង វត្តឧណ្ណាលោម វត្តខ្ពបតាយ៉ង់ វត្តបទុមវតី ជាដើម។

៨. ហេតុអ្វីបានជាព្រះបាទស្រីរាជា មិនអាចរំដោះទឹកដីពីសៀមបាន?

ចម្លើយ៖ ព្រោះដោយសារមានវិបត្តិរាជវង្ស ហើយឧកញ៉ាចក្រីម៉ែនត្រូវបាត់បង់ជីវិត និងការថមថយកម្លាំងកងទ័ពខ្មែរ។

៩. ចូររៀបរាប់ពីសង្គ្រាមរំដោះទឹកដីប៉ែកខាងលិចពីសៀម។

ចម្លើយ៖ ព្រះបាទស្រីរាជា បានដឹកនាំទ័ពដោយផ្ទាល់ហើយបានចាត់តាំងព្រះបាទស្រីសុរិយោទ័យ ជាក្មួយឱ្យប្រមូលកម្លាំងទ័ពស្បៀងដើម្បីឧបត្ថម្ភសមរភូមិ។ ចំណែកឯព្រះបាទធម្មរាជា បានចាត់តាំងនៅថៃរក្សារាជធានីនៅចតុមុខ។ កងទ័ពជាតិខ្មែរដឹកនាំដោយព្រះរាជាផ្ទាល់បានលើកសំដៅទៅទិសខាងលិច ហើយបានកម្ចាត់ពួកឈ្លានពានចេញផុតពីទឹកដី ខ្មែរយកបានអាណាខេត្តទាំងអស់មកវិញដូចជា៖ ចន្ទបុរី នគរាជសីម៉ា បស្ចឹមបុរី និងរយ៉ង ព្រះរាជាទ្រង់សប្បាយចិត្តណាស់ ដោយឃើញរាស្ត្រខ្មែរដែលរស់នៅទីនោះបានងើបឡើងរួមកម្លាំងគ្នានឹងកងទ័ពជាតិ ក្នុងការកម្ចាត់សត្រូវជាពិសេសព្រះរាជាខ្មែរសម្រេចព្រះទ័យវាយកម្ទេចសត្រូវសៀម

រលាយអស់ក្នុងពេលនោះតែម្តងរហូតដល់ក្រុងអយុធ្យា ប៉ុន្តែពេលនោះឧកញ៉ាចក្រីម៉ែនដែលជាប្រមុខមេទ័ពបានទទួលមរណភាពកងទ័ពខ្មែរចេមចយកម្លាំងម្យ៉ាងទៀតវិបត្តិរាជវង្សបានផ្ទុះឡើង។

១០. តើនៅក្នុងសម័យចតុមុខប្រទេសកម្ពុជាបែងចែកជាប៉ុន្មានអាណាចក្រ? អ្វីខ្លះ? ហើយគ្រប់គ្រងដោយស្តេចអង្គណាខ្លះ?

ចម្លើយ៖ ក្នុងសម័យចតុមុខប្រទេសកម្ពុជាបែងចែកជាបី អាណាចក្រផ្សេងគ្នារួមមាន៖

-អាណាចក្រខាងជើង គឺគ្រប់គ្រងដោយ ព្រះបាទ ស្រីរាជា។

-អាណាចក្រខាងត្បូង គ្រប់គ្រងដោយ ព្រះបាទធម្មរាជា។

-អាណាចក្រខាងកើត គ្រប់គ្រងដោយព្រះបាទស្រីសុរិយោទ័យ។

១១. តើវិបត្តិរាជវង្សានុវង្សខ្មែរបានផ្តល់ផលវិបាកអ្វីខ្លះដល់សង្គមនិងប្រជារាស្ត្រខ្មែរ?

ចម្លើយ៖ វិបត្តិរាជវង្សានុវង្សខ្មែរបានផ្តល់ផលវិបាកដល់សង្គមនិងប្រជារាស្ត្រខ្មែរ រួមមាន៖

-ធ្វើឱ្យមានចោរកម្ម ឆក់ប្លន់ កាប់សម្លាប់ ជំងឺរាតត្បាត គ្រោះទុរ្ភិក្ស ស្លាប់រង្គាល សង្គ្រាមអូសបន្លាយអស់រយៈពេល១០ឆ្នាំ (១៤៧៥ ដល់១៤៨៥)

-ប្រជារាស្ត្រខ្មែរត្រូវស្លាប់ដោយសារសង្គ្រាមស៊ីវិលជាច្រើន

-ធ្វើឱ្យបាក់បែកសាមគ្គីភាព

-មិនអាចរំលាយរាជធានីសៀមបានដូចការប៉ងរបស់ស្រីរាជា

-បាត់បង់ទឹកដីដោយសារបរទេសឈ្លានពាន

-ត្រូវអាប់ឱនកិត្តិយសក្នុងរាជវង្សខ្មែរ ...។

១២. តើព្រះបាទស្រីសុគន្ធបទ ជាបុត្ររបស់ស្តេចអង្គណា?

ចម្លើយ៖ ជាបុត្រច្បងរបស់ ព្រះបាទធម្មរាជា។

១៣. តើព្រះអង្គសោយរាជ្យ ពីឆ្នាំណាដល់ឆ្នាំណា?

ចម្លើយ៖ ព្រះអង្គសោយរាជ្យពីឆ្នាំ១៥០៤ ដល់ឆ្នាំ ១៥១២។

១៤. តើព្រះបាទស្រីសុគន្ធបទបានផ្លាស់រាជធានីតាំងនៅឯណា? ព្រោះអ្វី?

ចម្លើយ៖ ព្រះបាទស្រីសុគន្ធបទបានផ្លាស់រាជធានីតាំងនៅឡូលបាសាន (ស្រីសឈរ) ពីព្រោះព្រះអង្គពេញព្រះទ័យប្រពាតបឹងបង់សំណាញ់កំសាន្ត និងយាងចូលព្រៃបរបាញ់សត្វ ។

១៥. ចូររកមូលហេតុដែលធ្វើឱ្យស្តេចកនយកជ័យជម្នះលើព្រះបាទស្រីសុគន្ធបទ។

ចម្លើយ៖ មូលហេតុដែលធ្វើឱ្យស្តេចកនយកជ័យជម្នះលើព្រះបាទស្រីសុគន្ធបទ គឺបណ្តាលមកពីស្តេចកនបានប្រើឧបាយកលបោកបញ្ឆោតចៅហ្វាយខេត្តនានាថា ខ្លួនទទួលបេសកកម្មពីព្រះបាទស្រីសុគន្ធបទមកកែនទ័ពទៅកម្ចាត់មហាឧបរាជចន្ទរាជា ដែលក្បត់រាជបល្ល័ង្កប្រាថ្នាសោយរាជ្យនៅចតុមុខ។ ដំណឹងនេះបានឮទៅដល់ព្រះអង្គចន្ទធ្វើឱ្យព្រះអង្គនឹកស្មានថា ព្រះបាទស្រីសុគន្ធបទជាព្រះរាមចោទព្រះអង្គដូចការយោសនារបស់ឃុនលួងព្រះស្តេចកនមែន ក៏នាំ

ញាតិវង្សទៅសុំសិទ្ធិជ្រកកោននៅក្នុងប្រទេសសៀម។ បន្ទាប់ពីអង្គ
ចន្ទយាងចេញផុត នាយកនផ្តើមវាយយកខេត្តនានាដែលនៅជិត
រាជធានីទួលបាសាន។ នៅឆ្នាំ ១៥១២ ព្រះបាទស្រីសុគន្ធបទត្រូវ
កងទ័ពនាយកនធ្វើគត់នៅក្នុងបន្ទាយស្នឹងសែន។

១៦. តើព្រះបាទស្រីជេដ្ឋា (ស្តេចកន)ឡើងសោយរាជ្យពីឆ្នាំណា ដល់ឆ្នាំណា? ហើយបានតាំងរាជធានីនៅឯណា?

ចម្លើយ៖ ព្រះបាទស្រីជេដ្ឋា (ស្តេចកន)ឡើងសោយរាជ្យពីឆ្នាំ
១៥១២ ដល់ឆ្នាំ ១៥១៦។ ហើយព្រះអង្គបានតាំងរាជធានីនៅទួល
បាសាន។

១៧. នៅក្នុងឆ្នាំ ១៥១៤ ស្តេចកនបានកសាងរាជធានីថ្មីមួយទៀត ដែលមានឈ្មោះដូចម្តេច?

ចម្លើយ៖ ឈ្មោះថា « **ក្រុងស្រឡប់ពិជ័យព្រៃនគរ** »។

១៨. ក្នុងរជ្ជកាលព្រះបាទស្រីជេដ្ឋា (ស្តេចកន) តើប្រទេសជាតិមានស្ថានភាពដូចម្តេច?

ចម្លើយ៖ ក្នុងរជ្ជកាលព្រះបាទស្រីជេដ្ឋា (ស្តេចកន)ប្រទេសជាតិ
មានស្ថានភាពដូចជា ៖
-ប្រទេសជាតិទទួលបានសន្តិភាព។
-ធ្វើការទំនាក់ទំនងពាណិជ្ជកម្ម ជាមួយបរទេសបានល្អប្រសើរ។
-ប្រាក់ស្លឹងសញ្ញារូបនាគត្រូវបានបោះពុម្ពដើម្បីសម្រួលវិស័យ
ពាណិជ្ជកម្មក្នុង និង ក្រៅប្រទេស។

-ប្រជារាស្ត្រមានជីវភាពធូរធា តាមរយៈការបន្ធូរបន្ថយពន្ធដារ បន្ថយពិន័យ។

-កែប្រែច្បាប់ព្រហ្មទណ្ឌឱ្យមានលក្ខណៈធូរស្រាលជាងមុន។

១៩. តើសង្គ្រាមរវាងស្តេចកន និងព្រះបាទចន្ទរាជាបានចាប់ផ្តើមពីឆ្នាំណាដល់ ឆ្នាំណា?

ចម្លើយ៖ សង្គ្រាមរវាងស្តេចកន និងព្រះបាទចន្ទរាជាបានចាប់ផ្តើមពីឆ្នាំ១៥១៦ដល់ ឆ្នាំ១៥២៥។

២០. តើសង្គ្រាមរវាងព្រះបាទចន្ទរាជា និង ស្តេចកន ខាងណាជាអ្នកទទួលជ័យជំនះ?

ចម្លើយ៖ ព្រះបាទចន្ទរាជា។

២១. តើសង្គ្រាមរវាងស្តេចកន និង ព្រះបាទចន្ទរាជាផ្តល់ផលវិបាកអ្វីខ្លះដល់សង្គមខ្មែរនាពេលនោះ?

ចម្លើយ៖ សង្គ្រាមរវាងស្តេចកន និង ព្រះបាទចន្ទរាជាផ្តល់ផលវិបាកដល់សង្គមខ្មែរនាពេលនោះដូចជា ៖

-បែកបាក់សាមគ្គី។

-ប្រជាពលរដ្ឋមិនបានធ្វើស្រែចម្ការ។

-ទាហាន និងប្រជារាស្ត្រស្លាប់ជាច្រើននាក់។

-បន្សល់ទុកស្ត្រីមេម៉ាយ និង ក្មេងកំព្រា។

-ខូចហេដ្ឋារចនាសម្ព័ន្ធ។

-ធ្វើឱ្យប្រទេសដទៃគេមាក់ងាយ។

-ខាតបង់ប្រយោជន៍ជាតិ។

២២. តើស្រីជេដ្ឋា ឬស្តេចកន មានចំណង់ចំណូលចិត្តទៅលើអ្វី?

ចម្លើយ៖ ស្តេចកន មានចំណង់ចំណូលចិត្តលើ ការបាញ់សត្វ ចាប់ត្រី ល្បែងស្រី របាំ តន្ត្រីជាដើម។

២៣. តើក្នុងពេលធ្វើសង្គ្រាមជាមួយស្តេចកន ព្រះបាទចន្ទរាជាបានដណ្តើមបានខេត្តណាខ្លះ?

ចម្លើយ៖ក្នុងពេលធ្វើសង្គ្រាមជាមួយស្តេចកន ព្រះបាទចន្ទរាជាបានដណ្តើមបានខេត្តដូចជា ខេត្តក្រគរ ខ្លុងក្រង បរិបូរណ៌ កំពង់សៀម ជើងព្រៃ និងស្ទឹងត្រង់។

២៤. តើព្រះបាទចន្ទរាជា បានប្រើល្បិចដូចម្តេចដើម្បីចេញពីសៀមមកប្រទេសខ្មែរវិញ?

ចម្លើយ៖ ក្រោយពីដឹងថា ស្តេចកន បានសម្លាប់ព្រះបាទស្រីសុគន្ធបទរួចមក ចន្ទរាជាក៏បានប្រើល្បិចកុហកស្តេចសៀមថាព្រះអង្គនឹងទៅទាក់ដំរីថ្វាយស្តេចសៀមដោយយករោមជ្រូកទៅប្រឡាក់ដើមឈើ ពេលនោះស្តេចសៀមក៏បានយល់ព្រម ហើយបានប្រទានទ័ពចំនួន ៥០០០នាក់ ដំរីធ្នាក់១០០ អាវុធ ស្បៀងអាហារ និងជាវអាជ្ញាសឹកទៀតផង។ នៅឆ្នាំ១៥១៦ ចន្ទរាជាបានធ្វើដំណើរដល់ព្រំដែនខ្មែរក៏សុំទ័ពបន្ថែម ពញាអុងទៅគាល់ស្តេចសៀមប្រាប់ពីការពិត ស្តេចសៀមខឹងយ៉ាងខ្លាំងក៏បញ្ជាឱ្យគេចាប់ចន្ទរាជាទៅវិញ តែចន្ទរាជាបានបង្ហាញជាវអាជ្ញាសឹក ពួកគេក៏ត្រឡប់ទៅវិញ។

២៥. តើចេតិយវត្តភ្នំកសាងដោយព្រះរាជាខ្មែរអង្គណាខ្លះ?

ចម្លើយ៖ ចេតិយវត្តក្នុកសាងដោយ ព្រះបាទនរាយណ៍រាជា (១៤៦៦) និងព្រះបាទស៊ីសុវត្ថិ (១៩១៧)។

២៦. តើព្រះបាទនរាយណ៍រាជា សោយរាជ្យបានប៉ុន្មានឆ្នាំ? ពីឆ្នាំណាដល់ឆ្នាំណា?មានបុត្រឈ្មោះអ្វី?

ចម្លើយ៖ ព្រះអង្គសោយរាជ្យបាន៣ឆ្នាំគឺពីឆ្នាំ១៤៦៣-១៤៦៩) មានបុត្រឈ្មោះស្រីសុរិយោទ័យ។

២៧. តើព្រះរាជាអង្គណាបានពឹងសៀមឱ្យមកធ្វើជាចៅក្រមផ្សះផ្សាទំនាស់ក្នុងរាជវង្ស? ហើយខ្មែរទទួលបានលទ្ធផលដូចម្តេច?

ចម្លើយ៖ គឺព្រះបាទធម្មរាជាបានពឹងសៀមឱ្យមកធ្វើជាចៅក្រមផ្សះផ្សាទំនាស់ក្នុងរាជវង្សខ្មែរ។

+ក្រោយពីផ្សះផ្សាហើយស្តេចសៀមបានរៀបចំអភិសេកព្រះបាទធម្មរាជា ជាព្រះមហាក្សត្រក្រុងកម្ពុជាក្នុងឆ្នាំ១៤៨៦ នៅរាជធានីចតុមុខ ក្រោយពីអន្តរាគមន៍ ស្តេចសៀមបានទាមទារយកខេត្តដែលស្រីរាជាទើបរំដោះបានទៅវិញអស់។

សំណួរ-ចម្លើយ ស្តីពីសម័យលង្វែក

ប្រធាន

១. តើសម័យលង្វែក ពីឆ្នាំណាដល់ឆ្នាំណា?

ចម្លើយ៖ សម័យលង្វែក ពីឆ្នាំ១៥១៦ដល់១៦២០ នៃគ្រិស្តសករាជ ឬក្នុងសតវត្សទី១៦។

២. តើសម័យលង្វែក គេបែងចែកភូមិសាស្ត្រជាប៉ុន្មានតំបន់ធំៗ?

ចម្លើយ៖ គេបែងចែកភូមិសាស្ត្រជា៥តំបន់ធំៗគឺ៖ តំបន់ខាងជើង តំបន់ខាងលិច តំបន់កណ្តាល តំបន់ខាងកើត និង តំបន់ខាងត្បូង តំបន់ទាំង៥ មានខេត្តសរុបចំនួន៧០ ។

៣. ចូររៀបរាប់ខេត្តទាំង៧០នោះ។

ចម្លើយ៖ ខេត្តទាំង៧០នោះគឺ៖

១. កំពង់ធំ	២.សៀមរាប	៣.ឈ្លូង ឬក្រចេះ
៤. ស្ទឹងត្រែង	៥.អាចម៍ក្រពើ	៦.ចម្ប៉ាសាក់
៧.ប៉ាក់សេ	៨.ម្លូរព្រៃ	៩.ទន្លេរពៅ
១០.សៀមប៉ោយ	១១.ព្រះវិហារ	១២.អូរបុណ្យរាជធានី
១៣.ចន្ទបុរី	១៤.ព្រះប្រជែង	១៥.ធន់បុរី
១៦.បស្ចឹមបុរី	១៧.នាងរង	១៨.ត្រាច
១៩.រយ៉ង	២០.ស្ទឹងជ្រៅ	២១.ជល់បុរី

២២.បុរីរម្យ	២៣.នគរាជសីម៉ា	២៤.ស្រីស្លាកែត
២៥.គោកខ័ណ្ឌ	២៦.សុរិន្ទ	២៧.សិង្គារ
២៨.មង្គលបុរី	២៩.សិរីសោភ័ណ្ឌ	៣០.បាត់ដំបង
៣១.ពោធិ៍សាត់	៣២.កំពង់ប្រាក់	៣៣.ឫស្សីសាញ់
៣៤.ជីក្រែង	៣៥.ទទឹងថ្ងៃ	៣៦.គោកសេះ
៣៧.អន្លង់រាជ	៣៨.សំរោងទង	៣៩.អមរិន្ទគិរីបូរណ៌
៤០.រលាប្អៀរ	៤១.ស្រីសន្ធរ	៤២.កំពង់សៀម
៤៣.ចតុមុខ	៤៤.កំពង់ស្វាយ	៤៥.បាទី
៤៦.អង្គរបុរី	៤៧.បាភ្នំ	៤៨.កំពត
៤៩.កំពង់សោម	៥០.ពាម	៥១.មាត់ជ្រូក
៥២.ផ្សារដែក	៥៣.កំពង់ក្របី	៥៤.ព្រៃនគរ
៥៥.រោងជំរី	៥៦.ទួលតាមោក	៥៧.កំពង់ស្រែការត្រី
៥៨.ត្រពាំងចង្វារ	៥៩.អូរកាប់	៦០.កោះគង
៦១.មេសរ	៦២.កំពង់ឫស្សី	៦៣.លង់ហោរ
៦៤.ព្រះត្រពាំង	៦៥.ឃ្លាំង	៦៦.ព្រៃកឫស្សី
៦៧.បារាជ	៦៨.ក្រមួនស	៦៩.ពលលាវ
៧០.ទឹកខ្មៅញ៉ែ។		

៤. តើព្រះមហាក្សត្រខ្មែរអង្គណា ដែលបានកសាងបន្ទាយលង្វែក?

ចម្លើយ៖ ព្រះបាទ ចន្ទរាជា។

៥. ហេតុអ្វីបានជាព្រះបាទចន្ទរាជា កសាងបន្ទាយលង្វែក?

ចម្លើយ៖ បានជាព្រះបាទចន្ទរាជា កសាងបន្ទាយលង្វែក ព្រោះ៖

-កសាងបន្ទាយលង្វែកឱ្យរឹងមាំដើម្បីការពារសត្រូវ(សៀម)
-ចង់បង្កើតជាស្នាដៃរបស់ព្រះអង្គផ្ទាល់
-ចង់ប្រមូលអ្នកប្រាជ្ញ បណ្ឌិត កវី ដើម្បីចងក្រងឯកសារទុកបង្រៀនកូនខ្មែរជំនាន់ក្រោយ
-ចង់បង្កើតវប្បធម៌ថ្មីនៅសម័យក្រោយអង្គរ។

៦. តើមូលហេតុអ្វីបានជាមានឈ្មោះថា ខេត្តសៀមរាប?

ចម្លើយ៖មូលហេតុដែលនាំឱ្យមានឈ្មោះថា ខេត្តសៀមរាប ព្រោះពេលនោះស្តេចសៀមបានចាត់បញ្ជូនទូតមកបង្ខំឱ្យព្រះបាទចន្ទរាជាយកសួយសារអាករតាមទម្លាប់ពីមុនតែព្រះបាទចន្ទរាជាប្រកែកមិនព្រមនៅក្រោមអំណាចសៀម។ សៀមខឹងក៏លើកទ័ពមកវាយខ្មែរនៅក្បែរក្រុងអង្គរ ព្រះបាទចន្ទរាជាបានកេណ្ឌទ័ពទៅទប់ទល់នឹងទ័ពសៀមនៅស្ទឹងអង្គរ និងវាយបកសៀមឱ្យបាក់ទ័ពចាប់ជាឈ្លើយសឹកបានរាប់ពាន់នាក់។ នៅត្រង់កន្លែងនោះហៅភូមិសៀមរាប ឃុំសៀមរាប និងស្រុកសៀមរាប(សៀមចាញ់ខ្មែររាប) រហូតដល់សព្វថ្ងៃនេះ។

៧. តើព្រះបាទចន្ទរាជា បានលើកទ័ពចូលវាយសៀមប៉ុន្មានលើក? ឆ្នាំណាខ្លះ? រំដោះបានខេត្តណាខ្លះ?

ចម្លើយ៖ ព្រះបាទចន្ទរាជា បានលើកទ័ពចូលវាយសៀមចំនួន៤លើកគឺ៖
-លើកទី១ ឆ្នាំ១៥៣១ រំដោះបានខេត្តបស្ចិមបុរី
-លើកទី២ ឆ្នាំ១៥៥៧ រំដោះបានខេត្តចន្ទបុរីនិងខេត្តផ្សេងៗទៀត

-លើកទី៣ និងទី៤ គឺឆ្នាំ១៥៥៩និង១៥៦២ ដោយចាប់បានឈ្លើយសឹកសៀមជាច្រើននាក់មកស្រុកខ្មែរ។

៨. តើព្រះបាទចន្ទរាជា មានស្នាព្រះហស្តអ្វីខ្លះ?

ចម្លើយ៖ ស្នាព្រះហត្តព្រះបាទចន្ទរាជាមានដូចជា៖

-ព្រះអង្គពូកែខាងចម្បាំងរំដោះទឹកដីភាគខាងលិច ការពារជាតិមាតុភូមិ។

-ជួយទំនុកបម្រុងព្រះពុទ្ធសាសនា។

-ព្រះអង្គយកព្រះទ័យទុកដាក់លើគ្រប់វិស័យមានអក្សរសាស្ត្រ និងសេដ្ឋកិច្ចជាដើម។

-ប្រមូលអ្នកប្រាជ្ញ បណ្ឌិត បញ្ញវន្ត អ្នកខ្លាំងពូកែខាងសិល្បៈសាស្ត្រ ដើម្បីបណ្តុះបណ្តាលកូនខ្មែរជំនាន់ក្រោយ។

-ចំពោះសេដ្ឋកិច្ចព្រះអង្គបានបញ្ជាឱ្យគេកាប់ឆ្ការព្រៃ ពង្រីកផ្ទៃដីធ្វើស្រែចម្ការនិងសិប្បកម្មស្លដៃក ផលិតសម្ភារៈប្រើប្រាស់ផ្សេងៗ។

៩. តើវណ្ណៈសង្គមនាសម័យលង្វែក គេចែកជាប៉ុន្មានវណ្ណៈ?

ចម្លើយ៖ សង្គមវណ្ណៈសម័យលង្វែកបែងចែកជា ៧វណ្ណៈមានដូចជា

-វណ្ណៈរាជវង្ស (ក្រុមសាច់ញាតិស្តេច) មាននាម ជាអ្នកអង្គម្ចាស់ ព្រះរាជបុត្រ ព្រះមហេសី ព្រះស្នំឯក អ្នកម្នាង ។

-វណ្ណៈនាហ្មឺន (ក្រុមមន្ត្រី) មាននាម ចៅពញា ចៅហ្វ៊ា ចៅចម។

-វណ្ណៈគហបតី (ក្រុមអ្នកមាន) អ្នកឧកញ៉ា លោកដង្ហៅ សេដ្ឋី។

-វណ្ណៈរាស្ត្រ (ក្រុមមនុស្សទូទៅ) អ្នកដែលមិនមានឋានៈក្នុងសង្គមរដ្ឋបាល។

-វណ្ណៈអ្នកងារ (ក្រុមអ្នកធ្វើការឱ្យគេ) អ្នកមានទោសជាប់ខ្លួន អ្នកមានរឿងក្តីជាប់ខ្លួន។

-វណ្ណៈបាវព្រាវ (អ្នកគ្មានទីពឹង) សុំគេដើម្បីបានស្នាក់អាស្រ័យ និងធ្វើជាអ្នកបម្រើគេ។

-វណ្ណៈទាសករ (ក្រុមអ្នកលក់ខ្លួនបម្រើគេ) ក្លាយជាកញ្ជះគេអស់មួយជីវិត។

១០. តើបន្ទាយលង្វែក សាងសង់អស់រយៈពេលប៉ុន្មានឆ្នាំ?

ចម្លើយ៖ ៣ឆ្នាំ គឺពីឆ្នាំ១៥២៧ ដល់ ១៥២៩។

១១. តើគ្រឿងបញ្ចកកុធភ័ណ្ឌ សម្រាប់ក្សត្រឡើងសោយរាជ្យមានអ្វីខ្លះ?

ចម្លើយ៖ គ្រឿងបញ្ចកកុធភ័ណ្ឌ មាន៥គឺ៖

-ព្រះមកុដរាជ

-ព្រះវាលវីជនី ឬ ផ្លិតធ្វើពីរោមសត្វពណ៌ស

-ព្រះខ័នរាជ

-ព្រះមហាស្វេតច្ឆត្រ (ព្រះរាជបល្ល័ង្កនិងស្វេតច្ឆត្រ៩ជាន់)

-ព្រះសុវណ្ណបាទុកា ឬ ស្បែកជើងមាស

១២. តើនៅឆ្នាំ១៥៨៨ សៀមបានវាយយកខេត្តណាខ្លះ?

ចម្លើយ៖ សៀមបានវាយយកបានខេត្តដូចជា៖

-បន្ទាយមានជ័យ

-បាត់ដំបង

-ពោធិ៍សាត់

-បរិបូរណ៍

១៣. ចូររកមូលហេតុនៃការបែកបាក់បន្ទាយលង្វែក។

ចម្លើយ៖ មូលហេតុបានជាបែកបាក់បន្ទាយលង្វែក គឺ

-ព្រះរាជា ៖ សន្តិទី១ ឆោតល្ងង់ទៅជួយរំដោះក្រុងអយុធ្យារបស់សៀមពីការត្រួតត្រារបស់កូមា។

-សៀម ៖ សៀមរមិលគុល ប្រើល្បិចបញ្ជូនសង្ឃមកយកការណ៍ក្នុងបន្ទាយ និងប្រើល្បិចបាចប្រាក់ដួងចូលគុម្ពឫស្សី។

-វិបត្តិផ្ទៃក្នុង ៖ រាជវង្សានុវង្ស នាម៉ឺនមន្ត្រី ប្រជារាស្ត្រមិនពេញចិត្តនឹងព្រះសន្តិទី១ តែងតាំងកូនអាយុ ១១ឆ្នាំឱ្យគ្រងរាជ្យនឹង៦ឆ្នាំជាមហាឧបរាជ ដូចនេះហើយទើបពួកគេបាត់បង់ស្មារតីប្រយុទ្ធ។

-ប្រជារាស្ត្រខ្មែរ ៖ ក្រីក្រ ឆោតល្ងង់ ចង់បានប្រាក់ដួងក៏នាំគ្នាកាប់ឆ្ការគុម្ពឫស្សីដែលជារបស់ការពារបន្ទាយដ៏រឹងមាំ។

-សាមគ្គី៖ ប្រទេសខ្មែរហាក់ដូចជាបាត់បង់សាមគ្គីភាពដូចជាសន្តិទី១នាំកូនទាំងពីររត់ភៀសខ្លួនទៅប្រទេសឡាវ ប្រជារាស្ត្រអស់ជំនឿ។

១៤. ចូររៀបរាប់ពីស្នាព្រះហស្តរបស់ព្រះបាទចន្ទរាជា។

ចម្លើយ៖ ស្នាព្រះហស្តរបស់ព្រះបាទចន្ទរាជាគឺ

-រាជធានីក្រុងលង្វែក

-វត្តត្រឡែងកែង

-រូបព្រះគោ ព្រះកែវ និងបដិមាខាងព្រាហ្មណ៍សាសនា វត្តបឋមកេរ្តិ៍ (នៅឧដុង្គ)

-ការជីកស្រះទឹក

-ការរៀបចំប្រព័ន្ធប្រឡាយទឹក និងពង្រីកការជីកយកវ៉ែដែក
-ការកាប់ឆ្ការព្រៃឈើដើម្បីវាតទីដីថ្មីសម្រាប់ធ្វើស្រែ
-រំដោះខេត្តខ្មែរភាគខាងលិចពីសៀមដូចជា បស្ចិមបុរី ចន្ទបុរី នគរ រាជសីមា
-ការធ្វើឱ្យប្រទេសជាតិរុងរឿង សម្បូរសប្បាយ ក្នុងប្រវត្តិសាស្ត្រនា សម័យលង្វែក។

១៥. តើក្នុងរជ្ជកាលព្រះបាទចន្ទរាជា ប្រទេសខ្មែរមានទំនាក់ ទំនងជាមួយប្រទេសអឺរ៉ុបណាខ្លះ?

ចម្លើយ៖ ព័រទុយហ្គាល់ និង អេស្បាញ។

១៦. ចូររៀបរាប់ពីផលវិបាកក្រោយបែកបន្ទាយលង្វែក។

ចម្លើយ៖ ផលវិបាកក្រោយការបែកបាក់បន្ទាយលង្វែកគឺ៖
-ប្រទេសជាតិអស់ឫទ្ធានុភាព ធ្លាក់ជារដ្ឋទន់ខ្សោយនៅតំបន់អាស៊ីអាគ្នេយ៍
-ខ្មែរបាត់បង់កេតនកណ្ដាជាតិ ក្បួន ច្បាប់ អ្នកប្រាជ្ញ បណ្ឌិត និងវប្ប ធម៌ ត្រូវសៀមឆក់ប្លន់អស់
-ប្រទេសធ្លាក់ក្នុងភាពអនាធិបតេយ្យ គ្រោះទុរ្ភិក្សពេញប្រទេស
-ប្រជានុរាស្ត្រអស់ជំនឿលើព្រះរាជា ប្រទេសជាតិបាត់បង់ខេត្តចន្ទបុរី នគររាជសីមា បាត់ដំបង សៀមរាម ពោធិ៍សាត់។

១៧. ចូររៀបរាប់ពីការកសាងបន្ទាយលង្វែក។

ចម្លើយ៖ ក្រោយពីព្រះបាទចន្ទរាជា វាយយកដំយជម្នះលើស្តេចកន នៅឆ្នាំ១៥២៥ ព្រះអង្គក៏បានបញ្ជាឱ្យគេសាងសង់បន្ទាយលង្វែកនៅ

ឆ្នាំ១៥២៧ ដល់១៥២៩ ដោយប្រើរយៈពេល៣ឆ្នាំ។ បន្ទាយលង្វែក មានចំណុចយុទ្ធសាស្ត្រដូចជា ទន្លេ បឹង និងព្រៃឈើជារបាំងបន្ទាយ នេះមានរាងបួនជ្រុង បណ្តោយប្រវែង៣គីឡូម៉ែត្រ ទទឹង២គីឡូម៉ែត្រ កំពែងដីកម្ពស់១៥ហត្ថ ឬ៧ម៉ែត្រ ហ៊ុមព័ទ្ធដោយគូទឹក និងដាំដើមឫស្សីកម្រាស់៨ម៉ែត្រព័ទ្ធជុំវិញ។ ក្នុងបន្ទាយ លង្វែកមានវាំងស្តេច បន្ទាយទាហាន ផ្ទះស្រីស្នំ២២ រោងដំរី រោងសេះ ប្រាសាទពីរ ជីកស្រះធំ៤ គ្រប់ទិស ហើយចិញ្ចឹមត្រីព្រួល រ៉ស់ ឆ្តោ ព្រោះនៅជាប់មាត់ទន្លេសាប។ បន្ទាយលង្វែកមានទ្វារធំ៤នៅទិសទាំង៤ និងទ្វារតូច៤ នៅចំជ្រុងនៃទិសតូចទាំង៤។ មានសួនច្បារធំ២ មានភូមិអ្នកស្រុក៤ មានវត្ត៥ ជាដើម។ ដូច្នេះបន្ទាយលង្វែក គឺជាស្ថាបត្យកម្មដ៏ធំនិងល្បីល្បាញ នាសម័យនោះ។

១៨. ចូររៀបរាប់ពីព្រះមហាក្សត្រដែលបានសោយរាជ្យនៅសម័យលង្វែក។

ចម្លើយ៖ ព្រះរាជាខ្មែរនាសម័យលង្វែកគឺ៖

-ព្រះបាទចន្ទរាជា

-ព្រះបាទបរមរាជាទី៤

-ព្រះបាទបរមរាជាទី៥ ឬសត្ថាទី១

-ព្រះបាទជ័យជេដ្ឋាទី១

-ព្រះបាទរាមាជើងព្រៃ

-ព្រះបាទបរមរាជាទី៦ ឬ ពញាតន់

-ព្រះបាទបរមរាជាទី៧ ឬ ចៅពញាអន

-ចៅពញាញោម

១៩. តើព្រះបាទបរមរាជាទី៤ ជាបុត្ររបស់ព្រះរាជាអង្គណា? មានបុត្រប៉ុន្មានអង្គ? ព្រះនាមអ្វី?

ចម្លើយ៖ ព្រះមរមរាជាទី៤ ជាបុត្ររបស់ព្រះបាទចន្ទរាជា មានបុត្រ៣អង្គគឺ ព្រះបាទសត្តាទី១ ព្រះបាទស្រីសុរិយោពណ៌ និងពញាអន។

២០. ព្រះបាទបរមរាជាទី៤ មានស្នាព្រះហស្តអ្វីខ្លះ?

ចម្លើយ៖ ព្រះបាទបរមរាជាទី៤ មានស្នាព្រះហស្តដូចជា៖

-ឆ្នាំ១៥៦៨ ព្រះអង្គបានលើកទ័ពទៅវាយសៀមរំដោះខេត្តខាងលិច និងចាប់បានឈ្លើយសឹកសៀមជាច្រើន

-ឆ្នាំ១៥៧០ ព្រះអង្គបានរំដោះខេត្តនគរាជសីមា និងដាក់មន្ត្រីខ្មែរឱ្យត្រួតត្រា។

២១. តើព្រះបាទសត្តាទី១ ឬ បរមរាជាទី៥ មានបុត្រប៉ុន្មានអង្គ? ព្រះនាមអ្វីខ្លះ?

ចម្លើយ៖ ព្រះបាទសត្តាទី១ មានបុត្រ៣អង្គគឺ ព្រះបាទជ័យជេដ្ឋាទី១ ព្រះបាទពញាតន់ ព្រះបាទពញាញោម។

២២. តើព្រះបាទស្រីសុរិយោពណ៌មានបុត្រប៉ុន្មានអង្គ? ព្រះនាមអ្វីខ្លះ?

ចម្លើយ៖ ព្រះបាទស្រីសុរិយោពណ៌មានបុត្រចំនួន២អង្គ គឺ ព្រះបាទជ័យចេស្តា ឬជ័យជេដ្ឋាទី២។

២៣. ហេតុអ្វីបានជាព្រះបាទស្រីសុរិយោពណ៌ថាសៀមរមិលគុណ?

ចម្លើយ៖ ព្រោះមិនត្រឹមតែមិនអរគុណព្រះអង្គលើកទ័ពទៅរំដោះប្រទេសខ្លួនពីភូមាទេ បែរជាស្តេចសៀមនរេសូខឹងនឹងព្រះបាទស្រីសុរិយោពណ៌ដែលមិនលុតជង្គង់ថ្វាយលាខ្លួនទៅស្រុកវិញ។

២៤. តើព្រះបាទរាមាជើងព្រៃសោយរាជ្យពីឆ្នាំណាដល់ឆ្នាំណា?

ចម្លើយ៖ ពីឆ្នាំ១៥៩៤ដល់១៥៩៦។

២៥. ហេតុអ្វីបានជាព្រះបាទរាមាជើងព្រៃសុគត?

ចម្លើយ៖ ព្រោះពួកអេស្បាញឈ្មោះវេឡូសូ និងរីស ព្រមទាំងបក្សពួកបាននាំគ្នាលួចធ្វើគត់ព្រះអង្គដោយខឹងនឹងទ្រង់កាន់ដើងតែពួកជនជាតិចិន។

២៦. តើចៅពញាក្រោម ឬ សម្តេចកែវហ៊ា ជាបុត្ររបស់ព្រះរាជាអង្គណា? សោយរាជ្យពីឆ្នាំណាដល់ឆ្នាំណា?

ចម្លើយ៖ ចៅពញាក្រោម ជាបុត្រពៅរបស់ព្រះសត្ថាទី១។ សោយរាជ្យពីឆ្នាំ១៦០០ដល់១៦០៣។

សំណួរ-ចម្លើយ ស្តីពីសម័យឱដុង្គ

ប្រធាន

១. តើសម័យឧដុង្គ ពីឆ្នាំណាដល់ឆ្នាំណា?

ចម្លើយ៖ ១៦២០ ដល់ ១៨៦៣។

២. តើនៅសម័យឧដុង្គកំណត់ដោយព្រឹត្តិការណ៍ធំៗប៉ុន្មាន?អ្វីខ្លះ?

ចម្លើយ៖ កំណត់ដោយព្រឹត្តិការណ៍ធំៗចំនួន២គឺ

-ការជ្រៀតជ្រែករបស់យួនមកលើទឹកដីខ្មែរ

-តំណាងអំណាចសៀមនិងយួនមកលើប្រទេសខ្មែរ។

៣. តើការជ្រៀតជ្រែករបស់យួនមកលើខ្មែរ បានចាប់ផ្តើមឡើងនៅពេលណា? ក្នុងសតវត្សណា?

ចម្លើយ៖ ការជ្រៀតជ្រែករបស់យួនមកលើប្រទេសខ្មែរ បានចាប់ផ្តើមឡើងនៅសម័យឧដុង្គពីឆ្នាំ១៦២០ក្នុងសតវត្សទី១៧រហូតដល់ឆ្នាំ១៨៤៦ក្នុងសតវត្សទី១៩។

៤. តើយួនបានទន្ទ្រានទឹកដីខ្មែរ មានប៉ុន្មានសណ្ឋាន? អ្វីខ្លះ?

ចម្លើយ៖ យួនបានទន្ទ្រានទឹកដីខ្មែរ មាន២សណ្ឋានគឺ

-ចងមេត្រីភាពដោយប្រើល្បិចស្ងប់ស្ងៀម ដើម្បីកេងបន្លំ(ដោយល្បិចបោកបញ្ឆោត)

-នៅពេលមានវិបត្តិរាជសម្បត្តិ យួនប្រើល្បិចក្តៅដើម្បីទន្ទ្រានយកដីខ្មែរ(ដោយសង្គ្រាម)។

៥. តើព្រះបាទ ជ័យជេដ្ឋាទី២ ឡើងសោយរាជ្យនៅឆ្នាំណា?

ចម្លើយ៖ ១៦១៨។

៦. តើអគ្គមហេសីរបស់ព្រះបាទជ័យជេដ្ឋាទី២ មានឈ្មោះអ្វី?

ចម្លើយ៖ ព្រះនាមអង្គចូវ ឬ ង៉ុក វ៉ាន ជាបុត្រីរបស់ស្តេចយួន។

៧. ហេតុអ្វីបានជាប្រទេសកម្ពុជាធ្លាក់ចុះនៅសម័យឧជុង្គ?

ចម្លើយ៖ បណ្តាលមកពី៖

-វិបត្តិផ្ទៃក្នុង

-ជម្លោះដណ្តើមរាជសម្បត្តិក្នុងរាជវង្ស

-ការអន្តរាគមន៍ពីសំណាក់ប្រទេសជិតខាង

-ការឈ្លានពានពីប្រទេសជិតខាង ជាដើម។

៨.ហេតុអ្វីបានជាព្រះបាទស្រីសុរិយោពណ៌ប្តូរទំនាក់ទំនងពីការចងសម្ព័ន្ធភាពជាមួយសៀមមកចងសម្ព័ន្ធភាពជាមួយយួនវិញ?

ចម្លើយ៖ ព្រោះព្រះអង្គគិតថា៖

-លែងចង់ឈប់យកសួយសារអាករទៅថ្វាយស្តេចសៀមទៀត

-ធ្វើឱ្យប្រទេសខ្មែរលែងបាត់បង់ទឹកដីតទៅទៀត

-ខ្មែរលែងជាចំណុះរបស់សៀមតទៅទៀត

-យកយួនជាខ្នងបង្អែកដើម្បីការពារទឹកដីខ្មែរ។

៩. តើកត្តាអ្វីដែលនាំឱ្យមានសម្ព័ន្ធមេត្រីខ្មែរ-យួននៅដើមសតវត្សទី ១៧?

ចម្លើយ៖ កត្តាដែលនាំឱ្យមានសម្ព័ន្ធមេត្រីខ្មែរ-យួននៅដើមសតវត្សទី ១៧ គឺ

-តាំងពីចុងសតវត្សទី១៤ មកសៀមវាយខ្មែរជាបន្តបន្ទាប់ហើយយកបានរាជធានីខ្មែរ

-នៅពាក់កណ្តាលទី១៤ និងដើមសតវត្សទី១៥ សៀមវាយយកក្រុងអង្គរ១៤៣១

-នៅខែមេសា ឆ្នាំ១៥៩៤ សៀមវាយយកបានក្រុងលង្វែកទៀត

-ក្រោយមកព្រះបាទស្រីសុរិយោពណ៌បានធ្វើជន្លងជាមួយយួនទៀត

-ការចងសម្ព័ន្ធមេត្រីជាមួយយួននេះ គឺដើម្បីយកកម្លាំងយួន ជាដៃគូក្នុងការវាយទប់ទល់នឹងការវាយលុករបស់សៀម។

១០. តើស្តេចយួនបានខ្ចីដីខ្មែរដើម្បីអ្វី? នៅក្នុងឆ្នាំណា? ក្នុងរាជ្យស្តេចអង្គណា?

ចម្លើយ៖ ស្តេចយួនបានខ្ចីដីខ្មែរ ដើម្បីដាក់ទ័ពយួនត្រៀមវាយចិន គឺខេត្តកំពង់ក្របី និងព្រៃនគរ ហើយសុំកាន់កាប់រយៈពេល៥ឆ្នាំ។ ក្នុងរាជ្យព្រះបាទជ័យជេដ្ឋាទី២ និងនៅក្នុងឆ្នាំ១៦២៣។

១១. តើព្រះបាទជ័យជេដ្ឋាទី២មានស្នាព្រះហស្តអ្វីខ្លះ?

ចម្លើយ៖ ស្នាព្រះហស្តរបស់ព្រះបាទជ័យជេដ្ឋាទី២មាន៖

-ការពារពីការឈ្លានពានរបស់សៀម

-រៀបចំប្រទេសឱ្យមានការអភិវឌ្ឍ

-បានកែប្រែច្បាប់សង្គមដោយរៀបចំច្បាប់ឡើងវិញបាន២៤ក្រម

-ព្រះអង្គចូលទិវង្គតក្នុងឆ្នាំ១៦២៨ក្នុងព្រះជន្ម៥២ព្រះវស្សា។

១២. ហេតុអ្វីបានជាព្រះបាទពញ្ញាចន្ទធ្វើគត់ព្រះឧទ័យ?

ចម្លើយ៖ ព្រោះព្រះអង្គខឹងមិនបានសោយរាជ្យ។

១៣. តើព្រះបាទរាមាធិបតីឬពញ្ញាចន្ទជាបុត្ររបស់ព្រះរាជាអង្គណា? ឡើងសោយរាជ្យដូចម្តេច? ក្នុងព្រះជន្មប៉ុន្មាន?

ចម្លើយ៖ ព្រះបាទរាមាធិបតីឬពញ្ញាចន្ទជាបុត្ររបស់ព្រះបាទជ័យជេដ្ឋាទី២ហើយឡើងសោយរាជ្យដោយធ្វើគត់ព្រះឧទ័យជាព្រះបិតុលា។ សោយរាជ្យក្នុងព្រះជន្ម២៣វស្សា។

១៤. តើព្រះបាទពញ្ញាចន្ទយកប្រពន្ធសាសន៍អ្វី? ឈ្មោះអ្វី? នៅឯណា? ហើយប្រជាជនបានហៅព្រះអង្គដូចម្តេច?

ចម្លើយ៖ ព្រះបាទពញ្ញាចន្ទយកប្រពន្ធជនជាតិចាមឈ្មោះហ្វាទីម៉ា នៅភូមិឃ្លាំងស្បែកចំងាយ១០គីឡូម៉ែត្រខាងត្បូងកំពង់ហ្លួង។ ព្រះអង្គបាននាំប្រទេសកាន់សាសនាអ៊ីស្លាមរហូតប្រជារាស្ត្រនាំគ្នាហៅថា«ព្រះរាមចូលសាសន៍»។

១៥. ហេតុអ្វីបានជាព្រះបាទជ័យជេដ្ឋាទី៣ឬអង្គសូរឬចៅ ពញ្ញាសូរសោយរាជ្យរហូតដល់៥លើក?

ចម្លើយ៖ បានជាព្រះបាទជ័យជេដ្ឋាទី៣ឬអង្គសូរឬចៅពញ្ញាសូរសោយរាជ្យរហូតដល់៥លើកដោយសារក្សត្រដែលព្រះអង្គលើកឱ្យសោយរាជ្យទាំងនោះមានព្រះជន្មក្មេងពេកហើយពេលខ្លះពុំមានសមត្ថភាពទៀតផង។

១៦. តើព្រះបាទជ័យជេដ្ឋាទី៣អង្គសូរជាបុត្ររបស់ស្តេចអង្គណា? ទ្រង់ឡើងសោយរាជ្យប៉ុន្មានលើក?ក្នុងរជ្ជកាលនីមួយៗមានព្រឹត្តិការណ៍អ្វីខ្លះកើតឡើង ?

ចម្លើយ៖ ព្រះបាទជ័យជេដ្ឋាទី៣អង្គសូជាបុត្ររបស់ព្រះបាទអង្គសូរ ទ្រង់ឡើងសោយរាជ្យប្រាំលើកក្នុងរជ្ជកាលនីមួយៗមានព្រឹត្តិការណ៍ដូចជា៖

-រជ្ជកាលទី១ (១៦៧៥.១៦៨៨) មានជនជាតិចិនឈ្មោះម៉ាកគីវ បានភៀសខ្លួនពីខេត្តក្វាងទុងមកនៅស្រុកខ្មែរក្រោយមកត្រូវតែងតាំងជាមន្ត្រី ។

-រជ្ជកាលទី២ (១៦៨៨.១៦៩៥) ប្រគល់រាជសម្បត្តិឱ្យព្រះឧទ័យរាជា(អង្គយ៉ង)

-រជ្ជកាលទី៣(១៦៩៦.១៦៩៩) ផ្ទេររាជ្យឱ្យកែវហ្វាអង្គអិមម្តងទៀតដោយយល់ថាបិតាក្មេកជាអ្នកមានគុណលើករាជ្យសម្បត្តិឱ្យបិតាក្មេកវិញ ។

-រជ្ជកាលទី៤(១៧០០.១៧០២) និងទី៥ (១៧០៣.១៧០៦) ក្រុមលាវដែលច្បាំងចាញ់គ្នាឯងបានមកសុំចុះចូលជាមួយខ្មែរចំនួន ៥០០០នាក់ឱ្យនៅក្នុងខេត្តបាទី ។

១៧. តើព្រះបាទធម្មរាជាទី៣ ឡើងសោយរាជ្យនៅឆ្នាំណា? មានបុត្រប៉ុន្មានអង្គ? តើមានព្រឹត្តិការណ៍អ្វីកើតឡើងក្នុងរជ្ជកាលព្រះអង្គ?

ចម្លើយ៖ ព្រះបាទធម្មរាជាទី៣ឡើងសោយរាជ្យនៅឧដុង្គក្នុងឆ្នាំ ១៧០៦មានបុត្រ៤អង្គគឺ៖

-អង្គអឹម

-អង្គសូរ ឬបទុមរាជា

-អង្គចន្ទបទុមរាជា

-អង្គស្ងួន ។

ព្រឹត្តិការណ៍កើតឡើងក្នុងរជ្ជកាលព្រះអង្គធម្មរាជាទី៣ គឺនៅឆ្នាំ ១៧០៧ខេត្ត៣មត្រូវធ្លាក់ក្នុងការត្រួតត្រារបស់យួនទាំងស្រុងនិង មានការបះបោររបស់លាវ ។

១៨. តើព្រះបាទស្រីជ័យជេដ្ឋាអង្គស្ងួនសោយរាជ្យពីឆ្នាំណាដល់ឆ្នាំណា ?ជាបុត្ររបស់ព្រះរាជាអង្គណា ?សោយរាជ្យនៅឯណា ?ព្រះអង្គបានធ្វើអ្វីខ្លះ ?

ចម្លើយ៖ ព្រះបាទស្រីជ័យជេដ្ឋាអង្គស្ងួនសោយរាជ្យនៅឆ្នាំ១៧៤៩-១៧៥៥ជាបុត្ររបស់ព្រះបាទធម្មរាជាទី៣ព្រះអង្គបានសោយរាជ្យ នៅឧដុង្គ បានបណ្តេញពួកយួនឱ្យចេញពីទឹកដីខ្មែរ។

១៩. តើមានព្រឹត្តិការណ៍អ្វីខ្លះកើតឡើង នៅក្នុងរជ្ជកាល ព្រះបាទរាមាធិបតីទី៣អង្គទង ?

ចម្លើយ៖ ព្រឹត្តិការណ៍ដែលកើតឡើងនៅក្នុងរជ្ជកាលព្រះបាទរាមាធិបតីទី៣អង្គទងមាន៖

-ភាពមិនចុះសំរុងគ្នារវាងអង្គទងនិងអង្គហ៊ឹងជាឧបរាជ។

-អង្គទងពឹងយួននាំទ័ពធ្វើគត់អង្គហ៊ឹង និងអង្គឌួង ។

-១៧៥៧ព្រះអង្គទងបានប្រគល់ខេត្តផ្សារដែកនិងមាត់ជ្រូកព្រមទាំងស្រុកពីរទៀតនៅខែត្រលង់ហោរឱ្យទៅយួន ។

២០. តើព្រះបាទនរាយណ៍រាជាទី២អង្គតន់បានធ្វើអ្វីជាប្រយោជន៍សម្រាប់ប្រទេសជាតិដែរឬទេ ?

ចម្លើយ៖ ព្រះបាទនរាយណ៍រាជាទី២អង្គតន់ទ្រង់មិនបានធ្វើអ្វីជាប្រយោជន៍ជាតិទេ នៅឆ្នាំ១៧៥៨ព្រះអង្គបានថែមទាំងកាត់ខេត្តព្រះត្រពាំង និងខេត្តឃ្លាំងឱ្យទៅយួនទុកជាការសងគុណដែលយួនបានជួយខ្មែរ ។

២១. តើព្រះអង្គអេងឡើងសោយរាជ្យនៅព្រះជន្មប៉ុន្មាន ? ដោយសារអ្នកណា ?ក្នុងឆ្នាំណា ?ព្រះអង្គសុគតនៅថ្ងៃខែឆ្នាំណា ? ក្នុងព្រះជន្មប៉ុន្មានព្រះវស្សា ?

ចម្លើយ៖ ព្រះអង្គអេងបានឡើងសោយរាជ្យនៅព្រះជន្ម៧ព្រះវស្សា ដោយសារមន្ត្រីដែលកាន់អំណាចពិសេសគឺចៅហ្វាមូ ហើយទ្រង់សោយរាជ្យនៅឆ្នាំ១៧៧៩ និងសុគតនៅថ្ងៃទី៨ ខែវិច្ឆិកា ឆ្នាំ ១៧៩៦។ សុគតក្នុងព្រះជន្ម២៥ព្រះវស្សា។

២២. តើព្រះបាទអង្គអេងមានបុត្រប៉ុន្មានអង្គ ?ព្រះនាមអ្វីខ្លះ ?

ចម្លើយ៖ ព្រះអង្គអេងមានបុត្រ៥អង្គគឺ ៖

-អង្គចន្ទ

-អង្គស្ងួន

-អង្គកឹម

-អង្គអឹម

-អង្គដួង។

២៣. ក្នុងរជ្ជកាលព្រះបាទឧទ័យរាជាអង្គចន្ទ តើយួនតម្រូវឱ្យខ្មែរធ្វើអ្វីខ្លះ ?

ចម្លើយ៖ រជ្ជកាលព្រះបាទឧទ័យរាជាអង្គចន្ទ យួនតម្រូវឱ្យខ្មែរ៖

-ខ្មែរនាំសួយសារអាករថ្វាយស្តេចយួនចំនួនបីឆ្នាំជាប់ៗគ្នា ។

-ឆ្នាំ១៨១៥បានកេណ្ឌប្រជាជនខ្មែរចំនួន៥០០០នាក់ជីកព្រែកវិញតេ ឬព្រែកយួន នៅលើទឹកដីខេត្តមាត់ជ្រូកមានបណ្តោយ៥៣គីឡូម៉ែត ទទឹង៣៣ម៉ែត្រជម្រៅ២.៥ម៉ែត្រភ្ជាប់ពីមាត់ជ្រូកទៅសមុទ្រត្រង់ពាម(ហាទៀង) ព្រែកវិញអានមានបណ្តោយ១៤គ.មភ្ជាប់ពីទន្លេធំទៅទន្លេតូច(ទន្លេបាសាក់)។

២៤. តើក្នុងការជីកព្រែកជីកវិញតេ និងព្រែកជីកវិញអានយួនបានធ្វើបាបរាស្ត្រខ្មែរដូចម្តេចខ្លះ?

ចម្លើយ៖ ក្នុងការជីកព្រែកជីកវិញតេ និងវិញអានយួនបានធ្វើបាបរាស្ត្រដូចជា៖

-ឱ្យរាស្ត្រខ្មែរធ្វើការទាំងថ្ងៃទាំងយប់គ្មានពេលសម្រាក

-ឱ្យហូបអាហារមានក្លិនស្អុយនាំឱ្យឈឺចោទថាខ្មែរធ្វើពុត រួចធ្វើបាប

-ឱ្យដេកហាលមូស ហាលភ្លៀងមានជំងឺ

-យករាស្ត្រខ្មែរទឹមជំនួសសត្វដើម្បីអូសឈើចេញពីព្រៃ

-បើកទឹកបង្ហូរចូលព្រែកបណ្តាលឱ្យរាស្ត្រខ្មែរស្លាប់អណ្តែតតាមទឹកជាច្រើននាក់

-កាត់ក្បាលខ្មែរដាំតែអុង

-ទង្វើរបស់ពួកយួនអង្គចន្ទមិនអើពើហើយនាំប្រទេសខ្មែរធ្លាក់ក្រោមចំណុះយួន។

២៥. តើយួនបានរៀបចំប្រពន្ធ័រដ្ឋបាលដូចម្តេចក្នុងរជ្ជកាល ក្សត្រីអង្គម៊ី?

ចម្លើយ៖ យួនបានរៀបចំប្រពន្ធ័រដ្ឋបាលដូចជា៖

-ផ្លាស់ប្តូរឈ្មោះប្រទេស និងបែងចែកជាខេត្ត ក្រុងជាតំបន់រដ្ឋបាលដែលមាន៣២ខេត្ត ប្តូរមកឈ្មោះយួនទាំងអស់ដូចជាខេត្តសំរោងទង យួនហៅថាឡុងទោន។ បន្ទាយមាសហៅថាសាយម៉ាត ក្រុងឧដុង្គ ហៅថាបាក់កូណាម ។

-មានការរុះរើកុដនិងព្រះវិហារ និងកម្ទេចព្រះពុទ្ធរូបចោល ។

២៦. តើព្រះបាទអង្គដួងជាបុត្ររបស់ព្រះរាជាអង្គណា?សោយរាជ្យពីឆ្នាំណាដល់ឆ្នាំណា?

ចម្លើយ៖ ព្រះបាទអង្គដួងជាបុត្ររបស់ព្រះបាទអង្គអេងសោយរាជ្យពីឆ្នាំ១៨៤០-១៨៦០។

២៧. ចូរបង្ហាញស្នាព្រះហស្តរបស់ព្រះបាទហិរក្សរាមាធិបតីអង្គដួង។

ចម្លើយ៖ ព្រះហស្តព្រះបាទហិរក្សរាមាធិបតីអង្គដួងមាន៖

-ព្រះអង្គមានព្រះទ័យស្នេហាជាតិជ្រះថ្លាក្នុងពុទ្ធសាសនា (ការកសាងវត្តអារាម...)

-មានស្នាដៃខាងអក្សរសាស្ត្រ

-កំណែទម្រង់ផ្នែករដ្ឋ បង្កើតច្បាប់ថ្មី

-កសាងហេដ្ឋារចនាសម្ពន្ធ័ថ្មីមានផ្លូវពីឧដុង្គទៅកំពតភ្ជាប់ដល់កំពង់ផែកំពត

-កំណែទម្រង់ហិរញ្ញវត្ថុ កំណែទម្រង់រដ្ឋបាល កសាងទំនប់ ផ្លូវ ព្រះអង្គទ្រទ្រង់ព្រះពុទ្ធសាសនា និងអក្សរសាស្ត្រ(ព្រះអង្គបាននិពន្ធរឿងកាកី«១៨១៥»ច្បាប់ស្រី«១៨៣៧»ចំប៉ាថោង«១៨១០»)។

-ព្រះបាទអង្គដួងបានផ្តើមទំនាក់ទំនងជាមួយបារាំងនៅឆ្នាំ១៨៥៣ ដើម្បីសុំឱ្យមហាអំណាចបារាំងជួយការពារនូវប្រទេសកម្ពុជាពីការឈ្លានពានរបស់យួននិងសៀមជាដើម។

២៨. ចូររៀបរាប់ពីចំណុចខ្លាំងរបស់ព្រះបាទអង្គដួង។

ចម្លើយ៖ ចំណុចខ្លាំងរបស់ព្រះបាទអង្គដួងគឺ៖

-ព្រះអង្គព្យាយាមស្វែងរកអន្តរាគមន៍ពីបារាំង ឬធ្វើឱ្យនគរខ្មែរចាកផុតពីការត្រួតត្រា អាណានិគម ឬក្រោមឥទ្ធិពលពីយួន និងសៀម។

-ព្រះអង្គបានផ្តែផ្តាំមហាមន្ត្រីនិងបុត្រាបុត្រីឱ្យខិតខំធ្វើបែបនេះទោះជាកិច្ចការនេះមិនបានសម្រេចនៅក្នុងរជ្ជកាលទ្រង់ក៏ដោយ។

-ព្រះអង្គបានខ្នះខ្នែងច្រានចោលនូវការរងឥទ្ធិពលរបស់សៀមមកលើអាណាចក្រកម្ពុជា ប៉ុន្តែបានបរាជ័យ ព្រះអង្គត្រូវបានគេនាំព្រះកាយយាងយកទៅរាជធានីបាងកកដោយធ្វើជាអ្នកទោស ក្រោយមកដោយមានការជួយជ្រោមជ្រែងពីមន្ត្រីបារាំងដែលគ្រប់គ្រងកម្ពុជានិងព្រះបាទនរោត្តម សៀមក៏បានដោះលែងព្រះអង្គមកកម្ពុជាវិញ។

២៩. តើព្រះបាទអង្គដួងសោយទិវង្គតនៅថ្ងៃខែឆ្នាំណា?

ចម្លើយ៖ នៅថ្ងៃទី១៩ ខែតុលា ឆ្នាំ១៨៦០ វេលាម៉ោង៤រសៀលនៅឯព្រះបរមរាជវាំង រាជធានីឧដុង្គមានជ័យ។

៣០. តើព្រះបាទអង្គដួង មានមហេសីប៉ុន្មានអង្គ? និងមានបុត្រប៉ុន្មានអង្គ?

ចម្លើយ៖ ព្រះបាទអង្គដួង មានមហេសី៤អង្គនិងមានបុត្រ២០អង្គគឺ

+មហេសីទី១៖ អ្នកម្នាងប៉ែន មានបុត្រ៣អង្គគឺ

-ព្រះបាទនរោត្តម (១៨៣៤ដល់១៩០៤)

-ម្ចាស់ក្សត្រី អង្គដួង ចង់កុលណី (១៨៣៩ដល់១៩០២)

-ព្រះអង្គម្ចាស់ អង្គដួង កេសនី។

+មហេសីទី២៖ អ្នកម្នាងពូ មានបុត្រតែ១អង្គគឺ

-ព្រះបាទ ស៊ីសុវត្ថិ (១៨៤០ដល់១៩២៧)

+មហេសីទី៣៖ អ្នកម្នាង ខាម មានបុត្រា១អង្គគឺ ស៊ីវត្ថា។

+មហេសីទី៤៖ មានបុត្រ១៦អង្គគឺ

-ព្រះអង្គម្ចាស់ អង្គដួង មុំ (១៨២១ដល់១៨៨០)

-ព្រះអង្គម្ចាស់ អង្គដួង ត្រមុល (១៨២៨ដល់១៨៧២)

-ព្រះអង្គម្ចាស់ អង្គដួង អ៊ូ (១៨៣០ដល់១៨៦៦)

-ព្រះអង្គម្ចាស់ អង្គដួង ស៊ីវត្ថា (១៨៤១ដល់១៨៩១)

-ព្រះអង្គម្ចាស់ អង្គដួង សិរីវង្ស (១៨៤២ដល់១៨៨៣)

-ព្រះអង្គម្ចាស់ អង្គដួង ដាវ៉ាកា (១៨៤៣ដល់១៨៦៨)

-ព្រះអង្គម្ចាស់ អង្គដួង អ៊ឹង

-ព្រះអង្គម្ចាស់ អង្គដួង អ៊ូបុណ្យ (១៨៤៩ដល់មុន១៩០៩)

-ព្រះអង្គម្ចាស់ អង្គដួង ចន្ទវង្ស (១៨៥២ដល់១៨៩៣)
-ព្រះអង្គម្ចាស់ អង្គដួង ស្រអ៊ុក
-ព្រះអង្គម្ចាស់ អង្គដួង នុផារ័ត្ន (១៨៥៣ដល់១៨៩១)
-ព្រះអង្គម្ចាស់ អង្គដួង
-ព្រះអង្គម្ចាស់ អង្គដួង កែវ មនោហា (១៨៥៤ដល់មុន១៩០៩)
-ព្រះនាងម្ចាស់ អង្គដួង ខាន់ជាម្តី (១៨៥៥ដល់មុន១៩០៩)
-ព្រះអង្គម្ចាស់ អង្គដួង ចន្ទឆម
-ព្រះអង្គម្ចាស់ អង្គដួង នីឡាវង្ស (១៨៥៩ដល់១៨៨៦)។

៣១. ចូររៀបរាប់ពីព្រឹត្តិការណ៍ផ្ទៃក្នុងនាសម័យឧដុង្គ។

ចម្លើយ៖ ចាប់ពីឆ្នាំ១៧៧៥ ការកាប់សម្លាប់គ្នាដើម្បីរាជសម្បត្តិលែងមានទៀតហើយ ប៉ុន្តែខ្មែរមានលក្ខណៈមួយប្លែកពីអស់ប្រជាប្រិយ ភាពដោយស្តេចខ្លះនិយមយួន ស្តេចខ្លះនិយមសៀម។ រីឯប្រជាជនខ្មែរស្គាល់តែទុក្ខវេទនា មានអសន្តិសុខគ្រប់ទីកន្លែង ប្រទេសខ្មែរក្នុងអំឡុងពេលនោះ បិតនៅក្នុងសភាពងងឹតឥតទិសដៅអ្វីទាំងអស់។

៣២. តើវិបត្តិនៅសម័យឧដុង្គ បណ្តាលមកពីអ្វី?

ចម្លើយ៖ វិបត្តិនៅសម័យឧដុង្គ បណ្តាលមកពីកត្តាដូចជា៖
-ការគ្រប់គ្រងរដ្ឋតាមបែបបុរាណ
-សេដ្ឋកិច្ចកម្ពុជាមិនពឹងផ្អែកលើពាណិជ្ជកម្មជាមួយបរទេស
-កម្ពុជាគ្មានទំនាក់ទំនងសំខាន់ជាមួយប្រទេសខាងក្រៅជាហេតុនាំឱ្យការអភិវឌ្ឍធនធានមនុស្សនៅអន់ថយ
-មន្ត្រីធំៗមិនសូវគិតប្រយោជន៍ជាតិ។

៣៣. ចូររៀបរាប់ពីឈ្មោះអ្នកនិពន្ធខ្មែរល្បីៗនៅសម័យឧដុង្គ។

ចម្លើយ៖ ឈ្មោះអ្នកនិពន្ធខ្មែរល្បីៗនៅសម័យឧដុង្គគឺ

-អ្នក ប៉ាង ៖ តែងកំណាព្យ«ល្បើកអង្គរ» នៅឆ្នាំ១៦០៩ ដែលរៀបរាប់ពីភាពអស្ចារ្យក្នុងការកសាងប្រាសាទអង្គរវត្ត។

-ព្រះរាជសម្ភារ ៖ តែងកំណាព្យ«ច្បាប់ព្រះរាជសម្ភារ»នៅឆ្នាំ ១៦២២ ជាច្បាប់ទូន្មាន កំណាព្យ«ហេមន្តមាស» ឆ្នាំ១៦២៩ កំណាព្យ«ហិនលក្ខណ៍សល» ឆ្នាំ១៦៣០ កំណាព្យ«កាព្យនិរាស» ឆ្នាំ១៦៦០។

-បណ្ឌិត ជ័យនន្ទ៖ ជាកវីនិងមន្ត្រីមួយរូប ដែលបាននិពន្ធកំណាព្យជាភាសាខ្មែរមុនគេបង្អស់លើសិលាចារឹកនៅឆ្នាំ១៧០១ ដែលបាននិយាយពីប្រវត្តិ ទឹកចិត្ត និងសេចក្តីប្រាថ្នាទៅថ្ងៃអនាគតរបស់ខ្លួន។

-ឧកញ៉ាកោសាធិបតី កៅ ៖ ជាកវីឯកក្នុងរជ្ជកាលព្រះបាទអង្គចន្ទទី ២។ លោកបានសរសេររឿង«ក្រុងសុភមិត្រ»នៅឆ្នាំ១៧៩៨។

-ឧកញ៉ា ឃ្លាំង នង៖ ជាកវីក្នុងរជ្ជកាលព្រះបាទអង្គអេងនិងអង្គចន្ទ។ លោកបានសរសេរស្នាដៃដូចជា ច្បាប់សុភាសិត(១៧៩០) លោកនយបករណ៍(១៧៩៤) បុណ្ណសារសិរសោ(១៧៩៧) រឿងកោគកុលកុមារ(១៨០៤) វរនុជវរនេត្រ(១៨០៦) ព្រះសមុទ្រ(១៨០៨) និងពង្សាវតារ(១៨១៨)។

-ឧកញ៉ា សន្ធរោហាម៉ុក ៖ សរសេរ រឿងទេវន្ត (១៧៩៧) ល្បើកចចក និងរឿងទុំទាវ។

-ព្រះបាទអង្គដួង ៖ ស្នាព្រះហស្តជាពាក្យកាព្យដូចជា ចម្បាំបៅង (១៨១០) រឿងកាកី (១៨១៥) ច្បាបស្រី (១៨៣៧) និងរឿងព្រះមហាវេស្សន្តរ (ជាពាក្យរាយ)។

សំណួរ-ចម្លើយ ស្តីពីសម័យអាណានិគមចារ៉ាំង

ប្រធាន

១. តើសម័យបារាំងនៅកម្ពុជា ពីឆ្នាំណាដល់ឆ្នាំណា?

ចម្លើយ៖ ១៨៦៣ ដល់ ១៩៥៣។

២. ចូររៀបរាប់ពីស្ថានភាពប្រទេសកម្ពុជាមុនសន្ធិសញ្ញាថ្ងៃទី១១ ខែសីហា ឆ្នាំ១៨៦៣។

ចម្លើយ៖ ស្ថានភាពប្រទេសកម្ពុជាមុនសន្ធិសញ្ញាថ្ងៃទី១១ ខែសីហា ឆ្នាំ១៨៦៣ គឺ៖

-ប្រទេសខ្មែរត្រូវស្ថិតនៅក្រោមអំណាចត្រួតត្រាយួននិងសៀម។

-ប្រទេសខ្មែរក្រោមរជ្ជកាលព្រះបាទអង្គដួង សៀមនិងយួននៅប្រចាំការអមព្រះអង្គដើម្បីសម្រេចរាជកិច្ចជំនួសស្តេចខ្មែរ។

-ព្រះអង្គដួងចិញ្ចឹមចិត្តខិតខំរកមធ្យោបាយ ដើម្បីរំដោះប្រទេសចេញពីយួននិងសៀម។

-នៅឆ្នាំ១៨៥៤ ព្រះអង្គដួងបានឱ្យរាជទូតខ្មែរទៅទាក់ទងនឹងកុងស៊ុលបារាំងនៅសិង្ហបុរីប៉ុន្តែមិនបានសម្រេច ព្រោះសៀមបាន

គំរាមថា បើទ្រង់ព្រមចុះសន្ធិសញ្ញាសម្ព័ន្ធភាពជាមួយបារាំងដែលមានដីម៉ុងទីញីជាតំណាងនោះ សៀមនឹងលើកទ័ពចូលវាយលុកឬកម្ទេចខ្មែរជាពុំខាន។ ដូចនេះការចុះសន្ធិសញ្ញារវាងបារាំង-ខ្មែរត្រូវផ្អាកសិន។

-នៅថ្ងៃទី១៩ ខែតុលា ឆ្នាំ១៨៦០ ព្រះអង្គដួងបានសោយទិវង្គត រាជបុត្រច្បងរបស់ព្រះអង្គព្រះនាម អង្គច្រឡឹងឡើងគ្រងរាជសម្បត្តិ ដោយមាននាមថា ព្រះបាទនរោត្តម។

-ឆ្នាំ១៨៦១ មានចលនាបះបោរដឹកនាំដោយព្រះអង្គម្ចាស់ស៊ីវត្ថាគាំទ្រដោយស្នងសូរ និងកំហែងយុទ្ធ បានលើកទ័ពវាយដល់ភ្នំពេញ ព្រះបាទនរោត្តមក៏កៀសខ្លួនទៅក្រុងបាងកក ដោយយកទាំងបញ្ជាក្សែត្រទៅជាមួយផង។

-ឆ្នាំ១៨៦២ សៀមបាននាំព្រះអង្គមកស្រុកខ្មែរវិញ ដោយសម្លាប់កំហែងយុទ្ធ ចំណែកស៊ីវត្ថាកៀសខ្លួនទៅប្រទេសឡាវ រួចសុគតនៅឆ្នាំ១៨៩២។

៣. តើសន្ធិសញ្ញាអាណាព្យាបាលបារាំង -ខ្មែរ បានចុះនៅថ្ងៃខែឆ្នាំណា?

ចម្លើយ៖ នៅថ្ងៃទី១១ ខែសីហា ឆ្នាំ១៨៦៣។

៤. តើព្រះបាទនរោត្តមបានចុះសន្ធិសញ្ញាសម្ងាត់ជាមួយព្រះចៅសៀមនៅថ្ងៃខែឆ្នាំណា? មានអត្ថន័យដូចម្តេច?

ចម្លើយ៖ ព្រះបាទនរោត្តមបានចុះសន្ធិសញ្ញាសម្ងាត់ ឬហៅថាសន្ធិសញ្ញាខ្មែរ - សៀម ជាមួយព្រះចៅសៀម នៅថ្ងៃទី០១ ខែធ្នូ ឆ្នាំ១៨៦៣ ដោយមានអត្ថន័យ ឬខ្លឹមសារថា ប្រទេសកម្ពុជាជាសាមន្តរដ្ឋរបស់សៀមដដែល និងយល់ព្រមលះបង់ទឹកដីមួយចំនួនឱ្យសៀម ដូចជាខេត្តបាត់ដំបង អង្គរ មង្គលបុរី សិរីសោភ័ណ កំពង់ស្វាយ និងពោធិ៍សាត់។

៥. តើព្រះបាទនរោត្តម ឡើងសោយរាជ្យនៅថ្ងៃខែឆ្នាំណា?

ចម្លើយ៖ នៅថ្ងៃទី៣ ខែមិថុនា ឆ្នាំ១៨៦៤។

៦. តើបុព្វហេតុអ្វីដែលធ្វើឱ្យបារាំងធ្វើអន្តរាគមន៍ក្នុងបណ្តាប្រទេសនៅឥណ្ឌូចិន?

ចម្លើយ៖ បុព្វហេតុសំខាន់ៗមានបីគឺ៖

-បុព្វហេតុខាងសេដ្ឋកិច្ច : ចាប់តាំងពីសតវត្សទី១៨មក នៅទ្វីបអឺរ៉ុបមានការរីកលូតលាស់យ៉ាងឆាប់រហ័សខាងសេដ្ឋកិច្ចដោយប្រើប្រាស់នូវឧបករណ៍បង្កើតផលថ្មី គឺម៉ាស៊ីនជាដើម។ ដូចនេះនយោបាយវាតទីទីតាំងអាណានិគមនិងនយោបាយស្វែងរកទីផ្សារ ដើម្បីលក់ទំនិញដែលត្រូវបានផលិតយ៉ាងសម្បូរហូរហៀរក្នុងរោងចក្រនៃបណ្តាប្រទេសនៅទ្វីបអឺរ៉ុបបានជម្រុញឱ្យមហាអំណាចអាណានិគមទាំងនោះ វាតទីគ្រប់ទីកន្លែងដែលនៅសេសសល់ពុំទាន់មានម្ចាស់ ជាពិសេសគឺនៅអាហ្រ្វិកនិងអាស៊ី។

-បុព្វហេតុខាងយុទ្ធសាស្ត្រ : ឥណ្ឌូចិនបារាំងដែលមានប្រទេស៥ជាសមាជិកគឺខ្មែរ លាវ កូសាំងស៊ីន អណ្ណាម និងតុងកឹង គឺមានឯក

ភាពគ្នាខាងភូមិសាស្ត្រ។ អាស្រ័យហេតុនេះទើបបារាំងវាតទីយក
មួយម្តងៗនូវគ្រប់ប្រទេសទាំងអស់ក្នុងឧបទ្វីបឥណ្ឌូចិនគឺកូសាំងស៊ី
នឆ្នាំ១៨៨៤ កម្ពុជាឆ្នាំ១៨៦៣ អណ្ណាមឆ្នាំ១៨៨៣ តុងកឹងឆ្នាំ
១៨៨៤ ហើយប្រទេសលាវឆ្នាំ១៨៧៩ដល់១៨៩៥។

-បុព្វហេតុខាងវប្បធម៌ : ការឈ្លានពានខាងសេដ្ឋកិច្ចនិងទឹកដី ត្រូវ
តែបានបង្គ្រប់ដោយការឈ្លានពានខាងវប្បធម៌ថែមទៀត។ បារាំង
បានបញ្ចូលក្នុងប្រទេសដែលធ្លាប់ចូលក្នុងនឹមរបស់ខ្លួននូវវប្បធម៌
របស់គេ ដែលច្រើនតែជាវប្បធម៌ក្លែងក្លាយប្រាសចាកពីវប្បធម៌ដើម
ផង ហើយពុំបានយកចិត្តទុកដាក់ថែរក្សាឱ្យតម្លៃដល់វប្បធម៌ជាតិ
ឡើយ។ សម័យនោះអនក្ខរភាពគឺជាលក្ខណៈទូទៅ នៃប្រជាជន
យើង លើកលែងតែព្រះសង្ឃនិងមន្ត្រីមួយចំនួន កេរដំណែលនៃវប្ប
ធម៌ជាតិដែលត្រូវបានថែរក្សាទុកពីមុនមក ដោយសារព្រះមហាក្សត្រ
និងវត្តអារាមយើង ក៏ត្រូវពួកមហាអំណាចកាន់កាន់ កប់ចោលទាំង
ស្រុងដោយចេតនា ហើយបារាំងបានផ្សព្វផ្សាយចលនាថ្មីគឺគ្រិស្ត
សាសនា ពាសពេញផ្ទៃប្រទេស។

**៧. ចូររៀបរាប់ពីខ្លឹមសារនៃសន្ធិសញ្ញាថ្ងៃទី១១ ខែសីហា ឆ្នាំ
១៨៦៣។**

ចម្លើយ៖ ខ្លឹមសារនៃសន្ធិសញ្ញាថ្ងៃទី១១ ខែសីហា ឆ្នាំ១៨៦៣គឺ៖
-ព្រះចៅអធិរាជនៃប្រទេសបារាំងមានសិទ្ធិនិងផ្តល់នូវការការពារដល់
ព្រះរាជាខ្មែរ។

-ព្រះចៅអធិរាជបារាំងនឹងតែងតាំងរេស៊ីដង់ម្នាក់ដែលមានឋានៈជាមន្ត្រីជាន់ខ្ពស់ឱ្យនៅអមព្រះរាជាខ្មែរ ឯព្រះរាជាខ្មែរនឹងតែងតាំងរេស៊ីដង់ខ្មែរម្នាក់ឱ្យនៅអមលោកទេសាភិបាលបារាំងនៅកូសាំងស៊ីន។
-កប៉ាល់បារាំងមានសេរីភាពពេញលេញក្នុងការធ្វើជំនួញក្នុងដែនដីខ្មែរ ដោយមិនបង់ពន្ធអ្វីទាំងអស់ លើកលែងតែពន្ធអាករ។ រីឯកប៉ាល់ខ្មែរមានសិទ្ធិគ្រប់គ្រាន់ក្នុងការធ្វើជំនួញក្នុងកំពង់ផែទាំងឡាយនៃដែនដីកូសាំងស៊ីន។
-រដ្ឋាភិបាលខ្មែរត្រូវសន្យាថានឹងជួយការពារនូវពួកអ្នកផ្សព្វផ្សាយសាសនា ពួកអ្នកប្រាជ្ញបារាំង និងជនជាតិបារាំងទូទៅដែលរស់នៅឬធ្វើជំនួញក្នុងទឹកដីខ្មែរ។ ចំណែកឯជនជាតិខ្មែរដែលរស់នៅក្នុងទឹកដីជាកម្មសិទ្ធិរបស់បារាំងនឹងត្រូវបានទេសាភិបាលបារាំង ការពារវិញ។
-បារាំងសន្យាថានឹងរៀបចំប្រទេសកម្ពុជាបានស្ថិតនៅក្នុងសន្តិភាព និងរបៀបរៀបរយ និងការពារចំពោះការវាយលុកទាំងឡាយដែលមកពីខាងក្រៅ។
-បារាំងបានជួយខ្មែរក្នុងការដកហូតពន្ធគយ និងផ្តល់ភាពងាយស្រួលក្នុងការធ្វើគមនាគមន៍តាមសមុទ្រ។
-ជាថ្នូរមកវិញប្រទេសកម្ពុជាព្រមឱ្យសម្បទានដល់ប្រទេសបារាំងនូវដីត្រង់តំបន់ជ្រោយចង្វា ដើម្បីស្ថាបនាឃ្លាំងផ្ទុកធ្យូងថ្មឃ្លាំងសម្រាប់ផ្តល់ស្បៀងដល់កប៉ាល់បារាំង និងបន្ទាយសម្រាប់ទាហានបារាំងស្នាក់នៅ។ កម្ពុជាត្រូវបើកសិទ្ធិឱ្យបារាំងកាប់ឈើក្នុងព្រៃទាំងឡាយសម្រាប់ស្ថាបនាកប៉ាល់។

ដូច្នេះទោះបីកាគីខ្មែរចាញ់ប្រៀបខាងភាគីបារាំងខ្លះក៏ដោយក៏បារាំងពុំទាន់ដកហូតអំណាចពីព្រះរាជាខ្មែរទាំងស្រុងនោះឡើយ។

៨. ចូររៀបរាប់ពីខ្លឹមសារនៃអនុសញ្ញាថ្ងៃទី១៧ ខែមិថុនា ឆ្នាំ ១៨៨៤។

ចម្លើយ៖ នៅថ្ងៃទី១៧ ខែមិថុនា ឆ្នាំ១៨៨៤ លោកសាល ថុមសុន បានចតកប៉ាល់នៅមុខព្រះរាជវាំងភ្នំពេញ ហើយមកបង្ខំព្រះបាទ នរោត្តម ដែលកំពុងផ្ទុំឱ្យចុះហត្ថលេខាលើអនុសញ្ញាមួយដែលបានដកហូតអំណាចពីព្រះអង្គទាំងអស់ ហើយនៅក្នុងខ្លឹមសារនោះគឺ៖

-ព្រះមហាក្សត្រត្រូវទទួលស្គាល់នូវកំណែទម្រង់ផ្នែករដ្ឋបាល តុលាការ ហិរញ្ញវត្ថុ និងពាណិជ្ជកម្មរបស់បារាំង គួរតែត្រូវធ្វើក្នុងពេលអនាគតកាល។

-ការគ្រប់គ្រងខេត្តនិងក្រសួងនានា មន្ត្រីខ្មែរត្រូវស្ថិតនៅក្រោមការត្រួតពិនិត្យរបស់អាណាព្យាបាលបារាំង។

-គ្រប់ក្រសួងដែលមានប្រើវិស្វករ គឺបារាំងកាន់កាប់ដោយផ្ទាល់។

-រដ្ឋាភិបាលបារាំងអាចតែងតាំងរ៉េស៊ីដង់ និងរ៉េស៊ីដង់រងឱ្យត្រួតពិនិត្យមន្ត្រីខ្មែរនៅទីរួមខេត្ត។

-ចំណាយទាំងឡាយរបស់រាជាការខ្មែរនិងរាជការបារាំង ជាបន្ទុករបស់ប្រទេសកម្ពុជា។

-ព្រះរាជាត្រូវទទួលប្រាក់បៀវត្សដែលមានកម្រិតជាក់លាក់ ហើយមិនអាចខ្ចីប្រាក់ដោយគ្មានការយល់ព្រមពីបារាំងឡើយ។

-ដីធ្លីក្នុងប្រទេសកម្ពុជាទាំងអស់ ពីមុនជាកម្មសិទ្ធិផ្តាច់មុខរបស់ព្រះមហាក្សត្រ ឥឡូវអាជ្ញាធរបារាំងនិងខ្មែរ អាចរៀបចំឱ្យមានកម្មសិទ្ធិឯកជនខាងដីធ្លីបាន។

-ក្រុងភ្នំពេញត្រូវគ្រប់គ្រងដោយមន្ត្រីបារាំងម្នាក់ អមដោយក្រុមប្រឹក្សាមួយមានសមាជិកជាជនជាតិបារាំង៦នាក់ ជនបរទេស៣នាក់ (ចិន ចាម និងវៀតណាម) និងខ្មែរ៣នាក់។ ក្រោយអនុសញ្ញានេះ ព្រះរាជាខ្មែរត្រូវបាត់បង់នូវអំណាចស្ងួយភាពក្នុងការគ្រប់គ្រងស្ទើរទាំងស្រុង។ ដូច្នេះទើបព្រះអង្គបានរកមធ្យោបាយគ្រប់បែបយ៉ាងដើម្បីរំដោះប្រទេសឱ្យរួចផុតពីការត្រួតត្រារបស់បារាំង។ ចំណែកឯប្រជាពលរដ្ឋខ្មែរក៏មានការប្រតិកម្មយ៉ាងខ្លាំងក្លាចំពោះអនុសញ្ញាថ្ងៃទី១៧ ខែមិថុនា ឆ្នាំ១៨៨៤នេះ។

៩. ចូររៀបរាប់ពីនយោបាយកំណែទម្រង់សង្គមខ្មែររបស់បារាំងនៅឆ្នាំ១៨៧៧។

ចម្លើយ៖ កំណែទម្រង់សង្គមខ្មែរនាឆ្នាំ១៨៧៧គឺ៖

+មូលហេតុ

-កត្តាពីរសំខាន់ៗដែលជំរុញឱ្យបារាំងដាក់កម្មវិធីកំណែទម្រង់សង្គមខ្មែរនៅឆ្នាំ១៨៧៧ គឺកត្តាសេដ្ឋកិច្ច ពាណិជ្ជកម្មនិងនយោបាយ។

-កត្តាសេដ្ឋកិច្ចពាណិជ្ជកម្ម ៖ អស់រយៈពេល១៤ឆ្នាំ ដែលពួកពាណិជ្ជករបារាំងពុំអាចពង្រីកសកម្មភាពរកស៊ីនៅកម្ពុជាបានដោយសារប្រជាជនកម្ពុជារស់នៅតាមបែបប្រពៃណីសក្តិភូមិ មិនចាប់អារម្មណ៍នឹងប្រព័ន្ធទីផ្សារ។

-កត្តានយោបាយ៖ នយោបាយបារាំងរំពឹងថាអាចពង្រឹងអំណាចគ្រប់គ្រងរបស់ខ្លួននៅក្នុងឥណ្ឌូចិន។ ឥណ្ឌូចិនត្រូវតែមានប្រព័ន្ធឯកភាពបែបបារាំងទាំងនៅក្នុងតំបន់និងទាំងនៅក្នុងរចនាសម្ព័ន្ធសង្គម។

+ទិសដៅ

មូលហេតុខាងលើនេះហើយបានជាបារាំងមានទិសដៅចង់កែប្រែសង្គមប្រពៃណីទំនៀមទម្លាប់សក្តិភូមិខ្មែរឱ្យទៅជាសង្គមមូលធននិយម ដែលជាប្រព័ន្ធទីផ្សារសេរី ដូចសង្គមបារាំងដែរ។

+កម្មវិធីកំណែទម្រង់

ដើម្បីសម្រេចទិសដៅនេះ បារាំងបានរៀបចំកម្មវិធីនិងសកម្មភាពនយោបាយដូចខាងក្រោម៖

-ក្នុងសង្គមកម្ពុជា ត្រូវកាត់បន្ថយអំណាចស្តេចគ្រាញ់ មន្ត្រីសក្តិភូមិ និងលុបបំបាត់វណ្ណៈខ្ញុំគេ បង្កើនចំនួនកម្មសិទ្ធិឯកជន។

-បារាំងបានដាក់នូវកម្មវិធីបង្កើតតុលាការជាន់ខ្ពស់គ្រប់គ្រងលើតុលាការមូលដ្ឋាន និងបង្កើតពន្ធដារថ្មី។

-បញ្ហាជាមួយសៀម បារាំងបានរៀបចំជាហូរហែ ថ្វីត្បិតតែគ្មានចែងក្នុងកម្មវិធីកំណែទម្រង់ឆ្នាំ១៨៧៧ក៏ពិតមែន នេះជាការមួយមានសារៈសំខាន់ណាស់ ដើម្បីកសាងប្រព័ន្ធឯកភាពមួយក្នុងសហព័ន្ធឥណ្ឌូចិនបារាំង។

-ក្រោយពីសៀមបានទទួលស្គាល់ការគ្រប់គ្រងរបស់បារាំងលើកម្ពុជាមក បារាំង-សៀម បានចរចាអំពីបញ្ហាព្រំប្រទល់ដែនប្រទេសទាំងពី

រ។ ជាលទ្ធផលនៅឆ្នាំ១៩០៤ សៀមបានប្រគល់ទឹកដីភាគខាងជើងគឺម្លូព្រៃ ស្ទឹងត្រែងមកឱ្យខ្មែរវិញ។
នៅឆ្នាំ១៩០៧ សន្ធិសញ្ញាបារាំង-សៀមស្តីពីការប្រគល់ខេត្តបាត់ដំបង សៀមរាប សិរីសោភ័ណមកឱ្យខ្មែរវិញជាបន្តបន្ទាប់។
នៅឆ្នាំ១៩០៨ បារាំងបានធ្វើផែនទីមួយឈ្មោះថាផែនទីដងរែកដែលទទួលស្គាល់ដោយតំណាងបារាំង-សៀម និងនៅលើឆាកអន្តរជាតិរហូតដល់បច្ចុប្បន្ន។

១០. តើកំណែទម្រង់បារាំងបានផ្តល់ផលអ្វីខ្លះដល់កម្ពុជា?

ចម្លើយ៖ បានផ្តល់ផលដល់កម្ពុជាដូចជា៖

+វិស័យរដ្ឋបាល

-វិស័យរដ្ឋបាលធ្លាប់តែមានភាពអនាធិបតេយ្យ អសមត្ថភាព និងគ្មានប្រសិទ្ធភាពត្រូវជំនួសមកវិញនូវរបៀបគ្រប់គ្រងរដ្ឋបាលថ្មីដែលដឹកនាំដោយលោក រ៉ែស៊ីដង់នៅភ្នំពេញ និងនៅតាមខេត្ត។
-ការកែទម្រង់លើប្រព័ន្ធពន្ធដារ រដ្ឋបាល ការពង្រឹងច្បាប់កម្មសិទ្ធិដីធ្លី និងលុបបំបាត់របបទេសភាព។

+វិស័យចិត្តសាស្ត្រសង្គម

-ការបង្កើតឡើងនូវការចុះបញ្ជីដីធ្លី
-ការប្តូរប្រពៃណីទំនៀមទម្លាប់របៀបបុរាណ
-ការបង្កើតជាកម្មសិទ្ធិលើដីធ្លី និងការបង្កើតច្បាប់ថ្មី គឺជាជំនួយផ្នែកស្មារតីសង្គមខ្មែរឱ្យរស់នៅប្រកបដោយឯករាជ្យ និងស្ថិរភាពជាពិសេសម្ចាស់ដីតូចតាច។

+វិស័យពាណិជ្ជកម្ម

-ការលេចឡើងនូវពាណិជ្ជកម្មក្នុងការទិញដូរអចលនវត្ថុ ការដាក់បញ្ចាំស្របពេលនឹងការធ្វើដំនួញស្រូវ-អង្ករនៅទីក្រុង។

-ការលេចឡើងនូវប្រព័ន្ធទីផ្សារថ្មី ដែលជាទំនាស់នៅក្នុងទំនៀមទម្លាប់ប្រពៃណីខ្មែរ។

-ការលេចឡើងនូវពួកអ្នកមាន ដែលភាគច្រើនគឺជាជនជាតិចិននិងយួន។ រីឯកសិករខ្មែរភាគច្រើនក៏ក្លាយជាជនរងគ្រោះអស់ដីធ្លីដោយសារការលក់បញ្ចាំ។

+វិស័យកសិកម្ម

-ការបង្កើតឱ្យមានប្រព័ន្ធកសិកម្មឬកសិដ្ឋាន។

-ចំពោះប្រព័ន្ធកសិកម្មបែបនេះ កសិករខ្មែរពុំបានត្រៀមខ្លួនទុកជាមុនទេ ទាំងការយល់ដឹង ផ្នែកសម្ភារៈ និងមធ្យោបាយផលិតកម្ម។

-ធ្វើឱ្យកម្ពុជាមានមុខមាត់នៅលើទីផ្សារអន្តរជាតិ។

-សង្គមខ្មែរបានបង្កើតនូវប្រព័ន្ធផ្គត់ផ្គង់ផលិតផលលើទីផ្សារដែលកម្លាំងផលិតកម្ម។

១១. សន្ធិសញ្ញាក្រុងហ្សឺណែវឆ្នាំ១៩៥៤ តើកម្ពុជាទទួលបានលទ្ធផលអ្វីខ្លះ?

ចម្លើយ៖ លទ្ធផលដែលទទួលបាននោះគឺ៖

+សកម្មភាពយោធា

-សកម្មភាពយោធាបញ្ឈប់ទាំងស្រុងនៅលើទឹកដីកម្ពុជាចាប់ពីថ្ងៃទី ៧ ខែសីហា ឆ្នាំ១៩៥៤

-ការដកទ័ពបរទេសចេញពីទឹកដីប្រទេសកម្ពុជាឱ្យអស់ក្នុងអំឡុងពេល៩០ថ្ងៃ

-កម្លាំងកងទ័ពខ្មែរឥស្សរៈត្រូវបានរំសាយអំឡុង៣០ថ្ងៃ។

+សេចក្តីប្រកាសរបស់រាជរដ្ឋាភិបាល

-រាជរដ្ឋាភិបាលធានាដល់អតីតអ្នកចូលរួមក្នុងចលនាតស៊ូ ធានាសិទ្ធិពលរដ្ឋ ការពារជីវិតទ្រព្យសម្បត្តិ និងធានាដល់សិទ្ធិក្នុងការអនុវត្តសេរីភាព និងប្រជាធិបតេយ្យ។

-រាជរដ្ឋាភិបាលអះអាងចំពោះសេចក្តីសម្រេចថា ប្រជាពលរដ្ឋកម្ពុជាទាំងអស់រួមរស់នៅក្នុងសហគមន៍ជាតិតែមួយដោយមិនប្រកាន់ពូជសាសន៍ និងធានាដល់ប្រជាពលរដ្ឋទាំងអស់ក្នុងការប្រើសិទ្ធិ និងសេរីភាពរបស់ខ្លួនដូចដែលមានចែងក្នុងច្បាប់រដ្ឋធម្មនុញ្ញ។

នៅថ្ងៃទី១១ ខែកញ្ញា ឆ្នាំ១៩៥៥ ការបោះឆ្នោតជាសកលនៅកម្ពុជាស្របតាមសន្និសីទក្រុងហ្សឺណែវក៏បានប្រព្រឹត្តឡើង។

១២. ចូរពណ៌នាពីការតស៊ូរបស់កម្ពុជា ដើម្បីទទួលបានឯករាជ្យពីបារាំង។

ចម្លើយ៖ ការតស៊ូរបស់កម្ពុជា ដើម្បីទទួលបានឯករាជ្យពីបារាំងគឺ

-ការតស៊ូដោយហិង្សា ៖ គឺជាចលនាតស៊ូដោយប្រើអាវុធប្រយុទ្ធបង្ហូរឈាម ដើម្បីទាមទារឯករាជ្យ ដោយចលនាតស៊ូរបស់ខ្មែរឥស្សរៈដែលក្រុមនេះបានពង្រីកក្រុមខ្លួនទូទាំងប្រទេស។

-ការតស៊ូដោយអហិង្សា៖ គឺជាចលនាតស៊ូដោយសន្តិវិធី តាមរយៈមធ្យោបាយការទូតពោលគឺតាមរយៈនយោបាយក្រៅប្រទេសជាមួយ

បារាំង កាណាដា សហរដ្ឋអាមេរិក ថៃ តាមរយៈនយោបាយទូត និង កាសែត។

-ព្រះបាទនរោត្តម សីហនុ បានមានព្រះរាជបន្ទូលថា «បើបារាំងមិន ព្រមប្រគល់ឯករាជ្យឱ្យកម្ពុជាទេ នោះកម្ពុជានឹងក្លាយជាប្រទេស កុម្មុយនីស្ត»។

-សកម្មភាពខាងក្នុងប្រទេស ព្រះអង្គបានគង់នៅតំបន់ស្វយ័តក្នុង ខេត្តសៀមរាប បាត់ដំបង កំពង់ធំ ដោយមិនយាងមកភ្នំពេញ ហើយ ទ្រង់បានបង្កើតកងជីវពលនារីក្លាហាន ដើម្បីឱ្យប្រជានុរាស្ត្រក្រោក ឈរឡើង ដើម្បីទាមទារឯករាជ្យបរិបូរណ៌។

១៣. ចូររៀបរាប់ពីកំណែទម្រង់ផ្ទៃក្នុងរបស់បារាំងនៅឆ្នាំ១៩១១ បានចែងដូចម្តេចខ្លះ?

ចម្លើយ៖ នៅឆ្នាំ១៩១១ បារាំងបានធ្វើកំណែទម្រង់នៅសហភាព ឥណ្ឌូចិន តាមរយៈក្រឹត្យចំនួន៤របស់ប្រធានាធិបតី ដែលបានចែង អំពី៖

-ការកំណត់អំណាចរបស់អគ្គទេសាភិបាលឥណ្ឌូចិន

-ការកំណត់សមាសភាពនិងសមត្ថកិច្ចរបស់ក្រុមប្រឹក្សារដ្ឋាភិបា លឥណ្ឌូចិន

-ការកំណត់អំណាចរបស់ទេសាភិបាលកូសាំងស៊ីននិងបណ្តារ៉េស៊ីដ ង់ជាន់ខ្ពស់នៅកម្ពុជា អណ្ណាម តុងកឹង និងឡាវ

-ការរៀបចំឡើងវិញនូវថវិកាឥណ្ឌូចិន និងថវិកាតាមរដ្ឋនីមួយៗនៃ ឥណ្ឌូចិន។

១៤. ចូររៀបរាប់ពីផលវិជ្ជមាន និងផលអវិជ្ជមានរបស់បារាំងនៅកម្ពុជា។

ចម្លើយ៖ ផលវិជ្ជមាន និងផលអវិជ្ជមានរបស់បារាំងនៅកម្ពុជាមានដូចជា៖

+ផលវិជ្ជមាន

-បារាំងបានបង្កើតសាលាចុងបូព៌ាប្រទេស ដើម្បីស្រាវជ្រាវ ចងក្រង ផ្សព្វផ្សាយអំពីអរិយធម៌ សិល្បៈ ចម្លាក់ ប្រវត្តិសាស្ត្ររបស់ខ្មែរ និងជួសជុលប្រាសាទបុរាណខ្មែរជាច្រើនទៀត ធ្វើឱ្យមរតកអតីតកាលខ្មែរស្រស់ឡើងវិញ។

-ក្រោមការគាបសង្កត់របស់បារាំង សៀមបានប្រគល់មកឱ្យខ្មែរវិញនូវខេត្តកោះកុង ម្លូព្រៃ ទន្លេរពៅ ស្ទឹងត្រែង បាត់ដំបង សៀមរាប សិរីសោភ័ណ

-ឆ្នាំ១៩០៨ បារាំងបានធ្វើផែនទីភ្នំដងរែក ជាច្រើនផ្ទាំង ដែលទទួលស្គាល់ដោយរដ្ឋាភិបាលបារាំងនិងសៀម។ ហើយផែនទីនេះធ្វើឱ្យកម្ពុជាឈ្នះរឿងក្តីប្រាសាទព្រះវិហារនៅតុលាការ អន្តរជាតិទីក្រុងឡាអេ នៃប្រទេសហូឡង់។

-បារាំងបានកំណែទម្រង់ដែលនាំឱ្យកម្ពុជាមានទំនើបកម្មដូចជា៖

-វិស័យរដ្ឋបាល៖ បារាំងបានកែទម្រង់វិស័យរដ្ឋបាលខ្មែរឱ្យមានប្រសិទ្ធភាពនិងរបៀបរៀបរយ។

-វិស័យសង្គម៖ ការកែទម្រង់ប្រព័ន្ធពន្ធដារ រដ្ឋបាល ការពង្រឹងច្បាប់កម្មសិទ្ធិដីធ្លី និងការលុបបំបាត់ទេសភាព ព្រមទាំងការចុះបញ្ជីដីធ្លី

និងការបង្កើតនូវកម្មសិទ្ធិដីធ្លីបានផ្លាស់ប្តូរប្រពៃណីទំនៀមទម្លាប់បុរាណ ជាដើម។

-វិស័យអប់រំ៖ ការបង្កើតសាលាតាមវត្ត សាលាតាមឃុំ សាលាបឋមសិក្សា និងសាលាមធ្យមសិក្សា (អនុវិទ្យាល័យ ព្រះស៊ីសុវត្ថិ) ការដាក់ទោសដល់ឪពុកម្តាយណាដែលមិនបញ្ជូនកូនទៅរៀន និងបង្កើតគណៈកម្មការរៀបចំវចនានុក្រម ដើម្បីធ្វើឱ្យភាសាជាតិមានលក្ខណៈប្រាកដនិយមនៅឆ្នាំ១៩១៥។

-វិស័យសេដ្ឋកិច្ច៖ ពឹងផ្អែកលើកសិកម្ម និងកសិ-ឧស្សាហកម្មដូចជាម្រេច ក្រចៅ ថ្នាំជក់ កៅស៊ូ...។

-វិស័យកសិកម្ម៖ បារាំងបានបង្កើនដីកសិកម្ម និងដំណាំកៅស៊ូ។

-វិស័យសុខាភិបាល៖ មានការបង្កើតមន្ទីរពេទ្យ។

-វិស័យគមនាគមន៍៖ ការកសាងស្ពានព្រះមុនីវង្សឆ្លងកាត់ទន្លេបាសាក់ ផ្លូវរថភ្លើងមួយខ្សែប្រវែង២៧៥គីឡូម៉ែត្រដែលតភ្ជាប់ពីភ្នំពេញទៅអារញ្ញ ដោយឆ្លងកាត់តាមប៉ោយប៉ែត ព្រមទាំងផ្លូវថ្នល់ជាច្រើនដូចជា ផ្លូវជាតិ ផ្លូវខេត្ត និងផ្លូវលំជនបទ ជាដើម។

+ផលអវិជ្ជមាន

-បារាំងបានធ្វើការជិះជាន់ គាបសង្កត់ និងប្រមូលពន្ធដារគ្រប់ប្រភេទយ៉ាងធ្ងន់ធ្ងរដែលធ្វើឱ្យសង្គមខ្មែរកាន់តែក្រីក្រ។

-បារាំងបានកេណ្ឌប្រជាពលរដ្ឋខ្មែរឱ្យបម្រើយោធាបារាំងក្នុងសង្គ្រាមលោកលើកទី១ និងលើកទី២។

-នៅថ្ងៃទី៣១ ខែមករា ឆ្នាំ១៩៣៩ បារាំងបានបញ្ចូលកោះត្រល់ទៅក្នុងដែនរដ្ឋបាលកូសាំងស៊ីន។
-បារាំងបានកាត់ទឹកដីកម្ពុជាក្រោម ឬកូសាំងស៊ីន ទៅឱ្យស្តេចបាវដាវ ឬវៀតណាមកាន់កាប់ នៅថ្ងៃទី៤ ខែមិថុនា ឆ្នាំ១៩៤៩។
-បារាំងបានប្រមូលយកវត្ថុកេតនភណ្ឌរបស់ខ្មែរទៅស្រុកបារាំង។

១៥. តើកំណែទម្រង់ឆ្នាំ១៨៧៧និង១៨៨៤ មានលក្ខណៈខុសគ្នាដូចម្តេច?

ចម្លើយ៖ កំណែទម្រង់ឆ្នាំ១៨៧៧និង១៨៨៤ មានលក្ខណៈខុសគ្នាដូចជា៖

+កំណែទម្រង់ ១៨៧៧

-មានគោលនយោបាយអំណាចស្តេចត្រាញ់ មន្ត្រីសក្តិភូមិ និងការលុបបំបាត់វណ្ណៈខ្ញុំគេ បង្កើនចំនួនម្ចាស់កម្មសិទ្ធិដែលជាកម្លាំងចលកដ្ឋយវិធីកំណែទម្រង់បារាំងឱ្យបានជោគជ័យ។
-បង្កើតតុលាការជាន់ខ្ពស់គ្រប់គ្រងលើតុលាការមូលដ្ឋាន
-បង្កើតប្រព័ន្ធពន្ធដារថ្មី
-ឱ្យសៀមទទួលស្គាល់អំណាចរបស់បារាំងលើដែនកម្ពុជា
-ចរចាបញ្ហាព្រំដែនរវាងកម្ពុជានិងសៀម។

+កំណែទម្រង់ឆ្នាំ ១៨៨៤

-បារាំងប្រែក្លាយពីអាណាព្យាបាលទៅជាអាណានិគមលើប្រទេសកម្ពុជា ។

១៦. នៅពេលសន្ធិសញ្ញាថ្ងៃទី១១ ខែសីហា ឆ្នាំ១៨៦៣ តើមានចលនាតស៊ូនឹងបារាំងអ្វីខ្លះ? ចូររៀបរាប់។

ចម្លើយ៖ នៅពេលសន្ធិសញ្ញាថ្ងៃទី១១ ខែសីហា ឆ្នាំ១៨៦៣ មានចលនាតស៊ូនឹងបារាំងមួយចំនួនដូចជា ចលនាតស៊ូរបស់អាចារ្យស្វា ចលនាតស៊ូរបស់ពោធិ៍កំបោរ ចលនាតស៊ូរបស់អ្នកអង្គម្ចាស់ស៊ីវត្ថា។

-ចលនាតស៊ូរបស់អាចារ្យស្វា៖ ឆ្នាំ១៨៦៤ អាចារ្យស្វាបានកៀសខ្លួនទៅបង្កទ័ពនិងបានវាយយកខេត្តទ្រាំង ហើយក៏បន្តឆ្ពោះមកភ្នំពេញទៀត។

-ចលនាតស៊ូរបស់ពោធិ៍កំបោរ៖ ខែឧសភា ១៨៦៦ លោកពោធិ៍កំបោរ មានដើមកំណើតនៅខេត្តរោងដំរី បានកៀសខ្លួនមកខេត្តរោងដំរី ហើយបង្កទ័ពទៅវាយបារាំង នៅខែធ្នូ ១៨៦៦ លោកបាន លើកទ័ពឆ្ពោះទៅរាជធានីឧដុង្គ។

-ចលនាតស៊ូរបស់អ្នកអង្គម្ចាស់ស៊ីវត្ថា៖ ក៏បានប្រឆាំងបារាំង។

សរុបមកការតស៊ូរបស់អ្នកទាំងអស់នេះគឺសុទ្ធតែត្រូវបរាជ័យទាំងអស់ហើយចុងបញ្ចប់ត្រូវស្លាប់ដោយសារបារាំង។

១៧. ចូររៀបរាប់ពីសន្ធិសញ្ញាបារាំង-សៀមឆ្នាំ១៩០៤និងសន្ធិសញ្ញាបារាំង-សៀមឆ្នាំ១៩៧។

ចម្លើយ៖ រៀបរាប់ពីសន្ធិសញ្ញាបារាំង-សៀមឆ្នាំ១៩០៤និងសន្ធិសញ្ញាបារាំង-សៀមឆ្នាំ១៩៧គឺ៖

+សន្ធិសញ្ញាបារាំង-សៀមឆ្នាំ១៩០៤

-ធ្វើឱ្យកម្ពុជាទទួលបានមកវិញនូវខេត្តម្លូព្រៃ និងទន្លេរពៅ ជាថ្នូរនឹងការលុបបំបាត់សិទ្ធិយុត្តាធិការនិងការការពារ ដែលផ្តល់ឱ្យបារាំងដោយអនុសញ្ញាឆ្នាំ១៨៩៣។

-តាមរយៈសន្ធិសញ្ញាឆ្នាំ១៩០៤ បារាំងបានកាត់ផ្តាច់ទឹកដីពីរកន្លែងនៅត្រើយខាងឆ្វេងទន្លេមេគង្គពីប្រទេសសៀម ដូចជាខេត្តម្លូព្រៃនិងទន្លេរពៅរបស់កម្ពុជាដែលត្រូវប្រគល់ទៅឱ្យកម្ពុជាវិញ។

-សន្ធិសញ្ញានេះក៏បានទទួលស្គាល់ថាខ្សែបន្ទាត់ព្រំដែនទ្រនុងកំពូលភ្នំដងរែក គឺជាខ្សែបន្ទាត់ព្រំដែនកម្ពុជាជាមួយសៀម។

+សន្ធិសញ្ញាបារាំង-សៀមឆ្នាំ១៩០៧

-តាមរយៈសន្ធិសញ្ញាឆ្នាំ១៩០៧ រដ្ឋាភិបាលសៀមបានប្រគល់ឱ្យបារាំងនូវទឹកដីបាត់ដំបង សៀមរាប និងស៊ីសុផុន។ ជាថ្នូរមកវិញប្រទេសសៀមទទួលស្គាល់ទឹកដីត្រាតនិងដានសាយ ហើយសៀមក៏យកមកវិញនូវកោះទាំងឡាយដែលស្ថិតនៅខាងត្បូងនៃជ្រោយឡែមលីង រួមទាំងកោះគុតផងដែរ។

១៨. តើការអភិវឌ្ឍធនធានមនុស្សនៅក្នុងសម័យអាណាព្យាបាលបារាំងត្រូវបានលើកកម្ពស់តាមរយៈវិធានការសំខាន់ៗអ្វីខ្លះ?

ចម្លើយ៖ ការអភិវឌ្ឍធនធានមនុស្សនៅក្នុងសម័យអាណាព្យាបាលបារាំងត្រូវបានលើកកម្ពស់តាមរយៈវិធានការ២សំខាន់ៗគឺ

-ទីមួយ៖ ការបញ្ជូននិស្សិតកម្ពុជាឱ្យទៅរៀននៅតាមគ្រឹះស្ថានសិក្សានៅបារាំងនិងវៀតណាម។

-**ទីពីរ៖** ការបង្កើតប្រព័ន្ធអប់រំផ្លូវការ តាមរយៈការបង្កើតសាលារដ្ឋ ខ្មែរ-បារាំងនៅកម្ពុជា។

១៩. តើព្រះរាជាខ្មែរប៉ុន្មានអង្គដែលបានសោយរាជ្យនៅសម័យបារាំង?

ចម្លើយ៖ ព្រះរាជាខ្មែរដែលសោយរាជ្យនៅសម័យបារាំងមាន៤អង្គគឺ

-ព្រះបាទ នរោត្តម ១៨៦០-១៩០៤

-ព្រះបាទ ស៊ីសុវត្ថិ ១៩០៤-១៩២៧

-ព្រះបាទ ស៊ីសុវត្ថិ មុនីវង្ស ១៩២៧-១៩៤១

-ព្រះបាទ នរោត្តម សីហនុ ១៩៤១-១៩៥៥។

២០. តើរជ្ជកាលព្រះបាទនរោត្តមបានបន្សល់ទុកសមិទ្ធផលអ្វីខ្លះ?

ចម្លើយ៖ សមិទ្ធផលក្នុងរជ្ជកាលព្រះបាទនរោត្តមគឺកម្ពុជាបានបង្កើតឡើងនូវប្រព័ន្ធរដ្ឋបាលទំនើបនិងប្រព័ន្ធកម្មសិទ្ធិឯកជន។

+កំណែទម្រង់រដ្ឋបាល

-កាត់បន្ថយចំនួនខេត្តក្នុងគោលដៅកាត់បន្ថយចំណាយថវិកាជាតិ

-ការលុបបំបាត់ការបែងចែកការទទួលខុសត្រូវតាមខេត្តរបស់រាជវង្សានុវង្ស ហើយថវិកាត្រូវបានបង្វែរយកទៅសាងសង់ផ្លូវដើម្បីប្រយោជន៍របស់សាធារណៈ

-ការលុបបំបាត់ក្រុមប្រឹក្សាមន្ត្រីដែលទទួលបានប្រាក់ខែរដ្ឋ

-ការលុបបំបាត់ចោលនូវឧកញ៉ាហ្លួងដែលកេងប្រវ័ញ្ចលើប្រជាជន

-ការផ្តល់សិទ្ធិឱ្យចៅហ្វាយខេត្ត(រ៉េស៊ីដង់)បារាំងជាអ្នកតែងតាំងចៅហ្វាយស្រុក អភិបាលក្រុង មេឃុំនិងមេភូមិ

+កំណែទម្រង់តុលាការ

-ការលុបបំបាត់វណ្ណៈខ្ពើគេ

-ការកែលម្អលក្ខខណ្ឌរបស់អ្នកទោស

-ការកំណត់អំណាចតុលាការរដ្ឋបាលបុរាណខ្មែរ

-ការពង្រីកអំណាចចៅក្រមដែលប្រើប្រាស់ច្បាប់បារាំងសម្រាប់កាត់ក្តី។

+កំណែទម្រង់សេដ្ឋកិច្ច

-ការលុបបំបាត់ពាណិជ្ជកម្មផ្តាច់មុខ គឺការផ្លាស់ប្តូរយ៉ាងខ្លាំងពីរបបគ្រប់គ្រងតាមបែបសក្តិភូមិទៅជារបបគ្រប់គ្រងតាមបែបទំនើប។

២១. តើបារាំងបានផ្លាស់ប្តូររាជធានីឧដុង្គមកភ្នំពេញវិញ នៅឆ្នាំណា? ក្នុងរជ្ជកាលស្តេចអង្គណា?

ចម្លើយ៖ បារាំងបានផ្លាស់ប្តូររាជធានីពីឧដុង្គមកភ្នំពេញនៅឆ្នាំ ១៨៦៦ ក្នុងរជ្ជកាលព្រះបាទ នរោត្តម។

២២. តើសង្គ្រាមរវាងបារាំងនិងសៀម កើតឡើងនៅថ្ងៃខែឆ្នាំណា? បញ្ចប់នៅថ្ងៃខែឆ្នាំណា? មកពីមូលហេតុអ្វី?

ចម្លើយ៖ សង្គ្រាមរវាងបារាំងនិងសៀម បានកើតឡើងនៅថ្ងៃទី១៣ ខែកក្កដា ឆ្នាំ១៨៩៣។ ហើយបញ្ចប់នៅថ្ងៃទី៣ តុលា ១៨៩៣។

+មូលហេតុនៃសង្គ្រាមគឺ បន្ទាប់ពីនាវាបារាំងចំនួន៣គ្រឿងដែលបានចេញពីមាត់ពាមក្នុងសមុទ្រប្រាកាន ហើយចង់ឆ្លងចូលក្នុងទន្លេចៅប្រាយ៉ា ឆ្ពោះទៅរាជធានីបាងកក ដើម្បីជួយចរចាជាមួយសៀមពីរឿងការផ្ទេរទឹកដីលាវដែលសៀមកំពុងតែគ្រប់គ្រងមកឱ្យបារាំងវិញ

ប៉ុន្តែនាវាទាំងនោះត្រូវបានទាហានសៀមដែលប្រចាំការនៅបន្ទាយ ក្នុងចំណុចនោះ បដិសេធមិនអនុញ្ញាតឲឆ្លងឡើយ។ ដោយសារតែអាងខ្លួនជាប្រទេសមហាអំណាចអឺរ៉ុប មេបញ្ជាការកងនាវាបារាំងនៅតែចេសបើកនាវាឆ្លងរបារកាត់មុខប៉មបន្ទាយសៀម ពួកទាហានសៀមក៏បាញ់គំរាមបីបួនគ្រាប់ចូលក្នុងទឹក តែនាវាបារាំងនៅតែបន្តទៅមុខទៀតនៅពេលល្ងាយ ដោយសារយប់មានភ្លៀងធ្លាក់ផង កងទ័ពសៀមបានបាញ់នាវាបារាំង ធ្វើឲ្យនាវាពីរគ្រឿងបានឆេះខូចខាតហើយទំនិញដែលបារាំងនាំមកធ្វើអាជីវកម្មនោះត្រូវបានលិចអស់ចូលក្នុងទន្លេ។ ព្រឹកឡើងសៀមបានចាប់បុគ្គលិកនាវាបារាំងហើយដាក់គុកនៅបាងកក សង្គ្រាមបានកើតឡើង នាវាប្រយុទ្ធរបស់បារាំងឈ្មោះហ្វតហ្វេត(Fortfait)បំពាក់ដោយកាំភ្លើងធំក៏មកដល់ការប្រយុទ្ធគ្នាបានធ្វើឲ្យទាហានបារាំង៣នាក់សម្លាប់ ខណៈទាហានសៀមស្លាប់១០នាក់។ ដោយសារអាវុធទំនើបរបស់បារាំងបំពាក់នៅលើនាវា បានធ្វើឲ្យសៀមបរាជ័យ ហើយបារាំងបានបើកនាវាចូលតាមទន្លេចៅប្រាយ៉ាឆ្ពោះទៅបាងកកដូចបំណង។

២៣. តាមរយៈសន្ធិសញ្ញាបញ្ចប់សង្គ្រាមនៅថ្ងៃទី៣ តុលា ១៨៩៣ រវាងបារាំងនិងសៀម តើបារាំងបានបង្ខំឲ្យសៀមធ្វើអ្វីខ្លះ?

ចម្លើយ៖ ក្នុងសន្ធិសញ្ញានេះបារាំងបានបង្ខំឲ្យសៀមត្រូវសងថ្លៃខូចខាតចំនួន២លានហ្រ្វង់ ចំពោះថ្លៃខូចខាតពីការវាយប្រហារគ្នានៅមាត់សមុទ្រប៉ាកណាម ហើយបារាំងក៏សូមឲ្យសៀមបំពេញនូវ

លក្ខខណ្ឌដោយទាមទារពីការធានាឱ្យបារាំងកាន់កាប់ជាបណ្តោះអាសន្នក្នុងខេត្តចន្ទបុរីរបស់សៀមផងដែរ។

២៤. តើបារាំងបានទាមទារយកខេត្តបាត់ដំបង សៀមរាបនិងស៊ីសុផុនពីសៀមមកឱ្យខ្មែរវិញនៅថ្ងៃខែឆ្នាំណា?

ចម្លើយ៖ នៅថ្ងៃទី២៣ ខែមីនា ឆ្នាំ១៩០៧។

២៥. តើបារាំងបានប្តូរឈ្មោះភូមិក្រាំងលាវមកជាភូមិតិរច្ឆាននៅថ្ងៃខែឆ្នាំណា?

ចម្លើយ៖ នៅថ្ងៃទី២៣ ខែមេសា ឆ្នាំ១៩២៥។

២៦. ហេតុអ្វីបានជាប្តូរឈ្មោះភូមិក្រាំងលាវមកជាភូមិតិរច្ឆាន?

ចម្លើយ៖ បានជាប្តូរឈ្មោះភូមិក្រាំងលាវមកជាភូមិតិរច្ឆាន ដោយសារតែបារាំងបានធ្វើបាបប្រជារាស្ត្រខ្មែរខ្លាំងពេក ជាពិសេសផ្នែកពន្ធដារ ធ្វើឱ្យប្រជារាស្ត្រខ្មែររស់រងទុក្ខយ៉ាងវេទនា ហើយក៏ផ្ទុះជាកំហឹងពេញផ្ទៃប្រទេស។ ជាក់ស្តែងនៅខេត្តកំពង់ឆ្នាំងការបះបោរបានកើតមានឡើងក្រោមការដឹកនាំរបស់អ្នកក្លាហានជួននិងនៅ ជាអ្នកភូមិបន្ទាយអំពិល ឃុំព្រៃខ្មែរ ស្រុករលាប្អៀរ ខេត្តកំពង់ឆ្នាំង ពោលគឺបានរៀបគម្រោងការសម្លាប់លោករ៉ែស៊ីដង់ បារដេស ជារ៉ែស៊ីដង់ប្រចាំខេត្តកំពង់ឆ្នាំង បានចុះដើរទារពន្ធដោយខ្លួនឯង រួមទាំងមានអ្នកបកប្រែឈ្មោះសួន និងអង្គរក្សឈ្មោះឡាច លោកបារដេស បានប្រើឱ្យគេបាញ់សម្លាប់ស្ត្រីពីរនាក់ដែលមាត់រឹងចចេសតវ៉ានឹងលោកបារដេសរឿងមិនព្រមបង់ពន្ធ ស្រាប់តែមានមនុស្សម្នាក់បានវាសកាំភ្លើងឡើងលើ ក៏ស្រាប់តែកាំភ្លើងផ្ទុះទៅលើមេឃតែម្តង ដោយមើលឃើញពី

អំពើដ៏ឃោរឃៅរបស់បារដេស ស្រាប់តែអ្នកភូមិរាបសិបនាក់បានចូលដូចស្រមោចសំដៅរក លោកបារដេស អង្គរក្សឡាច និងអ្នកបកប្រែសួន ហើយបានសម្លាប់ចោលតែម្តងនៅថ្ងៃទី១៨ ខែមេសា ឆ្នាំ១៩២៥។ ពួកបារាំងខឹងយ៉ាងខ្លាំងក៏បានផ្តួចផ្តើមឱ្យព្រះរាជាខ្មែរហត្ថលេខាប្តូរឈ្មោះភូមិក្រាំងលាវ មកជាភូមិតិរច្ឆានវិញនៅថ្ងៃទី២៣ ខែមេសា។

២៧. តើភូមិតិរច្ឆានត្រូវបានប្តូរឈ្មោះមកជាភូមិក្រាំងលាវវិញនៅថ្ងៃខែឆ្នាំណា?

ចម្លើយ៖ នៅថ្ងៃទី៩ មេសា ឆ្នាំ១៩២៦ដោយព្រះបាទ ស៊ីសុវត្ថិ។

២៨. តើព្រះបាទ ស៊ីសុវត្ថិ សោយទិវង្គតនៅថ្ងៃខែឆ្នាំណា? នៅឯណា?

ចម្លើយ៖ នៅថ្ងៃទី៩ ខែសីហា ឆ្នាំ១៩២៧។ ក្នុងព្រះជន្ម៨៧ព្រះវស្សា នៅឯព្រះបរមរាជវាំងក្រុងចតុមុខឬក្នុំពេញ។

២៩. តើព្រះរាជាខ្មែរអង្គណាឡើងសោយរាជ្យបន្តពីព្រះបាទស៊ីសុវត្ថិ?

ចម្លើយ៖ ព្រះបាទ ស៊ីសុវត្ថិ មុនីវង្ស ជាបុត្ររបស់ព្រះបាទស៊ីសុវត្ថិ គ្រងរាជ្យនៅថ្ងៃទី៩ សីហា ឆ្នាំ១៩២៧ដល់២៤ មេសា ១៩៤១។

៣០. តើព្រះបាទ ស៊ីសុវត្ថិ មុនីវង្ស មានមហេសីនិងបុត្រប៉ុន្មានអង្គ?

ចម្លើយ៖ ព្រះបាទ ស៊ីសុវត្ថិ មុនីវង្ស មានមហេសីចំនួន១៦អង្គនិងមានព្រះរាជបុត្រាបុត្រីចំនួន២៤អង្គ។

៣១. ចូររៀបរាប់ពីសមិទ្ធផលធំៗមួយចំនួននៅក្នុងរជ្ជកាលព្រះបាទ ស៊ីសុវត្ថិ មុនីវង្ស។

ចម្លើយ៖ សមិទ្ធផលធំៗមួយចំនួនក្នុងរជ្ជកាលព្រះអង្គ ដែលបានបន្សល់ទុករហូតមកដល់បច្ចុប្បន្នដូចជា៖

-ការបើកសម្ពោធស្ពានឆ្លងទន្លេបាសាក់នៅម្តុំក្បាលថ្នល់នៅថ្ងៃទី១៨ ខែវិច្ឆិកា ឆ្នាំ១៩២៨ ហើយដាក់ឈ្មោះថា«ស្ពានព្រះមុនីវង្ស»។

-មន្ទីរពេទ្យមួយនៅខាងត្បូងផ្សារថ្មីលើវិថីត្រសក់ផ្អែមក្នុងរាជធានីភ្នំពេញក៏ត្រូវបានដាក់ឈ្មោះថា«មន្ទីរពេទ្យយោធាព្រះមុនីវង្ស»ដែរ នៅឆ្នាំ១៩៧៩ក្លាយជាពេទ្យនគរបាល។

-ស្ថានីយ៍រថភ្លើងដោយមានខ្សែរថលើកដំបូងពីភ្នំពេញទៅប៉ោយប៉ែត ឆ្លងកាត់ពោធិ៍សាត់និងបាត់ដំបង ភ្ជាប់ទៅថៃដែលសម្ពោធនៅឆ្នាំ ១៩៣២ កសាងនៅឆ្នាំ១៩៣០និងខ្សែរថពីរទៀតចេញពីភ្នំពេញទៅកំពត និងពីភ្នំពេញទៅក្រុងព្រះសីហនុ បានស្ថាបនាបន្តនៅរជ្ជកាលព្រះបាទនរោត្តម សីហនុ។

-ផ្សារធំថ្មីបានសាងសង់នៅឆ្នាំ១៩៣៧។

-ឧទ្យានលើកំពូលភ្នំបូកគោ សម្រាប់ជាការកម្សាន្តសប្បាយ ហើយបារាំងក៏បានសាងសង់រាជដំណាក់មួយសម្រាប់ព្រះបាទមុនីវង្សផងដែរ ដែលគេប្រសិទ្ធនាមថា«ឧទ្យានជាតិព្រះមុនីវង្ស»។

-ការកសាងសណ្ឋាគារនិងកាស៊ីណូ។

-ការកសាងអគារជាច្រើនរួមទាំងវិហារសាសនាកាតូលិកផងដែរ។

-ការបង្កើតសកាខ្មែរ នៅថ្ងៃទី១៨ ខែសីហា ឆ្នាំ១៩២៨ ដែលមានការកិច្ចផ្តល់យោបល់ពីបញ្ហាពន្ធដារ បញ្ហារដ្ឋបាល បញ្ហាបង្កើតផល ដែលទាក់ទងនឹងជីវភាពប្រជារាស្ត្រខ្មែរ។

-ការបង្កើតក្រុមជំនុំព្រះត្រៃបិដក ថ្ងៃទី១៤ ខែវិច្ឆិកា ឆ្នាំ១៩២៩ ក្រុមនេះមានការកិច្ចបកប្រែព្រះត្រៃបិដក។

-នៅឆ្នាំ១៩៣០ ការបង្កើតវិទ្យាស្ថានពុទ្ធសាសនបណ្ឌិត្យ ដើម្បីបំពេញការងារសិក្សា និងស្រាវជ្រាវពីព្រះពុទ្ធសាសនានៅក្នុងប្រទេសកម្ពុជា។

-នៅថ្ងៃទី១៦ ខែធ្នូ ឆ្នាំ១៩៣០ ព្រះបាទស៊ីសុវត្ថិ មុនីវង្ស បានរៀបចំឱ្យមានការសិក្សាភាសាបាលីនិងលទ្ធិពុទ្ធសាសនានៅទូទាំងប្រទេស និងបង្កើតសាលាអនុវត្តសម្រាប់ព្រះសង្ឃផ្តល់ឱកាសឱ្យព្រះសង្ឃជាគ្រូបាននិមន្តទៅសិក្សាពីវិធីបង្រៀនតាមបែបទំនើបនៅទីនោះ។

៣២. ក្រោយពីព្រះបាទ ស៊ីសុវត្ថិ មុនីវង្ស សោយទិវង្គតទៅ តើព្រះរាជាខ្មែរអង្គណាឡើងសោយរាជ្យបន្ត?

ចម្លើយ៖ ព្រះបាទនរោត្តម សីហនុ។

៣៣. តើព្រះបាទនរោត្តម សីហនុ ប្រសូតនៅថ្ងៃខែឆ្នាំណានិងសោយទិវង្គតនៅថ្ងៃខែឆ្នាំណា?

ចម្លើយ៖ ព្រះបាទនរោត្តម សីហនុ ប្រសូតនៅថ្ងៃទី៣១ ខែតុលា ឆ្នាំ១៩២២ និងសោយទិវង្គតនៅថ្ងៃទី១៥ ខែតុលា ឆ្នាំ២០១២។

៣៤. តើព្រះបាទនរោត្តម សីហនុ បានកាន់តំណែងជានាយករដ្ឋមន្ត្រីចំនួនប៉ុន្មានលើក? ចូររៀបរាប់។

ចម្លើយ៖ ព្រះបាទនរោត្តម សីហនុ បានកាន់តំណែងជានាយករដ្ឋមន្ត្រីចំនួន១០លើកគឺ៖

-លើកទី១៖ ១៨ មីនា ដល់១៣ សីហា ១៩៤៥ គឺព្រះអង្គកំពុងគ្រងរាជសម្បត្តិផង ហើយនគរបានស្ថិតនៅក្រោមអាណានិគមជប៉ុន (ចន្លោះឆ្នាំ១៩៤១-១៩៤៥)

-លើកទី២៖ ថ្ងៃទី៣-៣១ ឧសភា ១៩៥០ ព្រះអង្គជាព្រះមហាក្សត្រ ហើយប្រទេសបានស្ថិតនៅក្រោមអាណានិគមបារាំងជាថ្មី។

-លើកទី៣៖ ១៦ មិថុនា ១៩៥២ដល់ ២២ មករា ១៩៥៣ ខណៈដែលប្រទេសស្ថិតនៅក្រោមអាណានិគមបារាំងដដែល។

-លើកទី៤៖ ថ្ងៃទី៧-១៧ មេសា ១៩៥៤ ប្រទេសបានឯករាជ្យពីបារាំង។

-លើកទី៥៖ ៣ តុលា ១៩៥៥ ដល់ ៥ មករា ១៩៥៦ ព្រះអង្គជារដ្ឋមន្ត្រីការបរទេសនិងមហាផ្ទៃដែរ។

-លើកទី៦៖ ១ មីនា ដល់ ៣ មេសា ១៩៥៦ ព្រះអង្គនៅតែបន្តព្រះតំណែងជារដ្ឋមន្ត្រីការបរទេសនិងមហាផ្ទៃ។

-លើកទី៧៖ ១៥ កញ្ញា ដល់ ២៥ តុលា ១៩៥៦ ព្រះអង្គជារដ្ឋមន្ត្រីការបរទេសនិងមហាផ្ទៃ។

-លើកទី៨៖ ៩ មេសា ដល់ ២៦ កក្កដា ១៩៥៧ ព្រះអង្គជារដ្ឋមន្ត្រីការបរទេស ឧស្សាហកម្ម និងមហាផ្ទៃ។

-លើកទី៩៖ ១០ កក្កដា ១៩៥៨ ដល់ ១៩ មេសា ១៩៦០។

-លើកទី១០៖ ១៧ វិច្ឆិកា ១៩៦១ ដល់ ១៣ កុម្ភៈ ១៩៦២។

៣៥. ក្នុងរជ្ជកាលព្រះបាទនរោត្តម តើខេត្តណាខ្លះដែលបញ្ចូលទៅក្នុងដែនដីកម្ពុជាក្រោម? ហើយអ្នកណាជាអ្នកបញ្ចូល?

ចម្លើយ៖ ខេត្តដែលបានបញ្ចូលទៅក្នុងដែនដីកម្ពុជាក្រោមគឺ៖

-ខេត្តលុងហោ (វិញឡុង)

-មាត់ជ្រូក (ចូវដុក)

-ពាមបន្ទាយមាស (ហាទៀង)

៣៦. នៅពេលព្រះបាទនរោត្តម សីហនុឡើងគ្រងរាជ្យ តើមានព្រឹត្តិការណ៍កើតឡើងអ្វីខ្លះ?

ចម្លើយ៖ ព្រឹត្តិការណ៍មានដូចជា៖

-សង្គ្រាមលោកលើកទី២កំពុងឆាបឆេះ

-ជប៉ុនចូលរាតត្បាត

-សៀមរឹបអូសយកខេត្តបាត់ដំបង សៀមរាបមួយភាគ កំពង់ធំមួយភាគ ស្ទឹងត្រែងមួយភាគ

-ជប៉ុនដកអំណាចពីបារាំង

-ជប៉ុនប្រកាសរាជាណាចក្រកម្ពុជា ជារដ្ឋឯករាជ្យដោយខ្លួនឯង។

៣៧. ចូររៀបរាប់សង្ខេបពីព្រះរាជបូជនីយកិច្ចរបស់ព្រះបាទនរោត្តម សីហនុ ដើម្បីទាមទារឯករាជ្យជូនប្រទេសកម្ពុជា។

ចម្លើយ៖ រៀបរាប់សង្ខេបពីព្រះរាជបូជនីយកិច្ចរបស់ព្រះបាទនរោត្តម សីហនុ ដើម្បីទាមទារឯករាជ្យជូនប្រទេសកម្ពុជាគឺ៖

-នៅឆ្នាំ១៩៤៩ បារាំងបានទទួលស្គាល់តាមផ្លូវច្បាប់នូវឯករាជ្យភាពរបស់កម្ពុជានៃការទាមទារឯករាជ្យរបស់ព្រះបាទនរោត្តម សីហនុ។

ប៉ុន្តែបារាំងនៅតែក្តាប់កងទ័ព តុលាការ ប៉ូលិស ការទូត និងហិរញ្ញវត្ថុដដែល។

-នៅថ្ងៃទី១៥ ខែមិថុនា ឆ្នាំ១៩៥២ ព្រះបាទនរោត្តម សីហនុ បានសន្យាជាមួយប្រជារាស្ត្រខ្មែរថាព្រះអង្គនឹងទាមទារឯករាជ្យឱ្យបានដាច់ខាតយ៉ាងយូរបំផុតមិនលើលពី៣ឆ្នាំឡើយ។

-ព្រះបាទនរោត្តម សីហនុបានយាងចេញដំណើរទៅបរទេសដោយមានឯកឧត្តម ប៉ែន នុត នៅជួយការងារផ្ទាល់នឹងព្រះអង្គ ហើយទ្រង់យាងទៅប្រទេសបារាំង ក្នុងខែកុម្ភៈឆ្នាំ១៩៥៣។

-នៅថ្ងៃទី៥ ខែមីនា ឆ្នាំ១៩៥៣ ពីទីក្រុងណាពូល ព្រះអង្គបានផ្ញើព្រះសារលិខិតជូនលោក រ៉ាំង សង់អូរីយ៉ូល ប្រធានាធិបតីបារាំង។

-នៅថ្ងៃទី១១ ខែមេសា ឆ្នាំ១៩៥៣ ព្រះអង្គបានចេញពីបារាំងទៅប្រទេសកាណាដា និងសហរដ្ឋអាមេរិក។ ព្រះអង្គចាត់ឯកឧត្តម ប៉ែន នុត ឱ្យដឹកនាំគណៈប្រតិភូទៅចរចានឹងបារាំងនៅប៉ារីស។

-ថ្ងៃទី១២ ខែឧសភា ប៉ែន នុត ត្រឡប់មកកម្ពុជាវិញ។

-ថ្ងៃទី១៤ ខែឧសភា ព្រះអង្គយាងចូលកម្ពុជាវិញ។ ដោយទទួលបាននូវលទ្ធផលពុំបានសម្រេចបំណងឡើយ ក៏បានចេញសេចក្តីប្រកាសមួយឱ្យពិភពលោកជ្រួលច្របល់ពីទឹកដីកម្ពុជា។ ព្រះអង្គយាងទៅប្រទេសថៃ ដើម្បីបន្តយការទាមទារឯករាជ្យ។ ក្រោយមកព្រះអង្គក៏យាងទៅគង់នៅតំបន់ស្វយ័ត កំពង់ធំ សៀមរាប និងបាត់ដំបង។

-ព្រះបាទនរោត្តម សីហនុបានបញ្ជាឱ្យពង្រឹងកងទ័ព បង្កើតនូវជីវពលនារីក្លាហានពេញផ្ទៃប្រទេស ហើយធ្វើមហាព្យុហយាត្រាធំមួយនៅខេត្តសៀមរាប។ សកម្មភាពនេះបានធ្វើឱ្យបារាំងព្រួយបារម្ភ ហើយបន្តការចរចាជាមួយរដ្ឋាភិបាលខ្មែរនៅភ្នំពេញ។
-ការចរចារវាងរដ្ឋាភិបាលខ្មែរនិងបារាំង បានចាប់ផ្តើមឡើងពីខែសីហា ១៩៥៣ ដែលភាគីខ្មែរមានឯកឧត្តមប៉ែន នុត ជាអ្នកដឹកនាំ។
-ខែតុលា ឆ្នាំ១៩៥៣ ទើបបារាំងបានប្រគល់អធិបតេយ្យភាពយោធាទូទាំងប្រទេសឱ្យរដ្ឋាភិបាលខ្មែរ។
-ថ្ងៃទី៨ ខែវិច្ឆិកា ឆ្នាំ១៩៥៣ ព្រះបាទនរោត្តម សីហនុ យាងចូលមកគង់នៅភ្នំពេញ ដែលនៅពេលនោះប្រជារាស្ត្រខ្មែរយ៉ាងកុះករមកទទួលស្វាគមន៍ព្រះអង្គ។
-ថ្ងៃទី៩ ខែវិច្ឆិកា ឆ្នាំ១៩៥៣ គឺ៨ខែមុនសន្ធិសីទទីក្រុងសឺណែវ នៅមុខព្រះបរមរាជវាំងមានប្រារព្ធពិធីមួយស្តីពីការដកអំណាចបារាំងចេញពីកម្ពុជា លោកឧត្តមសេនីយ៍បារាំងឈ្មោះ«ឡង់ក្លាត» បានថ្វាយជាឧឡារិកនូវបញ្ជាយោធារបស់ខ្លួនថ្វាយព្រះមហាក្សត្រខ្មែរ ហើយបានដកកងទ័ពពីកម្ពុជាដោយប្រគល់ឯករាជ្យបរិបូណ៌ជូនព្រះរាជាណាចក្រកម្ពុជាវិញ។

៣៨. ហេតុអ្វីបានជាព្រះបាទនរោត្តម សីហនុយាងទៅប្រទេសថៃនិងគង់នៅតំបន់ស្វយ័ត?

ចម្លើយ៖ បានជាព្រះបាទនរោត្តម សីហនុយាងទៅប្រទេសថៃនិងគង់នៅតំបន់ស្វយ័ត ព្រោះ

-ព្រះអង្គទ្រង់ចង់ទតនិងពិនិត្យមើលស្ថានការណ៍ក្នុងតំបន់ទាំងនោះឱ្យបានច្បាស់លាស់សិន។
-ដើម្បីរៀបចំមូលដ្ឋានកងទ័ព
-ចង់ឱ្យបារាំងប្រគល់កេតនភណ្ឌឯករាជ្យទាំងស្រុងឱ្យកម្ពុជា។

៣៩. ចូររៀបរាប់ពីវិស័យអប់រំនៅក្នុងសម័យអាណានិគមបារាំង។

ចម្លើយ៖ ដើម្បីងាយស្រួលក្នុងការកសាងមនុស្សសម្រាប់បម្រើការរដ្ឋការបារាំង បារាំងបានបង្កើតគ្រឹះស្ថានសិក្សាដូចជា៖
-សាលាបឋមសិក្សា៖ ឆ្នាំ១៩១១មានសាលា៣០ ហើយនៅឆ្នាំ១៩៣៧មានសាលា៨១៣។
-សាលាមធ្យមសិក្សា៖ ឆ្នាំ១៩១១ មានអនុវិទ្យាល័យព្រះស៊ីសុវត្ថិ។ នៅឆ្នាំ១៩៣៥ អនុវិទ្យាល័យនេះត្រូវតំឡើងជាវិទ្យាល័យព្រះស៊ីសុវត្ថិវិញ។
-សាលាបច្ចេកទេស៖ ឆ្នាំ១៩១៧ មានសាលាអប់រំបច្ចេកទេសសិល្បៈ និងសិប្បកម្មមួយគឺសាលារចនា។

នៅឆ្នាំ១៩៣៧ ក្នុងចំណោមនិស្សិតមហាវិទ្យាល័យឥណ្ឌូចិននៅហាណូយ៦៣១នាក់ មានខ្មែរ៣នាក់។ នៅឆ្នាំ១៩៣៩បុគ្គលិកសុខាភិបាលនៅកម្ពុជាទាំងអស់មានគ្រូពេទ្យថ្នាក់មធ្យមជនជាតិបារាំងចំនួន៥នាក់និងខ្មែរ៨នាក់ ចំនួនបុគ្គលិកពេទ្យចំនួន១៥០នាក់។

៤០. ចូររៀបរាប់ពីវិស័យអប់រំកម្ពុជានៅចុងសម័យបារាំងឬទទួលបានឯករាជ្យ។

ចម្លើយ៖ នៅចុងសម័យបារាំង ពួកបារាំងបានកសាងសាលារៀន មួយចំនួនសម្រាប់ផលិតបុគ្គលិកបម្រើការិយាល័យ អាណានិគមរបស់ខ្លួន។ នេះជាឱកាសដ៏ស្តួចស្តើងមួយសម្រាប់ពលរដ្ឋកម្ពុជាមួយភាគតូចឈានទៅស្គាល់ពន្លឺចំណេះវិជ្ជា វិទ្យាសាស្ត្រ បច្ចេកទេសនៃពិភពលោក។

-ឆ្នាំ១៩២៥ កម្ពុជាមានសាលាមធ្យមសិក្សាទុតិយភូមិមួយកន្លែងគឺ វិទ្យាល័យព្រះស៊ីសុវត្ថិ អនុវិទ្យាល័យ៣កន្លែងគឺ អនុវិទ្យាល័យនារី អនុវិទ្យាល័យកំពង់ចាម អនុវិទ្យាល័យបាត់ដំបង និងសាលាគរុវិជ្ជាមួយនៅទីក្រុងភ្នំពេញ។

-ពីឆ្នាំ១៩២៥ ដល់១៩៥៣ មានបើកអនុវិទ្យាល័យបន្ថែមទៀតនៅខេត្តសៀមរាប កំពត និងស្វាយរៀង។

-ពីឆ្នាំ១៩៥៣ ដល់១៩៥៤ ក៏មានបើកអនុវិទ្យាល័យមួយនៅខេត្តតាកែវ។

៤១. តើចលនាខ្មែរឥស្សរៈ ជាអ្វី?

ចម្លើយ៖ ចលនាខ្មែរឥស្សរៈ គឺជាចលនាដែលខ្មែរមាននិន្នាការប្រឆាំងនឹងបារាំង បង្កើតឡើងក្នុងគោលបំណងទាមទារឯករាជ្យពីបារាំង។

៤២. តើក្នុងចលនានោះមានចរន្តសំខាន់ៗប៉ុន្មាន? អ្វីខ្លះ?

ចម្លើយ៖ ក្នុងចលនានោះមានចរន្តសំខាន់ៗ៣គឺ

-ចរន្តខ្មែរសេរី៖ ដែលដឹកនាំដោយលោក សឺង ង៉ុកថាញ់។

-ចរន្តរាជានិយម៖ ដឹកនាំដោយព្រះអង្គម្ចាស់នរោត្តមច័ន្ទរង្សី។

-ចន្លៃខ្មែរវៀតមិញ។

ចន្លៃខ្មែរទាំងបីនេះហើយដែលរួបរួមគ្នាបង្កើតបានជាចលនាខ្មែរឥស្សរៈឆ្នាំ១៩៤៧នៅទីក្រុងបាងកកប្រទេសថៃ ដើម្បីទាមទារឯករាជ្យពីបារាំង។

៤៣. ប្រទេសកម្ពុជាទទួលឯករាជ្យឆ្នាំ១៩៥៣ តើប្រទេសផ្សេងៗនៅអាស៊ីអាគ្នេយ៍ទទួលបានឯករាជ្យនៅឆ្នាំណាដែរ?

ចម្លើយ៖ ប្រទេសមួយចំនួននៅអាស៊ីអាគ្នេយ៍ទទួលបានឯករាជ្យមកវិញក្នុងពេលផ្សេងៗគ្នាដូចជា៖

-ប្រទេសហ្វីលីពីន៖ ទទួលឯករាជ្យពីអាមេរិកឆ្នាំ១៩៤៦។

-ប្រទេសភូមា៖ ទទួលឯករាជ្យពីអង់គ្លេសឆ្នាំ១៩៤៨។

-ប្រទេសឡាវ៖ ទទួលឯករាជ្យពីបារាំងឆ្នាំ១៩៥៤។

-ប្រទេសវៀតណាម៖ ទទួលឯករាជ្យពីបារាំងឆ្នាំ១៩៥៤។

-ប្រទេសម៉ាឡេស៊ី៖ ទទួលឯករាជ្យពីអង់គ្លេសឆ្នាំ១៩៥៧។

-ប្រទេសព្រុយណេ៖ ទទួលឯករាជ្យពីអង់គ្លេសឆ្នាំ១៩៨៤។

-ប្រទេសសិង្ហបុរី៖ ទទួលឯករាជ្យពីហូឡង់ឆ្នាំ១៩៦៥។

-ប្រទេសឥណ្ឌូនេស៊ី៖ ទទួលឯករាជ្យពីហូឡង់ឆ្នាំ១៩៤៥។

-ប្រទេសទីម័រខាងកើត៖ ទទួលឯករាជ្យពីព័រទុយហ្គាល់ឆ្នាំ២០០២។

សំណួរ-ចម្លើយ ស្តីពីសម័យសង្គមរាស្ត្រនិយម

ប្រធាន

១. តើសម័យសង្គមរាស្ត្រនិយម ចាប់ពីឆ្នាំណាដល់ឆ្នាំណា?

ចម្លើយ៖ ចាប់ពីឆ្នាំ១៩៥៥ដល់ឆ្នាំ១៩៧០។

២. តើសម័យសង្គមរាស្ត្រនិយមដឹកនាំដោយអ្នកណា?

ចម្លើយ៖ ព្រះបាទ នរោត្តម សីហនុ។

៣. តើបារាំងបានប្រគល់ឯករាជ្យឱ្យកម្ពុជានៅថ្ងៃខែឆ្នាំណា?

ចម្លើយ៖ ៩ វិច្ឆិកា ១៩៥៣។

៤. តើឥស្សរជនរូបណា ដែលបានទាមទារឯករាជ្យមកឱ្យកម្ពុជា?

ចម្លើយ៖ ព្រះបាទនរោត្តម សីហនុ។

៥. តើសម្តេចព្រះបាទ នរោត្តម សីហនុ ប្រសូតនៅថ្ងៃខែឆ្នាំណា?

ចម្លើយ៖ នៅថ្ងៃទី៣១ ខែតុលា ឆ្នាំ១៩២២។

៦. តើសម្តេចនរោត្តម សីហនុ បានប្រកាសដាក់រាជ្យសម្បត្តិថ្វាយព្រះបិតា នៅថ្ងៃខែឆ្នាំណា?

ចម្លើយ៖ ៣ មីនា ១៩៥៥។

៧. តើប្រទេសកម្ពុជាបានចូលជាសមាជិកអង្គការសហប្រជាជាតិនៅថ្ងៃខែឆ្នាំណា?

ចម្លើយ៖ ១៤ ធ្នូ ១៩៥៥។

៨. តើអង្គការសង្គមរាស្ត្រនិយម ត្រូវបានបង្កើតឡើងនៅថ្ងៃខែឆ្នាំណា?

ចម្លើយ៖ ២២ មីនា ១៩៥៥។

៩. តើរដ្ឋធម្មនុញ្ញលើកដំបូង បានប្រកាសឱ្យប្រើនៅថ្ងៃខែឆ្នាំណា?

ចម្លើយ៖ ៦ ឧសភា ១៩៤៧។

៩. តើក្បាលមាស៊ីនដឹកនាំសំខាន់ៗនៃអង្គការសង្គមរាស្ត្រនិយមក្រៅពីសម្តេចនរោត្តម សីហនុ មានឥស្សរជនណាខ្លះ?

ចម្លើយ៖ មានឥស្សរជននយោបាយជាច្រើនទៀតដូចជា

-លោក ស៊ឹម វ៉ា

-លោក សឺន សាន

-លោក យ៉ែម សំបូរ

-លោក សម សារី

-ព្រះអង្គម្ចាស់ នរិន្ទ ដេត ជាដើម។

១០. តើសម័យសង្គមរាស្ត្រនិយម បានបង្កើតសមាជជាតិនៅថ្ងៃខែឆ្នាំណា?

ចម្លើយ៖ ២៥ កញ្ញា ១៩៥៥។

១១. តើសមាជជាតិ មានតួនាទីដូចម្តេច?

ចម្លើយ៖ **សមាជជាតិ** មានតួនាទីជាវេទិការបើកចំហសម្រាប់មហាជននិងអ្នកដឹកនាំចោទនិងសួរដេញដោលគ្នាជុំវិញបញ្ហានយោបាយក្នុងប្រទេសនិងក្រៅប្រទេស។

១២. តើសមាជជាតិ បានសម្រេចសមិទ្ធផលអ្វីខ្លះ?

ចម្លើយ៖ សមាជជាតិបានសម្រេចសមិទ្ធផលជាច្រើនដូចជា៖
-ការប្រឆាំងនឹងអំពើពុករលួយ
-ការកំណត់ភាសាខ្មែរជាភាសាផ្លូវការ
-សភាតំណាងរាស្ត្រមានសិទ្ធិចូលរួមក្នុងការកែលម្អសកម្មភាពរដ្ឋបាលនិងទាមទារឱ្យដាក់ទណ្ឌកម្មទៅលើមន្ត្រីរាជការណាដែលអសកម្ម
-ផ្តល់សិទ្ធិដល់ស្ត្រីក្នុងការបោះឆ្នោត និងឈរឈ្មោះឱ្យគេបោះឆ្នោត។

១៣. តើកត្តាអ្វីខ្លះដែលធ្វើឱ្យប្រជាជនជឿជាក់លើសង្គមរាស្ត្រនិយម?

ចម្លើយ៖ កត្តាដែលធ្វើឱ្យប្រជាជនជឿជាក់លើសង្គមរាស្ត្រនិយមព្រោះ៖
-សម្តេចនរោត្តម សីហនុ ដែលជាស្ថាបនិក និងជាប្រធានមានប្រជាប្រិយភាពខ្លាំង ព្រោះប្រជារាស្ត្រទទួលស្គាល់ព្រះអង្គជាបិតាឯករាជជាតិ និងសន្តិភាព
-ភាពរឹងមាំនៃរចនាសម្ព័ន្ធដឹកនាំរបស់សង្គមរាស្ត្រនិយមថ្នាក់មូលដ្ឋាន
-ក្រៅពីសម្តេចនរោត្តម សីហនុ ដែលជាអ្នកដឹកនាំ មានឥស្សរជននយោបាយជាច្រើនទៀតបានចូលរួមក្នុងសង្គមរាស្ត្រនិយម មានដូចជា លោក ស៊ឹម វ៉ាន លោក សឺន សាន ព្រះអង្គម្ចាស់ នរិន្ទ ដេត លោក ញ៉ែម សំបូរ ជាដើម
-គណបក្សសង្គមរាស្ត្រនិយមមានហិរញ្ញវត្ថុរឹងមាំ ដែលបានមកពីការបរិច្ចាករបស់សមាជិក និងអ្នកមានទ្រព្យសម្បត្តិភាគច្រើនក្នុងស្រុក។

១៤. ចូរអធិប្បាយពីនយោបាយអព្យាក្រឹត របស់សម្តេចនរោត្តម សីហនុ។

ចម្លើយ៖

+អត្ថន័យនៃនយោបាយអព្យាក្រឹត

-នយោបាយអព្យាក្រឹត គឺជានយោបាយដែលមិនចូលបក្សសម្ព័ន្ធណាមួយរវាងប្លុកកុម្មុយ នីស្តនិងប្លុកសេរី។

+ទំនាក់ទំនងជាមួយប្លុកសេរី

-ទំនាក់ទំនងជាមួយប្លុកសេរី មានការធ្លាក់ចុះបន្ទាប់ពីមានការទន្ទ្រានចូលទឹកដីខ្មែរខេត្តស្វាយរៀងរបស់កម្ពុជា ដោយខុសច្បាប់ពីសំណាក់កងទ័ពវៀតណាមខាងត្បូង នៅឆ្នាំ១៩៥៨ ហើយពុំមានការអើពើពីសំណាក់សហរដ្ឋអាមេរិក។

-នៅឆ្នាំ១៩៦២ ថៃនិងវៀតណាមខាងត្បូង កាន់តែគំរាមកំហែងខ្លាំងមកលើបូរណភាពទឹកដីកម្ពុជា។ នៅខែតុលា ឆ្នាំ១៩៦២ អ្នកតំណាងថៃនៅអង្គការសហប្រជាជាតិ បានទាមទារយកទឹកដីបាត់ដំបងសៀមរាប និងកំពង់ធំពីខ្មែរ ចំណែកយន្តហោះរបស់វៀតណាមខាងត្បូង បានទម្លាក់គ្រាប់បែកទៅលើភូមិខ្មែរជាច្រើននៅតាមតំបន់ជាយដែន។

-នៅឆ្នាំ១៩៦៣ រាជរដ្ឋាភិបាលដែលដឹកនាំដោយសម្តេចនរោត្តម សីហនុ បានឈប់ទទួលជំនួយយោធាពីសហរដ្ឋអាមេរិក ដែលមានតម្លៃជាប្រាក់ចំនួន១៥ភាគរយនៃថវិកាជាតិ។

-ចាប់ពីកិច្ចប្រជុំកំពូលនៃទីក្រុងបានឌុងឆ្នាំ១៩៥៥មក កម្ពុជាបានបត់ឆ្វេងទៅជាមួយពួកកុម្មុយនីស្ត ហើយក៏ចេះតែឃ្លាតឆ្ងាយពីលោកសេរីបន្តិចម្តងៗ រហូតឈានទៅដល់ការ ផ្តាច់ទំនាក់ទំនងការទូតទាំងស្រុងជាមួយសហរដ្ឋអាមេរិកនៅឆ្នាំ១៩៦៥។

-នៅថ្ងៃទី២ ដល់ទី៨ ខែវិច្ឆិកា ឆ្នាំ១៩៦៧ មានដំណើរទស្សនកិច្ចរបស់លោកជំទាវ Kennedy មកដល់ទីក្រុងភ្នំពេញ ដែលចាប់ពីពេលនោះបរិយាកាសរវាងសហរដ្ឋអាមេរិក និងកម្ពុជាកាន់តែប្រសើរឡើងវិញ។ លទ្ធផលនាំមកនូវការបើកស្ថានទូតជាថ្មីឡើងវិញនៅថ្ងៃទី១៦ សីហា ឆ្នាំ១៩៦៩។

-នៅចុងទសវត្សឆ្នាំ១៩៦០ សម្តេចនរោត្តម សីហនុ បានប្តូរគោលនយោបាយពីមុន ទ្រង់បានផ្តើមផ្សាភ្ជាប់សម្ពន្ធភាពការទូតជាថ្មីជាមួយសហរដ្ឋអាមេរិក ដោយអនុញ្ញាតឱ្យសហរដ្ឋអាមេរិកទម្លាក់គ្រាប់បែកលើផ្លូវលំហូជីមិញ ហើយបានតែងតាំងលោកសេនាប្រមុខ លន់ នល់ ដែលតែងតែប្រឆាំងនឹងលទ្ធិកុម្មុយនីស្ត ជានាយករដ្ឋមន្ត្រីថ្មី។

+ទំនាក់ទំនងជាមួយប្តូកកុម្មុយនីស្ត

-នៅក្នុងសន្និសីទក្រុងបានឌុងឆ្នាំ១៩៥៥ សម្តេចនរោត្តមសីហនុ បានជួបនឹងមេដឹកនាំសំខាន់ៗ ដែលពេលនោះពួកគេបានអូសទាញឱ្យកម្ពុជាជាប្រទេសអព្យាក្រឹត។ ក្នុងពេលនោះដែរសម្តេចបានជួបនឹងមេដឹកនាំចិន ជូ អេនឡាយ រៀតណាមខាងជើង ផាម វ៉ាន់ដុង។

-នៅឆ្នាំ១៩៥៦ សម្តេចនរោត្តមសីហនុ បានយាងទៅធ្វើទស្សនកិច្ច នៅប្រទេសចិន ដោយបានចុះហត្ថលេខាលើកិច្ចព្រមព្រៀងមិត្តភាព កម្ពុជា-ចិន។ តាមរយៈកិច្ចព្រមព្រៀងនេះបានផ្តល់ឱកាសឱ្យពួកវៀតកុង បង្កើតទីស្នាក់ការភូមិភាគរបស់គេនៅក្រុងភ្នំពេញក្នុងឆ្នាំ ១៩៥៧។

-ខែកក្កដា ឆ្នាំ១៩៥៨ ប្រទេសកម្ពុជាបានភ្ជាប់ទំនាក់ទំនងទូតជាមួយប្រទេសកុម្មុយនីស្ត ខណៈពេលផ្តាច់ជំនួយពីសហរដ្ឋអាមេរិក ប្រទេសចិននិងវៀតណាមកុម្មុយនីស្តបានសន្យាថានឹងផ្តល់ជំនួយដើម្បីជួយជ្រោមជ្រែងសេដ្ឋកិច្ចកម្ពុជា ប៉ុន្តែអ្វីៗទាំងនោះគ្រាន់តែជាការសន្យាប៉ុណ្ណោះ ផ្ទុយទៅវិញពួកគេបានជាន់ឈ្លីសេដ្ឋកិច្ចកម្ពុជាឱ្យធ្លាក់ចុះយ៉ាងខ្លាំង ព្រមទាំងបង្កវិបត្តិនយោបាយគាំទ្រខ្មែរក្រហមឱ្យប្រឆាំងនឹងរដ្ឋាភិបាលសង្គមរាស្ត្រនិយម។

-កម្ពុជាបានអនុញ្ញាតឱ្យកងទ័ពវៀតណាមខាងជើង យៀកកុង ប្រើប្រាស់ទឹកដីខ្មែរនៅតំបន់ភូមិភាគខាងកើតប្រទេសនិងផ្តល់ស្បៀងគ្រឿងសព្វាវុធយុទ្ធភណ្ឌដល់យៀកកុងផងដែរ។ ចាប់ពីពេលនោះមកកម្ពុជាបានធ្លាក់ខ្លួនយ៉ាងជ្រៅផងដែរទៅក្នុងសង្គ្រាមឥណ្ឌូចិនលើកទី២។

-កងទ័ពកុម្មុយនីស្ត បានប្រើប្រាស់ទឹកដីកម្ពុជាភាគឦសាន និងខាងកើត ដើម្បីចល័តទ័ពមកវាយវៀតណាមខាងត្បូង ហើយប្រើប្រាស់កំពង់ផែក្រុងព្រះសីហនុ និងផ្លូវជាតិលេខ៤ សម្រាប់ដឹកជញ្ជូនស្បៀង និងសម្ភារៈសឹកទៅផ្គត់ផ្គង់កងទ័ពវៀតណាមខាងជើង។

+លទ្ធផល

នយោបាយអព្យាក្រឹតរបស់កម្ពុជាចុះខ្សោយដោយសារ

-ប្រទេសជាមហាអំណាចនៃប្លុកទាំងពីរមិនទុកកម្ពុជាឱ្យរស់នៅក្នុងមាគ៌ាសន្តិភាព ហើយគេបានធ្វើសកម្មភាពប្រឆាំងនឹងនយោបាយអព្យាក្រឹត។

-សហរដ្ឋអាមេរិកផ្តល់ជំនួយដល់កម្ពុជាពិសេសជំនួយផ្នែកយោធា ដែលជំនួយនោះមានទិសដៅចិញ្ចឹមពួកស្តាំនិយម គោលបំណងផ្តួលរំលំសម្តេចនរោត្តមសីហនុ។

-ប្រទេសថៃបានគាំទ្រសកម្មភាពសេរី ដែលជាកងទ័ពប្រឆាំងនឹងរាជរដ្ឋាភិបាល ដោយផ្តល់ ដីឱ្យកសាងជំរុំហាត់ទ័ព កសាងស្ថានីយ៍វិទ្យុផ្សាយសំឡេង ដើម្បីប្រឆាំងនយោបាយសង្គមរាស្ត្រនិយម។

-កងទ័ពវៀតណាមខាងត្បូងបានធ្វើសកម្មភាពឈ្លានពានលើទឹកដីខ្មែរតាមព្រំដែន។

-កងទ័ពវៀតណាមខាងជើងបានបង្កើតមូលដ្ឋានទ័ពលើទឹកដីខ្មែរតាមព្រំដែន។ ពួកនេះបានបណ្តុះបណ្តាលកងកម្លាំងខ្មែរក្រហមដើម្បីធ្វើបដិវត្តន៍។ សកម្មភាពរបស់ប្រទេសខាងលើមានទិសដៅប្រឆាំងនឹងនយោបាយអព្យាក្រឹត។

សរុបសេចក្តីមក នយោបាយអព្យាក្រឹតត្រូវបានបញ្ចប់ដោយសារកម្លាំងខាងក្នុង គឺការធ្វើរដ្ឋប្រហារទម្លាក់សម្តេចនរោត្តមសីហនុ ពីប្រមុខរដ្ឋ។ ការអូសទាញទាំងនេះបានធ្វើឱ្យកម្ពុជាធ្លាក់ចូលទៅក្នុង

សង្គ្រាមឥណ្ឌូចិនលើកទី២ ដោយជៀសពុំរួច ហើយទីបំផុតកម្ពុជាបានធ្លាក់ចូលក្នុងសង្គ្រាមស៊ីវិល និងរបបប្រល័យពូជសាសន៍។

១៥. តើការធ្វើប្រជាមតិនៃរបបសង្គមរាស្ត្រនិយមទទួលបានលទ្ធផលដូចម្តេច?

ចម្លើយ៖ .ការធ្វើប្រជាមតិនៃរបបសង្គមរាស្ត្រនិយមទទួលបានលទ្ធផលគឺប្រជាជន៩៩.៩៨%បានបោះឆ្នោតគាំទ្រកម្មវិធីនយោបាយសង្គមរាស្ត្រនិយមនិងសម្តេចព្រះ នរោត្តម សីហនុ ។

១៦. តើសម្តេចនរោត្តម សីហនុ ចូលកាន់តំណែងជាប្រមុខរដ្ឋនៅថ្ងៃ ខែ ឆ្នាំណា?

ចម្លើយ៖ សម្តេចនរោត្តមសីហនុចូលកាន់តំណែងជាប្រមុខរដ្ឋនៅថ្ងៃទី២០ ខែមិថុនា ឆ្នាំ១៩៦០។

១៧. តើនៅឆ្នាំ១៩៦៣ រាជរដ្ឋាភិបាល បានបង្កើតក្រុមហ៊ុនពាណិជ្ជកម្មឈ្មោះអ្វី?

ចម្លើយ៖ នៅឆ្នាំ១៩៦៣រាជរដ្ឋាភិបាលបានបង្កើតក្រុមហ៊ុនពាណិជ្ជកម្មឈ្មោះ "ក្រុមហ៊ុនអាហ័រណេ នីហរ័ណ"(សូណិចស៊ីម)

១៨. ចូររាប់ឈ្មោះរោងចក្រនានា នៅក្នុងសម័យសង្គមរាស្ត្រនិយម។

ចម្លើយ៖ រោងចក្រនានា ក្នុងសម័យ សង្គមរាស្ត្រនិយមរួមមាន៖

-រោងចក្រវាយនភ័ណ្ឌ(កំពង់ចាម)

-រោងចក្រក្តារបន្ទះដីឥដ្ឋ

-រោងចក្រកែវចម្ការដូង(កណ្តាល) រោងចក្រក្រដាសឆ្លូង(ក្រចេះ) រោងចក្រស៊ីម៉ងត៍ចក្រីទីង(កំពត) រោងចក្រក្រចៅដូនទាវ(បាត់

ដំបង) រោងចក្រស្ករសេកំពង់ត្រាំ(កំពង់ស្ពឺ) រោងចក្រស្រាបៀរនិង ដំឡើងត្រាក់ទ័រ(ក្រុងព្រះសីហនុ...)។

១៩. ចូររាប់ឈ្មោះមន្ទីរពេទ្យ ដែលបានសាងសង់នាសម័យសង្គមរាស្ត្រនិយម។

ចម្លើយ៖ មន្ទីរពេទ្យដែលបានសាងសង់នាសម័យសង្គមរាស្ត្រនិយម រួមមាន៖

-មន្ទីរពេទ្យកុមារ គន្ធបុប្ផា.ឪសថាល័យព្រះសុរាម្រឹត

.មហាវិទ្យាល័យកូមិន្ទវិជ្ជាពេទ្យ

.មន្ទីរសម្ភពផុះង៉ាង៉ាម

.មន្ទីរពេទ្យព្រះកុសមៈ(ពេទ្យលោកសង្ឃ)...។

២០. ចូររៀបរាប់ពីសមិទ្ធផលសម័យសង្គមរាស្ត្រនិយម។

ចម្លើយ៖ សមិទ្ធផលសម័យសង្គមរាស្ត្រនិយមគឺ៖

+វិស័យសេដ្ឋកិច្ច

-រាជរដ្ឋាភិបាលបានយកចិត្តទុកដាក់លើវិស័យកសិកម្ម ដោយពង្រីកផ្ទៃដីកសិកម្ម ធ្វើការជ្រើសរើសពូជ ធ្វើនយោបាយទឹក ប្រើប្រាស់ជីចាក់ថ្នាំបង្ការដល់សត្វពាហនៈដែលជាកម្លាំងអូសទាញ បង្កើតរុក្ខទិវាគ្រប់ខេត្តក្រុង។

-វិស័យនេសាទមានការរីកចម្រើនដែលអាចបម្រើជីវភាពប្រជាជនប្រចាំថ្ងៃនិងនាំចេញទៅលក់នៅបរទេសថែមទៀត។

+វិស័យគមនាគមន៍

-ពង្រីកកំពង់ផែភ្នំពេញ និងកសាងកំពង់ផែនៅក្រុងព្រះសីហនុ

-កសាងផ្លូវជាតិលេខ៤ប្រវែង២២៦គីឡូម៉ែត្រ
-ពង្រីកអាកាសយានដ្ឋានអន្តរជាតិសៀមរាប
-កសាងផ្លូវរថភ្លើងខ្សែទី២ ពីភ្នំពេញទៅក្រុងព្រះសីហនុ ប្រវែង ២៧០គីឡូម៉ែត្រនិងកសាងស្ពានជ្រោយចង្វា(ស្ពានមិត្តភាពកម្ពុជា-ជប៉ុន)
-ភ្ជាប់ខ្សែទូរសព្ទជាមួយក្រុងតូក្យូ សាន់ហ្វ្រាន់ស៊ីស្កូ ក្រុងអូសាកា..

+វិស័យពាណិជ្ជកម្ម

-ក្រុមហ៊ុនធំៗរបស់បារាំងនិងសាខាក្រុមហ៊ុនអាមេរិកជាច្រើន បានដាក់ទុនវិនិយោគនៅកម្ពុជា
-នៅខែវិច្ឆិកាឆ្នាំ១៩៦៣ រាជរដ្ឋាភិបាលបានសម្រេចនិងអនុវត្តការកែប្រែប្រព័ន្ធធនាគារ និងពាណិជ្ជកម្មក្រៅប្រទេស ដោយធ្វើការហាមឃាត់ក្រុមហ៊ុនពាណិជ្ជកម្មក្រៅប្រទេស និងធនាគារឯកជនខាងពាណិជ្ជកម្មនៅក្នុងស្រុក។ រាជរដ្ឋាភិបាលបានអនុញ្ញាតឱ្យក្រុមហ៊ុនបរទេសខ្លះបន្តសកម្មភាពរបស់ខ្លួនដូចជាក្រុមហ៊ុនសែល ក្រុមហ៊ុនអេសូ និងកាល់តិច
-រដ្ឋបានបង្កើតក្រុមហ៊ុនឈ្មោះក្រុមហ៊ុនអាហរ័ណ នីហរ័ណជាតិ ហៅកាត់ថាសូណិចស៊ីម ដែលមាន៦០ភាគរយជាទុនរបស់រដ្ឋ និង ៤០ភាគរយជាទុនពាណិជ្ជករកម្ពុជា
-នៅឆ្នាំ១៩៦៤ ក្រុមហ៊ុនពាណិជ្ជកម្មរដ្ឋពីរទៀតត្រូវបានបង្កើតឡើង គឺ ក្រុមហ៊ុនខ្មែរនៃការទិញផលិតផលកសិកម្ម ហៅកាត់ថាសូរ៉ាប៉ា

និងក្រុមហ៊ុនជាតិនៃការចែករំលែកទំនិញនាំចូល ហៅកាត់ថា សូ ណាព្រីម។

+វិស័យធនាគារ

-ប្រាក់រៀលដែលជារូបិយវត្ថុក្នុងស្រុកត្រូវបានចរាចរទូទាំងប្រទេស។ វិស័យធនាគារគេឃើញមានក្រុមហ៊ុនបរទេសពីរគឺ អង់គ្លេសមាន ធនាគារឆាទែរិច និងហុងកុងសៀងហៃ រីឯជប៉ុនមានធនាគារអូហ្វូតូក្យូ។

+វិស័យឧស្សាហកម្ម

-រាជរដ្ឋាភិបាលបានបានបង្កើតរោងចក្រជាច្រើនដូចជា រោងចក្រវាយនកណ្ដា រោងចក្រក្តារបន្ទះ រោងចក្រកែវ រោងចក្រក្រដាស រោងចក្រស៊ីម៉ង់ត៍ រោងចក្របាវក្រចៅ រោងចក្រ
ស្ករ រោងចក្រដំឡើងត្រាក់ទ័រ រោងចក្រចម្រាញ់ប្រេងកាត និងរោងចក្រស្រាបៀ។

-ការកសាងទំនប់វារីអគ្គិសនីនៅស្ទឹងច្រាល គិរីរម្យ និងព្រែកត្នោតក្នុងខេត្តកំពង់ស្ពឺ។

+វិស័យវប្បធម៌

-រាជរដ្ឋាភិបាលបានយកចិត្តទុកដាក់លើវិស័យសិក្សាធិការជាតិ ដោយការបណ្តុះបណ្តាលគ្រូបង្រៀន និងការកសាងសាលារៀនពីបឋមសិក្សាដល់សាកលវិទ្យាល័យ ព្រមទាំងធ្វើយុទ្ធនាការបំបាត់អនក្ខរភាព។

-ការបញ្ជូននិស្សិតឱ្យទៅសិក្សានៅឯបរទេសពិសេសប្រទេសបារាំង ព្រមទាំងកសាងអន្តេវាសិកដ្ឋាននៅទីនោះផងដែរ។
-ការលើកស្ទួយវិស័យកីឡា ដោយបានបណ្តុះបណ្តាលកីឡាគ្រប់ខេត្តក្រុង និងជួលគ្រូមកពីបរទេសមកបង្ហាត់បង្រៀន និងកសាងពហុកីឡដ្ឋានជាតិអូឡាំពិក។
-ការយកចិត្តទុកដាក់លើព្រះពុទ្ធសាសនា ដោយបានបង្កើតពុទ្ធិកបឋមសិក្សារហូតដល់ពុទ្ធិកមហាវិទ្យាល័យ។
-ការថែរក្សាសម្បត្តិវប្បធម៌ បេតិកភណ្ឌជាតិ ព្រមទាំងបង្កើតសាកលវិទ្យាល័យភូមិន្ទវិចិត្រសិល្បៈ និងសាលមហោស្រពតាមខេត្តក្រុង។

+វិស័យសង្គមកិច្ច

-ការកសាងមន្ទីរពេទ្យជាច្រើនដូចជា មន្ទីរពេទ្យកុមារគន្ធបុប្ផា ឱសថាល័យព្រះសុរាម្រឹត មហាវិទ្យាល័យភូមិន្ទវិជ្ជាពេទ្យ មន្ទីរសេម្ភពផះង៉ាង៉ាម ឬព្រះកេតុមាលា មន្ទីរពេទ្យព្រះកុសុមៈ ឬពេទ្យលោកសង្ឃ។
-ការចាត់វិធានការការពារ ដោយចាក់ថ្នាំការពាររោគរាតត្បាត ព្រមទាំងរក្សាអនាម័យតាមលំនៅដ្ឋាន ជីកអណ្តូងទឹង សង់ផ្ទះ ជីកស្រះ។
-ទប់ស្កាត់អំពើពេស្យាចារ និងបង្កើតមជ្ឈមណ្ឌលអប់រំស្ត្រីពេស្យានៅទួលគោក
-ផ្តល់សិទ្ធិឱ្យស្ត្រីមានសិទ្ធិបោះឆ្នោត និងឈរឈ្មោះឱ្យគេបោះឆ្នោត។

២១. ចូររៀបរាប់ពីផលវិជ្ជមាននៃនយោបាយអព្យាក្រឹត។

ចម្លើយ៖ ភាពវិជ្ជមាននៃនយោបាយអព្យាក្រឹតគឺ៖

-ធ្វើឱ្យកម្ពុជាមានកិត្យានុភាពល្បីល្បាញសុះសាយក្នុងតំបន់
-ក្រុមប្រឆាំងពុំហ៊ានប៉ះពាល់ ហើយទទួលស្គាល់គុណសម្បត្តិនៃនយោបាយអព្យាក្រឹត
-ប្រទេសកម្ពុជារស់នៅក្នុងសុខសន្តិភាពអស់រយៈពេល១៥ឆ្នាំ ក្នុងខណៈដែលប្រទេសជិតខាងដូចជាវៀតណាមស្ថិតក្នុងភ្លើងសង្គ្រាម។

២២.ហេតុអ្វីបានជាមានរដ្ឋប្រហារទម្លាក់ព្រះបាទនរោត្តម សីហនុ នៅថ្ងៃទី១៨ ខែមីនា ឆ្នាំ១៩៧០?

ចម្លើយ៖បានជាមានរដ្ឋប្រហារទម្លាក់សម្តេចនរោត្តម សីហនុ ព្រោះ

+វិបត្តិនយោបាយ

-សម្តេចនរោត្តម សីហនុ ប្រកាន់នូវនយោបាយអព្យាក្រឹតលំអៀងទៅរកកុម្មុយនីស្ត ដោយមានទំនាក់ទំនងជាមួយចិន វៀតណាមខាងជើង និងវៀតកុង
-មន្ត្រីអភិរក្សនិយមជាន់ខ្ពស់ និងស្តាំនិយមមួយចំនួនដែលមាននិន្នាការទៅរកពួកសេរី បានចាប់ផ្តើមធ្វើផែនការក្បត់សម្តេចព្រះនរោត្តមសីហនុ
-វត្តមានកងទ័ពវៀតណាមខាងជើង និងវៀតកុងលើទឹកដីខ្មែរ
-ការជ្រៀតជ្រែតរបស់មហាអំណាចចូលក្នុងកិច្ចការនយោបាយផ្ទៃក្នុងខ្មែរ

+វិបត្តិសេដ្ឋកិច្ច

-បាត់បង់ប្រាក់ចំណូលបណ្តាលមកពីការគេចពន្ធ និងការលក់ស្រូវឱ្យពួកយៀកកុង

-ការគ្រប់គ្រងឧស្សាហកម្មរដ្ឋមិនបានល្អ
-ការចំណាយខ្វះតុល្យភាព
-បញ្ហាកសិកម្មជួបនឹងវិបត្តិ ប្រព័ន្ធធារាសាស្ត្រគ្មានប្រសិទ្ធភាព ទិន្នផលកសិកម្មទាប
-ដើម្បីគេចពីសង្គ្រាមវៀតណាមឆ្នាំ១៩៦៣ សម្តេចនរោត្តម សីហនុ បានបដិសេធជំនួយអាមេរិក ឯជំនួយរបស់ចិនពុំអាចស្តារស្ថានភាពចុះខ្សោយនៃកងទ័ពបានទេ

+វិបត្តិសង្គម

-សង្គ្រាមស៊ីវិលចាប់ផ្តើមកើតឡើងនៅឆ្នាំ១៩៦៧
-នៅដើមឆ្នាំ១៩៧០ កងកម្លាំងខ្មែរក្រហម បានបង្កអសន្តិសុខ និងកាន់កាប់ទឹកដី១/៥នៃទឹកដីកម្ពុជាសរុប
-សង្គមកម្ពុជាចែកមនុស្សជា៣ក្រុមផ្សេងៗគ្នា គឺក្រុមឆ្វេងនិយម ស្តាំនិយម និងក្រុមនិយមកណ្តាល
-អំពើពុករលួយ និងបក្សពួកនិយម
-នៅថ្ងៃទី៨-៩ ខែមីនា ឆ្នាំ១៩៧០ មានបាតុកម្មប្រឆាំងវៀតណាមខាងជើង និងវៀតកុងដែលបំផុសដោយកងទ័ពនៅខេត្តស្វាយរៀង។
-នៅថ្ងៃទី១១-១៦ ខែមីនា ឆ្នាំ១៩៧០ មានកុប្បកម្មវាយកម្ទេចបំផ្លាញអគារស្ថានទូតវៀតណាមខាងជើង និងការិយាល័យរណសិរ្សសេរីកាជាតិវៀតណាមខាងត្បូងនៅភ្នំពេញ។

២៣. ចូររៀបរាប់សង្ខេបពីសម័យសង្គមរាស្ត្រនិយម ពីឆ្នាំ១៩៥៣ ដល់ឆ្នាំ១៩៧០។

ចម្លើយ៖ សម័យសង្គមរាស្ត្រនិយម ពីឆ្នាំ១៩៥៣ដល់ឆ្នាំ១៩៧០គឺ

+ការបង្កើតរបបសង្គមរាស្ត្រនិយម

-រដ្ឋធម្មនុញ្ញឆ្នាំ១៩៤៧ បានបញ្ញត្តិពីអំណាចព្រះមហាក្សត្រដោយព្រះអង្គសោយរាជ្យពេញមួយជីវិតប៉ុន្តែមិនកាន់អំណាច រាល់ទស្សនៈនយោបាយរបស់ព្រះមហាក្សត្រត្រូវដាក់ឱ្យសភាអនុម័តទើបយកទៅអនុវត្ត។

-សភាតែងតែជំទាស់រាល់គំនិតទស្សនៈនយោបាយរបស់ព្រះមហាក្សត្រ។

-ព្រះរាជាពុំចង់ឃើញការខ្វែងគំនិតគ្នានិងការបែកបាក់គ្នាក្នុងរង្វង់អ្នកដឹកនាំ។

-ព្រះរាជាចង់ឱ្យប្រជាជន អ្នកនយោបាយគ្រប់និន្នាការ នយោបាយស្ថិតក្រោមម្លប់រាជបល្ល័ង្កតែមួយ។

-ដូច្នេះហើយបានជាព្រះអង្គដាក់រាជ្យ នៅថ្ងៃទី៣ ខែមីនា ឆ្នាំ១៩៥៥ ហើយបានបង្កើតអង្គការសង្គមរាស្ត្រនិយមនៅថ្ងៃទី២៣ ខែមីនា ឆ្នាំ១៩៥៥ ដោយចូលរួមបោះឆ្នោតនៅថ្ងៃទី១១ ខែកញ្ញា ឆ្នាំ១៩៥៥ ទទួលបានជោគជ័យ៨៣,៨៧ភាគរយ។ ហើយសម័យសង្គមរាស្ត្រនិយមក៏ចាប់ផ្តើមកើតឡើង។

+សមាជជាតិ

-ជាវេទិកានៃលទ្ធិប្រជាធិបតេយ្យ ដែលតម្រូវឱ្យប្រជាជនចូលរួមបញ្ចេញមតិយោបល់ជាមួយថ្នាក់ដឹកនាំជាតិ ដើម្បីប្រយោជន៍រួមរបស់ជាតិ។

-សមាជជាតិត្រូវបានប្រារព្ធឡើងមួយឆ្នាំ២ដង។

+នយោបាយអព្យាក្រឹតនៅកម្ពុជា

-គោរពតាមស្មារតីសន្និសីទក្រុងហ្សឺណែវឆ្នាំ១៩៥៤

-ដើម្បីរក្សាសន្តិភាពនៅកម្ពុជា

-ដើម្បីរួមរស់ដោយសន្តិសហវិជ្ជមាន

-មានសុខសន្តិភាពរយៈពេល១៥ឆ្នាំ

-ទប់ទល់នឹងឥទ្ធិពលនៃសង្គ្រាមត្រជាក់

-ឥទ្ធិពលនៃសង្គ្រាមត្រជាក់ ធ្វើឱ្យនយោបាយអព្យាក្រឹតដួលរលំ

+សមិទ្ធផល៖ មានការរីកចម្រើនលើគ្រប់វិស័យដូចជា៖

-សេដ្ឋកិច្ច៖ រីកចម្រើនផ្នែកកសិកម្មនិងនេសាទ។

-គមនាគមន៍៖ ផ្លូវទឹក គោក អាកាស។

-ពាណិជ្ជកម្មនិងឧស្សាហកម្ម៖ មានការរីកចម្រើនផ្នែកអហរ័ណ នីហរ័ណជាតិ

-ធនាគារ៖ ប្រាក់រៀលត្រូវបានចរាចរណ៍នៅទូទាំងប្រទេស។

-វប្បធម៌៖ រីកចម្រើនផ្នែកសិក្សាធិការ កីឡា និងសិល្បៈ។

-សង្គមកិច្ច៖ ផ្តោតលើបញ្ហាពីរគឺសុខាភិបាលនិងការអនុវត្តច្បាប់។

២៤. តើសង្គ្រាមត្រជាក់ ជាអ្វី? ហើយឥទ្ធិពលនៃសង្គ្រាមត្រជាក់ នេះបានបង្កឱ្យមានបញ្ហាអ្វីខ្លះ?

ចម្លើយ៖ **សង្គ្រាមត្រជាក់** គឺជាសង្គ្រាមមនោគមវិជ្ជាដែលកើតឡើងបន្ទាប់ពីសង្គ្រាមលោកលើកទី២ ត្រូវបានបញ្ចប់។ សង្គ្រាមនេះគឺជា

ការប្រឈមមុខដាក់គ្នារវាងប្លុកកុម្មុយនិស្តដឹកនាំដោយសហភាពសូវៀតនិងប្លុកសេរីដឹកនាំដោយសហរដ្ឋអាមេរិក។

+ឥទ្ធិពលសង្គ្រាមត្រជាក់បានធ្វើឱ្យប្រទេសមួយចំនួនបែងចែកជាពីរដូចជា៖

-ប្រទេសអាល្លឺម៉ង់ (អាល្លឺម៉ង់ខាងលិចនិងអាល្លឺម៉ង់ខាងកើត)

-ប្រទេសវៀតណាម (វៀតណាមខាងជើងនិងវៀតណាមខាងត្បូង)

-ប្រទេសកូរ៉េ (កូរ៉េខាងត្បូងនិងកូរ៉េខាងជើង)។

២៥. តើចលនាមិនចូលបក្សសម្ព័ន្ធបង្កើតឡើងនៅឯណា? ហើយរៀបចំនៅថ្ងៃខែឆ្នាំណា? មានគោលបំណងអ្វី?

ចម្លើយ៖ ចលនាមិនចូលបក្សសម្ព័ន្ធបង្កើតឡើងនៅក្នុងសន្និសីទក្រុងបានឌុង ប្រទេសឥណ្ឌូនេស៊ី។ រៀបចំនៅនៅថ្ងៃទី១៨-២៤ ខែមេសា ឆ្នាំ១៩៥៥។ មេដឹកនាំប្រទេសនិងប្រតិភូមកពីប្រទេសចំនួន ២៩ប្រទេស តំណាងឱ្យប្រជាជនជាងពាក់កណ្តាលនៃប្រជាជនពិភពលោកចូលរួមក្នុងសន្និសីទនេះ។

+គោលបំណងនៃចលនានេះ:គឺ អំពាវនាវប្រទេសកំពុងអភិវឌ្ឍជាពិសេសប្រទេសទើបតែទទួលបានឯករាជ្យថ្មីៗមិនឱ្យចូលរួមក្នុងកិច្ចព្រមព្រៀងការពាររួមណាមួយ ដើម្បីបម្រើផលប្រយោជន៍ប្រទេសមហាអំណាចណាមួយឡើយ។

២៦. តើការប្រកាន់ជំហរអព្យាក្រឹតរបស់សម្តេចនរោត្តម សីហនុមានទិសដៅដូចម្តេច?

ចម្លើយ៖ គោលដៅគឺបង្រួបបង្រួមជាតិ បញ្ចៀសកម្ពុជាពីសង្គ្រាមស៊ីវិល និងការរីករាលដាលនៃសង្គ្រាមវៀតណាមលើទឹកដីកម្ពុជា។

២៧. តើសម្តេចនរោត្តម សីហនុ បានប្រកាសឈប់ទទួលយកជំនួយពីសហរដ្ឋអាមេរិកនៅឆ្នាំណា? មូលហេតុអ្វី?

ចម្លើយ៖ នៅឆ្នាំ១៩៦៣។

+មូលហេតុនោះគឺ សម្តេចនរោត្តម សីហនុ ចង់រក្សាជំហរអព្យាក្រឹតតាមរយៈការបដិសេធមិនចូលជាសមាជិកអង្គការសេអាតូ។ ការបដិសេធនេះបានធ្វើឱ្យសហរដ្ឋអាមេរិក ថៃ និងវៀតណាមខាងត្បូងដាក់សម្ពាធលើកម្ពុជា ដោយការគាំទ្រពួកស្តាំនិយមនៅកម្ពុជានិងនៅតាមបណ្តាព្រំដែនក្នុងការប្រឆាំងនឹងរដ្ឋាភិបាលនៃសង្គមរាស្ត្រនិយម។ មូលហេតុនេះទើបបានជាកម្ពុជាប្រកាសឈប់ទទួលជំនួយពីសហរដ្ឋអាមេរិក។

២៨. តើអង្គការសេអាតូ ជាអ្វី?

ចម្លើយ៖ អង្គការសេអាតូ (SEATO) គឺជាអង្គការកតិកាអាស៊ីអាគ្នេយ៍បានបង្កើតឡើងនៅថ្ងៃទី៨ ខែកញ្ញា ឆ្នាំ១៩៥៤ និងបានបញ្ចប់ទៅវិញនៅពាក់កណ្តាលឆ្នាំ១៩៧៧។ មានទីស្នាក់ការនៅទីក្រុងបាងកក។

២៩. តើអង្គការសេអាតូ មានប្រទេសណាខ្លះជាសមាជិក? បង្កើតឡើងក្នុងគោលបំណងអ្វី?

ចម្លើយ៖ អង្គការសេអាតូ មានសមាជិកសំខាន់ៗដូចជាសហរដ្ឋអាមេរិក អង់គ្លេស បារាំង អូស្ត្រាលី ញូសេសឡិន ប៉ាគីស្ថាន ថៃ និងហ្វីលីពីន ជាដើម។

+ការបង្កើតអង្គការសេអាតូ មានគោលបំណងទប់ស្កាត់ការរីករាលដាលរបស់លទ្ធិកុម្មុយនិស្តនៅតំបន់អាស៊ីអាគ្នេយ៍។

៣០. តើសម្តេចនរោត្តម សីហនុ បានបែងចែកចលនានយោបាយនៅសម័យសង្គមរាស្ត្រនិយមជាប៉ុន្មានពណ៌? អ្វីខ្លះ?

ចម្លើយ៖ សម្តេចនរោត្តម សីហនុ បានបែងចែកជា៣ពណ៌គឺ៖

-ពួកឆ្វេងនិយម ឬកុម្មុយនិស្ត ហៅថា**ខ្មែរក្រហម។**

-ពួកស្តាំនិយម ឬសាធារណរដ្ឋ ហៅថា**ខ្មែរខៀវ។**

-ពួកកណ្តាល ឬរាជានិយម ហៅថា**ខ្មែរស**។

សំណួរ-ចម្លើយ ស្តីពីសម័យសាធារណរដ្ឋខ្មែរ

ប្រធាន

១. តើសម័យសាធារណរដ្ឋ ចាប់ផ្តើមពីឆ្នាំណាដល់ឆ្នាំណា?

ចម្លើយ៖ ឆ្នាំ១៩៧០ ដល់ ១៩៧៥។

២. តើរដ្ឋប្រហារទម្លាក់នរោត្តម សីហនុ ប្រព្រឹត្តទៅនៅថ្ងៃខែឆ្នាំណា? ដោយនរណា?

ចម្លើយ៖ ថ្ងៃទី១៨ ខែមីនា ឆ្នាំ១៩៧០។ ដោយលោកសេនាប្រមុខ លន់ នល់។

៣. តើមូលហេតុអ្វីដែលធ្វើឱ្យកម្ពុជាធ្លាក់ក្នុងភ្លើងសង្គ្រាមក្នុងឆ្នាំ ១៩៧០?

ចម្លើយ៖ មូលហេតុដែលធ្វើឱ្យកម្ពុជាធ្លាក់ក្នុងភ្លើងសង្គ្រាមក្នុងឆ្នាំ ១៩៧០គឺ៖

-ឥទ្ធិពលនៃសង្គ្រាមត្រជាក់ គឺការប្រជែងឥទ្ធិពលគ្នារវាងអាមេរិកនិង សូវៀត

-ការអនុវត្តនយោបាយអព្យាក្រឹតរបស់សម្តេច នរោត្តម សីហនុ មិន បានសម្រេចគោលដៅ

-រដ្ឋប្រហារទម្លាក់សម្តេចនរោត្តមសីហនុ នៅថ្ងៃទី១៨ ខែមីនា ឆ្នាំ ១៩៧០ ដោយសេនាប្រមុខលន់ នល់

-អំពើពុករលួយ បក្សពួកនិយម កុប្បកម្មពេញផ្ទៃប្រទេស
-ការជ្រៀតជ្រែករបស់វៀតណាម ចិន និងសហរដ្ឋអាមេរិក នៅក្នុងនយោបាយខ្មែរ
-ការបង្កើតរណសិរ្សរួបរួមជាតិកម្ពុជារបស់ព្រះបាទនរោត្តម សីហនុ ឆ្នាំ១៩៧០
-ការគាំទ្ររបស់សហរដ្ឋអាមេរិកចំពោះរាជរដ្ឋាភិបាលសាធារណរដ្ឋខ្មែរ របស់លោកសេនាប្រមុខ លន់ នល់
-ការគាំទ្ររបស់ចិនចំពោះរណសិរ្សរបស់សម្តេចនរោត្តម សីហនុ និងក្រុមខ្មែរក្រហម។

៤. ចូររៀបរាប់ពីមេដឹកនាំសំខាន់ៗនៃរបបសាធារណរដ្ឋខ្មែរ។

ចម្លើយ៖ មេដឹកនាំសំខាន់ៗនៅសម័យសាធារណរដ្ឋខ្មែរមានដូចជា៖
-លន់ នល់
-សិរីមតៈ
-សឺងង៉ុក ថាញ់
-ចេង ហេង
-ហង្ស ធុនហាក់
-អ៊ិន តាំ
-ឡុង បូរ៉ែត។

៥. ចូរអធិប្បាយពីសម័យសាធារណរដ្ឋខ្មែរ។

ចម្លើយ៖ អធិប្បាយពីសម័យសាធារណរដ្ឋខ្មែរគឺ៖

+ការលេចឡើងនៃរបបសាធារណរដ្ឋខ្មែរ

-ថ្ងៃទី១៨ ខែមីនា ឆ្នាំ១៩៧០ រដ្ឋប្រហារផ្ទុះឡើងយ៉ាងស្ងៀមស្ងាត់ ដឹកនាំដោយលោក លន់ នល់ និងសិរីមតៈ
-គេរក្សាទុកសភាជាឧបករណ៍ពង្រឹងអំណាច ដោយថ្ងៃទី១៨ ខែមីនា ឆ្នាំ១៩៧០ ដដែល គេបានកោះប្រជុំសភាទាំងពីរ ដើម្បីបោះឆ្នោតអនុម័ត
-ប្រកាសជាសាធារណរដ្ឋ នៅថ្ងៃទី៩ ខែតុលា ឆ្នាំ១៩៧០ ដែលតែងតាំងលោក លន់ នល់ ជាប្រធានាធិបតី
-បង្កើតរដ្ឋធម្មនុញ្ញថ្មីនៅឆ្នាំ១៩៧២
-បោះឆ្នោតបង្កើតអ្នកតំណាងប្រជាពលរដ្ឋ និងព្រឹទ្ធសភា នៅឆ្នាំ ១៩៧២។

+សង្គមសម័យសាធារណរដ្ឋខ្មែរ

-ចាប់ពីឆ្នាំ១៩៦៩ ទឹកដីកម្ពុជាតែងរងការទម្លាក់គ្រាប់បែកពីសំណាក់សហរដ្ឋអាមេរិកនិងកាន់តែធ្ងន់ធ្ងរនៅឆ្នាំ១៩៧៣
-ឆ្នាំ១៩៧០ ពួកខ្មែរក្រហមបានបង្កអសន្តិសុខ និងកាន់កាប់តំបន់ជនបទ និងទីប្រជុំជនតូចៗនៅពាសពេញផ្ទៃប្រទេស
-ចាប់ពីឆ្នាំ១៩៧២ ពួកខ្មែរក្រហមបានចាប់ផ្តើមផ្តោតទៅលើទីប្រជុំជនធំៗ ដោយបាញ់ផ្លោងចូលភ្នំពេញ និងកម្ទេចស្ពានជ្រោយចង្វារ
-ការទម្លាក់គ្រាប់បែក ការបាញ់ផ្លោង ការបាញ់រះ ការបាញ់ផ្តក់រាងភាគីជម្លោះកម្ពុជាបានធ្វើឱ្យប្រជាជននាំគ្នាភៀសខ្លួនមករស់នៅទីរួមខេត្តនិងទីក្រុងភ្នំពេញ

-ក្នុងអំឡុងសង្គ្រាម៥ឆ្នាំ ក្រុងភ្នំពេញដូចជាបន្ទាយមួយដែលត្រូវបានខ្មាំងឡោមព័ន្ធនិងបានជួបនូវកំណើនប្រជាជនក្នុងទីក្រុង ព្រោះប្រជាជន១/៣ ភៀសខ្លួនមកកាន់ទីក្រុង ប្រជាជនរងទុក្ខលំបាក វេទនា និងកំសត់ ព្រោះខ្វះស្បៀង ម្ហូបអាហារឡើងថ្លៃហួសប្រមាណ
-អ្នកស្រែចម្ការដែលឃ្លាតពីភូមិស្រុកបាត់បង់មុខរបរ គ្មានការងារធ្វើ ព្រាត់ប្រាស់គ្រួសារ
-សង្គ្រាមបានបន្សល់ទុកនូវស្ត្រីមេម៉ាយ ក្មេងកំព្រា អ្នករបួស ជនពិការច្រើននាក់។
-ក្រុងភ្នំពេញដែលធ្លាប់តែធើតធាយ នៅតំបន់អាស៊ីអាគ្នេយ៍បានក្លាយទៅជាទីប្រជុំជនដែលមានប្រជាជនជាងពីរលាននាក់រស់នៅយ៉ាងតោកយ៉ាកបំផុត។

+ស្ថានភាពសេដ្ឋកិច្ចសម័យសាធារណរដ្ឋខ្មែរ

-ជនភៀសខ្លួនគ្មានការងារធ្វើ និងជួបប្រទះនូវកង្វះស្បៀងអាហារប្រចាំថ្ងៃ
-អតិផរណាប្រាក់រៀលចេះតែបន្ត
-តម្លៃទំនិញចេះតែឡើងថ្លៃហួសកម្រិត
-ដើម្បីផ្គត់ផ្គង់ទីក្រុងភ្នំពេញ រដ្ឋាភិបាលសាធារណរដ្ឋខ្មែរពឹងផ្អែកលើស្បៀងមួយចំនួន ដែលរដ្ឋាភិបាលអាមេរិកផ្តល់ឱ្យដោយដឹកតាមកងនាវាតាមដងទន្លេមេគង្គ
-នៅខែមករា ឆ្នាំ១៩៧៥ ខ្មែរក្រហមបានកាត់ផ្តាច់ស្បៀងដែលឡើងតាមដងទន្លេ ដូច្នេះគឺនៅសល់តែផ្លូវអាកាសប៉ុណ្ណោះ។

+សង្គ្រាមស៊ីវិលឆ្នាំ១៩៧០-១៩៧៥

-សេដ្ឋកិច្ចជាតិត្រូវបានរាំងស្ទះដោយសារសង្គ្រាម

-ទីក្រុងនិងទីប្រជុំជនមួយចំនួនធំ ត្រូវបានកាត់ផ្តាច់ពីគ្នាដោយកម្លាំងខ្មែរក្រហម

-រដ្ឋាភិបាលលន់ នល់គ្រប់គ្រងបានតែទីក្រុង និងទីប្រជុំជនមួយចំនួន

-ឥស្សរជននយោបាយជាច្រើនរូបនៅភ្នំពេញបង្កើតបក្សពួក និងប្រមូលទ្រព្យសម្បត្តិ ភ្លេចប្រយោជន៍ជាតិ ក្នុងនោះក៏មានលោក លន់ ណុន ប្អូនប្រុស លន់ នល់ ផងដែរ

-នាយទាហានខ្លះបានលក់យុទ្ធោបករណ៍ឱ្យទៅពួកខ្មែរក្រហម

-នៅដើមឆ្នាំ១៩៧៣ ពួកខ្មែរក្រហមបានពិសោធ ធ្វើកម្មវិធីសហករណ៍នីយកម្ម និងអនុវត្ត ដោយបង្ខំក្នុងតំបន់មួយចំនួនដែលពួកគេបានគ្រប់គ្រង ស្របពេលដែលសហរដ្ឋអាមេរិកទម្លាក់គ្រាប់បែក។

+ការដួលរលំរបបសាធារណរដ្ឋខ្មែរ

+នយោបាយ

-អស្ថិរភាពដោយសារសង្គ្រាម

-អាមេរិកដកខ្លួនពីឥណ្ឌូចិន

-ខ្មែរក្រហម វាយចូលក្រុងភ្នំពេញ

+សេដ្ឋកិច្ច

-អតិផរណាប្រាក់រៀល

-ដីស្រែចម្ការត្រូវបោះបង់ ខ្វះស្បៀង

-ហេដ្ឋារចនាសម្ព័ន្ធសេដ្ឋកិច្ចត្រូវបំផ្លាញ

+សង្គម

-អំពើពុករលួយ

-បក្សពួកនិយម

-ពោរពេញដោយភាពអាប់អួរ

+ការខូចខាតដោយសារសង្គ្រាមនិងផលវិបាក

-សង្គ្រាមបានសម្លាប់ប្រជាជនកម្ពុជាជាងមួយលាននាក់

-ប្រជាជនភៀសខ្លួនពីជនបទចូលទីក្រុង រស់ដោយខ្វះស្បៀង ជួបភាពអនាធិបតេយ្យ អំពើហិង្សា ចោរកម្ម

-អំពើសូកប៉ាន់រីកដុះដាលដល់វិស័យសិក្សាធិការ

-បំផ្លាញធនធានមនុស្ស គ្រឹះស្ថានសិក្សា វត្តអារាម

-ដីស្រែចម្ការត្រូវបានបោះបង់ចោល ព្រមទាំងក្លាយទៅជាចម្ការមីន និងរណ្តៅគ្រាប់B52

-រោងចក្រឧស្សាហកម្ម៧៥ភាគរយ ត្រូវបានបំផ្លិចបំផ្លាញ

-ចម្ការកៅស៊ូត្រូវបាត់បង់

-ផ្លូវថ្នល់ និងស្ពានពី៧០ភាគរយទៅ៨០ភាគរយត្រូវអន្តរាយ

-អស្ថិរភាពនយោបាយដោយសារសង្គ្រាមស៊ីវិល បានបង្កនូវវិនាសកម្មលើគ្រប់វិស័យដែលជាឱកាសឱ្យខ្មែរក្រហមឡើងកាន់អំណាចនៅឆ្នាំ១៩៧៥

-ដូច្នេះសង្គ្រាមបានបង្កនូវមហន្តរាយ និងបំផ្លាញហេដ្ឋារចនាសម្ព័ន្ធគ្រឹះសេដ្ឋកិច្ច សង្គម និងនាំកម្ពុជាទៅរកបបប្រល័យពូជសាសន៍។

៦. ចូររៀបរាប់ពីរដ្ឋប្រហារ១៨ មីនា ១៩៧០។

ចម្លើយ៖ រដ្ឋប្រហារ១៨ មីនា ១៩៧០គឺ

-ថ្ងៃទី១៤ ខែសីហា ឆ្នាំ១៩៦៩ សម្តេចនរោត្តម សីហនុ ផ្តល់អំណាចឱ្យលោក លន់ នល់ និងអ្នកអង្គម្ចាស់ សិរីមតៈ ក្នុងការដឹកនាំរដ្ឋាភិបាលដែលមានឈ្មោះថា រដ្ឋាភិបាលស្រោចស្រង់ជាតិ។

-នៅថ្ងៃទី២៣ ខែតុលា ឆ្នាំ១៩៦៩ ព្រះអង្គម្ចាស់សិរីមតៈ បានកាន់តំណែងជំនួសលោកលន់ នល់។ ក្នុងកំឡុងជាងពីរខែ បន្ទាប់មកទៀត អ្នកអង្គម្ចាស់ សិរីមតៈ និងសហសេវិក បានខិតខំរៀបចំសណ្តាប់ធ្នាប់សាធារណៈក្នុងប្រទេសដូចជា ការបិទទ្វារកាស៊ីណូ បង្កើតសេវាសាធារណៈ និងឯកជន ធ្វើឯកជនូបនីយកម្មធនាគារ

-ថ្ងៃទី៨-៩ ខែមីនា ឆ្នាំ១៩៧០ មានបាតុកម្មប្រឆាំងវៀតណាមខាងជើង និងវៀតកុងដែលបំផុសដោយកងទ័ពនៅខេត្តស្វាយរៀង។

-ថ្ងៃទី១១-១៦ ខែមីនា ឆ្នាំ១៩៧០ មានកុប្បកម្មវាយកម្ទេច បំផ្លិចបំផ្លាញអគារស្ថានទូតវៀតណាមខាងជើង និងការិយាល័យរណសិរ្សសេរីការវៀតណាមខាងត្បូងនៅភ្នំពេញ។

-ថ្ងៃទី១៨ ខែមីនា ឆ្នាំ១៩៧០ ព្រឹត្តិការណ៍រដ្ឋប្រហារផ្ទុះឡើងយ៉ាងស្ងៀមស្ងាត់ដឹកនាំដោយលោក លន់ នល់ និងសិរីមតៈ

-គេក្សាទុកសភាជាឧបករណ៍ពង្រឹងអំណាច ដោយថ្ងៃទី១៨ ខែមីនា ឆ្នាំ១៩៧០ដដែល គេកោះប្រជុំសភាទាំងពីរ ដើម្បីបោះឆ្នោតអនុម័តក្នុងការប្រជុំនោះសំឡេង៨៦ក្នុងចំណោម៨៩ គាំទ្រឱ្យដកសេចក្តីទុកចិត្ត និងដកសម្តេច នរោត្តម សីហនុចេញពីប្រមុខរដ្ឋ តែងតាំង

លោក ចេង ហេង ជាប្រធានរដ្ឋសភា មកជាប្រមុខរដ្ឋស្តីទីរហូតមានការបោះឆ្នោតជ្រើសរើសប្រមុខរដ្ឋថ្មី រីឯលោក លន់ នល់ បន្តជានាយករដ្ឋមន្ត្រីដដែល ឯអ្នកអង្គម្ចាស់ សិរីមតៈ ជាជំនួយការ។

ដូច្នេះមុនថ្ងៃរដ្ឋប្រហារ សម្តេចនរោត្តម សីហនុ នៅទីក្រុងប៉ារីសប្រទេសបារាំង។ ហើយក្នុងអំឡុងពេលរដ្ឋប្រហារគឺព្រះអង្គនៅបរទេស។ បន្ទាប់ពីសម្តេចនរោត្តម សីហនុ ដឹងជ្រាបពីរដ្ឋប្រហារទម្លាក់ព្រះអង្គពីប្រមុខរដ្ឋរួចមក សម្តេចនរោត្តម សីហនុ បានយាងទៅទីក្រុងប៉េកាំងនៃប្រទេសចិន បន្ទាប់ពីទស្សនកិច្ចរយៈពេលខ្លីនៅសហភាពសូវៀត។

៧. តើរបបសាធារណរដ្ឋខ្មែរ ពឹងផ្អែកលើជំនួយពីប្រទេសណា?

ចម្លើយ៖របបសាធារណរដ្ឋខ្មែរពឹងផ្អែកលើជំនួយពីសហរដ្ឋអាមេរិក។

៨. តើរបបសាធារណរដ្ឋខ្មែរ ជារបបដូចម្តេច?

ចម្លើយ៖ របបសាធារណរដ្ឋខ្មែរ ជារបបមួយដែលដឹកនាំដោយអ្នកនយោបាយអភិរក្សនិយម និងឱកាសនិយម និងពឹងផ្អែកទាំងស្រុងលើសហរដ្ឋអាមេរិក។

៩. តើសហរដ្ឋអាមេរិក បានទម្លាក់គ្រាប់បែកនៅកម្ពុជា ក្នុងអំឡុងសង្គ្រាមជាមួយវៀតណាម នៅឆ្នាំណា?

ចម្លើយ៖ ចាប់ពីឆ្នាំ១៩៦៩ ដល់ ១៩៧៣។

១០. តើសេនាប្រមុខលន់ នល់ បានចាកចេញពីកម្ពុជាទៅអាមេរិក ក្រោយពេលខ្មែរក្រហមវាយចូលក្រុងភ្នំពេញនៅថ្ងៃខែឆ្នាំណា?

ចម្លើយ៖ ១ មេសា ១៩៧៥

១១. តើបាវចនាជាតិនៅសម័យសាធារណរដ្ឋខ្មែរ ជាអ្វី?

ចម្លើយ៖ សេរីភាព សមភាព ភាតរភាព វឌ្ឍនភាព និងសុភមង្គល។

១២. ចូររៀបរាប់ពីឈ្មោះប្រធានាធិបតី នាសម័យសាធារណរដ្ឋខ្មែរ។

ចម្លើយ៖ ឈ្មោះប្រធានាធិបតី គឺ

-ចេង ហេង ពីឆ្នាំ១៩៧០-១៩៧២

-លន់ នល់ ពីឆ្នាំ១៩៧២-១៩៧៥

-សូខាំ ខូយ (បណ្តោះអាសន្ន) ១៩៧៥

១៣. ចូររៀបរាប់ពីនាយករដ្ឋមន្ត្រី សម័យសាធារណរដ្ឋខ្មែរ។

ចម្លើយ៖ នាយករដ្ឋមន្ត្រី សម័យសាធារណរដ្ឋខ្មែរមានដូចជា:

- លន់ នល់ ពីឆ្នាំ១៩៧០ -១៩៧១
- ស៊ីសុវត្ថិ សិរីមតៈ ពីឆ្នាំ១៩៧១ -១៩៧២
- សឺង ង៉ុកថាញ់ ឆ្នាំ១៩៧២
- ហង្ស ធុនហាក់ ពីឆ្នាំ១៩៧២ -១៩៧៣
- អ៊ិន តាំ ឆ្នាំ១៩៧៣
- ឡុង បូរ៉ែត ពីឆ្នាំ១៩៧៣ - ១៩៧៥

១៤. តើរបបសាធារណរដ្ឋខ្មែរ ត្រូវបានដួលរលំនៅថ្ងៃខែឆ្នាំណា?

ចម្លើយ៖ ១៧ មេសា ឆ្នាំ១៩៧៥ ដោយពួកខ្មែរក្រហម។

១៥.តើរដ្ឋាភិបាលសហរដ្ឋអាមេរិក និងវៀតណាមខាងជើងចុះហត្ថលេខាព្រមព្រៀង ឡាសែលសាំងគ្លូ នៅថ្ងៃទីខែឆ្នាំណា ?

ចម្លើយ៖ រដ្ឋាភិបាលសហរដ្ឋអាមេរិក និងវៀតណាមខាងជើងចុះហត្ថលេខាព្រមព្រៀង ឡាសែលសាំងគ្លូ នៅថ្ងៃទី ២៩ ខែមករា ឆ្នាំ ១៩៧៣ ។

១៦. ហេតុអ្វីបានជានៅឆ្នាំ១៩៧៣កងកម្លាំងអាកាសចរណ៍ បេ ៥២ របស់អាមេរិកទម្លាក់គ្រាប់បែបយ៉ាងខ្លាំងមកលើទឹកដីប្រទេសកម្ពុជា?

ចម្លើយ៖ បានជានៅឆ្នាំ១៩៧៣កងកម្លាំងអាកាសចរណ៍ បេ៥២ របស់អាមេរិកទម្លាក់គ្រាប់បែបយ៉ាងខ្លាំងកលើទឹកដីប្រទេសកម្ពុជា ព្រោះ

-ចងបណ្តេញកងទ័ពវៀតណាមខាងជើងចេញពីទឹកដីខ្មែរ ។

-អាមេរិកខ្លាចប្រទេសកម្ពុជាធ្លាក់ក្នុងរបបកុម្មុនីស្តនិងជាជម្រកសម្រាប់កងទ័ពរបស់វៀតកុង (វៀតណាមខាងជើង)វាយប្រទេសវៀតណាមខាងត្បូង។

-អាមេរិកខ្លាចដកខ្លួនមិនរួចពីសង្គ្រាមនៅវៀតណាម ។

១៧. តើនៅថ្ងៃទី២០-២១ ខែមេសា ឆ្នាំ១៩៧២ មានប្រជាជនប្រហែលជាប៉ុន្មាននាក់នៅទួលគោក ដែលបានទទួលមរណភាពដោយសារគ្រាប់ផ្លោងរបស់ពួកកុម្មុយនីស្ត ?

ចម្លើយ៖ នៅថ្ងៃទី២០-២១ ខែមេសា ឆ្នាំ១៩៧២ មានប្រជាជនប្រហែល៣០០នាក់នៅទួលគោកដែលបានទទួលមរណភាពដោយសារគ្រាប់ផ្លោងរបស់ពួកកុម្មុយនីស្ត ។

១៨. តើពួកខ្មែរក្រហម បានដាក់គ្រាប់កម្ទេចស្ពានជ្រោយចង្វាត្រូវនៅឆ្នាំណា ?

ចម្លើយ៖ ពួកខ្មែរក្រហមបានដាក់គ្រាប់កម្ទេចស្ពានជ្រោយចង្វាត្រូវនៅឆ្នាំ ១៩៧២ ។

១៩. តើសង្គ្រាមឥណ្ឌូចិនមានប៉ុន្មានលើក? ចូររៀបរាប់។

ចម្លើយ៖ សង្គ្រាមឥណ្ឌូចិនមាន៣លើកគឺ

-លើកទី១៖ ពីឆ្នាំ១៩៤៦ ដល់ ១៩៥៤ គឺជាសង្គ្រាមដណ្តើមឯករាជ្យរបស់ប្រទេសទាំងបីគឺកម្ពុជា វៀតណាម និងឡាវ ដែលស្ថិតនៅក្រោមការគ្រប់គ្រងរបស់មហាអំណាចអាណានិគមបារាំង ហើយសង្គ្រាមនេះបញ្ចប់ដោយសន្និសីទអន្តរជាតិក្រុងសឺណែវឆ្នាំ១៩៥៤។

-លើកទី២៖ ពីឆ្នាំ១៩៥៥ ដល់ ១៩៧៥ គឺជាសង្គ្រាមប្រឆាំងវត្តមានកងទ័ពសហរដ្ឋអាមេរិកក្នុងតំបន់ឥណ្ឌូចិនពីសំណាក់ប្រជាជនដែលមាននិន្នាការកុម្មុយនិស្តនិងនិន្នាការអព្យាក្រឹតនិយម។ សង្គ្រាមនេះបានបញ្ចប់កំឡុងពេលពួកកុម្មុយនិស្តបានចូលកាន់កាប់តំបន់ឥណ្ឌូចិនដែលពួកខ្មែរក្រហមចូលកាន់កាប់ប្រទេសកម្ពុជា និងវៀតណាមកុម្មុយនិស្តចូលកាន់កាប់វៀតណាមខាងត្បូង។

-លើកទី៣៖ ពីឆ្នាំ១៩៧៩ ដល់ ១៩៩១ គឺពេលដែលកងទ័ពវៀតណាមចូលផ្តួលរំលំរបបកម្ពុជាប្រជាធិបតេយ្យ ឬខ្មែរក្រហមនៅកម្ពុជានិងការវាយប្រហារដោយយោធាចិនទៅលើប្រទេសវៀតណាមនាដើមឆ្នាំ១៩៧៩។

២០. ចូររៀបរាប់ពីព្រឹត្តិការណ៍ នាថ្ងៃទី១១ ខែមីនា ឆ្នាំ១៩៧០។

ចម្លើយ៖ ថ្ងៃទី១១ ខែមីនា ឆ្នាំ១៩៧០ គឺជាព្រឹត្តិការណ៍មួយដែលប្រជាជនកម្ពុជារាប់ពាន់នាក់បានធ្វើបាតុកម្មនៅមុខស្ថានទូតវៀតកុងនិងវៀតណាមខាងជើងក្នុងទីក្រុងភ្នំពេញ ដើម្បីទាមទារឱ្យដកកងទ័ពនិងមូលដ្ឋានយោធារបស់ពួកវៀតណាមចេញពីទឹកដីកម្ពុជា។ ក្រោយមក បាតុករបានសម្រុកចូលក្នុងស្ថានទូតនិងបំផ្លាញឯកសារនានានៅក្នុងស្ថានទូត។ បន្ទាប់មកបាតុកម្មបានធ្វើឡើងជាបន្តបន្ទាប់នៅមុខរដ្ឋសភាជាតិ ហើយបាតុករក៏ប្រឆាំងនឹងសម្តេចនរោត្តមសីហនុ ដែលពេលនោះព្រះអង្គនៅជាព្រះប្រមុខរដ្ឋ ដោយបាតុករចោទព្រះអង្គថា បានអនុញ្ញាតឱ្យពួកវៀតកុងនិងវៀតណាមខាងជើងមកតាំងមូលដ្ឋានទ័ពនៅកម្ពុជា។

២១. ចូររៀបរាប់ពីព្រឹត្តិការណ៍ថ្ងៃទី៣០ មេសា ឆ្នាំ១៩៧០។

ចម្លើយ៖ នៅថ្ងៃទី៣០ ខែមេសា ឆ្នាំ១៩៧០ សហរដ្ឋអាមេរិកបានចាប់ផ្តើមទម្លាក់គ្រាប់បែកមកលើកម្ពុជាជាថ្មី បន្ទាប់ពីទម្លាក់សម្តេចនរោត្តមសីហនុចេញពីប្រមុខរដ្ឋ។

២២. តើរបបសាធារណរដ្ឋខ្មែរឬក្រុមគាំទ្ររបបនេះ បានបង្កើតបក្សនយោបាយប៉ុន្មាន? អ្វីខ្លះ?

ចម្លើយ៖ បង្កើតបក្សនយោបាយចំនួន៣គឺ៖

-បក្សសាធារណរដ្ឋ(ដឹកនាំដោយទ្រង់សិរីមតៈ)

-បក្សប្រជាធិបតេយ្យ (ដឹកនាំដោយលោក អ៊ិន តាំ)

-បក្សសង្គមសាធារណរដ្ឋ (ដឹកនាំដោយសេនាប្រមុខ លន់ នល់)។

២៣. ចូររៀបរាប់សង្ខេបពីព្រឹត្តិការណ៍ដើមឆ្នាំ១៩៧០រហូតដល់ធ្វើរដ្ឋប្រហារទម្លាក់នរោត្តម សីហនុ។

ចម្លើយ៖ សង្ខេបពីព្រឹត្តិការណ៍ដើមឆ្នាំ១៩៧០រហូតដល់ធ្វើរដ្ឋប្រហារទម្លាក់នរោត្តម សីហនុគឺ

-ថ្ងៃទី៦ មករា ១៩៧០ សម្តេចនរោត្តម សីហនុ យាងទៅបារាំង។

-ថ្ងៃទី១១ មីនា ១៩៧០ បាតុកម្មប្រជាជនខេត្តស្វាយរៀងប្រឆាំងនឹងវត្តមានកងទ័ពវៀតកុងនៅលើទឹកដីកម្ពុជា។

-ថ្ងៃទី២៧ កុម្ភៈ ១៩៧០ នៅទីក្រុងប៉ារីសសម្តេចនរោត្តម សីហនុ ប្រាប់ថាព្រះអង្គមានគោលបំណងយាងទៅទីក្រុងម៉ូស្គូនិងប្រទេសចិន ដើម្បីសុំឱ្យវៀតណាមកុម្មុយនិស្តដកទ័ពចេញពីកម្ពុជា។

-ថ្ងៃទី៨-៩ មីនា ១៩៧០ បាតុកម្មប្រឆាំងវៀតណាមនៅខេត្តស្វាយរៀង។

-ថ្ងៃទី១១-១៦ មីនា ១៩៧០ បាតុកម្មប្រឆាំងនឹងវៀតណាមកុម្មុយនិស្តនៅទីក្រុងភ្នំពេញ។ ស្ថានទូតវៀតណាមខាងជើងនិងរដ្ឋាភិបាលបដិវត្តបណ្តោះអាសន្នត្រូវបានបាតុករខ្មែរវាយកម្ទេច។

-ថ្ងៃទី១២ មីនា ១៩៧០ សម្តេចនរោត្តម សីហនុ បានផ្ញើទូរលេខមួយមកភ្នំពេញសម្តែងការមិនយល់ស្របនឹងបាតុកម្មនោះ។ រដ្ឋាភិបាល លន់ នល់ ស្នើសុំឱ្យទីក្រុងហាណូយដកទ័ពចេញពីកម្ពុជាយ៉ាងយូរបំផុតនៅត្រឹមថ្ងៃ១៥ ខែមីនា ១៩៧០។

-ថ្ងៃទី១៣ មីនា ១៩៧០ សម្តេចនរោត្តម សីហនុ ធ្វើដំណើរចេញពីបារាំងទៅទីក្រុងម៉ូស្គូនៃសហភាពសូវៀត មុនការចេញដំណើរនេះ

ព្រះអង្គពុំព្រមទទួលគណប្រតិភូនៃរដ្ឋាភិបាលលន់ នល់ ដឹកនាំដោយព្រះអង្គម្ចាស់ នរោត្តម កន្តុល នោះទេ។

-ថ្ងៃទី១៥ មីនា ១៩៧០ លន់ នល់ សុំដំនួយពីកងទ័ពវៀតណាមខាងត្បូង។

-ថ្ងៃទី១៦ មីនា ១៩៧០ សម្តេចនរោត្តម សីហនុ សម្រេចមិនវិលត្រឡប់មកកម្ពុជាវិញ បន្ទាប់ពីលោក អ៊ុំ ម៉ាណូរីន មិនបានសម្រេចផែនការដកឧត្តមសេនីយ៍ លន់ នល់ ចេញពីរដ្ឋាភិបាល។

-ថ្ងៃទី១៧ មីនា ១៩៧០ លោកវរសេនីយ៍ឯក អ៊ុំ ម៉ាណូរីន ត្រូវរដ្ឋាភិបាលលន់ នល់ ចាប់បង្ខំឱ្យលាលែងពីតំណែង។

-ថ្ងៃទី១៨ មីនា ១៩៧០ សភាទាំងពីរបានទម្លាក់នរោត្តម សីហនុ ចេញពីតំណែងប្រមុខរដ្ឋនៃប្រទេសកម្ពុជា ហើយចាត់តាំងលោក ចេង ហេង ជាប្រមុខរដ្ឋជំនួសវិញ។

២៤. ចូររៀបរាប់សង្ខេបពីព្រឹត្តិការណ៍នៅក្នុងឆ្នាំ១៩៧១។

ចម្លើយ៖ រៀបរាប់សង្ខេបពីព្រឹត្តិការណ៍នៅក្នុងឆ្នាំ១៩៧១គឺ

-ថ្ងៃទី១៣ កុម្ភៈ ១៩៧១ ឧត្តមសេនីយ៍លន់ នល់ ដែលមានជំងឺស្លាប់មួយចំហៀងខ្លួន ចេញដំណើរទៅព្យាបាលរោគនៅរដ្ឋហាវ៉ៃ សហរដ្ឋអាមេរិក។

-ថ្ងៃទី២ មេសា ១៩៧១ ឧត្តមសេនីយ៍លន់ នល់ ត្រឡប់មកស្រុកខ្មែរវិញ។

-ថ្ងៃទី២១ មេសា ១៩៧១ រដ្ឋាភិបាលលន់ នល់ លាលែងពីតំណែង ហើយឧត្តមសេនីយ៍លន់ នល់ បានទទួលងារជាសេនាប្រមុខ។

-ថ្ងៃទី៣ ឧសភា ១៩៧១ រដ្ឋាភិបាលថ្មីរបស់លន់ នល់ ប៉ុន្តែអំណាចទាំងអស់ត្រូវប្រគល់ឱ្យអ្នកអង្គម្ចាស់សិរីមតៈ។
-ខែកក្កដា ១៩៧១ អង្គការខ្មែរក្រហមបានរៀបចំគណៈកម្មការមជ្ឈិមបក្សថ្មី។ ចាប់ពីពេលនោះមក ដែលបក្សកុម្មុយនិស្តកម្ពុជាដាក់ឈ្មោះតំបន់ដែលគេកាន់កាប់ជាលេខសម្គាល់តែម្តង។
-ថ្ងៃទី២០ សីហា ១៩៧១ ការចាប់ផ្តើមប្រតិបត្តិការសឹក«ចេនឡា» ទី២។
-ថ្ងៃទី៣០ សីហា ១៩៧១ មហាសន្និបាតទី៣ នៃ«បក្សកុម្មុយនិស្តកម្ពុជា»។ ពេលនោះហើយដែលបក្សកុម្មុយនិស្តកម្ពុជាបានកំណត់យកប្រទេសវៀតណាមជាសត្រូវទី១។
-ថ្ងៃទី១៦ តុលា ១៩៧១ ប្រមុខរដ្ឋនៃប្រទេសកម្ពុជាបានប្រែក្លាយរដ្ឋសភា ដែលតែងតាំងនៅឆ្នាំ១៩៦៦ឱ្យទៅជាសភាធម្មនុញ្ញតាមរយៈព្រះរាជក្រឹត្យមួយ។
-ថ្ងៃទី២០ តុលា ១៩៧១ ការប្រកាសដាក់ប្រទេសក្នុងភាពមានអាសន្នសារជាថ្មី។ ប្រទេសទាំងមូលត្រូវគ្រប់គ្រងដោយការចេញក្រឹត្យត្រង់ៗតែម្តង សេរីភាព ជាមូលដ្ឋានត្រូវបានកាត់បន្ថយ។
-ថ្ងៃទី៣ ធ្នូ ១៩៧១ ប្រតិបត្តិការសឹកចេនឡាទី២បានទទួលបរាជ័យទាំងស្រុង។

សំណួរ-ចម្លើយ ស្តីពីសម័យកម្ពុជាប្រជាធិបតេយ្យ ប្រចាន

១. តើសម័យកម្ពុជាប្រជាធិបតេយ្យ ចាប់ពីឆ្នាំណាដល់ឆ្នាំណា?

ចម្លើយ៖ ១៩៧៥ - ១៩៧៩។

២. តើគោលការណ៍របស់ពួកខ្មែរក្រហម មានអ្វីខ្លះ?

ចម្លើយ៖ គោលការណ៍របស់ពួកខ្មែរក្រហមគឺ៖

-ជម្លៀសប្រជាជនឱ្យចេញពីទីក្រុងទាំងអស់ ជាពិសេសពីទីក្រុងភ្នំពេញមកជនបទ

-លុបបំបាត់ទីផ្សារ

-លុបបំបាត់ការប្រើប្រាស់រូបិយប័ណ្ណ

-ផ្សឹកព្រះសង្ឃឱ្យមកធ្វើស្រែចម្ការនៅតំបន់មូលដ្ឋាន

-ប្រហារជីវិតមេដឹកនាំលន់ នល់

-បង្កើតសហករណ៍កម្រិតខ្ពស់

-បណ្តេញជនជាតិភាគតិចវៀតណាមឱ្យចេញពីទឹកដីកម្ពុជា

-បញ្ជូនទ័ពទៅតាមព្រំដែន ជាពិសេសព្រំប្រទល់វៀតណាម។

៣. ចូររៀបរាប់ពីឈ្មោះមេដឹកនាំសំខាន់ៗនៃរបបកម្ពុជាប្រជាធិបតេយ្យ។

ចម្លើយ៖ ឈ្មោះមេដឹកនាំសំខាន់ៗនៃរបបកម្ពុជាប្រជាធិបតេយ្យមានដូចជា ខៀវ សំផន នួន ជា អៀង សារី សុន សេន សោ កឹម វន វ៉ែត ឈិត ជឿន ជាដើម។

៤. តើរដ្ឋធម្មនុញ្ញនៃរបបកម្ពុជាប្រជាធិបតេយ្យ ប្រកាសដាក់ប្រើប្រាស់ជាផ្លូវការនៅថ្ងៃខែឆ្នាំណា?

ចម្លើយ៖ នៅថ្ងៃទី៥ ខែមករា ១៩៧៦។

៥. តើរដ្ឋធម្មនុញ្ញរបបកម្ពុជាប្រជាធិបតេយ្យ មានប៉ុន្មានជំពូក និងប៉ុន្មានមាត្រា?

ចម្លើយ៖ មាន១៦ជំពូក និង២១មាត្រា។

៦. តើចម្រៀងជាតិ សម័យកម្ពុជាប្រជាធិបតេយ្យមានឈ្មោះដូចម្តេច?

ចម្លើយ៖ ឈ្មោះថា«១៧មេសា មហាជោគជ័យ»។

៧. តើប៉ុល ពត មានតួនាទីជាអ្វី?

ចម្លើយ៖ ប៉ុល ពត ឬសាឡុត ស គឺមានតួនាទីជាលេខាបក្ស។

៨. តើប៉ុល ពត ដែលជាលេខាបក្សបានកំណត់មុខព្រួញដូចម្តេចក្នុងការដឹកនាំរបស់លោក?

ចម្លើយ៖ ប៉ុល ពត បានកំណត់មុខព្រួញជាមូលដ្ឋានចំនួន២គឺ

-វាយរំលំរបបមូលធននិយមនិងរបបសក្តិភូមិ

-ការប្រឈមមុខនឹងប្រទេសវៀតណាម។

៩. តើរដ្ឋបាលនៃកម្ពុជាប្រជាធិបតេយ្យ បែងចែកតំបន់រដ្ឋបាលជាប៉ុន្មានភូមិភាគ?

ចម្លើយ៖ បែងចែកជា៧ភូមិភាគ និងមាន៣២តំបន់ មានដូចជា៖
-ភូមិភាគបូព៌ា (ភូមិភាគ២០៣)
-ភូមិភាគនិរតី (ភូមិភាគ៤០៥)
-ភូមិភាគឧត្តរ (ភូមិភាគ៣០៣)
-ភូមិភាគពាយ័ព្យ (ភូមិភាគ៥៦០)
-ភូមិភាគបស្ចិម (ភូមិភាគ៤០១)
-ភូមិភាគឦសាន (ភូមិភាគ១០៨)។

១០. តើសហករណ៍ខ្មែរក្រហម មានន័យដូចម្តេច?

ចម្លើយ៖ សហករណ៍ខ្មែរក្រហម មានន័យថា ប្រជាជនរស់នៅរួម ធ្វើការរួម ហូបរួម និងចែករំលែកការកម្សាន្តជាសមូហភាព គ្មានការរស់នៅជាបុគ្គល និងគ្មានកម្មសិទ្ធិឯកជន។

១១. តើសហករណ៍បង្កើតឡើងដើម្បីអ្វី?

ចម្លើយ៖ បង្កើតក្នុងគោលបំណងដូចជា៖
-ពង្រឹងវណ្ណកម្មករ និងកសិករ
-ការលុបបំបាត់កម្មសិទ្ធិឯកជន
-របបទាំងឡាយដែលមិនមែនសង្គមនិយម។

១២. តើការរៀបចំសហករណ៍ មានប៉ុន្មានដំណាក់កាល?

ចម្លើយ៖ មាន៣ដំណាក់កាលគឺ៖
-១៩៧០ ដល់ ១៩៧៥ ខ្មែរក្រហមបានរៀបចំប្រជាជននៅតំបន់រំដោះជាក្រុមប្រវាស់ដៃ មានសមាជិកពី១០ទៅ៣០គ្រួសារ

-បន្ទាប់ពីទទួលជ័យជម្នះ១៩៧៥ ក្រុមប្រវាស់ដៃត្រូវរៀបចំជា សហករណ៍កម្រិតទាប ដែលមានសមាជិកច្រើនគ្រួសារ ឬមួយភូមិទាំងមូល

-១៩៧៧ សហករណ៍កម្រិតទាប ត្រូវរៀបចំជាសហករណ៍កម្រិតខ្ពស់ ដែលមានគ្រួសារចាប់ពី៣ ទៅ៤ភូមិ ឬឃុំមួយទាំងមូល។

១៣. តើខ្មែរក្រហមបានបែងចែកវណ្ណៈជាប៉ុន្មានប្រភេទ? អ្វីខ្លះ?

ចម្លើយ៖ បែងចែកជា២ប្រភេទគឺ

-ប្រជាជនចាស់ ឬប្រជាជនមូលដ្ឋាន

-ប្រជាជនថ្មី ឬប្រជាជន១៧មេសា

១៤. ហេតុអ្វីបានជាពួកខ្មែរក្រហមជម្លៀសប្រជាជនចេញពីក្រុងភ្នំពេញ និងទីប្រជុំជននានា ?

ចម្លើយ៖បានជាពួកខ្មែរក្រហមជម្លៀសប្រជាជនចេញពីក្រុង ភ្នំពេញ និងទីប្រជុំជននានាព្រោះ៖

-ទាក់ទងនឹងស្បៀងមិនអាចផ្គត់ផ្គង់ប្រជាជននៅទីប្រជុំជនក៏ដូចជាក្រុងនៅឯជនបទមានស្បៀងអាហារគ្រប់គ្រាន់

-លំបាកក្នុងការគ្រប់គ្រងប្រជាជនរាប់លាននាក់ប្រឆាំងបដិវត្តន៍

-អ្នកដឹកនាំបក្សកុម្មុយនីស្តមានការភ័យខ្លាចចំពោះសន្តិសុខ សុវត្ថិភាពផ្ទាល់ខ្លួន។

១៥. តើគម្រោងផែនការបួនឆ្នាំរបស់ខ្មែរក្រហម រាប់គិតពីឆ្នាំណាដល់ឆ្នាំណា?

ចម្លើយ៖ គម្រោងផែនការបួនឆ្នាំរបស់ខ្មែរក្រហម រាប់គិតពីឆ្នាំ ១៩៧៧-១៩៨០។

១៦. ចូររៀបរាប់ពីពិធីមង្គលការនៅសម័យកម្ពុជាប្រជាធិបតេយ្យ។

ចម្លើយ៖ ការរៀបមង្គលការនៅសម័យកម្ពុជាប្រជាធិបតេយ្យគឺ៖

-មង្គលការនៅក្នុងរបបនេះខុសគ្នាទាំងស្រុងពីមង្គលការតាមទំនៀមទំលាប់ប្រពៃណីខ្មែរ

-កូនកំលោះក្រមុំចំនួនពី ៣ទៅ១០គូក្នុងពិធីតូច ហើយពិធីធំមានពី ៣០ទៅ៥០គូ ឬរហូតដល់១០០គូក៏មាន

-ការរៀបការ គេរៀបចំឡើងក្នុងពិធីរួមក្នុងរាត្រីតែមួយ យុវជនយុវនារីមិនអនុញ្ញាតឱ្យជ្រើសរើសគូស្រករតាមបំណងរបស់ខ្លួន

-នារីមួយចំនួនត្រូវបង្ខំចិត្តត្រូវរៀបការជាមួយយុវជនពិការដែលរងរបួសក្នុងសង្គ្រាម

-បើនរណាជំទាស់និងបំណងអង្គការ ត្រូវទទួលទណ្ឌកម្មដោយបញ្ជូនទៅធ្វើការងារនៅស្រុកឆ្ងាយពីលំនៅដ្ឋានធ្វើការជាទម្ងន់ឬយកទៅសម្លាប់ចោល។

១៧. តើជីវិតប្រជាជនខ្មែរក្នុងរបបកម្ពុជាប្រជាធិបតេយ្យជួបប្រទះនឹងបញ្ហាអ្វីខ្លះ ?

ចម្លើយ៖ ជីវិតប្រជាជនខ្មែរក្នុងរបបកម្ពុជាប្រជាធិបតេយ្យ ជួប ប្រទះនឹងបញ្ហាជាច្រើនដូចជា៖

-អនីតិជនអាយុលើសពី១៤ឆ្នាំ ត្រូវរែកដី លើកប្រព័ន្ធភ្លឺស្រែ លើកទំនប់ ជីកប្រឡាយ

ប្រជាជនធ្វើការច្រើនជាង១២ម៉ោងក្នុងមួយថ្ងៃ និង៧ថ្ងៃក្នុងមួយសប្តាហ៍ដោយគ្មានពេលសម្រាក។

-គ្មានអាហារបរិភោបគ្រប់គ្រាន់។

-ការមិនឱ្យប្រជាជនគោរពប្រពៃណី គ្មានសាសនា។

-ត្រូវពួកខ្មែរក្រហមយកទៅធ្វើបាប ធ្វើទារុណកម្ម កាប់សម្លាប់រាប់ពាន់នាក់។

-ត្រូវបានគេចោទប្រកាន់ថាជាជនក្បត់ជាតិ ក្បត់អង្គការ។

-គ្មានការផ្តល់ជម្រកសមរម្យ មិនអាចបញ្ចេញមតិយោបល់អ្វីទាំងអស់។

១៨. តើពួកខ្មែរក្រហម បានបណ្តុះបណ្តាលអប់រំ កុមារកុមារីយ៉ាងដូចម្តេច ?

ចម្លើយ៖ ពួកខ្មែរក្រហម បានបណ្តុះបណ្តាលអប់រំ កុមារកុមារីដូចជា៖

-អប់រំបណ្តុះស្មារតីកុមារឱ្យមានឆន្ទៈដាច់ខាត ជឿជាក់លើអង្គការតែមួយគត់ ។

-កុមារទាំងអស់ជាកូនរបស់អង្គការ។

-ត្រូវស៊ើបការណ៍ឪពុកម្តាយរបស់ខ្លួន ពេលខ្លះទៀតកុមារទាំងនោះហ៊ានសម្លាប់ទាំងឪពុកម្តាយបង្កើតរបស់ខ្លួនដោយចោទថាជាខ្មាំង ។

១៩. តើ សេ-អ៊ី-អា គឺជាអ្វី? ហើយ កា-ហ្សេ-បេ ជាអ្វី?

ចម្លើយ៖ ពាក្យថា សេ-អ៊ី-អា គឺជា ភ្នាក់ងារសម្ងាត់របស់សហរដ្ឋអាមេរិក។ ចំណែកឯពាក្យថា កា-ហ្សេ-បេ គឺជាភ្នាក់ងារសម្ងាត់របស់សូវៀត។

២០. ហេតុអ្វីបានជារបបកម្ពុជាប្រជាធិបតេយ្យ សម្លាប់ប្រជាជនខ្លួនឯង?

ចម្លើយ៖ បានជារបបកម្ពុជាប្រជាធិបតេយ្យ សម្លាប់ប្រជាជនខ្លួនឯង គឺ៖

-ការប្រកាន់យកបដិវត្តន៍កុម្មុយនីស្តដែលតម្រូវឱ្យមានការ«កម្ទេច»។

-គោលការណ៍«មហាលោតផ្លោះ មហាអស្ចារ្យ» ដើម្បីសម្រេចគោលដៅរបស់ខ្លួនឱ្យបានឆាប់រហ័ស។

-គំនិតស្នេហាជាតិនិយមជ្រុលនិយម ងងឹតងងុល ដោយតម្រូវឱ្យជឿជាក់តែលើអង្គការមួយ បើពុំនោះទេត្រូវសម្លាប់ចោល។

-ការអប់រំបំពាក់កំហឹងវណ្ណៈដល់កម្មាភិបាលខ្មែរក្រហម តាំងពីមុនឆ្នាំ ១៩៧៥។

-នយោបាយរឹមដ្ឋការសិទ្ធិអំណាចកាប់សម្លាប់មនុស្សដល់កម្មាភិបាលថ្នាក់ទាប ដែលភាគច្រើន ជាមនុស្សមានការសិក្សាតិចតួច ឬល្ងង់ខ្លៅ និងបានក្លាយជាមេដឹកនាំតាមមូលដ្ឋាន។

-គោលនយោបាយបោសសម្អាតសម្រិតសម្រាំងយកមនុស្សបដិវត្តន៍បរិសុទ្ធ។

២១. ហេតុអ្វីបានជាតុលាការយកមេដឹកនាំកំពូលរបស់ខ្មែរក្រហមដែលកាន់អំណាចនៅឆ្នាំ១៩៧៥ដល់១៩៧៩ មកកាត់ទោស?

ចម្លើយ៖ បានជាតុលាការយកមេដឹកនាំកំពូលរបស់ខ្មែរក្រហម ដែលកាន់អំណាចនៅឆ្នាំ១៩៧៥ដល់១៩៧៩ មកកាត់ទោសព្រោះ មេដឹកនាំខ្មែរក្រហមទាំងនេះបានប្រព្រឹត្តអំពើឧក្រិដ្ឋកម្មក្នុងពេលកាន់អំណាចមានដូចជា៖

-ឧក្រិដ្ឋកម្មប្រល័យពូជសាសន៍

-ឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិ

-ឧក្រិដ្ឋកម្មសង្គ្រាម

-ឧក្រិដ្ឋកម្មប្រឆាំងនឹងអ្នកទទួលបានការការពារជាអន្តរជាតិ

-ការរំលោភបំពានយ៉ាងធ្ងន់ធ្ងរទៅលើអនុសញ្ញាក្រុងហ្សឺណែវឆ្នាំ ១៩៤៩

-ការបំផ្លាញទ្រព្យសម្បត្តិវប្បធម៌របស់មនុស្សជាតិ។

២២. តើការកាត់ទោសមេដឹកនាំខ្មែរក្រហម គឺក្នុងគោលបំណងដើម្បីអ្វី?

ចម្លើយ៖ ការកាត់ទោសមេដឹកនាំខ្មែរក្រហមគឺដើម្បី៖

-ផ្តល់យុត្តិធម៌ ផ្តល់ភាពស្ងប់ស្ងាត់ចិត្ត ការផ្សះផ្សាវិបត្តិផ្លូវចិត្ត ដល់ជនរងគ្រោះដែលរស់រានមានជីវិត

-ជាមេរៀន ជាគំរូដល់មេដឹកនាំជំនាន់ក្រោយកុំឱ្យគ្រាប់តាមនិងដើម្បីទប់ស្កាត់កុំឱ្យមានរបបនេះកើតឡើងសាជាថ្មីទៀត

-ធ្វើការបង្រួបបង្រួមជាតិ ផ្សះផ្សាជាតិ

-ផ្តល់យុត្តិធម៌ឱ្យជនរងគ្រោះដែលបាត់បង់ជីវិត

-ជាការដាក់ទណ្ឌកម្មដល់អ្នកដែលបានប្រព្រឹត្តកុំឱ្យរួចខ្លួន។

២៣. តើមន្ទីរស-២១ ជាអ្វី?

ចម្លើយ៖ មន្ទីរស-២១ គឺជាមន្ទីរសន្តិសុខថ្នាក់មជ្ឈិមនៅភ្នំពេញ និងជាគុកដែលសំខាន់បំផុតនៃរបបកម្ពុជាប្រជាធិបតេយ្យ។

២៤. តើមន្ទីរស-២១ ស្ថិតក្រោមការគ្រប់គ្រងរបស់ស្ថាប័នណា? ដឹកនាំដោយអ្នកណា?

ចម្លើយ៖ ស្ថិតក្រោមការគ្រប់គ្រងរបស់ក្រសួងការពារជាតិ។ ដឹកនាំដោយ លោក សុន សេន ហៅ សមមិត្តខៀវ។

២៥. តើអ្នកទោសនៅក្នុងមន្ទីរស-២១ ភាគច្រើនជាអ្នកណា?

ចម្លើយ៖ អ្នកទោសភាគច្រើនគឺជាកម្មាភិបាល និងកងទ័ពខ្មែរក្រហម ដែលត្រូវបានចោទប្រកាន់ថាក្បត់បដិវត្តន៍ ឬអង្គការ។

២៦. តើមន្ទីរស-២១ ចំពោះអក្សរ«ស»និង«២១» តំណាងឱ្យអ្វី?

ចម្លើយ៖ អក្សរ«ស» តំណាងឱ្យពាក្យសន្តិបាល រីឯលេខ«២១» តំណាងឱ្យលេខសម្ងាត់។

២៧. តើអ្នកណាជាប្រធានមន្ទីរស-២១ ? អនុប្រធានជាអ្នកណា?

ចម្លើយ៖

-លោក កាំង ហ្គេចអ៊ាវ ហៅឌុច ជាប្រធាន។

-លោក ឃឹម វ៉ាត ហៅហ៊ី ជាអនុប្រធាន។

២៨. តើមន្ទីរស-២១ មានបុគ្គលិកប៉ុន្មាននាក់?

ចម្លើយ៖ មានបុគ្គលិកប្រមាណ១០០០នាក់។

២៩. តើបុគ្គលិកទាំងនោះមានតួនាទីឬភារកិច្ចអ្វីខ្លះ?

ចម្លើយ៖ បុគ្គលិកទាំងនោះគឺ៖

-បុគ្គលិកប្រមាណ៣០០ទៅ៤០០នាក់ ៖ បម្រើការជាបុគ្គលិកទូទៅ អ្នកជាំស្ល ដាំបន្លែ ...សម្រាប់បម្រើត្រូវការក្នុងគុក។

-អង្គភាពអ្នករៀបចំឯកសារ ៖ មានតួនាទីចម្លងចម្លើយសារភាព ចេញពីការសែត រាយអត្ថបទចម្លើយសារភាព សង្ខេបអត្ថបទចម្លើយ សារភាព និងរៀបចំទុកជាក់ឯកសារ។ ក្នុងនោះមានអង្គភាពរងផ្នែក ថតរូបផងដែរ។

-អង្គភាពការពារ ៖ ជាអង្គភាពធំបំផុតនៅមន្ទីរស-២១។ អង្គភាព នេះភាគច្រើនជាក្មេងជំទង់ ដែលត្រូវគោរពបទបញ្ជាដ៏តឹងរឹង។

-អង្គភាពអ្នកសួរចម្លើយ ៖ គេចែកជាក្រុងរងក្តៅ(ហៅកងកាច) ក្រុងរងត្រជាក់(ហៅកងស្លូត) និងក្រុមអង្កៀម។

៣០. តើខ្មែរក្រហមបានបែងចែកសត្រូវរបស់ខ្លួនជាប៉ុន្មានប្រភេទ? ចូររៀបរាប់។

ចម្លើយ៖ ខ្មែរក្រហមបានបែងចែកសត្រូវជាពីរប្រភេទគឺ សត្រូវខាងក្នុង និង សត្រូវខាងក្រៅ។

+សត្រូវខាងក្នុង

-ពួកប្រជាជនថ្មី ឬប្រជាជន១៧មេសា

-អ្នកធ្លាប់ធ្វើការក្នុងរបបសាធារណរដ្ឋខ្មែរ

-ក្រុមជនជាតិភាគតិច

-ក្រុមកម្មាភិបាលខ្មែរក្រហម ដែលត្រូវបានគេចោទថាខ្មាំងក្បត់ បដិវត្តន៍ ក៏ត្រូវសម្លាប់ចោលនោះដែរ។

+សត្រូវខាងក្រៅ

-សហរដ្ឋអាមេរិក
-ថៃ
-វៀតណាម
-សូវៀត
-និងសម្ព័ន្ធមិត្តរបស់ប្រទេសទាំងនេះ។

៣១. ចូររៀបរាប់ពីពាក្យស្លោកនៅសម័យកម្ពុជាប្រជាធិបតេយ្យ។

ចម្លើយ៖ ពាក្យស្លោកមានដូចជា៖
-ទុកមិនចំណេញ ដកចេញក៏មិនខាត
-ស៊ូសម្លាប់ច្រឡំ១០០ ប្រសើរជាជាងលែងច្រឡំ១
-គ្រុនញាក់គ្រុនញ័រ គ្រុនគ្រាក់ទ័រ គ្រុនឡាន គ្រុនបាយបាន គ្រុនសតិអារម្មណ៍
-កូនស្រីធ្វើពេទ្យ កូនប្រុសធ្វើទាហាន
-មិនចាំបាច់បង្រៀនមនុស្សឱ្យមានចំណេះដឹងច្រើននោះទេ គ្រាន់តែបង្រៀនមនុស្សមួយក្រុមតូចឱ្យមានចំណេះធ្វើយកទៅដឹកនាំមនុស្សមួយក្រុមធំជាការស្រេច
-អង្គការគ្មានសញ្ញាបត្រឱ្យទេ បើចង់ឃើញសញ្ញាបត្រទៅយកនៅភ្លឺស្រែ។

៣២. ចូររៀបរាប់ពីវិន័យសន្តិបាល ឬបទបញ្ញត្តិសម្រាប់អ្នកទោសនៅមន្ទីរស-២១។

ចម្លើយ៖ វិន័យសន្តិបាល នៅមន្ទីរស-២១ គឺ៖
-សួរអីឆ្លើយហ្នឹង មិនបង្វែរសំណួររបស់អញ។

-មិនឱ្យដោះស្រាយ យកលេសនេះលេសនោះតាមគំនិតឯងលាក់ឬប្រកែក តមាត់មិនបានជាច់ខាត។
-មិនឱ្យធ្វើល្ងង់ មិនយល់បញ្ហា ព្រោះឯងជាមនុស្សហ៊ានប្រឆាំងនឹងបដិវត្តន៍។
-សួរភ្លាម ឆ្លើយភ្លាម មិនឱ្យដំអក់មួយនាទីឡើយ។
-រឿងខ្វះខាត កំហុសបន្តិចបន្តួច ដូចជាសីលធម៌ ខូចនេះខូចនោះ ក៏មិនឱ្យនិយាយ រឿងខ្លឹមសារបដិវត្តន៍ ក៏មិនឱ្យនិយាយ។
-វៃ ឬឆក់ខ្សែភ្លើងមិនឱ្យស្រែកជាច់ខាត។
-មិនឱ្យធ្វើអ្វីទាំងអស់ គឺអង្គុយស្ងៀមរងចាំបញ្ជាអញ អត់បញ្ជាកុំធ្វើ អញបញ្ជាអីធ្វើហ្នឹងភ្លាម ប្រកែកច្រឹមច្រិមមិនបានទេ។
-កុំយកលេសកម្ពុជាក្រោម បាំងមុខមាត់ក្បត់របស់អាឯងឱ្យសោះ។
-គ្រប់បញ្ជាខាងលើ មិនធ្វើតាម គឺមួយថ្ងៃរងរំពាត់ ខ្សែភ្លើងឆក់រាប់មិនឈ្នះទេ។
-ប្រឆាំងវិន័យអញមួយចំណុច ត្រូវរងរំពាត់ដប់រំពាត់ ឬឆក់ខ្សែភ្លើងប្រាំឆាច់។

៣៣. តើទិន្នផលស្រូវដែលប្រមូលបានពីផែនការ៤ឆ្នាំរបស់ខ្មែរក្រហម ត្រូវបានគេបែងចែកជាប៉ុន្មានចំណែក? អ្វីខ្លះ?

ចម្លើយ៖ គេចែកជាបួនចំណែកគឺ៖
-ចំណែកទីមួយ ៖ ទុកសម្រាប់ជាស្បៀងរបស់ប្រជាជនដែលម្នាក់ៗទទួលបាន៣១២គីឡូក្រាមស្រូវក្នុង១ឆ្នាំ ឬ០.៨៥គីឡូក្រាមស្រូវក្នុងមួយថ្ងៃ។

-ចំណែកទីពីរ ៖ សម្រាប់ធ្វើពូជ។

-ចំណែកទីបី ៖ សម្រាប់ទុកបម្រុង។

-ចំណែកទីបួន ៖ សម្រាប់យកទៅលក់នៅឯបរទេស ដើម្បីប្តូរយកសាច់ប្រាក់ ដែលអាចប្រើប្រាស់ ដើម្បីទិញម៉ាស៊ីនសម្រាប់ធ្វើស្រែចម្ការ គ្រឿងសព្វាវុធ និងទំនិញផ្សេងៗ។

៣៤. តើការបែងចែកដីស្រែ សម័យកម្ពុជាប្រជាធិបតេយ្យមានលក្ខណៈដូចម្តេច?

ចម្លើយ៖ សម័យកម្ពុជាប្រជាធិបតេយ្យបានបែងចែកដីស្រែទៅជាដីស្រែល្អលេខមួយ និងដីស្រែមិនល្អធម្មតា។ ចំពោះទិន្នផលសម្រាប់ដីស្រែធម្មតាគឺបីតោនក្នុងមួយហិកតា ចំណែកដីស្រែលេខមួយកសិករត្រូវធ្វើឱ្យបានពី៦ទៅ៧ តោនក្នុងមួយហិកតា។ ជាងនេះទៅទៀត ទិន្នផលស្រូវនឹងត្រូវបង្កើនជារៀងរាល់ឆ្នាំ។

៣៥. តើសម័យកម្ពុជាប្រជាធិបតេយ្យ មានទំនាក់ទំនងការបរទេសជាមួយប្រទេសណាខ្លះ?

ចម្លើយ៖ កម្ពុជាប្រជាធិបតេយ្យ មានទំនាក់ទំនងជាមួយប្រទេសដូចជា ប្រទេសចិន ប្រទេសវៀតណាម ឡាវ គុយបា កូរ៉េខាងជើង រ៉ូម៉ានី យូហ្គោស្លាវី អាល់បានី អេហ្ស៊ីប។

៣៦. តើទំនិញនាំចេញរបស់កម្ពុជា នៅសម័យកម្ពុជាប្រជាធិបតេយ្យមានអ្វីខ្លះ?

ចម្លើយ៖ ទំនិញនាំចេញមានដូចជា ស្រូវ ជ័រកៅស៊ូ ឈើ សរីរាង្គសត្វ (ស្បែក ភ្លុក ស្នូក)។

៣៧. តើទំនិញនាំចូលរបស់កម្ពុជា នៅសម័យកម្ពុជាប្រជាធិបតេយ្យ មានអ្វីខ្លះ?

ចម្លើយ៖ ទំនិញនាំចូលមានដូចជា គ្រឿងសព្វាវុធ រថក្រោះ កាំភ្លើងធំ ម៉ាស៊ីនសម្រាប់ធ្វើស្រែចម្ការ ផលិតផលគីមី ក្រណាត់។

៣៨. តើអត្តចរិតរបស់សាឡុត ស មានលក្ខណៈដូចម្តេចខ្លះ?

ចម្លើយ៖ អត្តចរិតរបស់ សាឡុត ស គឺ បើយោងតាមសិស្សដែលរៀនជាមួយ សាឡុត ស នៅអនុវិទ្យាល័យកំពង់ចាម សាឡុត ស គឺជាមនុស្សសាមញ្ញម្នាក់ មិនសូវនិយាយស្តីច្រើន ចូលចិត្តលេងបាល់ទាត់ និងបាល់បោះ។ ជាមនុស្សរួសរាយ និងចេះគួរសម ហើយជាមនុស្សមិនបង្ហាញពីមហិច្ឆតាចង់ធ្វើអ្វីឲ្យបានធំដុំនោះទេ។ សាឡុត ស ខ្លួនឯងក៏ធ្លាប់បានអះអាងស្រដៀងគ្នានេះដែរ។

៣៩. ហេតុអ្វីបានជា សាឡុត ស បានទទួលអាហារូបករណ៍ទៅសិក្សានៅប្រទេសបារាំង?

ចម្លើយ៖ បានជា សាឡុត ស បានទទួលអាហារូបករណ៍ទៅសិក្សានៅប្រទេសបារាំង វាអាចមានហេតុផលពីរយ៉ាងគឺ៖

-ទីមួយ៖ នៅពេលនោះ ក្រសួងអប់រំស្ថិតក្រោមការគ្រប់គ្រងរបស់គណបក្សប្រជាធិបតេយ្យ ដែលឈ្នះឆ្នោត កាលពីឆ្នាំ១៩៤៧។ ប្រហែលជាដោយសារតែ សាឡុត ស បានជួយធ្វើការឃោសនាបោះឆ្នោតឲ្យគណបក្សប្រជាធិបតេយ្យ ទើបរដ្ឋមន្ត្រីក្រសួងអប់រំផ្តល់អាហារូបករណ៍ឲ្យ សាឡុត ស បានទៅរៀននៅបារាំង។

-ទីពីរ៖ នៅពេលនោះ មិនសូវមានកូនខ្មែរណាមានជំនាញខាងអេឡិចត្រូនិចទេ។ ប្រហែលជាមកពីហេតុនេះហើយបានជាក្រសួងអប់រំ បញ្ជូន សាឡុត ស ដែលរៀននៅសាលាបច្ចេកទេសស្រាប់ ឲ្យទៅបន្តការសិក្សាផ្នែកបច្ចេកទេសអេឡិចត្រូនិច នៅប្រទេសបារាំង។ ទោះជាក្នុងហេតុផលណាមួយក៏ដោយ សាឡុត ស បានក្លាយជាសិស្សមួយរូប ក្នុងចំណោមសិស្សពូកែទាំង២១រូប ដែលត្រូវបានរដ្ឋាភិបាលបញ្ជូនទៅរៀននៅប្រទេសបារាំង នៅឆ្នាំ១៩៤៩។ គឺនៅប្រទេសបារាំងនោះហើយ ដែល សាឡុត ស បានក្លាយទៅជាជនកុម្មុយនិស្ត។

៤០. តើខ្លឹមសារនៃការកសាងសង្គមនិយមដែលបក្សកុម្មុយនិស្តកម្ពុជាបានលើកឡើងមានប៉ុន្មានចំណុចសំខាន់ៗ?

ចម្លើយ៖ ខ្លឹមសារមាន២ចំណុចសំខាន់ៗគឺ

-ទី១ ពង្រឹងនិងពង្រីកទីតាំងសមូហភាព

-ទី២ ឈរលើទីតាំងសមូហភាព ការកសាងពង្រឹងពង្រីកសម្ភារៈបច្ចេកទេសវិទ្យាសាស្ត្រ សេដ្ឋកិច្ច សង្គមកិច្ច វប្បធម៌ អក្សរសាស្ត្រ។

៤១. នៅឆ្នាំ១៩៧៧ តើប៉ុល ពត បានសម្លាប់កម្មាភិបាលជាន់ខ្ពស់ណាខ្លះ?

ចម្លើយ៖ ដោយមានការសង្ស័យថាកម្មាភិបាលឬក្រុមរបស់ខ្លួនក្បត់និងចូលដៃជើងជាមួយវៀតណាម ប៉ុល ពត បានសម្លាប់កម្មាភិបាលជាន់ខ្ពស់ជាច្រើនដូចជា៖

-ថ្ងៃទី២៥ មករា ឆ្នាំ១៩៧៧ ចាប់ខ្លួនលោក កុយ ធួន ជារដ្ឋមន្ត្រីក្រសួងហិរញ្ញវត្ថុនិងពាណិជ្ជកម្ម។
-ថ្ងៃទី២៦ មករា ១៩៧៧ ចាប់ខ្លួន ទូច ភឿន ជារដ្ឋមន្ត្រីក្រសួងសាធារណការ។
-ខែកុម្ភៈ ចាប់ខ្លួនរដ្ឋមន្ត្រីម្នាក់ទៀតគឺ សឿ ឌឿម។
-ថ្ងៃទី១៤ មីនា ចាប់ខ្លួន ភោគ ឆាយ ជាអតីតប្រធានសមាគមមិត្តភាពចិន-ខ្មែរ។
-ថ្ងៃទី៦ កក្កដា ១៩៧៧ ចាប់ខ្លួន លោក ហ៊ូ នឹម ជារដ្ឋមន្ត្រីក្រសួងយោសនាការ។

ករណីនេះហើយដែលសមមិត្ត ហ៊ុន សែន បានភៀសខ្លួនចូលក្នុងព្រៃជាមួយ អ៊ឹង ផន នៅថ្ងៃ២០ ខែមិថុនា។ កាលនោះសមមិត្ត ហ៊ុន សែន គឺជាមេបញ្ជាការយោធារងនៅតំបន់២១នៃកងទ័ពខ្មែរក្រហមនៃភូមិភាគបូព៌ា។ បន្ទាប់ពីរស់នៅអស់ជាច្រើនខែ ទើបលោករត់ទៅប្រទេសវៀតណាម។

៤២. តើកត្តាអ្វីខ្លះដែលធ្វើឱ្យរបបកម្ពុជាប្រជាធិបតេយ្យដួលរលំ?

ចម្លើយ៖ កត្តាដែលធ្វើឱ្យរបបកម្ពុជាប្រជាធិបតេយ្យដួលរលំគឺ៖

+កត្តាប្រជាជន

-ការស្អប់ខ្ពើមរបបប៉ុល ពត របស់ប្រជាជនកម្ពុជា ព្រោះរបបនេះបានធ្វើទារុណកម្ម និងកាប់សម្លាប់ប្រជាជនខ្លួនឯង
-ការបង្ខិតបង្ខំមនុស្សឱ្យធ្វើការដោយទម្ងន់ ធ្វើឱ្យសុខភាពទ្រុឌទ្រោមនិងបាក់កម្លាំង

-កង្វះអាហារ កង្វះសម្លៀកបំពាក់ គ្មានថ្នាំសម្រាប់ព្យាបាល រង់ចាំតែសេចក្តីស្លាប់

-ការបំបិទសិទ្ធិសេរីភាពប្រជាជន ជំនឿ សាសនា ប្រពៃណី ទំនៀមទម្លាប់។

+កត្តាសម្រិតសម្រាំងយកមនុស្សបដិវត្តន៍បរិសុទ្ធ

-នៅពាក់កណ្តាលឆ្នាំ១៩៧៦ មានការសម្រិតសម្រាំងយកមនុស្សបដិវត្តន៍បរិសុទ្ធក្នុងចំណោមសមាជិកសំខាន់នៃបក្សកុម្មុយនីស្តកម្ពុជា ពោលគឺសម្លាប់អ្នកក្បត់បក្សតែម្តង។

-ការសម្រិតសម្រាំងនេះបានធ្វើឱ្យមានការបែកបាក់ផ្ទៃក្នុងជាពិសេសគឺជួរអ្នកដឹកនាំបក្សកុម្មុយនីស្ត។

+កត្តាសង្គ្រាមជាមួយវៀតណាម

-ខ្មែរក្រហមបានធ្វើសង្គ្រាមជាមួយវៀតណាមចាប់តាំងពីឆ្នាំ១៩៧៥ គឺជម្លោះតាមព្រំដែន ដោយកងកម្លាំងខ្មែរក្រហមមានចំនួនតិចអាវុធពុំទំនើប យុទ្ធសាស្ត្រខ្សោយ រីឯវៀតណាមមានចំនួនទ័ពច្រើនអាវុធទំនើប និងយុទ្ធសាស្ត្រខ្លាំង។

+កត្តារណសិរ្សសង្គ្រោះជាតិកម្ពុជា

-នៅថ្ងៃទី០២ ធ្នូ ១៩៧៨ រណសិរ្សសង្គ្រោះជាតិបានបង្កើតឡើងដែលមានគោលបំណងផ្តួលរំលំរបបកម្ពុជាប្រជាធិបតេយ្យ។

-នៅថ្ងៃទី២៥ ធ្នូ ១៩៧៨ រណសិរ្សសង្គ្រោះជាតិ និងកងទ័ពវៀតណាមបានបើកការវាយប្រហារលើកម្ពុជាប្រជាធិបតេយ្យរហូតទទួលបានជោគជ័យនៅថ្ងៃទី០៧ មករា ១៩៧៩។

៤៣. ក្រោយថ្ងៃទី៧ មករា ឆ្នាំ១៩៧៩ តើប៉ុល ពត បានរត់ភៀសខ្លួនទៅទីណា?

ចម្លើយ៖ ប៉ុល ពត បានរត់ភៀសខ្លួនទៅកាន់ព្រំដែនខ្មែរ-ថៃ។

៤៤. តើសាឡុត ស ឬប៉ុល ពត បានស្លាប់នៅថ្ងៃខែឆ្នាំណា? ដោយសារអ្វី?

ចម្លើយ៖ សាឡុត ស ឬប៉ុល ពត បានស្លាប់នៅថ្ងៃទី១៥ ខែមេសា ឆ្នាំ១៩៩៨ ដោយសារជម្ងឺបេះដូងក្នុងអាយុ៧៣ឆ្នាំ។

សំណួរ-ចម្លើយ ស្តីពីសម័យសាធារណរដ្ឋប្រជាមានិតកម្ពុជានិងសម័យរដ្ឋកម្ពុជា ប្រធាន

១. តើសម័យសាធារណរដ្ឋប្រជាមានិតកម្ពុជា ចាប់ពីឆ្នាំណាដល់ឆ្នាំណា?

ចម្លើយ៖ ១៩៧៩ ដល់ ១៩៨៩។

២. តើរណសិរ្សសង្គ្រោះជាតិកម្ពុជា បង្កើតឡើងនៅថ្ងៃខែឆ្នាំណា?

ចម្លើយ៖ ២ ធ្នូ ១៩៧៨។

៣. តើការបង្កើតរណសិរ្សសង្គ្រោះជាតិកម្ពុជា ក្នុងគោលបំណងអ្វីខ្លះ?

ចម្លើយ៖ បង្កើតឡើងក្នុងគោលបំណងធំៗមួយចំនួនរួមមាន៖

-រំដោះប្រទេសជាតិចេញពីរបប ប៉ុល ពត

-ជួយសង្គ្រោះអាយុជីវិតប្រជាពលរដ្ឋឱ្យចាកផុតពីមហន្តរាយនៃរបបអារក្ខៅ

-ជួយស្តារ កសាង និងអភិវឌ្ឍន៍មាតុភូមិកម្ពុជា មានការកែប្រែមុខមាត់ថ្មី។

៤. តើរណសិរ្សសង្គ្រោះជាតិកម្ពុជា បានបង្កើតនៅទីកន្លែងណា?

ចម្លើយ៖ នៅក្នុងតំបន់រំដោះ នាភូមិជើងឃ្លូ ឃុំ២ធ្នូ ស្រុកស្នួល ខេត្តក្រចេះ។

៥. ចូររៀបរាប់ពីចលនាតស៊ូដើម្បីរំដោះប្រទេសកម្ពុជា ពីរបបប្រល័យពូជសាសន៍ឬកម្ពុជាប្រជាធិបតេយ្យ។

ចម្លើយ៖ រៀបរាប់ពីចលនាតស៊ូដើម្បីរំដោះប្រទេសកម្ពុជា ពីរបបប្រល័យពូជសាសន៍គឺ

-ខែមករា ឆ្នាំ១៩៧៦ លោក ហ៊ូ នឹម បានចេញមុខប្រឆាំងនឹងប៉ុល ពត។

-ដើមខែមីនា ឆ្នាំ១៩៧៦ ប្រជាជននៅចម្ការលួង សៀមរាប ទាមទារដំឡើងកម្រិតជីវភាព។

-ខែមករា ឆ្នាំ១៩៧៧ ប្រជាជននៅខេត្តសៀមរាប និងបាត់ដំបងបានប្រឆាំងដូចគ្នា។

-ខែមីនា-មេសា ឆ្នាំ១៩៧៧ ប្រជាជននៅតាមខេត្តកំពង់ឆ្នាំង មណ្ឌលគិរី កំពង់ធំ បានបង្កើតចលនាប្រឆាំងនឹងប៉ុល ពត។

-នៅឆ្នាំ១៩៧៧ លោក ហ៊ុន សែន បានរត់ទៅប្រទេសវៀតណាម ដើម្បីបង្កើតទ័ពតស៊ូប្រឆាំងនឹងខ្មែរក្រហម។
-ថ្ងៃទី២ ខែធ្នូ ឆ្នាំ១៩៧៨ មហាសន្និបាតបានសម្រេចបង្កើតរណសិរ្ស សាមគ្គីសង្គ្រោះជាតិកម្ពុជា ដែលដឹកនាំដោយលោក ហេង សំរិន។
-មានជំនួយពីវៀតណាមនិងប្រជាជនកម្ពុជា។
-ក្នុងរយៈពេល៣សប្តាហ៍កងទ័ពរណសិរ្សសាមគ្គីសង្គ្រោះជាតិ និងកងទ័ពរំដោះប្រជាជនបានស្ទើរតែទាំងស្រុង។
-ថ្ងៃទី៧ មករា ១៩៧៩ ប្រជាជនខ្មែរបានរួចផុតពីរបបប្រល័យពូជសាសន៍ខ្មែរក្រហម។

៦. ចូររៀបរាប់សង្ខេបពីកំណើតរណសិរ្សសាមគ្គីសង្គ្រោះជាតិកម្ពុជា។

ចម្លើយ៖ នៅថ្ងៃទី២ខែធ្នូ ឆ្នាំ១៩៧៨ នៅមូលដ្ឋានតស៊ូក្នុងស្រុកស្នួល ខេត្តក្រចេះ មហាសន្និបាតបានប្រារព្ធឡើងដោយមានតំណាងកម្លាំងរំដោះគ្រប់តំបន់ទូទាំងប្រទេសចូលរួម។ មហាសន្និបាតបានសម្រេចជាឯកច្ឆ័ន្ទបង្កើតរណសិរ្សសាមគ្គីសង្គ្រោះជាតិកម្ពុជា និងធ្វើការបោះឆ្នោតជ្រើសរើសគណៈកម្មការមជ្ឈិមរណសិរ្សដែលមានសមាជិក១៤រូប ក្នុងនោះមាន សមមិត្ត ហេង សំរិន ជាប្រធាន។

៧. តើចលនាប្រឆាំងនឹងរបបខ្មែរក្រហមក្នុងឆ្នាំ១៩៧៧ មាននៅខេត្តណាខ្លះ?

ចម្លើយ៖ ចលនាប្រឆាំងនឹងរបបខ្មែរក្រហមក្នុងឆ្នាំ១៩៧៧ មាននៅខេត្តដូចជា សៀមរាប បាត់ដំបង កំពង់ធំ កំពង់ឆ្នាំង មណ្ឌលគិរី។

៨. ចូររៀបរាប់ពីសង្គ្រាមផ្តួលរំលំរបបខ្មែរក្រហមត្រឹមឆ្នាំ១៩៧៩។

ចម្លើយ៖រៀបរាប់ពីសង្គ្រាមផ្តួលរំលំរបបខ្មែរក្រហមត្រឹមឆ្នាំ១៩៧៩គឺ

-ថ្ងៃទី៣០ ខែធ្នូ ឆ្នាំ១៩៨៨ រំដោះបានលំផាត់ ក្រចេះ វ៉ឺនសៃ ទន្លេបិទ

-ថ្ងៃទី៣-៤ ខែមករា ឆ្នាំ១៩៧៩ រំដោះបានខេត្តស្វាយរៀងនិងស្ទឹងត្រែង។

-ថ្ងៃទី៥-៦ ខែមករា ឆ្នាំ១៩៧៩ រំដោះបានអ្នកលឿង និងទីរួមខេត្តកំពង់ចាម។

-ថ្ងៃទី៧ ខែមករា ឆ្នាំ១៩៧៩ រំដោះបានទីក្រុងភ្នំពេញ ខេត្តតាកែវ និងកំពង់សោម។

៩. តើសម័យសាធារណរដ្ឋប្រជាមានិតកម្ពុជា បានបើកសម័យប្រជុំលើកទី១ នៅថ្ងៃខែឆ្នាំណា?

ចម្លើយ៖ នៅថ្ងៃទី២៤ ខែមីនា ឆ្នាំ១៩៨១។

១០. តើការបើកសម័យប្រជុំនោះរដ្ឋសភាបានតែងតាំងឬបង្កើតស្ថាប័នរដ្ឋអ្វីខ្លះ?

ចម្លើយ៖រដ្ឋសភាបានបង្កើតស្ថាប័នរដ្ឋចំនួន២ធំៗគឺ

-រដ្ឋាភិបាល

-ក្រុមប្រឹក្សារដ្ឋ។

១១. តើស្ថាប័នក្រុមប្រឹក្សារដ្ឋមានតួនាទីអ្វី?

ចម្លើយ៖ ស្ថាប័ននេះមានតួនាទីជាគណៈប្រធានរដ្ឋ គឺអង្គការនីតិបញ្ញត្តិផង និងអង្គការនីតិប្រតិបត្តិផង។

១២. តើរបបសាធារណរដ្ឋប្រជាមានិតកម្ពុជា ដឹកនាំដោយគណបក្សមួយណា?

ចម្លើយ៖ របបថ្មីនេះគ្រប់គ្រងដឹកនាំដោយបក្សតែមួយគឺគណបក្សប្រជាជនបដិវត្តន៍កម្ពុជា។

១៣. ក្រោយពីការប្រកាសរបបសាធារណរដ្ឋប្រជាមានិតកម្ពុជា នៅថ្ងៃទី១១ ខែមករា ឆ្នាំ១៩៧៩ តើរបបនោះត្រូវប្រឈមមុខនឹងបញ្ហាសំខាន់ៗអ្វីខ្លះ?

ចម្លើយ៖ របបសាធារណរដ្ឋប្រជាមានិតកម្ពុជា ត្រូវប្រឈមមុខនឹងបញ្ហាសំខាន់ៗដូចជា៖

-ការមិនព្រមទទួលស្គាល់ពីសំណាក់អង្គការសហប្រជាជាតិ ព្រោះរបបនេះត្រូវបានគេចាត់ទុកថា ជារបបដែលវៀតណាមឈ្លានពានទឹកដីខ្មែរ

-ការកសាងប្រទេសឡើងវិញ ដោយបាតដៃទទេ ដែលបានបន្សល់ទុកពីរបប ប៉ុល ពត ជាពិសេសគឺការកសាងជីវភាព សុខាភិបាល សេដ្ឋកិច្ច និងវប្បធម៌ សិក្សាធិការជាតិ សម្រាប់ប្រជាជន ដែលបាត់បង់ទ្រព្យសម្បត្តិ វិជ្ជាជីវៈ ព្រមទាំងសមាជិកគ្រួសាររបស់គេ

-អាណានិគមកិច្ចរបស់វៀតណាម

-ការប្រជែងកម្លាំងគ្នារវាងក្រុមប៉ែន សុវណ្ណ មកពីហាណូយ និងក្រុមជា ស៊ីម ហេង សំរិន ខាងខ្មែរក្រហមក្នុងស្រុក ដែលបានប្រឆាំងនឹង ប៉ុល ពត

-ការប្រឈមមុខនឹងកងទ័ពខ្មែរក្រហម ព្រមទាំងចលនារំដោះនានា ដែលប្រជែងជាមួយពួកខ្មែរក្រហម ក្នុងការរំដោះប្រទេសកម្ពុជាចេញពីវៀតណាម។

១៤. តើស្ថានភាពប្រជាជនកម្ពុជាក្រោយថ្ងៃរំដោះថ្ងៃ៧ ខែមករា ឆ្នាំ ១៩៧៩មានសភាពដូចម្តេច?

ចម្លើយ៖ ស្ថានភាពប្រជាជនគឺ ក្រីក្រលំបាកគាកយ៉ាក និរាសព្រាត់ប្រាសគ្រួសារ បន្សល់ទុក្ខក្មេងកំព្រា ស្ត្រីមេម៉ាយ និងចាស់ជរា គ្មានផ្ទះសម្បែង គ្មានកម្លាំង គ្មានគោក្របី នង្គ័ល រនាស់ ឬឧបករណ៍សម្រាប់ធ្វើស្រែចម្ការ។

១៥. តើក្រុមបង្កបង្កើនផលបង្កើតឡើងនៅឆ្នាំណា? ដើម្បីអ្វី? មានប៉ុន្មានគ្រួសារ?

ចម្លើយ៖ ក្រុងបង្កបង្កើនផលបង្កើតឡើងនៅឆ្នាំ១៩៧៩។ បង្កើតដើម្បីជួយកម្លាំងដល់ស្ត្រីមេម៉ាយ ចាស់ជរា និងក្មេងកំព្រាដែលគ្មានកម្លាំងអូសទាញ។ ហើយមានសមាជិកចាប់ពី១០គ្រួសារឡើងទៅ។

១៦. តើក្រុមបង្កបង្កើនផលបានបញ្ចប់នៅពេលណា? ព្រោះអ្វី?

ចម្លើយ៖ ក្រុមបង្កបង្កើនផលបានបញ្ចប់នៅពេលដែលរដ្ឋបានចែកដីស្រែចម្ការតាមកម្លាំងពលកម្មនិងតាមសមាជិកនៅឆ្នាំ១៩៨៣ ឬខេត្តខ្លះឆ្នាំ១៩៨៧។

១៧. ចូររៀបរាប់ពីផលវិជ្ជមាននិងអវិជ្ជមាន នៃក្រុមសាមគ្គីបង្កបង្កើនផល។

ចម្លើយ៖ រៀបរាប់ពីផលវិជ្ជមាននិងអវិជ្ជមានរបស់ក្រុមសាមគ្គីបង្ក បង្កើនផលមានដូចជា៖

+ផលវិជ្ជមាន

-ជួយអ្នកគ្មានគោ ក្របី នង្គ័ល រនាស់ជាដើម។

-ជួយកម្លាំងស្ត្រីមេម៉ាយ ចាស់ជរា ក្មេងកំព្រា។

-ជួយដកស្ទូងនិងច្រូតកាត់គ្នាទាន់ពេលវេលា។

-ជួយដល់សង្គមសមូហភាព។

+ផលអវិជ្ជមាន

-អ្នកមានគោ ក្របី នង្គ័ល រនាស់ ច្រើនតែជាពួកមូលដ្ឋានចាស់ រីឯអ្នក១៧មេសា ឬអ្នកមូលដ្ឋានថ្មី គ្មានអ្វីទេ មានតែបាតដៃទទេ ដូចនេះអ្នកចាស់បានយកប្រៀបលើអ្នកថ្មី។

-ការបែងចែកផលតាមកម្លាំងពលកម្មគឺ គេចែកកម្លាំងជា៣គឺ កម្លាំងពេញ កម្លាំងមធ្យម និងកម្លាំងខ្សោយ អ្នកមានគោក្របី គឺស្ថិតនៅកម្លាំងពេញ ឯគោក្របីទទួលបានផលកម្លាំងមធ្យមទៀត។ កម្លាំងមធ្យម គឺក្មេងជំទង់បុរសស្ត្រីដែលបាក់កម្លាំង។ កម្លាំងខ្សោយ គឺពួកចាស់ជរានិងកូនក្មេងដែលនៅផ្ទះឬរៀនសូត្រ។ ដូច្នេះការបែងចែកកម្លាំងនេះមិនយុត្តិធម៌ដល់ប្រជាជនមូលដ្ឋានថ្មីសោះ ព្រោះបានបាត់បង់សាច់ញាតិ ហើយបានបាត់បង់កម្លាំងថែមទាំងទទួលផលស្រូវតិចតួចហូបមិនគ្រាន់ទៀតផង។ បើស្ត្រីមេម៉ាយមានកូនច្រើនកាន់តែយ៉ាប់ថែមទៀត។

សរុបសេចក្តីមកក្រុមសាមគ្គីបង្កបង្កើនផលមានផលល្អខ្លះ និងផលអាក្រក់ខ្លះ តែផលអាក្រក់ច្រើនជាងផលល្អ ជាអំពើអយុត្តិធម៌។

១៨. តើរចនាសម្ព័ន្ធគ្រប់គ្រងរដ្ឋនៅឆ្នាំ១៩៧៩ដល់១៩៨១ មានអ្វីខ្លះ?

ចម្លើយ៖ រចនាសម្ព័ន្ធមានដូចតទៅ៖

-ហេង សំរិន ជាប្រធានរដ្ឋ ឬប្រមុខរដ្ឋ និងជាប្រធានក្រុមប្រឹក្សាប្រជាជនបដិវត្តន៍កម្ពុជា។

-ប៉ែន សុវណ្ណ ជាអនុប្រធានក្រុមប្រឹក្សាប្រជាជនបដិវត្តន៍កម្ពុជា និងជារដ្ឋមន្ត្រីក្រសួងការពារជាតិ និងជានាយករដ្ឋមន្ត្រី។

-ជា ស៊ីម ជារដ្ឋមន្ត្រីក្រសួងមហាផ្ទៃ។

-ហ៊ុន សែន ជារដ្ឋមន្ត្រីក្រសួងការបរទេស។

-កែវ ចិន្តា ជារដ្ឋមន្ត្រីក្រសួងឃោសនាការ ព័ត៌មាន និងវប្បធម៌។

-ចាន់ វ៉ែន ជារដ្ឋមន្ត្រីក្រសួងអប់រំ។

១៩. តើអង្គការរដ្ឋសំខាន់ៗនៅសម័យសាធារណរដ្ឋប្រជាមានិតកម្ពុជាមានប៉ុន្មាន? អ្វីខ្លះ?

ចម្លើយ៖ អង្គការរដ្ឋសំខាន់ៗមាន៤គឺ

-គណបក្សប្រជាជនបដិវត្តន៍កម្ពុជា ដឹកនាំដោយអគ្គលេខាសមមិត្ត ប៉ែន សុវណ្ណ ជាខ្មែរឥស្សរៈធ្លាប់រៀននៅទីក្រុងហាណូយឆ្នាំ១៩៥៤ ហើយតំណែងនេះត្រូវបានធ្លាក់មកលើ សមមិត្តហេង សំរិន នៅខែធ្នូ ១៩៨១។

-ក្រុមប្រឹក្សាប្រជាជនបដិវត្តន៍កម្ពុជា ឬក្រុមប្រឹក្សារដ្ឋមន្ត្រីមានចំនួន ១៧រូប ប្រធានគឺសម មិត្តប៉ែន សុវណ្ណ ហើយតំណែងនេះធ្លាក់លើសមមិត្ត ចាន់ ស៊ី នៅខែធ្នូ១៩៨១។

-ក្រុមប្រឹក្សារដ្ឋដែលមានសមមិត្ត ហេង សំរិន ជាប្រធាន។

-សភាជាតិមានសមាជិក១១៧រូប បង្កើតឡើងនៅខែឧសភា ឆ្នាំ ១៩៨១។ នៅខែមិថុនា ឆ្នាំ១៩៨១ សភាបើកការប្រជុំលើកទី១ ដើម្បីជ្រើសរើសប្រធានសភា គណៈរដ្ឋមន្ត្រី និងក្រុមប្រឹក្សារដ្ឋ។

២០. ប្រទេសកម្ពុជាត្រូវបានរំដោះពីរបបប្រល័យពូជសាសន៍កម្ពុជាប្រជាធិបតេយ្យក៏ពិតមែន តែកម្ពុជាបានបែកខ្ញែកជា៤ភាគី។ តើមានភាគីណាខ្លះ?

ចម្លើយ៖ ភាគីខ្មែរមាន៤គឺ

-ភាគីទី១ គឺរដ្ឋាភិបាលសាធារណរដ្ឋប្រជាមានិតកម្ពុជា ដឹកនាំដោយ ហេង សំរិន ភាគីនេះជាអ្នករំដោះកម្ពុជាពីរបបខ្មែរក្រហម ដោយមានការឧបត្ថម្ភគាំទ្រពីវៀតណាម សហភាពសូវៀត និងសម្ពន្ធមិត្តរបស់សូវៀត។

-ភាគីទី២ គឺកម្ពុជាប្រជាធិបតេយ្យ ឬខ្មែរក្រហម ដែលដឹកនាំដោយប៉ុល ពត ទោះបីជាខ្មែរក្រហមលែងគ្រប់គ្រងកម្ពុជាមែនពិត តែពួកគេនៅតែរក្សាអាសនៈរបស់ខ្លួននៅអង្គការសហប្រជាជាតិ។

-ភាគីទី៣ គឺរណសិរ្សសង្គ្រោះជាតិរំដោះប្រជាពលរដ្ឋខ្មែរប្រជាធិបតេយ្យ ដែលដឹកនាំដោយ សឺន សាន ភាគីនេះបង្កើតឡើងនៅថ្ងៃទី៩ ខែតុលា ឆ្នាំ១៩៧៩។ រណសិរ្សនេះមានទិសដៅសំខាន់៣គឺ រំដោះ

ប្រទេសកម្ពុជាពីអំណាចរបស់វៀតណាម ប្រឆាំងការរំលៃត្រឡប់មកកាន់អំណាចរបស់ខ្មែរក្រហម និងកសាងជាតិឡើងវិញ។ រណសិរ្សនេះកាន់កាប់ទឹកដី និងជំរំជនភៀសខ្លួនមួយចំនួននៅតាមព្រំដែនខ្មែរ-ថៃ។

-ភាគីទី៤ គឺក្រុមរាជានិយមរបស់សម្តេច នរោត្តម សីហនុ (ហ៊ុនស៊ិនបុិច) ភាគីនេះបង្កើតឡើងនៅនៅខែមីនា ឆ្នាំ១៩៨១ ដោយមានការចូលរួមពីក្រុមម៉ូលីណាកាដែលបង្កើតតាំងពីឆ្នាំ១៩៧៩។ ទិសដៅសំខាន់របស់ហ៊ុនស៊ិនបុិច គឺប្រឆាំងនឹងវត្តមានវៀតណាមនៅលើទឹកដីកម្ពុជា។

២១. បន្ទាប់ពីសមមិត្ត ប៉ែន សុវណ្ណ ជាប់គុក តើអ្នកណាជាអ្នកទទួលតំណែងជានាយករដ្ឋមន្ត្រី ឬជាអគ្គលេខាធិការបក្សបន្ត?

ចម្លើយ៖ សមមិត្ត ចាន់ ស៊ី។

២២. តើផែនការ ក៥ មានន័យដូចម្តេច? ហើយផែនការនេះតម្រូវឱ្យប្រជាពលរដ្ឋធ្វើអ្វីខ្លះ?

ចម្លើយ៖ ផែនការ ក៥ គឺមានន័យជាពាក្យពេញថា កែនកម្លាំង កាប់ឆ្ការព្រៃ ការពារព្រំដែន កម្ពុជា។

+ផែនការនេះតម្រូវឱ្យប្រជាពលរដ្ឋចូលរួមដើម្បី៖

-សាងសង់ផ្លូវនៅតាមព្រំដែន ដើម្បីសម្រួលក្នុងការដឹកជញ្ជូនកងទ័ពអាវុធ ស្បៀង

-កាប់ឆ្ការព្រៃនៅក្បែរភូមិ ជុំវិញផ្លូវថ្នល់ ផ្លូវដែក និងផ្លូវទឹក តាមជនបទ និងតាមតំបន់ព្រំដែនដើម្បីបំផ្លាញជម្រកលាក់ខ្លួនរបស់ពួកកងទ័ពនៃរដ្ឋាភិបាលត្រីភាគី។

-រៀបចំកសាងប្រព័ន្ធការពារនៅតាមបណ្តោយព្រំដែនខ្មែរ-ថៃ ដោយក្នុងនោះមានការដាក់ចម្រូងឫស្សី ដាក់មីន លើកទំនប់ និងជីកលេណដ្ឋានជាដើម។

២៣. តើសមមិត្ត ចាន់ ស៊ី បានទទួលមរណភាពនៅថ្ងៃខែឆ្នាំណា? នៅឯណា?

ចម្លើយ៖ នៅថ្ងៃទី៣១ ខែធ្នូ ឆ្នាំ១៩៨៤។ នៅទីក្រុងម៉ូស្គូ នៃសហភាពសូវៀត។

២៤. ក្រោយពីសមមិត្ត ចាន់ ស៊ី ទទួលមរណភាពទៅ តើអ្នកណាជាអ្នកដឹកនាំបន្ត?

ចម្លើយ៖ សមមិត្ត ហ៊ុន សែន។

២៥. តើសមមិត្ត ហ៊ុន សែន ត្រូវបានតែងតាំងជានាយករដ្ឋមន្ត្រីនៃរបបសាធារណរដ្ឋប្រជាមានិតកម្ពុជា នៅថ្ងៃខែឆ្នាំណា?

ចម្លើយ៖ នៅថ្ងៃទី១៤ ខែមករា ឆ្នាំ១៩៨៥។

២៦. នៅថ្ងៃទី១២ ខែមីនា ឆ្នាំ១៩៨៥ តើនាយករដ្ឋមន្ត្រីហ៊ុន សែន បានស្នើផែនការសន្តិភាពប៉ុន្មានចំណុច?អ្វីខ្លះ?

ចម្លើយ៖ នាយករដ្ឋមន្ត្រីហ៊ុន សែនបានស្នើផែនការសន្តិភាពផែនការសន្តិភាពមាន៦ខ ឬចំណុចគឺ

-ទី១ រំសាយកងទ័ពខ្មែរក្រហមចោលទាំងអស់។

-ទី២ ពេលកងទ័ពខ្មែរក្រហមរំសាយអស់ហើយ នោះវៀតណាមនឹងដកទ័ពគេចេញពីប្រទេសកម្ពុជា។
-ទី៣ ការចាត់តាំងការបោះឆ្នោតដែលមានការត្រួតពិនិត្យ។
-ទី៤ សន្តិសហវិជ្ជមានរវាងប្រទេសអាស៊ីអាគ្នេយ៍នានាដែលមានប្រព័ន្ធសង្គមនិងនយោបាយខុសគ្នា។
-ទី៥ បញ្ឈប់រាល់ការជ្រៀតជ្រែកពីប្រទេសនានា ដែលមិនស្ថិតនៅក្នុងតំបន់អាស៊ីអាគ្នេយ៍។
-ទី៦ បង្កើតឱ្យមានការធានាអន្តរជាតិនិងការត្រួតពិនិត្យកិច្ចព្រមព្រៀងនានា។

២៧. មូលហេតុអ្វីបានជាសមមិត្ត ប៉ែន សុវណ្ណ ត្រូវជាប់គុក?

ចម្លើយ៖ បានជាសមមិត្ត ប៉ែន សុវណ្ណ ត្រូវជាប់គុក ព្រោះសមមិត្ត ប៉ែន សុវណ្ណ បានប្រមាថដល់ទីក្រុងហាណូយយ៉ាងខ្លាំង ដោយចង់មានទំនាក់ទំនងដោយផ្ទាល់ជាមួយសហភាពសូវៀត ហើយរំលងវៀតណាម។ មួយវិញទៀត ប៉ែន សុវណ្ណ បានប្រឆាំងនឹងនយោបាយអន្តោប្រវេសន៍របស់ជនជាតិវៀតណាមមកលើកម្ពុជានិងការប៉ុនប៉ងរំដោះប្រទេសកម្ពុជារួចផុតពីការគាបសង្កត់របស់វៀតណាម ព្រមទាំងមានជម្លោះផ្ទៃក្នុងផងដែរ។

២៨. ចូររៀបរាប់សង្ខេបពីព្រឹត្តិការណ៍សំខាន់ៗនៅឆ្នាំ១៩៨១។

ចម្លើយ៖ សង្ខេបពីព្រឹត្តិការណ៍សំខាន់ៗនៅឆ្នាំ១៩៨១គឺ

-ថ្ងៃទី៨ ខែកុម្ភៈ ឆ្នាំ១៩៨១ សម្តេចនរោត្តម សីហនុ បានថ្លែងថាព្រះអង្គត្រៀមលក្ខណៈជាស្រេចដើម្បីដឹកនាំកម្លាំងទាំងអស់ ដែលប្រឆាំងនឹងវត្តមានកងទ័ពវៀតណាមនៅលើទឹកដីកម្ពុជា។
-ថ្ងៃទី២៦ ខែមីនា ឆ្នាំ១៩៨១ ការបង្កើតចលនារាជានិយម«ហ៊ុន សិនប៊ុច»នៅទីក្រុងប៉ារីស។
-ថ្ងៃទី៦ ខែឧសភា ឆ្នាំ១៩៨១ របបសាធារណរដ្ឋប្រជាមានិតកម្ពុជាបានបោះឆ្នោតជ្រើសតាំងរដ្ឋសភា(១១៧អសនៈ ១៤៨បេក្ខជន)។
-ថ្ងៃទី២៦-២៩ ឧសភា ១៩៨១ មហាសន្និបាតទី៤នៃបក្សប្រជាជនបដិវត្តន៍កម្ពុជា លោកប៉ែន សុវណ្ណត្រូវបានគេតែងតាំងជាអគ្គលេខាធិការបក្ស។។
-ថ្ងៃទី២៤ មិថុនា ១៩៨១ ការប្រជុំពេញអង្គលើកដំបូងបំផុតនៃរដ្ឋសភានៃរបបសាធារណរដ្ឋប្រជាមានិតកម្ពុជា លោក ជា ស៊ីម ត្រូវបានតែងតាំងជាប្រធានរដ្ឋសភា លោក ហេង សំរិន ជាប្រធានក្រុមប្រឹក្សារដ្ឋនិងលោក ប៉ែន សុវណ្ណ ជារដ្ឋមន្ត្រីទី១។
-ថ្ងៃទី៩ កក្កដា ១៩៨១ ការចេញផ្សាយរដ្ឋធម្មនុញ្ញនៃរបបសាធារណរដ្ឋប្រជាមានិតកម្ពុជា។
-ថ្ងៃទី៤ ធ្នូ ១៩៨១ លោកប៉ែន សុវណ្ណ ត្រូវបានដកតំណែងរដ្ឋមន្ត្រីទី១ និងពីមុខតំណែងអគ្គលេខាធិការបក្សប្រជាជនបដិវត្តន៍កម្ពុជា។

២៩. នៅឆ្នាំ១៩៨២ ក្រុមខ្មែរក្រហម(ភាគីទី២) ក្រុមសឺន សាន (ភាគីទី៣) និងក្រុមរាជានិយម(ភាគីទី៤) បានរួបរួមគ្នាបង្កើតរដ្ឋា

កិបាលសម្ព័ន្ធត្រីភាគី ដោយដឹកនាំដោយសម្តេចនរោត្តម សីហនុ។ តើគោលបំណងដើម្បីអ្វី?

ចម្លើយ៖ គោលបំណង គឺដើម្បី ប្រឆាំងនឹងវត្តមានវៀតណាមនៅកម្ពុជា និងរដ្ឋាភិបាលសាធារណរដ្ឋប្រជាមានិតកម្ពុជា(ភាគីទី១) តាមរយៈការទូត និងសង្គ្រាមឈ្លបៗ

៣០. នៅថ្ងៃទី១ ខែមីនា ឆ្នាំ១៩៨៣ តើប្រទេសចិនបានស្នើឱ្យប្រទេសវៀតណាមទទួលយកផែនការសន្តិភាពមួយដែលមានគោលការណ៍ប៉ុន្មានចំណុច? អ្វីខ្លះ?

ចម្លើយ៖ មានគោលការណ៍៥ចំណុចគឺ

-ទី១ ប្រទេសវៀតណាម ត្រូវសន្យាថានឹងដកកងទ័ពរបស់ខ្លួនចេញពីប្រទេសកម្ពុជាដោយឥតលក្ខខណ្ឌ។

-ទី២ សហភាពសូវៀតត្រូវឈប់គាំទ្រការឈ្លានពានរបស់កងទ័ពវៀតណាមលើទឹកដីកម្ពុជា។

-ទី៣ បន្ទាប់ពីវៀតណាមដកទ័ពមួយចំនួនពីកម្ពុជា ចិននឹងសុខចិត្តធ្វើការចរចាជាមួយវៀតណាមក្នុងគោលដៅឈានទៅរកប្រក្រតីកម្មនៃទំនាក់ទំនងរវាងប្រទេសទាំងពីរ។

-ទី៤ នៅពេលវៀតណាមដកកងទ័ពទាំងអស់ពីកម្ពុជា ប្រទេសកម្ពុជាត្រូវដោះស្រាយបញ្ហាខ្លួនដោយខ្លួនឯងគឺជ្រើសរើសប្រព័ន្ធគ្រប់គ្រងសង្គមដោយខ្លួនឯងនិងជ្រើសរើសរដ្ឋាភិបាលដែលគេប្រាថ្នាចង់បាន។

-ទី៥ ប្រទេសចិននិងប្រទេសនានាឯទៀត នៅក្នុងតំបន់ត្រូវសន្យាថានឹងមិនចូលជ្រៀតជ្រែកក្នុងកិច្ចការផ្ទៃក្នុងរបស់កម្ពុជា គឺត្រូវតែគោរពឯករាជ្យនិងអព្យាក្រឹតភាពនៃប្រទេសកម្ពុជា ព្រមទាំងលក្ខន្តិក:នៃបណ្តាប្រទេសមិនចូលបក្សសម្ព័ន្ធផងទៀត។

៣១. តើប្រទេសកម្ពុជា បានប្តូរឈ្មោះពីសាធារណរដ្ឋប្រជាមានិតកម្ពុជា មកជារដ្ឋកម្ពុជាវិញនៅថ្ងៃខែឆ្នាំណា ?

ចម្លើយ៖ ៣០ មេសា ១៩៨៩។

៣២. តើវៀតណាមបានដកកងទ័ពពីកម្ពុជានៅថ្ងៃខែឆ្នាំណា?

ចម្លើយ៖ ២៦ កញ្ញា ១៩៨៩។

៣៣. បន្ទាប់ពីវៀតណាមដកទ័ពចេញពីកម្ពុជា តើរដ្ឋាភិបាលកម្ពុជាបានធ្វើកំណែទម្រង់អ្វីខ្លះ?

ចម្លើយ៖ បន្ទាប់ពីវៀតណាមដកទ័ពចេញពីកម្ពុជា រដ្ឋាភិបាលកម្ពុជាបានធ្វើកំណែទម្រង់ដូចជា៖

-ការផ្លាស់ប្តូរភ្លេងជាតិ និងទង់ជាតិ

-ការធ្វើវិសោធនកម្មរដ្ឋធម្មនុញ្ញ

-ការដាក់ព្រះពុទ្ធសាសនា ជាសាសនារបស់រដ្ឋ

-ផ្តល់កម្មសិទ្ធិ ដល់ប្រជាពលរដ្ឋប្រជាកសិករខ្មែរអោចផ្ទេរកម្មសិទ្ធិដីធ្លីផ្ទះ ឬលំនៅដ្ឋានទៅឲ្យកូនចៅ ឬមានសិទ្ធិទិញនិងលក់អចលនទ្រព្យ

-ការលុបចោលទោសប្រហារជីវិត

-បង្កើតឲ្យមានសិទ្ធិសេរីភាពសារព័ត៌មាន និងអង្គការសង្គមស៊ីវិលឡើងវិញ

-លុបចោលលក្ខខ័ណ្ឌកំណត់អាយុសាងផ្ទះ លើបុរសខ្មែរពីអាយុ ៥០ឆ្នាំឡើងទៅ

-អនុញ្ញាតឲ្យមានការហូរចូលផលិតផលពីបរទេស និងឥទ្ធិពលសកលភាវូបនីយកម្ម ហើយរបបសមូហភាពនិយមបានដួលរលំ

៣៤. ចូរពណ៌នាពីការកសាងជាតិឡើងវិញ ក្រោយរបបខ្មែរក្រហមពីឆ្នាំ១៩៧៩ ដល់ឆ្នាំ១៩៩០។

ចម្លើយ៖ ការកសាងជាតិឡើងវិញ ក្រោយរបបខ្មែរក្រហមពីឆ្នាំ ១៩៧៩ ដល់ឆ្នាំ១៩៩០៖

+វិស័យនយោបាយ

-រំដោះប្រជាជនរួចផុតពីរបបប្រល័យពូជសាសន៍ប៉ុល ពត ទាំងស្រុង។

-ទប់ស្កាត់ការវិលត្រឡប់នៃរបបប្រល័យពូជសាសន៍ប៉ុល ពត។

-ទប់ស្កាត់អំពើអសកម្មក្នុងសង្គម ការជួញដូរមនុស្ស អាវុធ គ្រឿងញៀន។

-លើកកម្ពស់លទ្ធិប្រជាធិបតេយ្យ និងការគោរពសិទ្ធិមនុស្ស។

-ធ្វើកំណែទម្រង់រដ្ឋធម្មនុញ្ញ(វិសោធនកម្មរដ្ឋធម្មនុញ្ញ)។

-អនុវត្តនយោបាយបង្រួបបង្រួមជាតិ។

+វិស័យសេដ្ឋកិច្ច: រដ្ឋាភិបាលបានស្ថាបនាសេដ្ឋកិច្ចដោយ ៖

-បង្កើតក្រុមសាមគ្គីបង្កបង្កើនផល ដើម្បីជួយដល់ស្ត្រីមេម៉ាយ ក្មេងកំព្រា ចាស់ជរា...។

-ឆ្នាំ១៩៨០ បោះពុម្ពក្រដាសប្រាក់ឱ្យចាយវាយទូទាំងប្រទេស។

-ឆ្នាំ១៩៨៣-១៩៨៦ ប្តូរពីក្រុមសាមគ្គីបង្កបង្កើនផលទៅជាម្ចាស់ការទាំងស្រុងដោយធ្វើការបែងចែកដីធ្លី
និងឈានទៅរកកម្មសិទ្ធិឯកជន។
-អនុវត្តមុខព្រួញទាំង៤នៃសេដ្ឋកិច្ច។
-កសាងហេដ្ឋារចនាសម្ព័ន្ធសេដ្ឋកិច្ច (ផ្លូវថ្នល់ ស្ពាន កំពង់ផែ..) ។
-ពង្រឹងកិច្ចសហប្រតិបត្តិការសេដ្ឋកិច្ចជាមួយប្រទេសក្នុងតំបន់ និងពិភពលោក។
-ពង្រឹងសុខសន្តិភាព សុវត្ថិភាព និងសណ្តាប់ធ្នាប់សង្គមដើម្បីទាក់ទាញវិនិយោគទុនពីបរទេស។
-បង្កើតសេដ្ឋកិច្ចទីផ្សារសេរី និងជំរុញការអភិវឌ្ឍធនធានមនុស្ស។

+វិស័យសង្គមកិច្ច

-វិស័យអប់រំ : ប្រព័ន្ធអប់រំត្រូវបានស្តារឡើងវិញដោយ បើកទ្វារសាលាគ្រប់ភូមិសិក្សា ដល់ឧត្តមសិក្សាទទួលសិស្សឱ្យចូលរៀនតាំងពីទីក្រុងដល់ជនបទ ធ្វើការជ្រើសរើស និងបណ្តុះបណ្តាលគ្រូបង្រៀន ជំរុញនិងបំផុសចលនាអនក្ខរកម្ម បំពេញវិជ្ជា អនុវត្តនយោបាយ« អ្នកចេះច្រើនបង្រៀនអ្នកចេះតិច អ្នកចេះតិចបង្រៀនអ្នកមិនចេះ » បញ្ជូនសិស្ស និស្សិតទៅសិក្សានៅបរទេស និងអញ្ជើញគ្រូបរទេសមកបង្ហាត់បង្រៀនកូនខ្មែរនៅក្នុងប្រទេស...។
-វិស័យវប្បធម៌: បើកសេរីភាពដល់ជំនឿ សាសនា ប្រពៃណីទំនៀមទម្លាប់ បើកទ្វារសាលាវិចិត្រសិល្បៈ និងប្រមូលផ្តុំសិល្បករ។

-វិស័យសង្គមកិច្ច : បង្កើតមជ្ឈមណ្ឌលកុមារកំព្រា បង្កើតសាលាបណ្តុះបណ្តាលវិជ្ជាជីវៈ សម្រាប់ជនពិការ និងស្ត្រីមេម៉ាយ បង្កើតច្បាប់ការពារកម្មសិទ្ធិឯកជន (១៩៨៧)។

-វិស័យសុខាភិបាល : បើកទ្វារមន្ទីពេទ្យទទួលពិនិត្យ និងព្យាបាលជំងឺ បើកទ្វារសាលាបណ្តុះបណ្តាលពេទ្យ មានមហាវិទ្យាល័យ វេជ្ជសាស្ត្រ ឱសថសាស្ត្រ ទន្តសាស្ត្រ.។

៣៥. តើសេដ្ឋកិច្ចរបស់សាធារណរដ្ឋប្រជាមានិតកម្ពុជា ពឹងផ្អែកលើអ្វីខ្លះ?

ចម្លើយ៖ សេដ្ឋកិច្ចរបស់សាធារណរដ្ឋប្រជាមានិតកម្ពុជា ពឹងផ្អែកលើមុខព្រួញសំខាន់ៗ៤គឺ

-វិស័យកសិកម្ម៖ ប្រជាជន៨៨% ជាកសិករ។ វិធានការពាយ៉ាងសម្រាប់ផលិតកម្មស្បៀងគឺ ពង្រីកផ្ទៃដីដាំដុះ និងប្រពលវប្បកម្ម។

-កៅស៊ូ៖ ជាផលិតផលឧស្សាហកម្មយ៉ាងសំខាន់សម្រាប់នាំចេញទៅបរទេស។

-អាជីវកម្មឈើ៖ កម្ពុជាសម្បូរឈើ ដូចនេះវាជាមុខព្រួញសម្រាប់នាំចេញ។

-នេសាទ៖ ខ្មែរសម្បូរត្រីទឹកសាប ទឹកប្រៃ ហើយត្រីអាចដោះស្រាយជីវភាពប្រជាជនបានមួយកម្រិតធំ។

៣៦. តើចម្ការកៅស៊ូមាននៅខេត្តណាខ្លះ? ហេតុអ្វីបានជាកៅស៊ូ ជាមូលដ្ឋានសម្រាប់នាំចេញ?

ចម្លើយ៖ ដំណាំកៅស៊ូមាននៅខេត្តកំពង់ចាម កំពង់សោម ក្រចេះ រតនគិរី។

+បានជាកៅស៊ូ ជាមូលដ្ឋានសម្រាប់នាំចេញ ព្រោះកៅស៊ូមានអត្ថប្រយោជន៍ជាច្រើននិងជាវត្ថុធាតុដើមយ៉ាងសំខាន់សម្រាប់វិស័យឧស្សាហកម្ម។ កម្ពុជាមានកៅស៊ូច្រើននិងពុំមានរោងចក្រផលិតផលសម្រេច ទើបកៅស៊ូត្រូវនាំចេញទៅបរទេស។

៣៧. តើគម្រោងការជួបចរចារវាងនរោត្តម សីហនុ និងតំណាងសាធារណរដ្ឋប្រជាមានិតកម្ពុជានៅឆ្នាំណា?

ចម្លើយ៖ នៅខែវិច្ឆិកា ឆ្នាំ១៩៨៤ តែគម្រោងនេះត្រូវបរាជ័យព្រោះតែប្រទេសចិននិងក្រុមត្រីភាគីបដិសេធ។

៣៨. តើរដ្ឋមន្ត្រីការបរទេសឥណ្ឌូនេស៊ីបានធ្វើទស្សនកិច្ចជាផ្លូវការនៅវៀតណាមនៅពេលណា? ហើយពិភាក្សាអ្វីខ្លះពីបញ្ហាជម្លោះនៅកម្ពុជា?

ចម្លើយ៖ រដ្ឋមន្ត្រីការបរទេសឥណ្ឌូនេស៊ីបានធ្វើទស្សនកិច្ចជាផ្លូវការនៅវៀតណាមនៅថ្ងៃទី២៧ ខែកក្កដា ឆ្នាំ១៩៨៧។ បានពិភាក្សាលើរូបមន្តនៃការជួបចរចារវាងគូវិវាទខ្មែរទាំងអស់ជាពីរដំណាក់កាលគឺ

-ការជួបគ្នារវាងភាគីខ្មែរនិងខ្មែរ

-ការជួបគ្នារវាងភាគីខ្មែរនិងប្រទេសពាក់ព័ន្ធ ដើម្បីដោះស្រាយបញ្ហានយោបាយនៅកម្ពុជា។

៣៩. តើជំនួបលើកទី១ និងលើកទី២ រវាងនរោត្តម សីហនុ និងលោក ហ៊ុន សែន ធ្វើនៅឯណា? បានលទ្ធផលដូចម្តេច?

ចម្លើយ៖ ជំនួបលើកទី១ និងលើកទី២ រវាងនរោត្តម សីហនុ និង លោក ហ៊ុន សែនគឺ៖

-ជំនួបលើកទី១៖ នាថ្ងៃទី២ ខែធ្នូ ឆ្នាំ១៩៨៧ នៅទីក្រុងហ្វ្រៃអង់តាដឺ នរ(បារាំង) រវាងសម្តេចនរោត្តម សីហនុ និងលោក ហ៊ុន សែន ដោយបានចុះហត្ថលេខាព្រមព្រៀងរកដំណោះស្រាយបញ្ហានៅកម្ពុជា។

-ជំនួបលើកទី២៖ នៅថ្ងៃទី២១-២២ ខែមេសា ឆ្នាំ១៩៨៨ នាប្រទេសបារាំង ប៉ុន្តែមិនបានចេញសេចក្តីប្រកាសរួមគ្នាណាមួយឡើយ។ ចំណែកគម្រោងជំនួបលើកទី៣-៤-៥ ត្រូវបានលុបចោលទាំងអស់។

៤០. ហេតុអ្វីបានជារដ្ឋាភិបាលរដ្ឋកម្ពុជាប្រកាសកំណែទម្រង់ជាបន្តបន្ទាប់?

ចម្លើយ៖ បានជារដ្ឋាភិបាលរដ្ឋកម្ពុជាប្រកាសកំណែទម្រង់ជាបន្តបន្ទាប់ ព្រោះដើម្បីលើកកម្ពស់នយោបាយក្រៅប្រទេស ការរៀបចំប្រទេសឱ្យស្របតាមសាកលភាវូបនីយកម្ម និងបង្ហាញទម្រង់ថ្មីគឺចេញពីសង្គមនិយម។

៤១. តើអ្វីជាបញ្ហារបស់កម្ពុជា?

ចម្លើយ៖ បញ្ហារបស់កម្ពុជា គឺជាការប្រឈមមុខដាក់គ្នារវាងរដ្ឋាភិបាលសាធារណរដ្ឋប្រជាមានិតកម្ពុជានិងកម្លាំងតស៊ូត្រីភាគី គឺខ្មែរក្រហម នរោត្តម សីហនុ និងសឺន សាន ដែលមានការប៉ះទង្គិចគ្នាជារឿយៗជាពិសេសជាមួយខ្មែរក្រហម។

៤២.តើអ្នកណាដែលខិតខំរកដំណោះស្រាយបញ្ហាកម្ពុជា?

ចម្លើយ៖ គឺរដ្ឋមន្ត្រីការបរទេសថៃ លោកស៊ីឌី សាវេតស៊ីឡា និងរដ្ឋមន្ត្រីការបរទេសឥណ្ឌូនេស៊ី លោក អាលីអាឡា តាស តាមរយៈកិច្ចប្រជុំនៅទីក្រុងហ្សាកាតា៣លើក។

៤៣. តើSNC បង្កើតឡើងនៅថ្ងៃខែឆ្នាំណា? មានសមាជិកប៉ុន្មានរូប?

ចម្លើយ៖ SNC (Supreme National Council) ប្រែជាខ្មែរថា ក្រុមប្រឹក្សាជាតិជាន់ខ្ពស់។ បង្កើតឡើងនៅថ្ងៃទី១០ ខែកញ្ញា ឆ្នាំ ១៩៩០។

+សមាជិកមានចំនួន១២រូប ដែលក្នុងនោះមាន៦រូបមកពីភាគីរដ្ឋកម្ពុជា និង៦រូបទៀតមកពីចលនាតស៊ូត្រីភាគី(២+២+២) មានដូចជា៖

-សម្តេចនរោត្តមសីហនុ ជាប្រធានក្រុមប្រឹក្សា

-លោកឱត មន្ទីរ(ប្រជាជន)

-លោក ហោ ណាំហុង(ប្រជាជន)

-សម្តេច ហ៊ុនសែន(ប្រជាជន)

-លោក អៀង ម៉ូលី(រណសិរ្សសឺនសាន)

-លោក អ៊ឹម ឈុនលឹម(ប្រជាជន)

-លោក ខៀវ សំផន(កម្ពុជាប្រជាធិបតេយ្យ)

-អ្នកអង្គម្ចាស់នរោត្តម រណឫទ្ធិ(ហ៊ុនសិនប៊ិច)

-លោក សឺន សាន (រណសិរ្សសឺន សាន)

-លោក សុន សេន(កម្ពុជាប្រជាធិបតេយ្យ)

-លោក ទៀ បាញ់(ប្រជាជន)

៤៤. តើSNCមានភារកិច្ចអ្វីខ្លះក្នុងដំណាក់កាលអន្តរកាល?

ចម្លើយ៖ SNCមានភារកិច្ចក្នុងដំណាក់កាលអន្តរកាល ដូចជា៖

-បញ្ឈប់ការបាញ់គ្នា ជំនួយយោធា បញ្ឈប់ជំនួយ និងសកម្មភាពគ្រប់ប្រភេទដែលនាំឲ្យមានការប្រយុទ្ធសារជាថ្មី។

-ប្រគល់នូវសិទ្ធិអំណាច និងស្ថាប័នដែលទាក់ទងនឹងវិស័យសេដ្ឋកិច្ច ការបរទេស ការពារជាតិនិងឃោសនាឲ្យ ស្ថិតនៅក្រោមការត្រួតពិនិត្យរបស់អ៊ុនតាក់(UNTAC)។

-រំសាយកងទ័ព ការកាត់បន្ថយអាវុធ និងការប្រមូលផ្តុំក្នុងបន្ទាយដែលរៀបចំដោយអ៊ុនតាក់។

-រាយការណ៍ទៅអ៊ុនតាក់ពីព័ត៌មានទាក់ទងនឹងស្ថានភាពនៃកងកម្លាំងប្រដាប់អាវុធយុទ្ធភណ្ឌ ព្រមទាំងឃ្លាំង លាក់អាវុធរបស់គូភាគីជម្លោះទាំងអស់។

-រៀបចំច្បាប់បោះឆ្នោតជាមួយអ៊ុនតាក់។

-បង្កើតបក្សថ្មីដែលជាបក្សខ្មែរ ដើម្បីចូលរួមប្រកួតប្រជែងក្នុងការបោះឆ្នោត។

-ព្រមទទួលស្គាល់លទ្ធផលនៃការបោះឆ្នោតដែលរៀបចំនិងប្រកាសដោយអ៊ុនតាក់។

-ផ្ទេរអំណាចដោយសន្តិវិធីទៅឲ្យភាគីដែលឈ្នះឆ្នោត។

៤៥. តើគូបដិបក្ខទាំងបួនបានជួបជុំគ្នានៅឯណា? ពេលណា?

ចម្លើយ៖ គូបដិបក្ខទាំងបួន បានជួបជុំគ្នានៅប៉ាតាយ៉ា(ប្រទេសថៃ) នាថ្ងៃទី២៣-២៤ មិថុនា ១៩៩១ ហើយបានចុះសម្រុងគ្នាអំពីគម្រោងដោះស្រាយបញ្ហាជាតិ។ លក្ខខណ្ឌនេះដែលបានជំរុញឱ្យមានសន្និសីទក្រុងប៉ារីស នាថ្ងៃទី២៣ ខែតុលា ឆ្នាំ១៩៩១ ដើម្បីទម្លុះទម្លាយវិបត្តិនយោបាយនៅកម្ពុជា។

៤៦. តើលទ្ធផលនៃកិច្ចចរចាសន្តិភាពទីក្រុងប៉ារីស២៣ តុលា ១៩៩១ ទទួលបានអ្វីខ្លះ?

ចម្លើយ៖ កិច្ចចរចាសន្តិភាពទីក្រុងប៉ារីស បានលទ្ធផលយ៉ាងប្រសើរដោយតំណាងភាគីជម្លោះបានចាប់ដៃគ្នា យល់ព្រមធ្វើការបោះឆ្នោតជាសាកលដែលមានអ៊ុនតាក់មើលខុសត្រូវ។

៤៧. តើអាជ្ញាធរបណ្តោះអាសន្នរបស់អង្គការសហប្រជាជាតិ ដែលមកកម្ពុជាមានចំនួនប៉ុន្មាន?

ចម្លើយ៖ មានចំនួន១៧០០០នាក់ និងជនស៊ីវិល៨០០០នាក់មកពី ២២ប្រទេស។

៤៨. តើអ៊ុនតាក់ (UNTAC) មានតួនាទីអ្វីខ្លះនៅកម្ពុជា?

ចម្លើយ៖ តួនាទីរបស់អ៊ុនតាក់មាន៖

-ដកហូតអាវុធ ដែលប្រឈមមុខដាក់គ្នារវាងកងទ័ពរដ្ឋាភិបាល និងខ្មែរក្រហម កងទ័ពរណសិរ្សរំដោះប្រជាពលរដ្ឋខ្មែរនិងកងទ័ពអ្នករាជានិយម

-បញ្ជូនរដ្ឋអំណាចតាំងពីរឲ្យជួបចរចាគ្នា

-រៀបចំការបោះឆ្នោតដោយសេរីមួយនៅកម្ពុជា

-នាំជនភៀសខ្លួន ប្រហែល៣៥0,000នាក់មាតុភូមិនិវត្ត ។

៤៩. តើប្រទេសណាខ្លះដែលចូលរួមក្នុងកិច្ចចរចាថ្ងៃ២៣ តុលា ១៩៩១?

ចម្លើយ៖ ប្រទេសដែលចូលរួមមាន១៨ប្រទេសគឺ អូស្ត្រាលី កាណាដា ប្រ៊ុយណេ ចិន យូហ្គោស្លាវី សហរដ្ឋអាមេរិក បារាំង ឥណ្ឌា ឥណ្ឌូនេស៊ី ជប៉ុន ឡាវ ម៉ាឡេស៊ី ហ្វីលីពីន អង់គ្លេស សិង្ហបុរី ថៃ សហភាពសូវៀត និងវៀតណាម។

៥0. តើការបោះឆ្នោតឆ្នាំ១៩៩៣ បានប្រព្រឹត្តទៅដោយប៉ុន្មានគណបក្សចូលរួម?

ចម្លើយ៖ ការបោះឆ្នោតឆ្នាំ១៩៩៣ បានប្រព្រឹត្តទៅនៅថ្ងៃទី២៣-២៨ ខែឧសភា មានគណបក្ស២0ចូលរួមដែលក្នុងនោះខ្មែរក្រហមពហិការមិនចូលរួម។

៥១. តើគណបក្សណាឈ្នះឆ្នោត?

ចម្លើយ៖ គណបក្សហ្វុនស៊ិនប៉ិចឈ្នះឆ្នោត តែកាន់អំណាចជារដ្ឋាភិបាលចម្រុះ ដែលមានព្រះអង្គម្ចាស់រណឫទ្ធ ជានាយករដ្ឋមន្ត្រីទី១ និងលោក ហ៊ុន សែន ជានាយករដ្ឋមន្ត្រីទី២។

៥២. តើរដ្ឋធម្មនុញ្ញថ្មីប្រកាសឱ្យប្រើប្រាស់ជាផ្លូវការនៅពេលណា?

ចម្លើយ៖ ប្រកាសនៅថ្ងៃទី២៤ ខែកញ្ញា ឆ្នាំ១៩៩៣។

៥៣. ចូរអ្នកពណ៌នាឡើងវិញពីរបបសាធារណរដ្ឋប្រជាមានិតកម្ពុជា។

ចម្លើយ៖ ពណ៌នាពីរបបសាធារណរដ្ឋប្រជាមានិតកម្ពុជាគឺ

+អង្គការគ្រប់គ្រងសំខាន់ៗនៃរដ្ឋាភិបាលសាធារណរដ្ឋប្រជាមានិតកម្ពុជា៖ របបសាធារណរដ្ឋប្រជាមានិតកម្ពុជាគ្រប់គ្រងដោយគណបក្សតែមួយ គឺគណបក្សប្រជាជនបដិវត្តន៍កម្ពុជា និងមានអង្គការចាត់តាំងចំនួន៤គឺ៖

-គណបក្សប្រជាជនបដិវត្តន៍កម្ពុជា

-ក្រុមប្រឹក្សាប្រជាជនបដិវត្តន៍ ឬក្រុមប្រឹក្សារដ្ឋមន្ត្រី

-ក្រុមប្រឹក្សារដ្ឋ

-រដ្ឋសភាជាតិ

+រដ្ឋអំណាចខ្មែរ

-ដំណាក់កាលដំបូង ៖ ក្រសួងសំខាន់ៗគ្រប់គ្រងដោយមនុស្សពីរក្រុមគឺអ្នកតស៊ូចាស់ៗនៅភូមិភាគបូព៌ា (សមមិត្ត ហេង សំរិន សមមិត្ត ជា ស៊ីម សមមិត្ត ហ៊ុន សែន) និងអ្នករៀននៅវៀតណាមក្រោយសន្និសីទហ្សឺណែវឆ្នាំ១៩៥៤ (សមមិត្ត ប៉ែន សុវណ្ណ និងចាន់ ស៊ី)។

-ដំណាក់កាលបន្ទាប់៖ ពេលសន្តិសុខប្រទេសមានលំនឹងរដ្ឋាភិបាលជ្រើសរើសអ្នកមានសមត្ថភាពឱ្យបម្រើក្នុងក្បាលម៉ាស៊ីនដឹកនាំរដ្ឋ។

+ជំនាញការ និងកងទ័ពវៀតណាម

-អ្នកជំនាញការវៀតណាមអមរដ្ឋអំណាចខ្មែរតាំងពីថ្នាក់ក្រសួងដល់ថ្នាក់មូលដ្ឋាន ដើម្បីជួយពង្រឹងរដ្ឋបាលសាធារណរដ្ឋប្រជាមានិតកម្ពុជា

-កងទ័ពវៀតណាមនៅពេញផ្ទៃប្រទេស ដើម្បីជួយទប់ស្កាត់ការវិលត្រឡប់មកវិញនៃរបបប្រល័យពូជសាសន៍

របបសាធារណរដ្ឋប្រជាមានិតកម្ពុជាមានកាតព្វកិច្ចចាំបាច់ពីរគឺ ការកសាងសន្តិភាព និងការស្តារបនាជាតិឡើងវិញ។

+កិច្ចការការពារជាតិ ៖ ដើម្បីទប់ស្កាត់ការវិលត្រឡប់មកវិញនូវរបបខ្មែរក្រហម រដ្ឋាភិបាលសាធារណរដ្ឋប្រជាមានិតកម្ពុជាបានចាត់វិធានការដូចតទៅ៖

-បង្កើតកងសេនាជនភូមិ

-បង្កើតក្រុមស្វ័យការពារ ក្រុមយាមកាម

-ធ្វើការជ្រើសរើសកងទ័ព

-បង្កើតកាតព្វកិច្ចយោធា

-ធ្វើការហ្វឹកហាត់ក្បួនយោធាដល់សិស្ស និស្សិតមុនចូលរៀន

-លើកទ័ពវាយលុកលើខ្មែរក្រហមនារដូវប្រាំ និងធ្វើការគ្រប់គ្រងតំបន់តាមព្រំដែន

-បង្កើនការការពារនៅតាមព្រំដែនកម្ពុជា-ថៃ ដោយអនុវត្តផែនការក៥

-ស្វែងរកការចរចាបញ្ចប់សង្គ្រាម

+ការកសាងជាតិរដ្ឋាភិបាលបានរៀបចំកសាងដូចជា៖

+ការស្តារបនាសេដ្ឋកិច្ច

-អំពាវនាវសុំជំនួយពីសហគមន៍អន្តរជាតិ

-បង្កើតក្រុមសាមគ្គីបង្កបង្កើនផល

-ឆ្នាំ១៩៨០ បោះពុម្ពក្រដាសប្រាក់ឱ្យចាយវាយទូទាំងប្រទេស
-ឆ្នាំ១៩៨៣-១៩៨៦ ប្តូរពីក្រុមសាមគ្គីបង្កបង្កើនផលទៅជាម្ចាស់ការទាំងស្រុងដោយធ្វើការបែងចែកដីធ្លីនិងឈានទៅរកកម្មសិទ្ធិឯកជន
-អនុវត្តមុខព្រួញទាំង៤នៃសេដ្ឋកិច្ច

+ការស្តាបនាសង្គម

+វិស័យអប់រំ

-ការបើកទ្វារសាលាទទួលសិស្ស និស្សិតឱ្យចូលរៀន
-ធ្វើការជ្រើសរើស និងបណ្តុះបណ្តាលគ្រូ
-ជំរុញចលនាអក្ខរកម្ម និងបំពេញវិជ្ជា
-អនុវត្តនយោបាយ«អ្នកចេះច្រើនបង្រៀនអ្នកចេះតិច ឯអ្នកចេះតិចបង្រៀនអ្នកមិនចេះសោះ»
-បញ្ជូននិស្សិតឱ្យទៅសិក្សានៅឯបរទេស

+វិស័យវប្បធម៌

-បើកសេរីភាពដល់ជំនឿ សាសនា ប្រពៃណី ទំនៀមទម្លាប់
-បើកទ្វារសាលាវិចិត្រសិល្បៈនិងប្រមូលផ្តុំសិល្បករ

+វិស័យសង្គមកិច្ច

-បង្កើតមជ្ឈមណ្ឌលកុមារកំព្រា
-បង្កើតសាលាបណ្តុះបណ្តាលវិជ្ជាជីវៈ សម្រាប់ជនពិការនិងស្ត្រីមេម៉ាយ
-បង្កើតច្បាប់ការពារកម្មសិទ្ធិឯកជន

+វិស័យសុខាភិបាល

-បើកទ្វារមន្ទីរពេទ្យទទួលពិនិត្យ និងព្យាបាលជំងឺ
-បើកទ្វារសាលាបណ្តុះបណ្តាលពេទ្យ មានមហាវិទ្យាល័យវេជ្ជសាស្ត្រ ឱសថសាស្ត្រ ទន្តសាស្ត្រ។

សំណួរនិងចម្លើយពីឆេះពីឆោះ ស្តីពីប្រវត្តិវិទ្យា

១. មូលហេតុអ្វីបានជារដ្ឋាភិបាលកម្ពុជាបង្កើតនយោបាយរួបរួមជាតិ?

ចម្លើយ៖ មូលហេតុបានជារដ្ឋាភិបាលកម្ពុជាបង្កើតនយោបាយរួបរួមជាតិគឺ៖
-ដើម្បីស្វែងរកដំណោះស្រាយវិបត្តិនយោបាយកម្ពុជា
-ដើម្បីបញ្ចប់ជម្លោះរវាងខ្មែរ និងខ្មែរ
-ឱ្យភាគីខ្មែរទាំងបួនក្រុមសម្រុះសម្រួលគ្នា ដោះស្រាយបញ្ហាជាតិ
-ឈានទៅរកការបោះឆ្នោតជាសកល ក្នុងគោលបំណងឱ្យមានឯកភាពជាតិ។
-ស្តារប្រទេសជាតិឡើងវិញ។
-ធានាឱ្យអ្នកនយោបាយ និងប្រជាពលរដ្ឋដែលមាននិន្នាការនយោបាយផ្សេងគ្នា មានភាពអត់ឱន យោគយល់ និងទុកចិត្តគ្នាទៅវិញទៅមក។
-ធ្វើឱ្យប្រជាពលរដ្ឋគ្រប់រូបឈប់ខ្លាចដោយសារឿងនយោបាយ។

២. ចូរពណ៌នាពីការខិតខំចរចារកសន្តិភាពនិងការបង្រួបបង្រួមជាតិនៅកម្ពុជា។

ចម្លើយ៖ ការខិតខំចរចារកសន្តិភាពនិងការបង្រួបបង្រួមជាតិនៅកម្ពុជា៖

-ខែវិច្ឆិកា ១៩៨៤ប្រទេសបារាំងរៀបចំគម្រោងជំនួបរវាងនរោត្តម សីហនុ និងតំណាងសាធារណរដ្ឋប្រជាមានិតកម្ពុជា។

-ឆ្នាំ១៩៨៥ សភាពការណ៍នយោបាយនៅអាស៊ី អនុគ្រោះដល់ការចរចារកសន្តិភាពនៅកម្ពុជា។

-ខែកក្កដា ១៩៨៧ ទស្សនកិច្ចជាផ្លូវការរបស់រដ្ឋមន្ត្រីការបរទេសឥណ្ឌូនេស៊ី នៅវៀតណាមពិភាក្សាលើរូបមន្តនៃការជួបគ្នារវាងគូវិវាទខ្មែរទាំងអស់ជាពីរដំណាក់កាល គឺការជួបគ្នារវាងបណ្តាភាគីខ្មែរបដិបក្ខទាំងពីរ និងការជួបគ្នារវាងបណ្តាភាគីខ្មែរ និងប្រទេសពាក់ព័ន្ធដើម្បីដោះស្រាយនយោបាយនៅកម្ពុជា។

-ឆ្នាំ១៩៨៧ ជំនួបកំពូលរវាងអាមេរិក និងសហភាពសូវៀតធ្វើឲ្យសភាពការណ៍នៅកម្ពុជាធូរស្រាល។

-ខែសីហា និងតុលា ១៩៨៧ រដ្ឋាភិបាលសាធារណរដ្ឋប្រជាមានិតកម្ពុជាដាក់សំណើសន្តិភាពនិងបង្រួបបង្រួមជាតិទៅភាគីសម្តេចនរោត្តមសីហនុ

-ថ្ងៃទី២ ខែធ្នូ ឆ្នាំ១៩៨៧ ជួបលើកទី១ រវាងសម្តេចនរោត្តម សីហនុ និងសម្តេច ហ៊ុនសែន។

-ជំនួបលើកទី២ រវាងសម្តេចនរោត្តមសីហនុ និងសម្តេចហ៊ុន សែន ប្រព្រឹត្តទៅនៅលើទីក្រុងប៉ារីស នៅហ្សាកាតា និងប៉ាតាយ៉ា ដើម្បីដោះស្រាយនយោបាយកម្ពុជា។
-ថ្ងៃទី២៦ កញ្ញា ១៩៨៩ កងទ័ពវៀតណាមដកចេញពីកម្ពុជា។
-ថ្ងៃទី៣០ កក្កដា ដល់ ៣០ សីហា ១៩៨៩ នៅទីក្រុងប៉ារីស សហប្រធាន(បារាំងនិងឥណ្ឌូនេស៊ី) បានបង្កើតក្រុមប្រឹក្សាជាតិជាតិខ្ពស់ (SNC) នៅថ្ងៃទី១០ ខែកញ្ញា ឆ្នាំ១៩៩០ ដែលមានសមាជិក១២រូប(៦រូប មកពីភាគីរដ្ឋកម្ពុជា និង៦រូបទៀតមកពីសម្ព័ន្ធត្រីភាគី) ក្រុមប្រឹក្សាជាតិជាន់ខ្ពស់ប្រជុំនៅទីក្រុងបាងកក នៅ ប្រទេសបារាំង ក្រុងញូយ៉ក ហ្សាកាតា ប៉ាតាយ៉ា និងប៉េកាំង ដើម្បីរកដំណោះស្រាយបញ្ចប់សង្គ្រាមនៅកម្ពុជា។
-ថ្ងៃទី២៣-២៤ មិថុនា ១៩៩១ ភាគីទាំង៤បានស្រុះស្រួលគ្នាដោះស្រាយបញ្ហាជាតិ។
-ថ្ងៃទី២៣ ខែតុលា ១៩៩១ សន្និសីទទីក្រុងប៉ារីស បានចុះកិច្ចព្រមព្រៀងចុះហត្ថលេខាលើសន្ធិសញ្ញាសន្តិភាព ហើយវិបត្តិនយោបាយនៅកម្ពុជាត្រូវបានបញ្ចប់។
-ថ្ងៃទី២៣-២៨ ខែឧសភា ឆ្នាំ១៩៩៣ ការបោះឆ្នោតដោយសេរីនិងយុត្តិធម៌បានរៀបចំឡើងដោយអ៊ុនតាក់
-នយោបាយឈ្នះ-ឈ្នះ របស់សម្តេច ហ៊ុន សែន
-ឆ្នាំ១៩៩៨ សមាហរណកម្ម កងកម្លាំងខ្មែរក្រហម ឲ្យចូលមករួមរស់ជាមួយរដ្ឋាភិបាលដែលនាំសន្តិភាពពេញលេញមកឲ្យកម្ពុជា។

៣. តើសន្តិភាពដែលសម្រេចបានឆ្នាំ១៩៩៨ បាននាំមកនូវការអភិវឌ្ឍនៅក្នុងប្រទេសកម្ពុជាលើវិស័យអ្វីខ្លះ?

ចម្លើយ៖ សន្តិភាពដែលសម្រេចបានឆ្នាំ១៩៩៨ បាននាំមកនូវការអភិវឌ្ឍនៅក្នុងប្រទេសកម្ពុជាលើវិស័យដូចជា៖

+វិស័យនយោបាយ

នយោបាយក្នុងប្រទេស

-កម្ពុជាបានសុខសន្តិភាព និងមានស្ថិរភាពនយោបាយ

-ការបោះឆ្នោតជ្រើសរើសអ្នកដឹកនាំតាមបែបលទ្ធិប្រជាធិបតេយ្យ។

នយោបាយក្រៅប្រទេស

-១៩៩៩ កម្ពុជាចូលជាសមាជិកអាស៊ាន

-២០០៤ ចូលជាសមាជិកអង្គការពាណិជ្ជកម្មពិភពលោក

-២០១២ កម្ពុជាធ្វើជាប្រធានអាស៊ាន

-កម្ពុជាមានទំនាក់ទំនងល្អជាមួយប្រទេសក្នុងតំបន់និងក្នុងពិភពលោក

+វិស័យសេដ្ឋកិច្ច

-កសិកម្ម ៖ កំណើនទិន្នផលកសិកម្មព្រោះសម្បូរទីផ្សារ

-ឧស្សាហកម្ម៖ កំណើនរោងចក្រ សហគ្រាស ....

-ពាណិជ្ជកម្ម៖ សម្បូរវិនិយោគិន សម្បូរទីផ្សារ...

-ហិរញ្ញវត្ថុ៖ ស្ថិរភាពអត្រាប្តូរប្រាក់

-គមនាគមន៍៖ មានការសាងសង់ស្ពាន ផ្លូវពីទីក្រុងដល់ជនបទ ដោយមានប្រព័ន្ធទឹកភ្លើងគ្រប់ទីកន្លែង និង កំណើនសេដ្ឋកិច្ចជារៀងរាល់ឆ្នាំ។

+វិស័យសង្គមកិច្ច

-ការអប់រំ៖ មានសាលារៀនគ្រប់កម្រិត គ្រប់ទីកន្លែង និងមានកំណើនធនធានមនុស្ស

-វប្បធម៌៖ គាស់កកាយវប្បធម៌ឲ្យរស់ឡើងវិញ ដាក់បញ្ចូលសម្បត្តិវប្បធម៌ជាបេតិកភណ្ឌពិភពលោក

-សុខដុមរមនាក្នុងសាសនា

-សុខាភិបាល៖ មានការបង្កើតមន្ទីរពេទ្យ មណ្ឌលសុខភាព ពីទីក្រុងដល់ជនបទ

-ផ្តល់សិទ្ធិដល់ស្ត្រី(សមភាពយេនឌ័រ)។

៤. តើចំណុចសំខាន់នៃគោលនយោបាយឈ្នះ-ឈ្នះមានប៉ុន្មានចំណុច? អ្វីខ្លះ?

ចម្លើយ៖ ចំណុចសំខាន់នៃគោលនយោបាយឈ្នះ-ឈ្នះមាន ៣ ចំណុចគឺ៖

-ការធានាដល់អាយុជីវិត និងសុវត្ថិភាពរបស់អតីតគូបដិបក្ស

-ការផ្តល់ការងារ និងអាជីពដល់អ្នកដែលបានដាក់អាវុធ

-ការទទួលស្គាល់កម្មសិទ្ធិលើទ្រព្យ ជាពិសេសដី និងអគារដែលពួកគេកាន់កាប់។

៥. ចូររៀបរាប់ពីព្រឹត្តិការណ៍សំខាន់ៗនៃប្រវត្តិសាស្ត្រកម្ពុជានៅសតវត្សទី២០។

ចម្លើយ៖ ព្រឹត្តិការណ៍សំខាន់ៗនៃប្រវត្តិសាស្ត្រកម្ពុជា នៅក្នុងសតវត្សទី២០គឺ៖

+សម័យអាណានិគមបារាំង

-១៩០៤ សៀមបានប្រគល់ទឹកដីខេត្តត្រាត ម្លូព្រៃ ទន្លេរពៅ និងស្ទឹងត្រែងមកឲ្យកម្ពុជាវិញ។

-១៩០៧ សៀមបានប្រគល់ខេត្តបាត់ដំបង សិរីសោភ័ណ សៀមរាបមកឲ្យកម្ពុជាវិញ។

-១៩០៨ បារាំងធ្វើផែនទីភ្នំដងរែក ដែលទទួលស្គាល់ដោយតំណាងបារាំង សៀម នៅលើឆាកអន្តរជាតិ។

-១៩៤៧ ប្រកាសឲ្យប្រើរដ្ឋធម្មនុញ្ញដំបូងលើកដំបូងគេនៅប្រទេសកម្ពុជា។

-៤ មិថុនា ១៩៤៩ បារាំងបានប្រគល់ទឹកដីកម្ពុជាឱ្យទៅយួន

-៨ វិច្ឆិកា ១៩៤៩បារាំងប្រគល់ឯករាជ្យបណ្តោះអាសន្នឲ្យកម្ពុជា

-១៩៥២ ព្រះបាទនរោត្តមសីហនុបានធ្វើព្រះរាជបូជនីយកិច្ចទាមទារឯករាជ្យ

-៩ វិច្ឆិកា ១៩៥៣ កម្ពុជាទទួលបានឯករាជ្យពេញលេញពីបារាំង

-១៩៥៤ ប្រតិបត្តិការបណ្តេញពួកវៀតមិញចេញពីកម្ពុជា

-១៩៥៤ សៀមបានលើកទ័ពទាំងកំរោលមូលកាន់កាប់ប្រាសាទព្រះវិហារ។

+សម័យសង្គមរាស្ត្រនិយម១៩៥៥ដល់១៩៧០

-១៩៥៥ សម្តេចនរោត្តម សីហនុ ដាក់រាជ្យនិងបង្កើត
សង្គមរាស្ត្រនិយម

-១៤ ធ្នូ ១៩៥៥ កម្ពុជាចូលជាសមាជិកអង្គការសហប្រជាជាតិ

-១៥ មិថុនា ១៩៦២ សៀមប្រគល់ប្រាសាទព្រះវិហារឲ្យខ្មែរវិញ
ដោយតុលាការអន្តរជាតិទីក្រុងឡាអេ ចេញសាលក្រមឲ្យកម្ពុជាឈ្នះ
ក្តីក្នុងរឿងក្តីក្តាំងប្រាសាទព្រះវិហារ។

+សម័យសាធារណរដ្ឋខ្មែរ ១៩៧០-១៩៧៥

-១៨ មីនា ១៩៧០ លន់ នល់ ធ្វើរដ្ឋប្រហារទម្លាក់សម្តេចនរោត្តម
សីហនុ

-១៩៦៩-១៩៧៣ សហរដ្ឋអាមេរិកទម្លាក់គ្រាប់បែកលើកម្ពុជា

-១៩៧០-១៩៧៥ សង្គ្រាមស៊ីវិលនៅកម្ពុជា

+សម័យកម្ពុជាប្រជាធិបតេយ្យ ១៩៧៥-១៩៧៩

-១៧ មេសា ១៩៧៥ ផ្តួលរលំរបប លន់ នល់(សាធារណរដ្ឋខ្មែរ)

-ជម្លៀសប្រជាជនចេញពីទីក្រុងភ្នំពេញនិងទីប្រជុំជននានា

-របបប្រល័យពូជសាសន៍

-២ ធ្នូ ១៩៧៨ បង្កើតរណសិរ្សសង្គ្រោះជាតិកម្ពុជា

-៧ មករា ១៩៧៩ ថ្ងៃជ័យជម្នះលើរបបកម្ពុជាប្រជាធិបតេយ្យ

+របបសាធារណរដ្ឋប្រជាមានិតកម្ពុជា

-ការស្តារនិងកសាងប្រទេសជាតិឡើងវិញ

-១៩៨៩-១៩៩១ បង្កើតរដ្ឋកម្ពុជា

-១៩៩១-១៩៩៣ បង្កើតរដ្ឋាភិបាលបណ្តោះអាសន្ន
-២៣ តុលា ១៩៩១ កិច្ចព្រមព្រៀងក្រុងប៉ារីស
-១៤ វិច្ឆិកា ១៩៩១ មាតុភូមិនិវត្តន៍របស់សម្តេចនរោត្តសីហនុ
-១៤ ធ្នូ ១៩៩២ តំបន់អង្គរដាក់បញ្ចូលក្នុងបញ្ជីបេតិកភណ្ឌពិភពលោក។
-២៣-២៨ ឧសភា ១៩៩៣ បោះឆ្នោតជាសកលអាណត្តិទី១ រៀបចំដោយ អ៊ុនតាក់
-២៤ កញ្ញា ១៩៩៣ ប្រទេសកម្ពុជាជាព្រះរាជាណាចក្រកម្ពុជាទី២
-នៅថ្ងៃ២៤ កញ្ញា ១៩៩៣
-ព្រះបាទនរោត្តម សីហនុ ឡើងសោយរាជ្យលើកទី២
-ការប្រកាសឲ្យប្រើរដ្ឋធម្មនុញ្ញ
-កំណើតរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជាទី២។
-១៩៩៨ បោះឆ្នោតលើកទី២ កម្ពុជាទទួលបានសុខសន្តិភាពទាំងស្រុង ក្រោមនយោបាយឈ្នះ-ឈ្នះរបស់សម្តេច ហ៊ុនសែន
-៣០ មេសា ១៩៩៩ កម្ពុជាចូលជាសមាជិកអាស៊ាន។

៦. តើអ្វីជាគោលនយោបាយឈ្នះ ឈ្នះ? ចូររៀបរាប់ពីសមិទ្ធផលនៃគោលនយោបាយឈ្នះ ឈ្នះ។

ចម្លើយ៖ គោលនយោបាយឈ្នះ ឈ្នះ គឺជាគោលនយោបាយឬយុទ្ធសាស្ត្រក្នុងការដោះស្រាយជម្លោះដោយការសម្របសម្រួលគ្នារវាងភាគីជម្លោះពីរ ឬច្រើនដើម្បីឈានទៅរកកិច្ចព្រមព្រៀងដែលភាគីទាំងអស់ទទួលបានផលប្រយោជន៍ទាំងអស់គ្នាឬឈ្នះទាំងអស់គ្នា។

សម្តេចហ៊ុនសែន ចាប់ផ្តើមអនុវត្តគោលនយោបាយឈ្នះ ឈ្នះដោយប្រើយុទ្ធសាស្ត្រឌីហ្វីដ(DIFID)៖ ការបំបែក ការធ្វើឱ្យឯកោ ការបញ្ចប់ ការធ្វើសមាហរណកម្ម និងការអភិវឌ្ឍ។ នយោបាយនេះគឺទទួលជ័យជម្នះបានអាស្រ័យលើគោលការណ៍៣គឺ ការធានាអាយុជីវិតនិងរូបរាងកាយ ការធានាអាជីពនិងមុខរបរ ការធានាកម្មសិទ្ធិទាំងចលនទ្រព្យនិងអចលនទ្រព្យ។ ហើយគោលនយោបាយនេះផងដែរទទួលបានជោគជ័យទាំងស្រុងនៅថ្ងៃទី២៩ ខែធ្នូ ឆ្នាំ១៩៩៨ ដែលនាំសន្តិភាពពេញលេញជូនកម្ពុជា។

+សមិទ្ធផលនៃនយោបាយឈ្នះឈ្នះ

- **វិស័យនយោបាយ**

-ធ្វើឱ្យកម្ពុជាបានសុខសន្តិភាព និងមានស្ថិរភាពនយោបាយ
-រៀបចំការបោះឆ្នោតជ្រើសរើសមេដឹកនាំតាមបែបប្រជាធិបតេយ្យ
-កម្ពុជាបង្កើនទំនាក់ទំនងល្អជាមួយប្រទេសក្នុងតំបន់និងពិភពលោក
-កម្ពុជាបង្កើនទំនាក់ទំនងល្អជាមួយប្រទេសក្នុងតំបន់និងពិភពលោក
-សមាហរណកម្មកងទ័ពខ្មែរក្រហមជាមួយកងទ័ពរដ្ឋាភិបាលដើម្បីស្តារប្រទេសឡើងវិញ
-តាមតំបន់ព្រំដែនមានសុខសុវត្ថិភាពនិងការអភិវឌ្ឍ
-មាតុភូមិនិវត្តន៍របស់ជនភៀសខ្លួនតាមតំបន់ព្រំដែន

-មានការផ្តល់តួនាទី បុណ្យស័ក្តិ ដល់បងប្អូនខ្មែរក្រហម ដែលធ្លាប មានពីមុនមក។

- **វិស័យសង្គម**

-សេដ្ឋកិច្ចជាតិមានការរីកចម្រើនគួរឱ្យកត់សម្គាល់

-មានទំនាក់ទំនងពាណិជ្ជកម្មអន្តរជាតិជាមួយប្រទេសក្នុងតំបន់និង អន្តរជាតិ

-កម្ពុជាមានឱកាសក្នុងការពង្រឹងសេដ្ឋកិច្ចជាតិ ដើម្បីក្លាយជា ប្រទេសដែលមានចំណូលមធ្យមកម្រិតខ្ពស់

- **វិស័យសង្គម**

-កម្ពុជាមានសុវត្ថិភាព សន្តិភាពពេញលេញ

-មានឯកភាពជាតិ និងបង្រួបបង្រួមជាតិ

-សន្តិភាពនាំមកនូវការអភិវឌ្ឍគ្រប់វិស័យ

-មានកំណែទម្រង់វិស័យសុខាភិបាល ព័ត៌មាន កសិកម្ម ច្បាប់ ជា ដើម

-សង្គមសន្តិភាពនាំឱ្យកម្ពុជាក្លាយជាប្រធានអាស៊ានប្តូរវេន និងជា ម្ចាស់ផ្ទះប្រជុំកំពូលអាស៊ានប្រកបដោយជោគជ័យ។

៧. ចូររៀបរាប់ពីកត្តាដែលនាំឱ្យកម្ពុជាអាចបញ្ចប់សង្គ្រាមបាន ហើយងាកមករកការអភិវឌ្ឍសេដ្ឋកិច្ច-សង្គមវិញ។

ចម្លើយ៖ កត្តាដែលនាំឱ្យកម្ពុជាអាចបញ្ចប់សង្គ្រាមបាន ហើយងាក មករកការអភិវឌ្ឍសេដ្ឋកិច្ច-សង្គមមាន៖

+កត្តាខាងក្រៅ

-កំណែទម្រង់របស់លោកមីខាអ៊ីល ហ្គោបាឆូវ នៅសហភាពសូវៀត នាពាក់កណ្តាលទសវត្សរ៍ឆ្នាំ១៩៨០
-ការដួលរលំនៃរបបកុម្មុយនិស្តនៅអឺរ៉ុបខាងកើត នៅចុងទសវត្សរ៍ឆ្នាំ ១៩៨០ និងបន្តបន្ទាប់
-ការផ្តាច់ជំនួយរបស់សូវៀតចំពោះប្រទេសវៀតណាម នាចុងទសវត្សរ៍ឆ្នាំ១៩៨០
-ការដកកងទ័ពវៀតណាមចេញពីកម្ពុជានាឆ្នាំ១៩៨៩
-ការដួលរលំនៃអតីតសហភាពសូវៀតឆ្នាំ១៩៩១
-ការបញ្ចប់នៃសង្គ្រាមត្រជាក់ឆ្នាំ១៩៩១
-អន្តរាគមន៍របស់បរទេសបានធ្វើឱ្យភាគីជម្លោះខ្មែរយល់ព្រមចូលតុចរចា
-ការជួយជ្រោមជ្រែងពីសមាគមប្រជាជាតិអាស៊ីអាគ្នេយ៍ ជាពិសេសថៃ និងឥណ្ឌូនេស៊ី ក្នុងការរៀបចំដំណើរការសន្តិភាព រហូតទទួលបានកិច្ចព្រមព្រៀងសន្តិភាពក្រុងប៉ារីស ២៣ តុលា ១៩៩១
-ការរៀបចំការបោះឆ្នោតនៅឆ្នាំ១៩៩៣ ដោយអង្គការសហប្រជាជាតិ

+កត្តាក្នុងស្រុកនិងមេដឹកនាំខ្មែរ

-ថ្ងៃទី២ ធ្នូ ១៩៨៧ មានការជួបគ្នាលើកទី១នៅហ្វៃអង់តាជឺន័រ ប្រទេសបារាំង ការចរចាលើកទី២នៅខែមករា ឆ្នាំ១៩៨៨ នៅបារាំង រវាងសីហនុ-ហ៊ុនសែន
-រដ្ឋាភិបាលក្រុងភ្នំពេញធ្វើវិសោធកម្មរដ្ឋធម្មនុញ្ញនៅឆ្នាំ១៩៨៩

-ចាប់ពីឆ្នាំ១៩៨៩មក វេទិការបស់សម្តេចនរោត្តមសីហនុ និងលោក ហ៊ុនសែន ដើម្បីស្វែងរកដំណោះស្រាយវិបត្តិនយោបាយនៅកម្ពុជា បានប្រព្រឹត្តទៅជាបន្តបន្ទាប់ នៅទីក្រុងប៉ារីស ប្រទេសបារាំង ទីក្រុងហ្សាកាតា ប្រទេសឥណ្ឌូនេស៊ី ទីក្រុងតូក្យូ ប្រទេសជប៉ុន និងទីក្រុងប៉ាតាយ៉ា ប្រទេសថៃ

-ថ្ងៃទី១០ កញ្ញា ១៩៩០ បង្កើតក្រុមប្រឹក្សាជាតិជាតិខ្ពស់SNC សម្តេចសីហនុជាប្រធាន

-ថ្ងៃទី២៣-២៤ មិថុនា ១៩៩១ នៅទីក្រុងប៉ាតាយ៉ា គូបដិបក្ខខ្មែរទាំងបួនបានជួបជុំគ្នានិងបានចុះសម្រុងគ្នាអំពីគម្រោងការដោះស្រាយបញ្ហាជាតិ

-ថ្ងៃទី២៣ តុលា ១៩៩១ កិច្ចព្រមព្រៀងសន្តិភាពទីក្រុងប៉ារីស៖ ភាគីជម្លោះបានចាប់ដៃគ្នា យល់ព្រមធ្វើការបោះឆ្នោតជាសកលដែលមានអាជ្ញាធរបណ្តោះអាសន្ននៃអង្គការសហប្រជាជាតិនៅកម្ពុជាដែលហៅកាត់ថាអ៊ុនតាក់(UNTAC)មើលការទទួលខុសត្រូវ

+ការផ្សះផ្សាជាតិក្រោយឆ្នាំ១៩៩៣និងនយោបាយឈ្នះ-ឈ្នះ

-ការបង្កើតរដ្ឋាភិបាលចម្រុះក្រោយការបោះឆ្នោត

-ធ្វើការទប់ស្កាត់មិនឱ្យពួកខ្មែរក្រហមវិលត្រឡប់មកកាន់អំណាចវិញ

-ខេត្តប៉ៃលិនបានចុះចូលជាមួយរដ្ឋាភិបាលនាថ្ងៃទី២២ ខែតុលា ឆ្នាំ ១៩៩៦ និងទីកន្លែងដទៃទៀតដូចជា សំឡូត កំរៀង ភ្នំព្រឹក្ស សំពៅលូន និងតំបន់ម៉ាឡៃ បានចុះចូលជាបន្តបន្ទាប់

-ការអនុវត្តនយោបាយឈ្នះ-ឈ្នះរបស់សម្តេចហ៊ុនសែន ទទួលបានជោគជ័យទាំងស្រុងនៅចុងឆ្នាំ១៩៩៨និងដើមឆ្នាំ១៩៩៩ដោយក្រុមខ្មែរក្រហមបានធ្វើសមាហរណកម្មទាំងស្រុងជាមួយរដ្ឋាភិបាល។

៨. តើប្រទេសកម្ពុជា បានចូលជាសមាជិកអង្គការយូណេស្កូ នៅថ្ងៃខែឆ្នាំណា?

ចម្លើយ៖ នៅថ្ងៃទី០៣ ខែកក្កដា ឆ្នាំ១៩៥១។

៩. ចាប់តាំងពីកម្ពុជាបានចូលជាសមាជិករបស់អង្គការយូណេស្កូ តើកម្ពុជាបានចុះបញ្ជីសម្បត្តិបេតិកភណ្ឌអ្វីខ្លះ? ចូររៀបរាប់។

ចម្លើយ៖ កម្ពុជាបានចុះសម្បត្តិបេតិកភណ្ឌដូចជា៖

+បេតិកភណ្ឌរូបីចំនួន៤ គឺ

-តំបន់រមណីយដ្ឋានអង្គរ៖ ចុះបញ្ជីបេតិកភណ្ឌពិភពលោកនៅ**ថ្ងៃទី ១៤ ខែធ្នូ ឆ្នាំ១៩៩២** នៅក្រុងសាន់តាហ្វេ សហរដ្ឋអាមេរិក។

-ប្រាសាទព្រះវិហារ៖ ចុះបញ្ជីបេតិកភណ្ឌពិភពលោកនៅ**ថ្ងៃទី៧ ខែកក្កដា ឆ្នាំ២០០៨** នៅក្រុងកេបិច ប្រទេសកាណាដា។

-ប្រាសាទសម្ប៉ូរព្រៃគុហ៍៖ ចុះបញ្ជីបេតិកភណ្ឌពិភពលោកនៅ**ថ្ងៃទី៨ ខែកក្កដា ឆ្នាំ២០១៧** នៅទីក្រុងក្រាកូវ ប្រទេសប៉ូឡូញ។

-ប្រាសាទកោះកេរ៖ ចុះបញ្ជីបេតិកភណ្ឌពិភពលោកនៅ**ថ្ងៃទី១៧ ខែកញ្ញា ឆ្នាំ២០២៣** នៅក្រុងរីយ៉ាដ រាជាណាចក្រអារ៉ាប៊ីសាអូឌីត។

+បេតិកភណ្ឌអរូបីចំនួន៦ គឺ៖

-របាំព្រះរាជទ្រព្យ៖ ចុះបញ្ជីបេតិកភណ្ឌនៅថ្ងៃទី៧ ខែវិច្ឆិកា ឆ្នាំ ២០០៣។

-ល្ខោនស្រមោលស្បែកធំ៖ ចុះបញ្ជីបេតិកភណ្ឌនៅថ្ងៃទី២៥ ខែវិច្ឆិកា ឆ្នាំ២០០៥។

-ល្បែងទាញព្រ័ត្រ៖ ចុះបញ្ជីបេតិកភណ្ឌនៅថ្ងៃទី០២ ខែធ្នូ ឆ្នាំ ២០១៥។

-ចាប៉ីដងវែង៖ បានចុះបញ្ជីនៅ**ថ្ងៃទី៣០ ខែវិច្ឆិកា ឆ្នាំ២០១៦** នៅទីក្រុងអាឌីសអាបាបា ប្រទេសអេត្យូពី។

-ល្ខោនខោលវត្តស្វាយអណ្តែត៖ ចុះបញ្ជីនៅ**ថ្ងៃទី២៨ ខែវិច្ឆិកា ឆ្នាំ ២០១៨** នៅទីក្រុងព័រល្វី សាធារណរដ្ឋម៉ូរីស។

-គុនល្បុក្កតោ៖ បានចុះបញ្ជីនៅ**ថ្ងៃទី២៩ ខែវិច្ឆិកា ឆ្នាំ២០២២** នៅទីក្រុងប៉ាបាត់ ព្រះរាជាណាចក្រម៉ារ៉ុក។

+បញ្ជីស្មារតីចងចាំនៃពិភពលោកចំនួន៣ គឺ

-សារមន្ទីរឧក្រិដ្ឋកម្មប្រល័យពូជសាសន៍ទួលស្លែង៖ បានដាក់បញ្ចូល **ថ្ងៃទី ៣១ ខែ កក្កដា ឆ្នាំ ២០០៩** នៅទីក្រុងប្រិចថោន ប្រទេសបារបាវដូស។

-ក្រាំងរឿងអ៊ីណាវបុស្បា៖ បានដាក់បញ្ចូលនៅ**ថ្ងៃទី ៣០ ខែ តុលា ឆ្នាំ ២០១៧** នៅទីក្រុងប៉ារីស ប្រទេសបារាំង។

-ឯកសារសំឡេងនិទានរឿងរាមកេរ្តិ៍ ដោយតាគ្រុឌ៖ ចុះបញ្ជីនៅថ្ងៃទី **១៥ ខែឧសភា ឆ្នាំ២០១៤** នៅខេត្តខ្វាងចូវ ប្រទេសចិន។

១០. តើយូណេស្កូ មកពីភាសាអង់គ្លេសដូចម្តេច?

ចម្លើយ៖ យូណេស្កូមកពីភាសាអង់គ្លេស UNESCO = United Nations Educational Scientific and Cultural Organization

បកប្រែជាភាសាខ្មែរថា អង្គការសិក្សាវិទ្យាសាស្ត្រអប់រំ និងវប្បធម៌នៃអង្គការសហប្រជាជាតិ។

១១. តើអង្គការយូណេស្កូ បង្កើតឡើងនៅថ្ងៃខែឆ្នាំណា?

ចម្លើយ៖ អង្គការនេះជាទីភ្នាក់ងារពិសេសរបស់អង្គការសហប្រជាជាតិ ដែលបានបង្កើតឡើងនៅថ្ងៃទី១៦ ខែវិច្ឆិកា ឆ្នាំ១៩៤៥។

១២. តើអង្គការនេះបង្កើតឡើងក្នុងគោលបំណងអ្វីខ្លះ? ហើយបានបង្កើតគណៈកម្មការនិងកម្មវិធីអ្វីខ្លះ?

ចម្លើយ៖ អង្គការនេះបង្កើតឡើងក្នុងគោលបំណងបង្រួបបង្រួមឱ្យមានសន្តិភាព ស្ថេរភាព ដោយលើកតម្កើងឱ្យមានកិច្ចសហប្រតិបត្តិការលើវិស័យ អប់រំ វិទ្យាសាស្ត្រ និង វប្បធម៌ ជាពិសេសការគោរពជាសកល ដើម្បីអោយមាន យុត្តិធម៌ មានការគោរពច្បាប់ និងសិទ្ធិមនុស្ស។

+អង្គការយូណេស្កូបានបង្កើតឲ្យមានកម្មវិធីនិងគណៈកម្មាធិការមួយចំនួនដើម្បីលើកកម្ពស់ការអប់រំ វិទ្យាសាស្ត្រ និងវប្បធម៌។

+ក្នុងកម្មវិធីទាំងនោះមានដូចជា

-គណៈកម្មាធិការបេតិកភណ្ឌពិភពលោក

-គណៈកម្មាធិការបេតិកភណ្ឌវប្បធម៌អរូបី

-កម្មវិធីស្មារតីនៃការចងចាំពិភពលោក ឋបនីយជីវមណ្ឌល ជាដើម។

១៣. ចូររៀបរាប់ពីតួនាទីរបស់សហគមន៍អាស៊ានៅអាស៊ីអាគ្នេយ៍។

ចម្លើយ៖ តួនាទីរបស់សហគមន៍អាស៊ាននៅអាស៊ីអាគ្នេយ៍មាន៖

+ផ្នែកនយោបាយ

-រក្សាសន្តិសុខ សន្តិភាព ក្នុងតំបន់និងអន្តរជាតិ
-ចូលរួមដោះស្រាយវិវាទ ឬជម្លោះក្នុងតំបន់និងអន្តរជាតិ
-ធ្វើឲ្យមានឯកភាពក្នុងការដឹកនាំស្របតាមលទ្ធិប្រជាធិបតេយ្យ
+ផ្នែកសេដ្ឋកិច្ច
-ជំរុញការអភិវឌ្ឍវិស័យសេដ្ឋកិច្ចក្នុងតំបន់ និងពិភពលោក
-ជំរុញកិច្ចសហប្រតិបត្តិការផ្នែកពាណិជ្ជកម្ម និងអភិវឌ្ឍទីផ្សារដើម្បីប្រកួតប្រជែងនៅក្នុងប្រទេសជឿនលឿន
-បង្កើនកិច្ចសហប្រតិបត្តិការលើវិស័យទេសចរណ៍ ដើម្បីបង្កើតការងារនិងប្រាក់ចំណូលដល់ប្រជាជន។

+ផ្នែកសង្គម

-ជំរុញកិច្ចសហប្រតិបត្តិការផ្នែកវប្បធម៌ ជំនឿសាសនា និងប្រពៃណីទំនៀមទម្លាប់
-ផ្លាស់ប្តូរបទពិសោធន៍ផ្នែកអប់រំសិក្សាធិការ ការបណ្តុះបណ្តាលធនធានមនុស្ស បច្ចេកវិទ្យា និងវិទ្យាសាស្ត្រ
-លើកកម្ពស់សិទ្ធិមនុស្ស និងសមភាពយេនឌ័រក្នុងតំបន់
-បង្កើនទំនាក់ទំនងល្អរវាងប្រជាជាតិនានាក្នុងតំបន់និងពិភពលោក

១៤. បើតាមប្រវត្តិសាស្ត្រ តើប្រទេសសៀមចែកចេញជាប៉ុន្មានសម័យកាល?

ចម្លើយ៖ តាមប្រវត្តិសាស្ត្រ ប្រទេសសៀមចែកចេញជា៤សម័យកាលគឺ៖

-សម័យសុខោទ័យ(1238-1350) សៀមបានវាយដណ្តើមយកខេត្តសុខោទ័យពីខ្មែរ និងបង្កើតរដ្ឋសៀមដោយស្តេចរាមាកំហែង។
-សម័យអយុធ្យា(1350-1767) សៀមបានពង្រីកទឹកដីមកលើចក្រភពខ្មែរ និងត្រួតត្រាតាមដងទន្លេមេណាម។ នៅឆ្នាំ1767ស្តេចភូមាបាយិនណោងវាយក្រុងអយុធ្យាខ្ទេចខ្ទីអស់។
-សម័យធនបុរី(1767-1800) ព្រះចៅតាក់ស៊ីន រំដោះក្រុងអយុធ្យាពីភូមា រួចលើករាជធានីមកតាំងនៅធនបុរីឆ្នាំ1767 តែព្រះចៅតាក់ស៊ីនលោភលន់អំណាច ត្រូវព្រះចៅយ៉ឺតហ្វា(រាមាទី១) នៃរាជវង្សចក្រីកាត់ ទោសប្រហារជីវិត។
-សម័យក្រុងបាងកក(1800-សព្វថ្ងៃ) ព្រះចៅរាមាទី១ នៃរាជវង្សចក្រី បានឡើងសោយរាជ្យបន្តរហូតមក ដល់សព្វថ្ងៃ។

១៥. តើអ្វីដែលជាបញ្ហារួមរបស់ពិភពលោកនៅចុងសតវត្សទី២០?

ចម្លើយ៖ បញ្ហារួមរបស់ពិភពលោកនៅចុងសតវត្សទី២០គឺ៖

+បញ្ហាបរិស្ថាន

-ការបំពុលអាកាសធាតុ៖ តាមរយៈផ្សែងពុលពីរថយន្ត រោងចក្រ ភ្លើងឆេះព្រៃ និងទង្វើរបស់មនុស្សជាច្រើនទៀត។

-បញ្ហាកង្វះទឹកស្អាត៖ ការស្រកចុះនៃទឹកទន្លេ ស្ទឹង បឹង បង្កឱ្យមានបញ្ហាកង្វះទឹកប្រើប្រាស់។

-បញ្ហាសំរាម និងកាកសំណល់ពីរោងចក្រ៖ សំរាម និងកាកសំណល់រោងចក្រធ្វើឱ្យខូចបរិស្ថានក្នុងទឹក និងលើគោក។

-ការថយចុះគុណភាពដី និងការបំផ្លាញព្រៃឈើ៖ ការប្រើប្រាស់ដីគីមី ថ្នាំពុល និងការកាប់ទន្ទ្រានព្រៃ ដើម្បីធ្វើកសិកម្មបានប៉ះពាល់យ៉ាងខ្លាំងដល់គុណភាពដី។ ការកាប់បំផ្លាញព្រៃឈើជាកត្តាចម្បងដែលនាំឱ្យកើនកម្តៅផែនដី គ្រោះរាំងស្ងួត ទឹកជំនន់និងការបាត់បង់សត្វព្រៃជាដើម។

+បញ្ហាកំណើនប្រជាជន និងអន្តោប្រវេសន៍៖កំណើនប្រជាជនដ៏ច្រើនបង្កឱ្យមាននូវ៖

-បញ្ហាឧបត្ថម្ភជាមពល

-បញ្ហាសុវត្ថិភាពស្បៀង(កង្វះស្បៀង)

-ជំងឺឆ្លង(ខ្វះអនាម័យ និងការការពារ)

-ភាពក្រីក្រ (ការជួញដូរផ្លូវភេទ គ្រឿងញៀន ពលកម្មកុមារ)

-បញ្ហាជនអន្តោប្រវេសន៍ ចំណាកស្រុក (ស្វះស្វែងរកការងារធ្វើ ការភ័យខ្លាចសង្គ្រាម)

-វិបត្តិសេដ្ឋកិច្ចនិងសង្គម

+បញ្ហាសន្តិសុខស្បៀង៖ កង្វះស្បៀងបណ្តាលមកពី៖

-កំណើនប្រជាជនយ៉ាងឆាប់រហ័ស

-ការបាត់បង់ដីធ្វើស្រែចម្ការ ដែលបណ្តាលមកពីការកសាងលំនៅដ្ឋាន ការសាងសង់រោងចក្រ

-គ្រោះធម្មជាតិ(ទឹកជំនន់ កម្តៅផែនដី ភាពរាំងស្ងួត កង្វះទឹក...)

-ការបាត់បង់ដីវាលស្រែ រុក្ខជាតិ...ដែលជាប្រភពស្បៀងអាហារ។

+បញ្ហាសង្គ្រាម និងអស្ថិរភាពសង្គម

-នៅសតវត្សទី២ ពិភពលោកបានជួបប្រទះនឹងសង្គ្រាមលោកពីរលើកគឺ សង្គ្រាមលោកលើកទី១ និងសង្គ្រាមលោកលើកទី២ ដែលបានបង្កនូវមហន្តរាយជីវិតមនុស្ស សត្វ និងសម្ភារៈដ៏ច្រើនមហិមា។
-ក្រោយសង្គ្រាមលោកលើកទី២ នៅមានសង្គ្រាមដូចជាសង្គ្រាមកូរ៉េ សង្គ្រាមនៅឥណ្ឌូចិន សង្គ្រាមនៅអាហ្វហ្គានីស្ថាន ជាដើម។
-ឧក្រិដ្ឋកម្ម និងភេរវកម្មអន្តរជាតិ បានកើតឡើងជាបន្តបន្ទាប់ដែលជាការគំរាមកំហែងដល់សន្តិសុខជាតិផងដែរ។

១៦. តើមូលហេតុចម្បងនៃការរលេចឡើងនូវបញ្ហារួមលើពិភពលោកមានប្រភពមកពីអ្វី?

ចម្លើយ៖ មូលហេតុចម្បងនៃការរលេចឡើងនូវបញ្ហារួមលើពិភពលោកមានប្រភពមកពី៖
-ប្រភពទី១៖ ធនធានធម្មជាតិនៅលើដីមិនអាចទ្រទ្រង់តម្រូវការរបស់មនុស្ស ដែលមានកំណើនយ៉ាងច្រើន និងទំហំសេដ្ឋកិច្ចពិភពលោកដែលត្រូវការធនធានធម្មជាតិទាំងនោះ។
-ប្រភពទី២៖ កើតចេញពីការរីកចម្រើននៃបដិវត្តន៍វិទ្យាសាស្ត្របច្ចេកទេស ដែលនាំមកនូវផលវិជ្ជមាននិងអវិជ្ជមានព្រមគ្នាក្នុងពេលតែមួយ។
-ប្រភពទី៣៖ កំណើនប្រជាជនបានទាមទារឱ្យមានការផ្គត់ផ្គង់គ្រឿងឧបភោគបរិភោគកាន់តែច្រើន ស្របនឹងធម្មជាតិចេះតែរិចរឹលទៅៗ។

-ប្រភទទី៤៖ ការចំណាយធនធានយ៉ាងច្រើនសន្ធឹកសន្ធាប់ទៅលើសព្វាវុធ និងកងទ័ព។

-ប្រភពទី៥៖ ភាពយឺតយ៉ាវរបស់ស្ថាប័នអំណាចជាតិក្នុងការឆ្លើយតប និងរកវិធីដោះស្រាយបញ្ហាឱ្យទាន់ពេលវេលា។

១៧. ដូចម្តេចហៅថា សកលភាវូបនីយកម្ម?

ចម្លើយ៖ សកលភាវូបនីយកម្ម គឺជាដំណើរការវិវត្តនៅក្នុងចន្លៃនៃការបង្កើតឡើងនូវប្រព័ន្ធតែមួយនៅលើពិភពលោក។

១៨. តើកត្តាអ្វីដែលជំរុញឱ្យមានសកលភាវូបនីយកម្ម?

ចម្លើយ៖ កត្តាដែលជំរុញឱ្យមានសកលភាវូបនីយកម្មរួមមាន៖

-កម្លាំងចលករនៃប្រព័ន្ធសេដ្ឋកិច្ចសកលលោក ដែលជំរុញឱ្យកាន់តែលេចឡើងនូវអស្ថិរភាព និងផលវិបាកចំពោះបញ្ហាផ្ទៃក្នុងនិងទំនាក់ទំនងរវាងប្រទេសលើពិភពលោក។

-កំណើនយ៉ាងខ្លាំងនូវបម្លាស់ប្តូរទីកន្លែងរស់នៅរបស់ប្រជាពលរដ្ឋនៅលើពិភពលោក។

-ការរីកចម្រើនខ្លាំងនូវប្រព័ន្ធទំនាក់ទំនងទូរគមនាគមន៍អន្តរជាតិ។

-ការរីកសាយភាយយ៉ាងខ្លាំងនូវបច្ចេកវិទ្យាយោធាទំនើប ដែលជានិច្ចកាលបានក្លាយជាឧបករណ៍នយោបាយពិភពលោក។

-បញ្ហារួមជាច្រើនបានកើតឡើង ដែលទាមទារឱ្យមានការសម្រេចចិត្តដោះស្រាយបញ្ហាទាំងនេះតាមរយៈថ្នាក់ដឹកនាំរដ្ឋាភិបាល អង្គការអន្តរជាតិ សហគមន៍អន្តរជាតិជាដើម។

១៩. ចូរពណ៌នាពីទិដ្ឋភាពវិជ្ជមាន និងអវិជ្ជមាននៃសកលភាវូបនីយកម្ម។

ចម្លើយ៖ ពណ៌នាពីទិដ្ឋភាពវិជ្ជមាន និងអវិជ្ជមាននៃសកលភាវូបនីយកម្មគឺ

+ទិដ្ឋភាពវិជ្ជមាន

-ធ្វើឱ្យមានការរីកចម្រើនផ្នែកសេដ្ឋកិច្ច សង្គម វប្បធម៌ សិល្បៈ...។

-អភិវឌ្ឍផ្នែកបច្ចេកវិទ្យាទំនើប(បង្កើតគ្រឿងម៉ាស៊ីនស្វ័យប្រវត្តិផ្សេងៗ)

-ធ្វើឱ្យមានការរីកចម្រើនផ្នែកទូរគមនាគមន៍អន្តរជាតិ (ទូរសព្ទ ទូរទស្សន៍ អ៊ីនធឺណេត)

-បង្កើតសេដ្ឋកិច្ចទីផ្សារសេរី

-មានទំនាក់ទំនងល្អក្នុងការទំនាក់ទំនងការបរទេស

-បង្កើតកិច្ចសហប្រតិបត្តិការល្អ ដើម្បីដោះស្រាយរាល់បញ្ហាដែលបង្កការគំរាមកំហែងដល់ពិភពលោកឱ្យទាន់ពេលវេលា(បរិស្ថាន ជំងឺឆ្លង សន្តិសុខ កំណើនប្រជាជន...)

-មានភាពងាយស្រួលក្នុងការធ្វើបម្លាស់ប្តូរលំនៅដ្ឋានរបស់ប្រជាជននៅលើពិភពលោក។

+ទិដ្ឋភាពអវិជ្ជមាន

-ប្រទេសតូចតាចត្រូវបាត់បង់អធិបតេយ្យរបស់ខ្លួននៅចំពោះមុខប្រទេសមហាអំណាច(អ៊ុយក្រែន អ៊ីរ៉ាក់ លីប៊ី...)

-មានការជ្រៀតជ្រែកកិច្ចការផ្ទៃក្នុងពីសំណាក់ប្រទេសមហាអំណាចមកពីលើប្រទេសទន់ខ្សោយ ដែលធ្វើឱ្យមានការផ្លាស់ប្តូរនៅក្នុងវិស័យនយោបាយ សេដ្ឋកិច្ចសង្គម
-បង្កឱ្យមានសង្គ្រាមរដ្ឋនិងរដ្ឋ (អ៊ីស្រាអែលនិងប៉ាលេស្ទីន)
-ធ្វើឱ្យមានការរីកសាយភាយខ្លាំងនូវបច្ចេកវិទ្យាយោធាទំនើបដែលអាចបង្កការគំរាមកំហែងដល់ពិភពលោក
-កំណើនប្រជាជនឱ្យមានបញ្ហាចោទដល់សេដ្ឋកិច្ចនិងសង្គម
-ប្រព័ន្ធផ្កាយរណបក៏អាចជាប្រភពបញ្ហាដែលធ្វើឱ្យរដ្ឋាភិបាលរឹតតែបាត់បង់ប្រសិទ្ធភាពក្នុងការគ្រប់គ្រងប្រព័ន្ធព័ត៌មានវិទ្យា។

២០. តើរាជរដ្ឋាភិបាលបានកសាងវិមានឈ្នះ ឈ្នះ ក្នុងគោលបំណងអ្វី?

ចម្លើយ៖ រាជរដ្ឋាភិបាលបានកសាងវិមានឈ្នះ ឈ្នះ ក្នុងគោលបំណង៣គឺ៖
-ទី១ គឺការរំឭកដឹងគុណ និងចង់បង្ហាញនូវគុណតម្លៃនៃនយោបាយឈ្នះ ឈ្នះ។
-ទី២ គឺបង្ហាញអំពីភាពសុខដុមរមណីយកម្មរបស់កម្ពុជា សំដៅលើការបង្ហាញនូវភាពសុខដុមរមនានៃសង្គមកម្ពុជា មានការរីកចម្រើនទាំងសេដ្ឋកិច្ចសង្គម កិច្ចការបរទេស ការពារជាតិ អប់រំ វប្បធម៌ កសិកម្ម សំណង់ ជាដើម។
-ទី៣ គឺការផ្តល់នូវការសិក្សា ជាមជ្ឈមណ្ឌលស្រាវជ្រាវឈ្វេងយល់

និងខិតខំបង្កើតនូវចក្ខុវិស័យក្នុងការបន្តស្ថានភាពដែលមាននៅពេលបច្ចុប្បន្ននិងទៅអនាគត ពោលគឺប្រទេសមានសន្តិភាពគឺមានអ្វីៗទាំងអស់។

២១. តើព្រះបាទនរោត្តម សីហមុនី សោយរាជ្យនៅថ្ងៃខែឆ្នាំណា?

ចម្លើយ៖ ព្រះបាទនរោត្តម សីហមុនី សោយរាជ្យនៅថ្ងៃទី២៩ ខែតុលា ឆ្នាំ២០០៤។

២២. តើកម្ពុជាបានចូលជាសមាជិកទី១០នៃអាស៊ាននៅថ្ងៃខែឆ្នាំណា?

ចម្លើយ៖ ៣០ មេសា ១៩៩៩។

២៣. តើអង្គការពាណិជ្ជកម្មពិភពលោក(WTO) បង្កើតឡើងនៅថ្ងៃខែឆ្នាំណា? មានទីស្នាក់ការនៅឯណា?

ចម្លើយ៖ អង្គការពាណិជ្ជកម្មពិភពលោក(WTO) បង្កើតឡើងនៅថ្ងៃទី០១ ខែមករា ឆ្នាំ១៩៩៥។ មានទីស្នាក់ការនៅទីក្រុងហ្សឺណែវ នៃប្រទេសស្វីស។

២៤. តើអង្គការពាណិជ្ជកម្មពិភពលោកនេះ មានតួនាទីអ្វី?

ចម្លើយ៖ អង្គការនេះមានតួនាទីដូចជា៖

-ការគ្រប់គ្រងការធ្វើពាណិជ្ជកម្មលើទំនិញ

-សេវាកម្មផ្តល់មធ្យោបាយដោះស្រាយជម្លោះពាណិជ្ជកម្ម

-ជាវេទិការចរចាដើម្បីអភិវឌ្ឍការធ្វើសេរីភាវូបនីយកម្មនៃពាណិជ្ជកម្មអន្តរជាតិ។

២៥. តើប្រទេសកម្ពុជា បានចូលជាសមាជិកអង្គការពាណិជ្ជកម្ម ពិភពលោកនៅថ្ងៃខែឆ្នាំណា?

ចម្លើយ៖ នៅថ្ងៃ១៣ ខែតុលា ឆ្នាំ២០០៤។

២៦. តើវិមានឯករាជ្យកសាងនៅឆ្នាំណា? ដើម្បីអ្វី?ស្ថាបត្យករ ជាអ្នកណា?

ចម្លើយ៖ វិមានឯករាជ្យកសាងនៅឆ្នាំ១៩៥៨។

+ដើម្បីរំឭកដល់វិញ្ញាណក្ខន្ធយុទ្ធជនអ្នកស្នេហាជាតិ។

+ស្ថាបត្យករ គឺលោក វ៉ណ្ណ ម៉ូលីវ៉ណ្ណ។

២៧. តើសាលាបារាំងចុងបូព៌ា កសាងនៅឆ្នាំណា?

ចម្លើយ៖ បង្កើតឡើងនៅឆ្នាំ១៨៩៨។ មានតួនាទីថែរក្សាការពារនូវសម្បត្តិវប្បធម៌នៅឥណ្ឌូចិន។

២៨. តើអភិរក្សដ្ឋានអង្គរ បង្កើតឡើងនៅឆ្នាំណា? ដើម្បីអ្វី?

ចម្លើយ៖ បង្កើតឡើងនៅឆ្នាំ១៩០៧។ ដើម្បីរក្សាទុកនូវវត្ថុបុរាណដែលគេប្រមូលបាន ថែរក្សានិងជួសជុលប្រាង្គប្រាសាទបុរាណខ្មែរ។

២៩. តើអាជ្ញាធរអប្សរា បង្កើតឡើងនៅឆ្នាំណា? ដើម្បីអ្វី?

ចម្លើយ៖ បង្កើតឡើងនៅឆ្នាំ១៩៩៥។ ដើម្បីរៀបចំនិងការពារតំបន់អង្គរ។

៣០. ចូរវិភាគពីព្រះរាជាណាចក្រកម្ពុជាទី២និងការកសាងកម្ពុជាឡើងវិញ។

ចម្លើយ៖ វិភាគពីព្រះរាជាណាចក្រកម្ពុជាទី២និងការកសាងកម្ពុជាឡើងវិញមានដូចជា៖

+ព្រះរាជាណាចក្រកម្ពុជាទី២

-កើតឡើងនៅថ្ងៃទី២៤ ខែកញ្ញា ឆ្នាំ១៩៩៣ដែលមានព្រះមហាក្សត្រសោយរាជ្យគឺព្រះបាទនរោត្តម សីហនុ

-មានរដ្ឋធម្មនុញ្ញថ្មីនិងសេរីពហុបក្ស

-មានរដ្ឋាភិបាលស្របច្បាប់មួយ

-ព្រះរាជាណាចក្រកម្ពុជាទី២ កើតឡើងតាមរយៈការបោះឆ្នោតនៅថ្ងៃទី២៣-២៨ ឧសភា ១៩៩៣ រៀបចំដោយអង្គការសហប្រជាជាតិ ដែលនាំឱ្យមានការរៀបចំរដ្ឋាភិបាលដឹកនាំដោយសម្តេចហ៊ុនសែន និងនរោត្តម រណឫទ្ធិ ជាសហនាយករដ្ឋមន្ត្រី

-ព្រះរាជាណាចក្រកម្ពុជា គឺចាប់ពីឆ្នាំ១៩៩៣រហូតដល់បច្ចុប្បន្ន។ ព្រះរាជាណាចក្រកម្ពុជាទី២បានបោះឆ្នោតជាសកលដោយសេរី ជ្រើសតាំងតំណាងរាស្ត្របាន៥អណត្តិនៃរដ្ឋសភា។

+ការស្តារបនាកម្ពុជាឡើងវិញ

-ការស្តារវិស័យសេដ្ឋកិច្ច កសិកម្ម ពាណិជ្ជកម្ម ឧស្សាហកម្ម

-វប្បធម៌និងការអប់រំ បង្កើតសាលារៀនគ្រប់កម្រិតសិក្សា បង្កើតវត្ត អារាម ជំនឿ សាសនា។

+វិស័យនយោបាយ

-ធ្វើកំណែទម្រង់គ្រប់ហេដ្ឋារចនាសម្ព័ន្ធជាតិ

-ធ្វើកំណែទម្រង់លើវិស័យកងទ័ព នគរបាលជាតិ

-បង្កើតឱ្យមានសេដ្ឋកិច្ចទីផ្សារសេរី ផ្តល់កម្មសិទ្ធិឯកជន

-ផ្តល់សិទ្ធិសេរីភាពដល់ប្រជាពលរដ្ឋ ជាដើម។

៣១. តើព្រះបាទជ័យវរ្ម័នទី៧ បានបង្កើតនូវរចនាបថអ្វីក្នុងសិល្បៈខ្មែរ?

ចម្លើយ៖ ព្រះបាទជ័យវរ្ម័នទី៧ បានបង្កើតរចនាបថបាយ័ន ដែលមានប្រាសាទបាយ័នជាតំណាង។ ហើយលក្ខណៈរបស់បាយ័នគឺមានមុខ៤ញញឹមទៅរកទិសទាំងបួន។

៣២. ដូចម្តេចដែលហៅថា អង្គរ? មហានគរ?

ចម្លើយ៖ **អង្គរ** មានន័យថាទីក្រុង បុរី នគរ គឺសំដៅយកទីតាំងតំបន់ឬកន្លែងណាមួយដែលគេសាងជាបុរី រាជធានីឬទីក្រុង។

+មហានគរ សំដៅយកការរីកចម្រើនរុងរឿងបំផុតនៃទឹកដី ឬបុរីក្នុងសម័យកាលមួយរបស់ខ្មែរយើងពីសតវត្សទី៩ដល់សតវត្សទី១៤នៃគ្រិស្តសករាជ។

៣៣. ដូចម្តេចហៅថា ប្រាសាទអង្គរ?

ចម្លើយ៖ **ប្រាសាទអង្គរ** គឺជាក្រុមប្រាសាទទាំងឡាយដែលកសាងក្នុងសម័យអង្គរ ឬសម័យមហានគរដ៏រុងរឿង។ ឧទាហរណ៍ ប្រាសាទអង្គរវត្ត ដែលកសាងឡើងដោយព្រះមហាក្សត្រខ្មែរមួយអង្គព្រះនាមសុរិយាវរ្ម័នទី២ ក្នុងគ្រិស្តសករាជ១១១៣ដល់១១៤៥។

៣៤. តើគេសាងសង់ប្រាសាទដើម្បីអ្វី?

ចម្លើយ៖ គេសាងសង់ប្រាសាទដើម្បី៖

-ជាទីសក្ការៈបូជារបស់សាសនិកជនដែលជឿលទ្ធិសាសនាណាមួយ។

-សម្រាប់តម្កល់នូវវត្ថុសក្តិសិទ្ធិផ្សេងៗ។

-សម្រាប់សម្តែងនូវមហិទ្ធិឫទ្ធិរបស់ក្សត្រអង្គណាមួយឬវីរបុរសស្នេហាជាតិ។

-សម្រាប់ជាកន្លែងស្នាក់នៅរបស់អាទិទេព ព្រះព្រហ្ម ព្រះវិស្ណុ និងព្រះសិវៈ ជាដើម។

៣៥. តើសសរប្រាសាទចែកជាប៉ុន្មានយ៉ាង? អ្វីខ្លះ?

ចម្លើយ៖ សសរប្រាសាទមាន២យ៉ាងគឺ

-សសរពេជ្រ ឬសសរស្តម្ភ គឺជាសសរដែលនៅខាងមុខប្រាសាទសម្រាប់ផ្តែរ។

-សសរបញ្ឆោត គឺសង់នៅតាមជ្រុងប្រាសាទមើលទៅហាក់ដូចជាសសរ តែតាមពិតគ្រាន់តែជាជញ្ជាំងធម្មតាតែប៉ុណ្ណោះ។

៣៦. ហេតុអ្វីបានជាគេសាងសង់ប្រាសាទច្រើនតែបែរមុខទៅទិសខាងកើត?

ចម្លើយ៖ បានជាគេសាងសង់ប្រាសាទច្រើនតែបែរមុខទៅទិសខាងកើត ព្រោះមានជំនឿថាទិសខាងកើតជាទិសមានពន្លឺថ្ងៃមុនគេបង្អស់ជាទិសដែលកើតមានសេចក្តីរុងរឿង។ ដោយសារជំនឿនេះហើយបានជាប្រាសាទភាគច្រើនសង់បែរមុខទៅទិសខាងកើត។

៣៧. ចូររៀបរាប់ពីប្រភេទនៃប្រាសាទខ្មែរ?

ចម្លើយ៖ ប្រាសាទខ្មែរមានច្រើនប្រភេទណាស់ដែលគួរឱ្យកត់សម្គាល់ដូចតទៅ៖

-ប្រាសាទមានលក្ខណៈជារូងភ្នំ ដូចជាប្រាសាទក្នុងរូងភ្នំនៅខេត្តកំពត ជាដើម។

-ប្រាសាទសង់ឡើងមានលក្ខណៈប្រាង្គតែមួយម្នាក់ឯង។ ដូចជាប្រាសាទបាយ័ង ប្រាសាទនៅភូមិប្រាសាទ នៅខេត្តកំពង់ធំ។

-ប្រាសាទសង់ឡើងមានប្រាង្គច្រើន នៅលើខឿនតែមួយជាន់។ ដូចជាប្រាសាទព្រះគោ ប្រាសាទលលៃ...។

-ប្រាសាទភ្នំ ជាប្រាសាទដែលសង់ខ្ពស់ដូចភ្នំ នៅលើខឿនច្រើនជាន់ឬច្រើនថ្នាក់។ ប្រាសាទភ្នំមានពីរយ៉ាងគឺ ប្រាសាទសង់នៅលើភ្នំធម្មជាតិ ដូចជាប្រាសាទនៅលើភ្នំបាខែង ប្រាសាទព្រះវិហារ...និង ប្រាសាទសង់លើដីរាប ដែលគេបានលើកឱ្យខ្ពស់ដូចជាប្រាសាទបាគង ប្រាសាទបក្សីចាំក្រុង ប្រាសាទប្រែរូប ប្រាសាទតាកែវ បាពួន អង្គរវត្ត និងបាយ័នជាដើម។

-ប្រាសាទសង់នៅលើដីរាបគ្មានខឿន ដូចជាប្រាសាទព្រះខ័ន ប្រាសាទតានី ជាដើម។

៣៨. តើព្រះរាជានៅសម័យហ្វូណានឬនគរភ្នំ មានមន្ត្រីបម្រើប៉ុន្មានបែប? អ្វីខ្លះ?

ចម្លើយ៖ ព្រះរាជានៅសម័យនគរភ្នំមានមន្ត្រីបម្រើពីរបែបគឺ

-មន្ត្រីឆ្វេង៖ អង្គុយគាល់ព្រះរាជាខាងឆ្វេង។

-មន្ត្រីស្តាំ៖ អង្គុយគាល់ព្រះរាជាខាងស្តាំ។ មន្ត្រីស្តាំមានឋានៈធំជាងមន្ត្រីឆ្វេង។

៣៩. តើការបាត់បង់ទឹកដីកម្ពុជាក្រោម ចាប់ផ្តើមឡើងនៅក្នុងរជ្ជកាលស្តេចអង្គណា? ដោយសារអ្វី? ហើយការបាត់បង់ទាំងស្រុងដោយសារអ្វី?

ចម្លើយ៖ ការបាត់បង់ទឹកដីកម្ពុជាក្រោម ចាប់ផ្តើមក្នុងរជ្ជកាលព្រះបាទ ជ័យជេដ្ឋាទី២ (១៦១៩-១៦២៧)។ ដោយសារតែពេលនោះ យួនបានខ្ចីទឹកដីខ្មែរ ដោយសន្យាសងវិញក្នុងរយៈពេល៥ឆ្នាំ តែយួនពុំព្រមធ្វើតាមសន្យា។

+ការបាត់បង់ទឹកដីកម្ពុជាក្រោមនេះបានសព្វគ្រប់នៅពេលដែលបារាំងបានប្រគល់ឱ្យវៀតណាមនៅថ្ងៃទី៤ ខែមិថុនា ឆ្នាំ១៩៤៩។

៤០. តើពលរដ្ឋកម្ពុជាត្រូវចងចាំពីមេរៀនប្រវត្តិសាស្ត្រពីសង្គ្រាមស៊ីវិល និងឥទ្ធិពលមនោគមវិជ្ជានយោបាយ ដូចម្តេចខ្លះ?

ចម្លើយ៖ ពលរដ្ឋកម្ពុជាត្រូវចងចាំពីមេរៀនប្រវត្តិសាស្ត្រពីសង្គ្រាមស៊ីវិល និងឥទ្ធិពលមនោគមវិជ្ជានយោបាយ៖

+ផ្នែកសង្គម

-ខូចខាតហេដ្ឋារចនាសម្ព័ន្ធ ផ្លូវថ្នល់ សាលារៀន មន្ទីរពេទ្យ...។

-ការសម្លាប់រង្គាល់ ការស្លាប់បាត់បង់ជីវិតរបស់ប្រជាជនខ្មែរ

-ការបែកបាក់គ្រួសារ ប្តីប្រពន្ធ

-បន្សល់ទុកនូវក្មេងកំព្រា ស្ត្រីមេម៉ាយ

-ការរស់នៅដោយការភិតភ័យ និងគ្មានសេរីភាព

-បាត់បង់ឱកាសការងារ ការអប់រំ និងសុខភាព

+ផ្នែកនយោបាយ

-ការបែកបាក់ផ្ទៃក្នុង និងការជ្រៀតជ្រែកពីបរទេស នាំឱ្យប្រទេសជាតិរងគ្រោះមហន្តរាយ និងភាពវឹកវរ នយោបាយផ្ទៃក្នុង

-អស្ថិរភាពនយោបាយ អសន្តិសុខសង្គម

-ប្រទេសបាត់បង់កិត្តិយស បាត់បង់កិត្យានុភាព

+ផ្នែកសេដ្ឋកិច្ច

-សេដ្ឋកិច្ចធ្លាក់ចុះ អតិផរណា វិបត្តិហិរញ្ញវត្ថុ

-ដីស្រែចម្ការត្រូវទំនេរចោល ខូចខាតផលដំណាំ

-ឧស្សាហកម្មពុំដំណើរការ

-ពាណិជ្ជកម្មត្រូវរាំងស្ទះ

+ការបាត់បង់ឱកាស

-ក្នុងការអភិវឌ្ឍសេដ្ឋកិច្ច កសាងសង្គម

-ការរួបរួមជាតិ និងការពារជាតិ

-ចូលរួមក្នុងឆាកនយោបាយ

-ទទួលយកវិនិយោគទុនពីបរទេស ជាដើម។

៤១. តើកម្ពុជាចូលជាសមាជិកអាស៊ានផ្តល់នូវគុណសម្បត្តិនិងគុណវិបត្តិអ្វីខ្លះ?

ចម្លើយ៖ កម្ពុជាចូលជាសមាជិកអាស៊ានផ្តល់នូវគុណសម្បត្តិនិងគុណវិបត្តិដូចជា

+គុណសម្បត្តិ

-ពង្រឹងជំហរស្មើគ្នានិងសហប្រតិបត្តិការបណ្តាប្រទេសក្នុងតំបន់

-ចូលរួមប្រកួតប្រជែងទីផ្សារក្នុងតំបន់ពាណិជ្ជកម្មសេរី

-រក្សាស្ថិរភាពនយោបាយ ពង្រឹងសន្តិភាព...។

+គុណវិបត្តិ

-ធនធានមនុស្សនិងកម្លាំងផលិតកម្មកម្ពុជានៅមានកម្រិត

-ត្រូវខិតខំពង្រឹងសមត្ថភាពនិងបណ្តុះបណ្តាលធនធានមនុស្ស បន្ថែម

-កម្ពុជាអាចក្លាយជាទីផ្សាររួម ប្រសិនបើគ្មានផលិតកម្មនាំចេញ...។

៤២. ហេតុអ្វីបានជាគេបង្កើតអាស៊ាន?

ចម្លើយ៖ បានជាគេបង្កើតអាស៊ាន ព្រោះដើម្បី៖

-រក្សាសន្តិសុខ និងសន្តិភាពពិភពលោក

-ពង្រីកទំនាក់ទំនងមិត្តភាពរវាងប្រជាជាតិទាំងឡាយ

-សហប្រតិបត្តិការអន្តរជាតិផ្នែកសេដ្ឋកិច្ចនិងមនុស្សធម៌

-ស្វែងរកទិសដៅរួមគ្នាក្នុងក្របខណ្ឌប្រជាជាតិ។

៤៣. មូលហេតុអ្វីខ្លះដែលនាំឱ្យផ្ទុះសង្គ្រាមលោកលើកទី១?

ចម្លើយ៖ មូលហេតុគឺ៖

-ការប្រណាំងប្រជែងខាងសេដ្ឋកិច្ចនិងយោធារវាងអង់គ្លេសនិងអាល្លឺម៉ង់

-ការប្រណាំងប្រជែងរវាងចក្រភពអូទ្រីស-ហុងគ្រី ជាមួយរុស្ស៊ីនៅឧបទ្វីបបាល់កង់ក្នុងរឿងសែប៊ី

-ការបង្កើតបក្សសម្ព័ន្ធយោធា២ប្រឆាំងគ្នា (សម្ព័ន្ធត្រីភាគីនិងអនុសញ្ញាត្រីភាគី)

-ការប្រណាំងប្រជែងខាងទីផ្សារអាណានិគមរវាងអាល្លឺម៉ង់ អង់គ្លេសនិងបារាំង។

-ការធ្វើឃាតរដ្ឋទាយាទអូទ្រីស-ហុងគ្រី នៅសារ៉ាសឺវ៉ូ នៅថ្ងៃទី២៨ ខែមិថុនា ឆ្នាំ១៩១៤។

ឯកសារយោង

១. ក្រសួងអប់រំ យុវជន និងកីឡា២០១៧**សៀវភៅប្រវត្តិវិទ្យា ថ្នាក់ទី១២**

២. ក្រសួងអប់រំ យុវជន និងកីឡា២០២២ **សៀវភៅប្រវត្តិវិទ្យា ថ្នាក់ទី១១**

៣. ឌី ខាំបូលី ២០០៧ **ប្រវត្តិសាស្ត្រកម្ពុជាប្រជាធិបតេយ្យ ១៩៧៥-១៩៧៩**

៤. Paul Brunon និង ស៊ុនហេង ម៉េងឈាង២០០៣ **ជនជាតិខ្មែរ ពីស.វ ទី១-ស.វទី១៥**

៥. វ៉ាន់ឌី កាអុន ២០១២ **សុបិន និងការពិត ភាគទី២ ប្រទេសកម្ពុជាពីឆ្នាំ ១៨៦៣ -១៩៩២**

៦. ត្រឹង ងា ភ្នំពេញ ១៩៧៣ **ប្រវត្តិសាស្ត្រខ្មែរ**

៧. ក្រសួងអប់រំ យុវជន និងកីឡា ២០១៧ **ប្រវត្តិវិទ្យា (សម័យអាណានិគមបារាំង-ព្រះរាជាណាចក្រកម្ពុជាទី២)**»

៨. ក្រសួងអប់រំ យុវជន និងកីឡា (២០២០) នាយកដ្ឋានមធ្យមសិក្សា ចំណេះទូទៅ គម្រោងកែលម្អការអប់រំនៅមធ្យមសិក្សា«**ឯកសារបណ្តាញចំណេះដឹង សម្រាប់សិស្សស្វ័យសិក្សា មុខវិជ្ជាប្រវត្តិវិទ្យា**»

៩. បណ្ឌិតសភាចារ្យ ហង់ជួន ណារ៉ុង ២០១៩ ភ្នំពេញ **«ប្រវត្តិសាស្ត្រកម្ពុជាក្នុងបរិបទសកលលោក»**

១០. ក្រសួងអប់រំ យុវជន និងកីឡា **«កម្រងវិញ្ញាសាប្រឡងសញ្ញាបត្រមធ្យមសិក្សាទុតិយភូមិ ពីឆ្នាំ២០១៤ដល់២០១៩»**

១១. លោក អាដេម៉ារ ឡឺក្លែរ ប៉ារីស ១៩១៤ ប្រែសម្រួលដោយទីឃាវុធ **«ប្រវត្តិសាស្ត្រប្រទេសកម្ពុជា ចាប់តាំងពីសតវត្សទី១នៃគ្រិស្តសករាជរហូតមក»**

១២. ឆាយ សុផល រាជធានីភ្នំពេញ ២០១៥ **«អំណាច និងរាជបល្ល័ង្កនៃមហាក្សត្រខ្មែរសែ អង្គឌួង នរោត្តម ស៊ីសុវត្ថិ»**

១៣. បណ្ឌិត ម.ត្រាណេ ភ្នំពេញ ២០០២ **«ប្រវត្តិសាស្ត្រកម្ពុជា»** អាណាចក្រភ្នំ(ស.វទី១ដល់ទី៦)

១៤. ក្រសួងអប់រំ យុវជន និងកីឡា ២០២០ **«ប្រវត្តិវិទ្យា»** សេចក្តីសង្ខេបមេរៀនប្រវត្តិសាស្ត្រតំបន់អាស៊ីអាគ្នេយ៍និងពិភពលោក

១៥. បណ្ឌិត ស៊ិន សំណាង និងយ៉ង់ ធី ១៩៩៩ **«ប្រវត្តិនៃការអប់រំបឋមសិក្សានិងមធ្យមសិក្សានៅកម្ពុជា»**

១៦. ដេវិឌ ឆាណ្ឌលឺរ ផ្សាយចេញលើកទី៣ **«ប្រវត្តិសាស្ត្រខ្មែរ»**

១៧. វ៉ាន់ឌី កាអុន ២០១០ **«ប្រវត្តិសាស្ត្រនៃប្រទេសកម្ពុជា»** ភាគទី៣ ពីសម័យអាណានិគមបារាំងមកដល់បច្ចុប្បន្ន

១៨. នួន សុធិមន្ត ភ្នំពេញ ២០០៥ **«ហេតុការណ៍ពិតសង្គ្រាមអាមេរិកនៅកម្ពុជា លន់ នល់ និងខ្មែរក្រហម ១៩៧០ដល់១៩៧៥»**

១៩. សេង គឹមលី ភ្នំពេញ ២០០២ **«ប្រវត្តិសិល្បៈខ្មែរ» សម្រាប់មហាវិទ្យាល័យសិល្បៈនាដសាស្ត្រ**

២០. ក្រសួងអប់រំ យុវជន និងកីឡា ប្រឡងជ្រើសរើសគ្រូបង្រៀនកម្រិតឧត្តម(បរិញ្ញា+១) ជំនាន់ទី២២ **«អត្រាកំណែវិញ្ញាសាប្រវត្តិវិទ្យា»** សម័យប្រឡង៖ ៥ តុលា ២០១៦